# ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៨

## សាលាដំបូង ជំនុំជម្រះស្ត្រីម្នាក់ពីរឿងជួញដូរមនុស្ស

http://www.postkhmer.com/ ប្រភពភ្នំពេញប៉ុស្ដិ៍ Fri, 29 December 2017 នៀម ឆេង

ភ្នំពេញៈ សាលាដំបូងរាជធានីភ្នំពេញកាលពីម្សិលមិញបានជំនុំជម្រះករណីស្ត្រីម្នាក់ពាក់ព័ន្ធនឹងការជួញដូរមនុស្សបន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនកាលពីខែមេសា ឆ្នាំ ២០១៧ ខណៈត្រឡប់មកពីប្រទេសចិន។ ស្ត្រីជាជនសង្ស័យឈ្មោះ ផៃ ចន្ថា អាយុ ៣៤ ឆ្នាំជាប់ចោទពីបទ «ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន» តាមមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស។ បើតាមមាត្រានេះជនជាប់ចោទប្រឈមជាប់ពន្ធនាគារពី៧ទៅ១៥ឆ្នាំ។

ក្នុងសវនាការ ផៃ ចន្ថា បានរៀបរាប់ថា គាត់មានទីលំនៅនៅកៀនស្វាយក្នុងភូមិជាមួយនឹងជនរងគ្រោះហើយបានការប្ដីចិនតាមរយៈមេខ្យល់កាលពី ៥ ឆ្នាំមុន។ កាលពី ២ ឆ្នាំមុនគាត់បានមកលេងស្រុកខ្មែរហើយគ្រួសារជនរងគ្រោះឈ្មោះ .ម.ន.ក បានសួរនាងថា មានចិនចង់បានប្រពន្ធខ្មែរទៀតឬអត់? ពេលនោះនាងក៏បានប្រាប់ថា មាន បន្ទាប់មកក៏បានជូនជនរងគ្រោះទៅធ្វើលិខិតឆ្លងដែន ហើយបាននាំទៅចិនជាមួយគ្នាតាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ ក្នុងការនាំចេញនេះជនសង្ស័យទទួលប្រាក់ ១.២០០ ដុល្លារពីបុរសចិន ដើម្បីរៀបចំឯកសារ និងប្រគល់ ៧០០ ដុល្លារទៅម្ដាយជនរងគ្រោះ ចំណែកខ្លួនបាន ២០០ ដុល្លារ។ ជនសង្ស័យបន្តថាៈ «ពេលទៅដល់ចិន បុរសចិនបានមកទទួលជនរងគ្រោះហើយបានយកទៅធ្វើពិធីរៀបការ និងចុះលិខិតអាពាហ៍ពិពាហ៍។ ខ្ញុំទាក់ទងសួរសុខទុក្ខគាត់ញឹកញាប់ តែក្រោយមកគេលែងចូល»។

ប៉ុន្តែតាមចម្លើយជនរងគ្រោះដែលត្រូវបានអានក្នុងសវនាការថាពេលគាត់ទៅដល់ចិនគាត់បានទៅការប្ដីចិនជាជាងសំណង់។ ជនរងគ្រោះថាៈ «៣ ខែដំបូងមិនមានរឿងអ្វីកើតឡើងទេ ប៉ុន្តែក្រោយមកប្ដីចេះតែរករឿង និងបង្ខំរួមភេទទាំងពេលមានរដូវ។ ប្ដីបានប្រាប់ថាគេបានចំណាយប្រាក់អស់ ២ ម៉ឺន ២ ពាន់ដុល្លារដើម្បីយកខ្ញុំមកទីនេះ។ ប្ដីក៏បានប្រាប់ថា ឈ្មោះ ផៃ ចន្ថា បានយកប្រាក់គាត់ ៧ ពាន់ដុល្លារដើម្បីឲ្យម្ដាយខ្ញុំ តែម្ដាយខ្ញុំមិនដែលបានទទួលទេ»។ ជនរងគ្រោះ ន.ម.ន.ក បន្តថានាងបានរត់មកកម្ពុជាវិញដោយមានស្ត្រីខ្មែរម្នាក់ជួយ។ ពេលមកដល់ភ្លាមនាងក៏ដាក់ពាក្យបណ្ដឹងតែម្ដងដោយទាមទារសំណង ៣ ពាន់ដុល្លារ និងបានស្នើសុំឲ្យតុលាការផ្ដន្ទាទោស ផៃ ចន្ថា តាមច្បាប់។

ព្រះរាជអាជ្ញាលោក សេង ហៀង ថ្លែងថា ពិតជាមានបទល្មើសដូចការចោទមែន ហើយស្នើឲ្យតុលាការផ្ដន្ទាទោសតាមច្បាប់។ ប៉ុន្តែលោក កែវ វ៉ាន់នី មេធាវីការពារជនជាប់ចោទបានស្នើថាៈ «សូមតុលាការឲ្យកូនក្ដីរបស់ខ្ញុំរួចផុតពីបទចោទ និងសូមច្រានចោលការទាមទារសំណងទាំងអស់។ កូនក្ដីខ្ញុំមិនបានទៅល្បួងលោមជនរងគ្រោះទេ ហើយគាត់ទៅដល់ចិនបានរៀបការប្ដីចិនពិតប្រាកដមែន។ រឿងហិង្សាដោយប្ដីរបស់ជនរងគ្រោះគឺជារឿងកើតឡើងក្រោយមិនពាក់ព័ន្ធនឹងកូនក្ដីខ្ញុំទេ»។ ចំណែក ផៃ ចន្ថា បាននិយាយជាសម្ដីចុងក្រោយថាៈ «សូមដោះលែងខ្ញុំទៅ!»។

លោក ម៉ុង វិមានសោភា ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានឲ្យដឹងថា សាលក្រមរឿងនេះនឹងប្រកាសនៅថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៨៕

## រដ្ឋបាលខេត្តបន្ទាយមានជ័យ ឲ្យពលរដ្ឋមានទីលំនៅអចិន្ត្រៃ ក្នុងខេត្ត ធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ គំរូថ្មី ចាប់ពីថ្ងៃទី២ មករា នេះ តទៅ

http://ann.com.kh/site/news/ ថ្ងៃអង្គារ, 2 ខែមករា 2018 9:12 ព្រឹក

ខេត្តបន្ទាយមានជ័យៈ រដ្ឋបាលខេត្តបន្ទាយមានជ័យ បានចេញសេចក្ដីជូនដំណឹងឲ្យពលរដ្ឋដែលមានទីលំនៅអចិន្ត្រៃក្នុងខេត្ត ធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ គំរូថ្មី នៅច្រកចេញចូលតែមួយ នៃរដ្ឋបាលខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៨ នេះតទៅ។ ឯកឧត្តម សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ បានបញ្ជាក់ថា ការចេញប័ណ្ណព្រំដែនគំរូថ្មីនេះ ធ្វើបានសម្រាប់តែពលរដ្ឋទូទៅ ដែលមានទំលំនៅអចិន្ត្រៃនៅក្នុងខេត្តបន្ទាយមានជ័យតែប៉ុណ្ណោះ គឺ

ផ្អែកលើកិច្ចព្រមព្រៀងថ្មី ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ ស្តីពីការឆ្លងកាត់ព្រំដែននៃភាគីទាំង២ ដែលបានព្រមព្រៀងគ្នា ដើម្បីប្រើប្រាស់ប័ណ្ណព្រំដែននេះ ជាឯកសារផ្លូវការ សម្រាប់ប្រជាពលរដ្ឋរស់នៅអចិន្ត្រៃ ក្នុងតំបន់ព្រំដែន អាចប្រើប្រាស់នៅពេលចេញចូលឆ្លងកាត់ព្រំដែនរវាងប្រទេសទាំង២។

គួរបញ្ជាក់ផងដែរថា ប័ណ្ណព្រំដែនកន្លងមក គឺធ្វើដោយនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដែលការធ្វើនេះ មានរយៈពេលច្រើនឆ្នាំមកហើយ ហើយសម្រាប់ឆ្នាំ២០១៨នេះ គឺប័ណ្ណព្រំដែនគំរូថ្មី ត្រូវបានបង្វែមកធ្វើដោយរដ្ឋបាលខេត្តបន្ទាយមានជ័យវិញ ទៅតាមលក្ខខណ្ឌនៃក្រសួងមហាផ្ទៃ។

ជុំវិញប័ណ្ណព្រំដែនគំរូថ្មី ដែលនឹងធ្វើឡើងដោយរដ្ឋបាលខេត្តបន្ទាយមានជ័យនេះ ត្រូវបានប្រជាពលរដ្ឋសង្ឃឹម និងជឿជាក់ថា ការធ្វើប័ណ្ណព្រំដែននឹងមានលក្ខណៈងាយស្រួលជាងការធ្វើប័ណ្ណព្រំដែន ដែលធ្វើដោយនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត។ ចំពោះតម្លៃប័ណ្ណព្រំដែនគំរូថ្មីនេះ គឺតាមការកំណត់ក្នុង១ក្បាល សម្រាប់ប្រជាពលរដ្ឋ មានទីលំនៅអចិន្ត្រៃក្នុងខេត្តបន្ទាយមានជ័យ តម្លៃ២ម៉ឺនរៀលតែប៉ុណ្ណោះ។ បន្ថែមលើនេះទៀតនោះ គឺការធ្វើប័ណ្ណព្រំដែនសម្រាប់ឆ្លងទៅប្រទេសថៃ ឬថៃឆ្លងមកកម្ពុជា កន្លងមកមានភាពលំបាកណាស់ ដោយមានការកំណត់ឲ្យថតរូបធ្វើកាត ដើម្បីបិតភ្ជាប់ជាមួយសៀវភៅប័ណ្ណព្រំដែន ដែលការធ្វើនេះ ត្រូវតម្រង់ជួររងចាំធ្វើកាតនៅខាងភាគីថៃ បើមិនដូច្នោះខាងភាគីថៃ នឹងមិនអនុញ្ញាតឲ្យចូលនោះទេ៕

## ឱកាសចុងក្រោយរបស់ពលករខុសច្បាប់ នៅក្នុងប្រទេសថៃ

http://www.pheaktraprak.com December 31, 2017

ក្តីសង្ឃឹមចុងក្រោយរបស់ពលករបរទេសខុសច្បាប់ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ នៅក្រោយកិច្ចប្រជុំកំពូលរបស់សមាជិករដ្ឋសភារបស់រាជរដ្ឋាភិបាលថៃ នៅពាក់កណ្តាលខែមករា ឆ្នាំ២០១៨ខាងមុខនេះ។ យោងតាមការផ្សព្វផ្សាយរបស់គេហទំព័រសារព័ត៌មានធំៗនៅក្នុងប្រទេសថៃ បានចុះផ្សាយកាលពីថ្ងៃសៅរ៍ទី៣០ខែធ្នូ ឆ្នាំ២០១៧ អោយដឹងថា ក្រសួងការងារថៃត្រៀមធ្វើសេចក្តីព្រាងច្បាប់ស្នើទៅកិច្ចប្រជុំកំពូលរបស់សមាជិករដ្ឋសភាថៃ ដើម្បីអោយគណៈរដ្ឋមន្ត្រីពិចារណាលើការពន្យារពេលស្នាក់នៅដល់ពលករបរទេសនិង បើកអោយចុះបញ្ជីឈ្មោះសាជាថ្មីម្តងទៀតពលករដែលគ្មានឯកសារស្របច្បាប់នៅក្នុងប្រទេសថៃ។

បើយោងតាមខ្លឹមសារនៃអត្ថបទសារព័ត៌មានធំមួយចំនួនក្នុងប្រទេសថៃបានសរសេរបញ្ជាក់ ថា1-ចំពោះពលករខ្មែរ,ភូមា,ឡាវ ដែលមានឯកសារស្របច្បាប់ត្រឹមត្រូវហើយតែមិនបានបញ្ជាក់អត្តសញ្ញាណឬហៅ (ត្រួតសញ្ជាតិ) ត្រូវទៅបង្ហាញខ្លួននៅការិយាល័យ(OSS) ក្នុងខេត្តដែលខ្លួនស្នាក់នៅចាប់តាំងពីថ្ងៃទី៣១ខែ០៣ខែ០១ ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣០ខែមិថុនាឆ្នាំ២០១៨។ 2-ចំពោះពលករបរទេសដែលគ្មានឯកសារស្របច្បាប់នៅក្នុងប្រទេសថៃ ត្រូវទៅបង្ហាញខ្លួននៅការិយាល័យ(OSS)ក្នុងខេត្តដែលខ្លួនស្នាក់នៅ ចាប់តាំងពីថ្ងៃទី០៣ខែមករាឆ្នាំ២០១៨ខាងមុខនេះ ក៏ប៉ុន្តែត្រូវរង់ចាំសេចក្តីសម្រេចរបស់កិច្ចប្រជុំកំពូលសមាជិកសភាថៃជាមុនសិន។ ដូច្នេះបើសិនជាដំណឹងនេះជាការពិត វាជាឱកាសល្អមួយសម្រាប់បងប្អូនពលករកម្ពុជាដែលខុសច្បាប់ អាចមានសង្ឃឹមនិងបានធ្វើឯកសារស្របច្បាប់ម្តងទៀត។ តែយ៉ាងណាមិញអ្វីទាំងអស់អាស្រ័យទៅលើកិច្ចប្រជុំសមាជិកសភានៅពាក់កណ្តាលខែមករាខាងមុខនេះ ទើបដឹងលិទ្ធផលពិតប្រាកដ។ ដកស្រង់អត្ថបទព័ត៌មាន:.thairath.co.th/

## ពន្យារពេលរយៈ 6ខែជូនដល់ពលករមានប័ណ្ណស៊ីជម្ពូ និងលិខិតលុងបៀនថ្មី

http://www.pheaktraprak.com December 29, 2017

ក្រសួងការងារថៃបានធ្វើលិខិតស្នើសុំទៅគណៈរដ្ឋមន្ត្រីថៃ អោយពន្យាររយៈពេលបន្ថែមចំនួន៦ខែបន្តទៅមុខទៀត ដើម្បីអោយពលករខ្មែរ,ភូមា,ឡាវ, ដែលមានប័ត្រស៊ីជម្ពូ,ប័ត្រស៊ីជម្ពូនេសាទ, លិខិតបញ្ជាក់រវាងពលករនិងថៅកែ(លុងបៀនថ្មី) ដើម្បីឲ្យពួកគេអាចស្នាក់នៅ និងធ្វើការបន្តរហូតដល់បានត្រួតសញ្ជាតិ និងទទួលបានលិខិតឆ្លង

ដែនធ្វើការពីប្រទេសរបស់ខ្លួនចប់សព្វគ្រប់អស់រួចរាល់។ នេះបើយោងតាមខ្លឹមសារក្នុងកិច្ចប្រជុំរបស់លោក អាដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃ នៅទីស្នាក់ការក្រសួងការងារថៃប្រចាំទីក្រុងបាងកកកាលពីព្រឹកថ្ងៃសុក្រទី២៩ ខែធ្នូ ឆ្នាំ២០១៧ ។ ក្នុងការពន្យាររយៈពេលចំនួន ៦ខែបន្តទៅខាងមុខទៀតនេះ គឺចំពោះតែពលករទាំង៣ក្រុមខាងលើប៉ុណ្ណោះ ហើយចំពោះអ្នកដែលគ្មានឯកសារធ្វើការ គឺខុសច្បាប់និងត្រូវសម្ថកិច្ចចាប់យកទៅចាត់វិធានការតាមផ្លូវច្បាប់។

## ពលរដ្ឋខ្មែរ៣នាក់ ឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូងត្រូវ អាជ្ញាធរថៃបញ្ជូនមកកម្ពុជា

http://cambodiapolice.com 12:25 pm 31 ធ្នូ 2017

ឧត្តរមានជ័យ ៖ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ វេលា ម៉ោង០៩និង៥៥នាទីអាជ្ញាធរថៃបានបញ្ជូនប្រជាជនខ្មែរចំនួន៣នាក់ តាមច្រកអន្តរជាតិជាំ ។ ពលរដ្ឋខ្មែរទាំង៣នាក់មានឈ្មោះដូចខាងក្រោម ៖

១,ឈ្មោះ សេង វណ្ណី ភេទប្រុស អាយុ២៥ឆ្នាំ ភូមិវត្តអង្គ ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត។ ចាប់ខ្លួនថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៦ ពីបទឆ្លងដែន ខុសច្បាប់ កាប់ឈើគ្រញូង ចូលតាមច្រកអូរស្មាច់ ជាប់ពន្ធនាគារ នៅខេត្តស៊ីសាកេត ប្រទេសថៃ។

២,ឈ្មោះ ដុល ចិត្រ ភេទប្រុស អាយុ១៦ឆ្នាំ ភូមិអូរស្មាច់ ឃុំអូរស្មាច់ ស្រុកត្រពាំប្រាសាទ ខេត្តឧត្តរមានជ័យ

៣,ឈ្មោះ អាត ម ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅ ភូមិអូរស្មាច់ ឃុំអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទាំងពីរនាក់ ក្រុមទាហានថៃ ចាប់ខ្លួនថ្ងៃទី១៨,១០,២០១៧ ពីបទឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូង ចូលតាមច្រក អូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ជាប់ ពន្ធនាគារ នៅខេត្តអូរប៊ុន ប្រទេសថៃ ។

បច្ចុប្បន្ន សមត្ថកិច្ចនៅមាត់ច្រកអន្តរជាតិជាំ បានធ្វើអប់រំរួច លើយបានឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងខ្លួនវិញ ៕

## ពលករខ្មែរ ចុះនៅផ្ទះគ្មានឯកសារចំនួន២៣នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួន

http://www.pheaktraprak.com December 31, 2017

ពលករខ្មែរប្រុស-ស្រីចំនួន23នាក់ ត្រូវកម្លាំងអាជ្ញាធរតម្រួតថៃប្រចាំខេត្តឡាំប៉ាងឃាត់ខ្លួនបន្ទាប់ពីធ្វើដំណើរតាមរយៈរថយន្តក្រុងទៅលេងស្រុកកំណើតតែគ្មានឯកសារបញ្ជាក់ការធ្វើដំណើរ និងស្នាក់នៅក្នុងប្រទេសថៃ។ យោងតាមប្រភពសារព័ត៌មានថៃបានចុះផ្សាយពីកាលពីថ្ងៃអាទិត្យទី៣១ខែ ធ្នូ ឆ្នាំ២០១៧ បានអោយដឹងថាកម្លាំងសមត្ថកិច្ចតម្រួត ខេត្តឡាំងប៉ាង ប្រទេសថៃ បានធ្វើការត្រួតពិនិត្យរថយន្តក្រុងដឹកអ្នកដំណើរមួយគ្រឿងធ្វើដំណើរមកពីខេត្តឈាងម៉ៃ បានរកឃើញពលករខ្មែរប្រុស ស្រី កូនក្មេង សរុបចំនួន២៣នាក់ គ្មានឯកសារធ្វើដំណើរស្នាក់នៅធ្វើការក្នុងប្រទេសថៃ ទើបត្រូវសមត្ថកិច្ចថៃធ្វើការឃាត់ខ្លួនតែម្តង។ តាមការរៀបរាប់របស់ពលករម្នាក់បានប្រាប់អោយដឹងថាពួកគេទាំងអស់គ្នាធ្វើការបេះផ្លែមៀននៅក្នុងខេត្តឈាងម៉ៃ តែត្រូវថៅកែដកហូតលិខិតឆ្លងដែនធ្វើការនិងឯកសារប្រចាំខ្លួនអស់។ ហើយឱកាសបុណ្យចូលឆ្នាំសកលនេះចង់នាំគ្រួសារទៅលេងស្រុកកំណើត បាននាំគ្នាធ្វើដំណើរតាមរយៈរថយន្តក្រុងពីខេត្តឈាងម៉ៃទៅចុះនៅម៉ូហ្សិតទីក្រុងបាងកក រួចធ្វើដំណើរបន្តទៅព្រំដែនអន្តរជាតិបានឡែមខេតចាន់បុរី ដើម្បីឆ្លងទៅខាងប្រទេសកម្ពុជាវិញ។

បច្ចុប្បន្នពលករខ្មែរទាំងអស់ត្រូវកម្លាំងសមត្ថកិច្ចថៃប្រគល់ខ្លួនអោយមូលនិធិគាំពារជនរងគ្រោះដោយសារការជួញដូរមនុស្សខេត្តឡាំប៉ាង ដើម្បីធ្វើការបញ្ជូនខ្លួនបន្តទៅប្រទេសកម្ពុជាតាមរយៈច្រកព្រំដែនអន្តរជាតិបានឡែមខេត្តចាន់បុរី។

## អភិបាលខេត្តបន្ទាយមានជ័យ អំពាវនាវដល់ពលករខ្មែរ ឈប់លួចឆ្លងដែនខុសច្បាប់ បែរមកបំពេញឯកសារស្របច្បាប់ ឬមកកាន់សាលាខេត្ត បំពេញឯកសារធ្វើលិខិតឆ្លងដែន (Boder Pass)

http://www.freshnewsasia.com/ 2018-01-02

(បន្ទាយមានជ័យ)៖ លោក សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ បានថ្លែងឲ្យដឹងនៅល្ងាចថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨នេះថា រាល់ថ្ងៃនេះមានប្រជាពលរដ្ឋជាច្រើននាក់ បាននាំគ្នាទៅប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើដោយខុសច្បាប់ ខ្លះស្របច្បាប់ ដូច្នេះក្នុងនាមអាជ្ញាធរខេត្ត សូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវមកកាន់ច្រកចេញចូលតែមួយ នៅសាលាខេត្ត ដើម្បីឲ្យមន្ត្រីជួយបំពេញនៅឯកសារ ពាក់ព័ន្ធដោយស្របច្បាប់។ លោកថ្លែងបន្តថា ការធ្វើលិខិតឆ្លងដែន(Boder Pass)ប្រជាពលរដ្ឋត្រូវយកភ្ជាប់ជាមួយអត្តសញ្ញាប័ណ្ណចំលងនៅច្រកចេញចូលតែមួយនៅតាមបណ្ដាក្រុង-ស្រុកសៀវភៅគ្រួសារឬសៀវភៅស្នាក់ចំលងនៅច្រកចេញចូលតែមួយនៅតាមបណ្ដាស្រុក-ក្រុង សំបុត្របញ្ជាក់កំណើតចំលងនៅច្រកចេញចូលតែមួយនៅតាមបណ្ដាស្រុក-ក្រុងនិងបង់ថ្លៃសេវា២ម៉ឺនរៀលក្នុង១ក្បាល។

នាឱកាសនោះដែរលោក អ៊ុ រាត្រី អភិបាលរងខេត្តបន្ទាយមានជ័យ ក៏បានថ្លែង និងពន្យល់ដល់ប្រជាពលរដ្ឋដែលបានមកកាន់ច្រកចេញចូលតែមួយដូច្នេះថា មុនបងប្អូនប្រជាពលរដ្ឋ ត្រូវយកឯកសារពាក់ព័ន្ធទាំងអស់ ដើម្បីងាយស្រួលទាំងអស់គ្នា ទាំងមន្ត្រីទាំងប្រជាពលរដ្ឋ។ លោកបានពន្យល់ សំរាប់សៀវភៅឆ្លងដែន(Boder Pass) ចាស់ដែលមានពណ៌លឿងនៅ យើងនៅតែបន្តឲ្យប្រើប្រាស់ ទាល់តែអស់សន្លឹកទើបមកធ្វើលិខិតឆ្លងដែនថ្មី (Boder Pass) ប្រសិនជាយើងប្រើប្រាស់អស់ លើកក្រោយគ្រាន់តែយករូបថត ៤គុណ៦ ចំនួន២សន្លឹក និងបំពេញឯកសារស្នើសុំម្ដងទៀតប៉ុណ្ណោះ ព្រោះអីមន្ត្រីជំនាញយើងមាន Program ចង់រួចរាល់អស់ហើយវានឹងងាយស្រួល។

ប្រជាពលរដ្ឋ បានឲ្យដឹងថា ការមកធ្វើលិខិតឆ្លងដែន(Boder Pass) នេះថ្ងៃទី១ មានការពិបាកបន្តិច ព្រោះអីខាងមន្ត្រីជំនាញឲ្យបំពេញឯកសារ និងត្រូវយកអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត សៀវភៅគ្រួសារ ទាំង៣ ទៅចំលងនៅតាមសាលាស្រុកក្រុង ដែលពួកយើងរស់នៅ ដូច្នេះហើយពួកយើងមានការពិបាកទៅវិញ ទៅមក មួយណានៅឆ្ងាយអស់លុយច្រើន តែថ្លៃសេវាវិញនោះគឺល្អ មានតម្លៃថោកត្រឹមតែ២ម៉ឺនរៀលប៉ុណ្ណោះ៕

## កម្ពុជាសង្ឃឹមថាការសុំកូនចិញ្ចឹម នឹងមានភាពល្អប្រសើរ ក្រោយមាននីតិវិធីថ្មី

https://khmer.voanews.com/ 03 មករា 2018 ស៊ុន ណារិន

ភ្នំពេញ៖ រយៈពេលច្រើនឆ្នាំបន្ទាប់ពីរដ្ឋាភិបាលកម្ពុជា បានផ្អាកការសុំកូនខ្មែរយកទៅចិញ្ចឹមក្រៅប្រទេស ដើម្បីរៀបចំនីតិវិធីមួយចំនួន ប្រទេសចំនួនបីបានចុះកិច្ចព្រមព្រៀងសុំកូនជាមួយរដ្ឋាភិបាលកម្ពុជា ដោយកម្ពុជាសង្ឃឹមថា ការសុំកូនចិញ្ចឹមនេះ នឹងមានភាពល្អប្រសើរឡើង។ នេះបើយោងតាមមន្ត្រីនៃអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស។ កម្ពុជា បានសម្រេចផ្អាកការសុំកូនអន្តរប្រទេសទាំងអស់ ចាប់ពីឆ្នាំ២០១១ ដោយសារប្រទេសនេះ ស្ថិតក្នុងដំណាក់កាលនៃការរៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍នានា ក្នុងការធានាឲ្យមានដំណើរការសុំកូនអន្តរប្រទេស ស្របតាមច្បាប់ជាតិ អន្តរជាតិ ប្រកបដោយក្រមសីលធម៌ តម្លាភាព ដើម្បីការពារឧត្តមប្រយោជន៍របស់កុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស។ ការផ្អាកសុំកូននេះ ធ្វើឡើង ចំពេលដែលមានសេចក្ដីរាយការណ៍អំពីការជួញដូរកុមារ ដូចជាការលក់ដូរក្មេងទៅឱ្យមណ្ឌលកុមារកំព្រា និងបញ្ហាពុករលួយផ្សេងៗ។

ទោះជាយ៉ាងណា កាលពីខែមីនា ឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញសេចក្ដីជូនដំណឹងមួយ ដោយលើកឡើងថា កម្ពុជា នឹងចាប់ផ្ដើមចុះឈ្មោះទីភ្នាក់ងារសុំកូនអន្តរប្រទេស ហើយប្រកាសស្វាគមន៍ប្រទេសណាដែលមានបំណងចុះកិច្ចព្រមព្រៀងសុំកូនពីប្រទេសកម្ពុជា។ សេចក្ដីជូនដំណឹងបាន

បញ្ជាក់ថា៖ «កម្ពុជានឹងចាប់ផ្តើមដំណើរការសុំកូនអន្តរប្រទេសជាមួយនឹងកុមារដែលមានតម្រូវការពិសេស បន្ទាប់ពីអស់លទ្ធភាពស្វែងរកឪពុកម្តាយចិញ្ចឹមក្នុងប្រទេស ឬអ្នកអាណាព្យាបាលស្របច្បាប់សម្រាប់អនីតិជន»។

អ្នកនាង សៅ សំភ័ស ប្រធានការិយាល័យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសនៃក្រសួងសង្គមកិច្ច បានថ្លែងប្រាប់ VOA ថា មកដល់ពេលនេះ មានប្រទេសចំនួនបី បានចុះកិច្ចព្រមព្រៀង ដើម្បីបើកទីភ្នាក់ងារសុំកូននៅក្នុងប្រទេសកម្ពុជា ក្នុងនោះ មានប្រទេសម៉ាល់ត៍ (Malta) អ៊ីតាលី និងតំបន់ Catalonia នៃប្រទេសអេស្ប៉ាញ។ អ្នកនាងបន្តថា ប្រទេសផ្សេងទៀត ក៏កំពុងដំណើរការចរចា ដើម្បីចុះកិច្ចព្រមព្រៀងជាមួយកម្ពុជាផងដែរ ក្នុងនោះ រួមមានប្រទេសបែលហ្សិក នូវែលសេឡង់ ប្រេស៊ីល ន័រវែស និងរដ្ឋ Quebec នៃប្រទេសកាណាដាជាដើម។ អ្នកនាង សៅ សំភ័ស មានប្រសាសន៍ថា៖ «រដ្ឋាភិបាលប្រទេសកម្ពុជា ស្វាគមន៍ចំពោះប្រទេសផ្សេងៗ ដែលចង់មកចុះកិច្ចព្រមព្រៀងទ្វេភាគី កំណត់ទីភ្នាក់ងារឲ្យប្រតិបត្តិការលើការងារសុំកូនហ្នឹង»។ អ្នកនាងបន្ថែមថា រដ្ឋាភិបាល បានរៀបចំបានល្អ ដើម្បីស្វាគមន៍ការសុំកូនអន្តរប្រទេស ដោយសង្ឃឹមថា ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់កាលពីឆ្នាំ២០០៩ និងនីតិវិធីផ្សេងៗ អាចធ្វើឲ្យប្រសើរឡើងនូវការសុំកូនចិញ្ចឹម និងធានាផលប្រយោជន៍ដល់ក្មេង។ អ្នកនាងមានប្រសាសន៍ថា៖ «ច្បាប់យើងមានមែន ប៉ុន្តែយើងត្រូវការលិខិតបទដ្ឋានគតិយុត្តិមួយចំនួន ដើម្បីសម្របសម្រួលឲ្យអនុវត្តច្បាប់បាន»។

ប្រទេសកម្ពុជា បានក្លាយជាសមាជិកនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស កាលពីឆ្នាំ២០០៧។ មុនពេលកម្ពុជាសម្រេចផ្អាកការសុំកូន ក្មេងកម្ពុជាដែលត្រូវបានសុំទៅក្រៅប្រទេស មានចំនួន៣៦៩៦នាក់ ក្នុងនោះមានក្មេងស្រីចំនួន១៨៦៥នាក់។ នេះបើយោងតាមគេហទំព័ររបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។ ក្មេងទាំងនោះត្រូវបានសុំទៅប្រទេសជាច្រើន ដូចជាប្រទេសបារាំង សហរដ្ឋអាមេរិក បែលហ្សិក កាណាដា អ៊ីតាលី អង់គ្លេស ម៉ាល់ត៍ អេស្ប៉ាញ អាហ្វ្រិកខាងត្បូង អាល្លឺម៉ង់ អូស្ត្រាលី ន័រវែស ដាណាម៉ាក់ ស៊ុយអែត សិង្ហបុរី និងហ្វីលីពីនជាដើម។ អ្នកនាង សៅ សំភ័ស មានប្រសាសន៍ថា រដ្ឋាភិបាល ក៏នៅតែតាមដានស្ថានភាពកុមារដែលនៅក្រៅប្រទេសរហូតមកដល់ពេលនេះ ជាពិសេសកុមារដែលនៅមានអាយុក្រោម១៨ឆ្នាំ។ ជាមួយដំណើរការសុំកូនថ្មីនេះ អ្នកនាងមានប្រសាសន៍ថា កម្ពុជាត្រូវការធនធានមនុស្សបន្ថែម ដើម្បីធ្វើកិច្ចការសុំកូននេះឲ្យបានល្អប្រសើរ។ អ្នកនាងមានប្រសាសន៍ថា៖ «យើងត្រូវការអ្នកធ្វើការហ្នឹង ហើយនៅខាងយើង មានចំនួនកំណត់។ យើងត្រូវការបំពេញបន្ថែម។ យើងមើលអ្នកក្រោមជាតិ មិនទាន់មាននៅឡើយទេ»។ ទោះជាយ៉ាងណា អ្នកនាងមានប្រសាសន៍ថា ដំណើរការនេះ ត្រូវការពេលវេលាបន្ថែមទៀត។ អ្នកនាងបន្តថា កាលពីមិនទាន់មានច្បាប់ស្តីពីការសុំកូនអន្តរប្រទេស និងនីតិវិធីផ្សេងៗ ឪពុកម្តាយចិញ្ចឹម អាចទៅមើលក្មេងនៅមណ្ឌលកុមារកំព្រាបាន តែបច្ចុប្បន្ននេះ ពួកគេមិនអាចធ្វើបាននោះទេ។

អ្នកនាងមានប្រសាសន៍ថា៖ «អត់មានក្មេងគាត់ថា គាត់ត្រូវទៅមើលនៅមណ្ឌល យកក្មេងនេះ អត់មានទេ ហើយប្រសិនបើទីភ្នាក់ងារហ្នឹង គាត់មានធ្វើការងារទាក់ទងនឹងខាងមណ្ឌលដើម្បីRecruit (ជ្រើសរើស) ក្មេងយកទៅ ក៏យើងអត់ផ្តល់ការអនុញ្ញាតឲ្យដែរ»។ អ្នកនាងពន្យល់ថា ទីភ្នាក់ងារសុំកូនដែលមានទីតាំងនៅក្នុងប្រទេសសុំកូន និងនៅក្នុងប្រទេសកម្ពុជា នឹងក្លាយជាកន្លែងទំនាក់ទំនងរវាងឪពុកម្តាយដែលចង់សុំកូន ជាមួយមន្ត្រីជំនាញកម្ពុជា ដើម្បីបំពេញតាមនីតិវិធីជាបន្តបន្ទាប់។

បើតាមមន្ត្រីជំនាញ កម្ពុជាក៏ត្រូវការរបាយការណ៍សិក្សាអំពីស្ថានភាពផ្ទះរបស់ឪពុកម្តាយសុំកូនផងដែរ សម្រាប់នីតិវិធីនៃការសុំកូន និងទាមទារឲ្យមានការផ្តល់របាយការណ៍ជាទៀងទាត់អំពីការវិវត្តរបស់ក្មេងនៅពេលពួកគេយកទៅចិញ្ចឹម។

បើតាមច្បាប់ស្តីអំពីការសុំកូនអន្តរប្រទេស ក្មេងអាយុក្រោម៨ឆ្នាំ ទើបអាចក្លាយជាកម្មវត្ថុនៃការសុំកូនបាន លើកលែងតែករណីមួយចំនួន ដូចជាក្មេងមានជំងឺមិនអាចព្យាបាលក្នុងប្រទេសកម្ពុជាបាន ក្មេងមានបញ្ហាសតិបញ្ញា និងក្មេងពិការជាដើម។

អ្នកនាង សៅ សំភ័ស បានបញ្ជាក់ថា ការសុំកូនចិញ្ចឹមទៅរស់នៅជាមួយឪពុកម្តាយនៅក្រៅប្រទេស គឺជាជម្រើសចុងក្រោយមួយសម្រាប់ក្មេង ក្រោយពេលរដ្ឋាភិបាលព្យាយាមឲ្យអស់លទ្ធភាពជួយក្មេងឲ្យបានរស់នៅក្នុងប្រទេស មុននឹងឈានទៅដល់ការសុំកូនទៅក្រៅប្រទេស។ អ្នកនាងមានប្រសាសន៍ថា៖ «សុំកូនអន្តរប្រទេសគឺជាជម្រើសមួយចុងក្រោយសម្រាប់ផែនការអចិន្ត្រៃយ៍របស់ក្មេង ទាក់ទងនឹងការរកគ្រួសារអចិន្ត្រៃយ៍ឲ្យក្មេង។ អញ្ចឹង មុននឹងឈានដល់សុំកូនអន្តរប្រទេសហ្នឹង គឺយើងត្រូវទុកដាក់ក្នុងស្រុកឲ្យអស់ពីលទ្ធភាព។ ក្នុងការសុំកូននេះ សម្រាប់យើង គឺគោលដៅរបស់យើង គឺយើងចង់រកគ្រួសារអចិន្ត្រៃយ៍មួយឲ្យកុមារ។ សម្រាប់កុមារដែលគ្មានអត់មានលទ្ធភាពគ្មានអត់មានឱកាសក្នុងការមានគ្រួសារអចិន្ត្រៃយ៍មួយ»។ អ្នកនាងបញ្ជាក់បន្ថែមថា៖ «បើសិនជាយើងអត់គិតគូដល់ការសុំកូនទេ យើងថាអាចទុកដាក់កុមារនៅក្នុងមណ្ឌល ឲ្យគាត់រស់នៅក្នុងមណ្ឌល»។

រដ្ឋាភិបាល បាននិងកំពុងអនុវត្តផែនការបីឆ្នាំ ចាប់ពីឆ្នាំ២០១៦ដល់២០១៨ ដោយមានគោលដៅកាត់បន្ថយកុមារ៣០ភាគរយចេញពីមណ្ឌលថែទាំ ឲ្យទៅរស់នៅជាមួយក្រុមគ្រួសាររបស់ក្មេង ប្រសិនបើពួកគេមានលទ្ធភាពអាចទទួលចិញ្ចឹមបាន។ របាយការណ៍ផ្លូវការបង្ហាញថា ក្មេងជាង១៦០០០នាក់ រស់នៅក្នុងមណ្ឌលចំនួន៤០៦ទូទាំងប្រទេស។

អង្គការយូនីសេហ្វ (Unicef) បាននិយាយថា ការផ្អាកការសុំកូន គឺដោយសារកង្វះខាតនូវនីតិវិធីច្បាស់លាស់សម្រាប់ការការពារកុមារ កង្វះសមត្ថភាពក្នុងការគ្រប់គ្រងកុមារ ក៏ដូចជាការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋាភិបាល និងមន្ត្រីយុត្តិធម៌។ ប្រធានក្រុមទំនាក់ទំនងនៃអង្គការយូនីសេហ្វគឺអ្នកស្រី Iman Morooka បានថ្លែងប្រាប់VOAតាមរយៈអ៊ីមែលឬសារអេឡិចត្រូនិកថា៖ «បញ្ហាប្រឈមមួយនៅក្នុងប្រទេសកម្ពុជា គឺថាមិនមានមន្ត្រីសង្គមកិច្ច ដើម្បីធានាអំពីដំណើរការគ្រប់គ្រងករណីឲ្យបានពេញលេញមួយ ដែលតម្រូវឲ្យមានការបញ្ចូលនូវការវាយតម្លៃស្ថានភាពកុមារ ក៏ដូចជាការស្វែងរកក្រុមគ្រួសារ និងការវាយតម្លៃផ្សេងៗ ដើម្បីបញ្ជាក់ ប្រសិនបើក្មេងមានលក្ខណៈគ្រប់គ្រាន់សម្រាប់សុំកូនឬទេ»។ ទោះជាយ៉ាងណា អ្នកស្រីនិយាយថា រដ្ឋាភិបាលកម្ពុជាកំពុងដំណើរការលើជំហានសំខាន់មួយចំនួន ដើម្បីឲ្យមានស្តង់ដារត្រឹមត្រូវមួយសម្រាប់ការសុំកូនអន្តរប្រទេស។ អ្នកស្រី Iman Morooka មានប្រសាសន៍បន្ថែមថា៖ «វាមានសារសំខាន់ ដើម្បីកត់សម្គាល់ថានៅក្នុងប្រទេសកម្ពុជា ក្មេង៤នាក់ក្នុងចំណោម៥នាក់នៅក្នុងមណ្ឌលថែទាំ មិនមែនជាក្មេងកំព្រានោះទេ។ ពួកគេមានគ្រួសារ ហើយបានដាក់នៅទីនោះ ដើម្បីការអប់រំ ឬដើម្បីកាត់បន្ថយបន្ទុកចំណាយថវិកា ប៉ុន្តែពួកគេមិនមែនជាកម្មវត្ថុសម្រាប់ការសុំកូននោះទេ»។

ចំណែកសហរដ្ឋអាមេរិក បានផ្អាកការសុំកូនជាមួយប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០០១ រហូតមកដល់ពេលនេះ។ អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំនៅកម្ពុជាគឺលោក David Josar មានប្រសាសន៍ថា រហូតមកដល់ពេលនេះ ស្ថានភាពនៃការសុំកូនមិនមានការផ្លាស់ប្តូរនោះទេ។ លោកមានប្រសាសន៍ថា ចំពោះការផ្តួចផ្តើមរបស់កម្ពុជាដើម្បីពង្រឹងប្រព័ន្ធសុខុមាលភាពកុមារ និងការធ្វើឲ្យប្រសើរនូវសុចរិតភាពនៃដំណើរការសុំក្នុងប្រទេស និងអន្តរប្រទេស កម្ពុជាមិនទាន់បានបំពេញនូវដំណើរការតាមអនុសញ្ញាទីក្រុងឡាអេនៅឡើយទេ៕

## ពលរដ្ឋកម្ពុជា ៥៦នាក់ត្រូវបានជួយសង្គ្រោះពីប្រទេសចំនួន ៣

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៨ម៉ោង ១១:២១ សហការី

រាជធានីភ្នំពេញ ៖ ស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី វៀតណាម និងស្ថានទូតខ្មែរប្រចាំប្រទេសថៃ បានអន្តរាគមន៍ជួយពលរដ្ឋខ្មែរចំនួន ៥៦ នាក់ បានវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីពួកគេខ្លះចូលទៅប្រកបរបរលក់ឆ្នោតខុសច្បាប់ និងខ្លះជាពលការិនីចូលទៅធ្វើការខុសច្បាប់នៅប្រទេសគេ ។

សម្រាប់ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ បានសហការជាមួយអាជ្ញាធរវៀតណាមបានរៀបចំធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ២៨ នាក់ ដែលក្នុងនោះមានកុមារ ២១នាក់ អាយុចន្លោះពី១ ទៅ៥៩ ឆ្នាំមកខេត្តស្វាយរៀងវិញ។ អ្នកទាំងអស់នេះចូលទៅស្នាក់នៅ និងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់វៀតណាម។

ចំណែកស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី និងប្រទេសថៃ បានជួយអន្តរាគមន៍ជួយពលរដ្ឋខ្មែរត្រឡប់មកប្រទេសវិញជាបន្តបន្ទាប់៕

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

# ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរចំនួន៥៦នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍ របស់ពលរដ្ឋខ្មែរចំនួន**៥នាក់** (ក្នុងនោះពលការិនី៤នាក់ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី និងកុមារម្នាក់) ដែលបានមកដល់កម្ពុជាវិញ នៅថ្ងៃទី**៣១** ខែ**ធ្នូ ឆ្នាំ២០១៧**។

២. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ**២៩នាក់**(ក្នុងនោះកុមារចំនួន២១នាក់) មានអាយុចន្លោះពី០១ឆ្នាំដល់៥៩ឆ្នាំ មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅនិងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់នៅវៀតណាម។ អាជ្ញាធរវៀតណាម បានរៀបចំអោយពលរដ្ឋខ្មែរស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារសង្គមក្នុងខេត្តទៀនយ៉ាង និងក្នុងទីក្រុងហូជីមិញ មុនពេលបញ្ជូនមកស្ថានអគ្គកុងស៊ុល។

ស្ថានអគ្គកុងស៊ុល បានជូនពលរដ្ឋទាំង២៩នាក់ មកកម្ពុជាវិញ នៅថ្ងៃទី **២៧** និងទី **២៩** ខែ **ធ្នូ ឆ្នាំ ២០១៧** ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត។

៣. តាមការសម្របសម្រួលរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ តុលាការខេត្តត្រាត ប្រទេសថៃ បានបើកសវនាការនិងសម្រេចដោះលែងពលរដ្ឋខ្មែរចំនួន**២២នាក់** នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧ ក្រោយពីពួកគេត្រូវបានអាជ្ញាធរថៃឃាត់ខ្លួនជាមួយទូកនេសាទ៥គ្រឿង កាលពីថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ២០១៧ ពីបទចូលនេសាទក្នុងដែនទឹករបស់ថៃ។ ពលរដ្ឋទាំងនោះបានត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី**២៣** ខែ**ធ្នូ** តាមច្រកព្រំដែនអន្តរជាតិផាក់កាត(ខេត្តត្រាត)-ចាំយាម(ខេត្តកោះកុង) ចំណែកទូកនេសាទទាំង៥គ្រឿង ត្រូវបានអាជ្ញាធរថៃរក្សាទុក ដោយរង់ចាំតុលាការសម្រេចនៅពេលក្រោយ។

ថ្ងៃ ពុធ ២រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៨

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៨

## តុលាការផ្តន្ទាទោសស្ត្រីម្នាក់ ដាក់ពន្ធនាគារ៨ឆ្នាំ ករណី នាំនារីខ្មែរឆ្លងដែន ទៅធ្វើពេស្យាចារប្រទេសចិន

https://www.dap-news.com/kh/ ថ្ងៃពុធ, 03 មករា ២០១៨ 15:00 ដោយ: គិរី ID:013

ភ្នំពេញ៖ លោក លី លីបម៉េង ចៅក្រមជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨ ប្រកាសសាលក្រមផ្តន្ទាទោសស្ត្រីម្នាក់ ដាក់ពន្ធនាគារ៨ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្តដល់ជនរងគ្រោះ ចំនួនពីរនាក់ ក្នុងម្នាក់ៗពីរលានរៀល ពីបទ ការនាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ ពាក់ព័ន្ធករណី បញ្ជូននារីខ្មែរពីរនាក់ ទៅធ្វើពេស្យាចារនៅបរទេស។

ជនជាប់ចោទឈ្មោះ អ៊ុច សេងហុង ភេទស្រី អាយុ៤៥ឆ្នាំ រស់នៅស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ មុខរបរ ជាអ្នកធ្វើចម្ការ ។ ជនសង្ស័យ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន កាលពីវេលាម៉ោងប្រមាណ ១៖៣០នាទី រសៀល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧ នៅពេលជនសង្ស័យ បាននាំនារីរងគ្រោះពីរនាក់ មកពីស្រុកកំណើត បម្រុងនាំចេញទៅប្រទេសចិន ។

សមត្ថកិច្ចបានឱ្យដឹងថា លុះពេលនាំជនរងគ្រោះ មកដល់ផ្លូវ៦A ស្ថិតក្នុងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ពួកគេបានចុះពីរថយន្តតាក់ស៊ី ដើម្បីរង់ចាំមេខ្យល់នៅភ្នំពេញទៅទទួលយក ។ ពេលកំពុងឈប់ចាំមេខ្យល់ ក៏ត្រូវបានសមត្ថកិច្ចទៅនាំខ្លួន ទៅកាន់ការិយាល័យដើម្បីធ្វើការសាកសួរ ។

ជនសង្ស័យឈ្មោះ អ៊ុច សេងហុង បានសារភាពថា ខ្លួនពិតជាបាននាំ នារីអ្នកចម្ការពីរនាក់ យកមកឱ្យមេខ្យល់នៅភ្នំពេញនេះមែន និងមានគោលដៅនាំពួកគេ ទៅកាន់ប្រទេសចិន តាមច្រកព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម បាវិតខេត្តស្វាយរៀង ។ ចម្លើយជនសង្ស័យ ប្រាប់សមត្ថកិច្ចថា សកម្មភាពនាំនារីខ្មែរ បម្រុងទៅលក់ដូរ នៅប្រទេសចិននេះ រូបគេទទួលបានប្រាក់ពីមេខ្យល់ ក្នុងនារីម្នាក់ ចំនួន ២.០០០ដុល្លារអាមេរិក ប៉ុន្តែប្រាក់នេះ គេបានចំណាយទៅវិញ ក្នុងការធ្វើដំណើរអស់៥០០ដុល្លារ ផងដែរ ។ ជនសង្ស័យជាមុខសញ្ញា ធ្លាប់ប្រកបមុខរបរនាំនារីខ្មែរ លក់ទៅប្រទេសចិន ចំនួន៣ លើកមកហើយ និងមាននារីខ្មែរ៣នាក់ ដែលបានរងគ្រោះដោយស្នាដៃ ជនសង្ស័យរូបនេះ៕

## សេចក្តីជូនដំណឹង! រដ្ឋបាលខេត្តបាត់ដំបង ប្រាប់ឲ្យពលរដ្ឋដែលមានទីលំនៅអចិន្ត្រៃយ៍ ធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ គំរូថ្មីចាប់ពីថ្ងៃ២ ខែមករា តទៅ

http://www.freshnewsasia.com/ 2018-01-03

**(បាត់ដំបង)៖** អភិបាលខេត្តបាត់ដំបងលោក ងួន រតនៈ បានចេញសេចក្តីជូនដំណឹងឲ្យពលរដ្ឋ ដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងខេត្ត ភាគពាយ័ព្យមួយនេះ ធ្វើប័ណ្ណព្រំដែន កម្ពុជា-ថៃ គំរូថ្មី នៅច្រកចេញចូលតែមួយ នៃរដ្ឋបាលខេត្តបាត់ដំបង ចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ នេះតទៅ។

ការចេញប័ណ្ណព្រំដែនគំរូថ្មីនេះ ធ្វើបានសម្រាប់តែពលរដ្ឋទូទៅ ដែលមានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងខេត្តបាត់ដំបង ដោយផ្អែកលើកិច្ចព្រមព្រៀងថ្មីចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរដ្ឋាភិបាលកម្ពុជា ជាមួយរាជរដ្ឋាភិបាលថៃ ស្តីពីការឆ្លងកាត់ព្រំដែននៃភាគីទាំង២ ដើម្បីប្រើប្រាស់ប័ណ្ណព្រំដែននេះ ជាឯកសារផ្លូវការ សម្រាប់ប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន អាចប្រើប្រាស់នៅពេល ចេញចូលឆ្លងកាត់ព្រំដែនរវាងប្រទេសទាំង២។

សូមបញ្ជាក់ថា ប័ណ្ណព្រំដែនចាស់ ដែលដាក់ឲ្យប្រើប្រាស់កន្លងមក គឺធ្វើដោយនគរបាលអន្តោប្រវេសន៍ ប្រចាំច្រកទ្វារអន្តរជាតិដូង ដែលការធ្វើនេះមានរយៈពេលច្រើនឆ្នាំមកហើយ ហើយសម្រាប់ឆ្នាំ២០១៨នេះ គឺប័ណ្ណព្រំដែនគំរូថ្មី ត្រូវបានបង្វែរមកធ្វើដោយរដ្ឋបាលខេត្តបាត់ដំបងវិញ ទៅតាមលក្ខខណ្ឌ នៃក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងមហាផ្ទៃនៃប្រទេសថៃ។

លោក សឿម ប៊ុនរិទ្ធ អភិបាលរងខេត្តបានថ្លែងថា ប័ណ្ណព្រំដែនគំរូថ្មី ដែលនឹងធ្វើឡើងដោយរដ្ឋបាលខេត្តបាត់ដំបងនេះ ត្រូវបានប្រជាពលរដ្ឋសង្ឃឹម និងជឿជាក់ថា ការធ្វើប័ណ្ណព្រំដែន នឹងមានលក្ខណៈងាយស្រួលជាងការធ្វើប័ណ្ណព្រំដែន (Boder Pass) ដែលធ្វើដោយនគរបាលអន្តោប្រវេសន៍ ប្រចាំច្រកទ្វារអន្តរជាតិដូង ហើយចំពោះតម្លៃប័ណ្ណព្រំដែនគំរូថ្មីនេះ គឺតាមការកំណត់ក្នុង១ក្បាល សម្រាប់ប្រជាពលរដ្ឋមានទីលំនៅអចិន្ត្រៃយ៍ក្នុងខេត្តបាត់ដំបងតម្លៃ២ម៉ឺនរៀលតែប៉ុណ្ណោះ ក្នុង១ក្បាល។

លោក សឿម ប៊ុនរិទ្ធ បានបញ្ជាក់ថា ការធ្វើប័ណ្ណព្រំដែន (Boder Pass) ជាដំបូងបានប្រកាសឲ្យប្រជាពលរដ្ឋអញ្ជើញ មកដាក់ពាក្យសុំប័ណ្ណនេះជាបណ្តោះអាសន្ន តាមរយៈយន្តការការិយាល័យ ច្រកចេញចូលតែ១របស់សាលាខេត្តសិន ហើយទីតាំងទទួលពាក្យនោះគឺបានខ្ចីកន្លែងការិយាល័យស្ថិតិ និងអាត្រានុកូលដ្ឋានធ្វើការងារនេះ និងថ្ងៃក្រោយមានការប្តូរទីតាំងរដ្ឋបាលខេត្ត នឹងជម្រាបជូនដំណឹងតាមក្រោយទៀត។ លោក សឿម ប៊ុនរិទ្ធ បានបន្តថា ប័ណ្ណព្រំដែន (Boder Pass) គំរូថ្មីនេះ សម្រាប់ពលរដ្ឋខេត្តបាត់ដំបង គឺអាចចេញចូលប្រទេសថៃចំនួន៣ខេត្ត គឺខេត្តត្រាត ខេត្តច័ន្ទបុរី និងខេត្តស្រះកែវ ហើយអ្នកកាន់ប័ណ្ណនេះ បើចេញទៅប្រទេសថៃ តាមច្រកមួយណាពេលត្រឡប់វិញ ត្រូវចូលមកវិញតាមច្រកនោះវិញ បានន័យថា មិនអាចចូលតាមច្រកផ្សេងបានទេ។

បន្ថែមលើនេះទៀតនោះ គឺការធ្វើប័ណ្ណព្រំដែនសម្រាប់ឆ្លងទៅប្រទេសថៃ ឬថៃឆ្លងមកកម្ពុជា កន្លងមក មានភាពលំបាកណាស់ ដោយមានការកំណត់ឲ្យថតរូបធ្វើប័ណ្ណ ដើម្បីបិទភ្ជាប់ជាមួយ សៀវភៅប័ណ្ណព្រំដែន ដែលការធ្វើនេះត្រូវតម្រង់ជួររង់ចាំធ្វើប័ណ្ណនៅខាងភាគីថៃ បើមិនដូច្នោះ ខាងភាគីថៃ នឹងមិនអនុញ្ញាតឲ្យចូលនោះទេ តែឥឡូវមានភាពងាយស្រួលជាងមុន៕

## ប៉ូលិសរំលោភក្មេងស្រីដល់ទៅ២នាក់ បែរជារួចខ្លួន

http://www.yobminh.com/ ប្រភពគេហទំព័រ យប់មិញ បញ្ញា January 4, 2018

អាណាព្យាបាលកុមារីពីរនាក់ជាជនជាតិដើមភាគតិចចារ៉ាយ រស់នៅខេត្តរតនគិរី សម្រេចទទួលសំណង ១ម៉ឺន ២ពាន់ដុល្លារ ពីនគរបាលម្នាក់ដែលចាប់រំលោភកូនស្រីរបស់ខ្លួនពីរនាក់ ដើម្បីបញ្ចប់សំណុំរឿងព្រហ្មទណ្ឌ។ ប៉ុន្តែមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សចាត់ទុកករណីនេះ ជាទង្វើខុសច្បាប់ និងបង្ហាញពីការកើនឡើងនូវវប្បធម៌និទ្ទណ្ឌភាព ទោះបីជាជនល្មើសបានផ្តល់សំណងជំងឺចិត្តយ៉ាងណាក្តី។ អាណាព្យាបាលក្មេងស្រីពីរនាក់ នៅខេត្តរតនគីរីឲ្យដឹងនៅថ្ងៃទី៣ មករា ថា មូលហេតុដែលលោកព្រមទទួលសំណង ដោយសារ ពួកគាត់ក្រីក្រគ្មានប្រាក់ប្តឹងរឿងនេះទៅតុលាការ ហើយពួកគេក៏គ្មានជំនឿលើតុលាការដែរ ថានឹងស្វែងរកយុត្តិធម៌ជូនគ្រួសារគាត់បាន។

បុរសដែលត្រូវជាឪពុកក្មេងស្រីរងគ្រោះជាជនជាតិដើមភាគតិចចារ៉ាយ ឲ្យដឹងថា លោកសម្រេចដកពាក្យបណ្តឹងសំណុំរឿងនេះ ខណៈដែលជនសង្ស័យឯកភាពព្រមផ្តល់សំណងជាប្រាក់ ជាង ១ម៉ឺនដុល្លារ។ លោករំឭកថា កាលពីចុងខែធ្នូ ឆ្នាំ ២០១៧ នគរបាលនៃប៉ុស្តិ៍រដ្ឋបាលឃុំ ម្នាក់ឈ្មោះ មាស សោភ័ណ បានចាប់រំលោភកូនស្រីរបស់លោកអាយុ ១៤ ឆ្នាំម្នាក់ និងកុមារីម្នាក់ទៀតត្រូវជាបងប្អូនជីដូនមួយបានសម្រេច។ លោកបាន ប្តឹងរឿងនេះទៅប៉ុស្តិ៍រដ្ឋបាលឃុំ ក៏ប៉ុន្តែដោយមានអាជ្ញាធរ និងមេប៉ុស្តិ៍នគរបាលសម្របសម្រួលរឿងនេះ លោកសម្រេចដកពាក្យបណ្តឹងវិញ ៖ «អត់ប្តឹងទៅគឺតាមប្រពៃណី មូលហេតុគេសងជំងឺចិត្ត ទាំងអស់ពីរនាក់ហ្នឹង មួយម៉ឺនពីរពាន់ដុល្លារ»។ កាលពីថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១៧ ឪពុកជនរងគ្រោះ បានដាក់ពាក្យប្តឹងករណីនេះទៅនគរបាលនៃប៉ុស្តិ៍រដ្ឋបាលឃុំ។ ខ្លឹមសារពាក្យបណ្តឹងនោះគឺប្តឹងឈ្មោះ មាស សោភ័ណ ពីបទរំលោភផ្លូវភេទ លើកុមារីកំពុងសិក្សាថ្នាក់ទី៦។ លើសពីនេះ គឺរាល់ពេលដែលនាងចេញពីសាលារៀន នាងតែងតែទៅជួយការងារផ្ទះ ក្រោយមកជនសង្ស័យឈ្មោះ សោភ័ណ បានលួងលោមនាងឲ្យទៅក្រុងបានលុង ខេត្តរតនគិរីដោយសន្យាថា ទិញទូរស័ព្ទដៃ និងខោខ្សែក នាងយល់ព្រមទៅជាមួយ តែនគរបាលរូបនោះបែរជានាំនាងទៅផ្ទះសំណាក់ រួចចាប់រំលោភ។

មេភូមិម្នាក់ទទួលស្គាល់ថា បទល្មើសឧក្រិដ្ឋមិនអាចសម្របសម្រួលក្រៅប្រព័ន្ធតុលាការបានទេ ក៏ប៉ុន្តែអាណាព្យាបាលជនរងគ្រោះបានសំណូមពរឲ្យសម្របសម្រួលសំណុំរឿងនេះ ដោយសារមិនចង់មានរឿងវែងឆ្ងាយ ម្យ៉ាងជនសង្ស័យដែលជាមន្ត្រីប៉ូលិសគឺជាសាច់ញាតិ៖ «ខាងប៉ូលិសព្រហ្មទណ្ឌគាត់ថា ចង់ធ្វើការព្រហ្មទណ្ឌដែរ តែខាងឪពុកម្ដាយជនរងគ្រោះគេសុំសម្របសម្រួលគ្នា។ ខាងយើងនេះក្រីក្រដែល អត់មានលុយ សម្របសម្រួលអ៊ីចឹងទៅបើគេសងយើងហើយ យើងព្រមដែលក៏ធ្វើកិច្ចសន្យាទៅ»។

មន្ត្រីឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៃសមាគមអាដហុក (Adhoc) ខេត្តរតនគិរី លោក ឌិន ឧន្នី ពន្យល់ថា សំណុំរឿងបទល្មើសឧក្រិដ្ឋ មិនអាចមានអាជ្ញាធរណាមួយ សម្របសម្រួលបានទេ។ លោកថា អាជ្ញាធរមូលដ្ឋាន និងមេប៉ុស្តិ៍រដ្ឋបាលណា ដែលហ៊ានចេញមុខសម្របសម្រួលបទល្មើសឧក្រិដ្ឋ គឺជាទង្វើខុសច្បាប់។ លោកបញ្ជាក់ថា ការសម្របសម្រួលផ្ដល់សំណង មិនអាចបញ្ចប់សំណុំរឿងព្រហ្មទណ្ឌបានទេ គឺគ្រាន់តែការជួសជុលការខូចខាត រីឯទោសព្រហ្មទណ្ឌនៅតែអនុវត្ត៖ «ទោះបីជាការសម្របសម្រួលរឿងសងលុយ សងកាក់តែនេះពុំមែនជាការសម្របសម្រួលបញ្ចប់រឿងព្រហ្មទណ្ឌទេ តែនេះអ្វីដែលគាត់សងលុយសងកាក់ គ្រាន់តែជាការជួសជុលការខូចខាត ធ្វើឲ្យកុមារីរងគ្រោះ។ ចំណែកឯទោសព្រហ្មទណ្ឌគាត់នៅទទួលរងដដែលគឺជាប់ពន្ធនាគារ»។

លោក ឌិន ឧន្នី សង្កត់ធ្ងន់ថា ការសម្របសម្រួលផ្ដល់សំណង ដើម្បីបញ្ចប់សំណុំរឿងព្រហ្មទណ្ឌ គឺជាសញ្ញាបង្ហាញពីការកើនឡើងវប្បធម៌និទ្ទណ្ឌភាព ឬភាពគ្មានទោសពៃរ៍ បង្កឲ្យជនល្មើសមិនរាងចាល និងមិនខ្លាចច្បាប់ ។ ក្រមព្រហ្មទណ្ឌមាត្រា ២៤០ និង ២៤១ ចែងថា បទរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ឡើងទៅ ១៥ឆ្នាំ។ បទល្មើសនេះ គឺប្រព្រឹត្តទៅលើបុគ្គលទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គល ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ និងការប្រើគ្រប់វិធីដែលនាំឲ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ។

## ពលរដ្ឋខេត្តឧត្តរមានជ័យ ងាកមកប្រកបរបរកសិកម្ម កាត់បន្ថយការធ្វើចំណាកស្រុក

http://bayontv.com.kh/ 03/01/2018

ឧត្តរមានជ័យ ៖ ប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យ ជាបណ្ដើរៗ បានងាកមកប្រកបរបរដាំដំណាំកសិកម្មវិញហើយ ដើម្បីចៀសវាងការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសដោយប្រថុយប្រថាន។ ដោយបច្ចុប្បន្ននេះ ដំណាំដំឡូងមី និងដំណាំផ្សេងៗមានកំណើនតម្លៃពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើឲ្យប្រជាកសិករនៅ ក្នុងភូមិទឹកថ្លា ឃុំបុស្សស្បូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ចំនួនប្រមាណជា៧០ភាគរយ ដែលពីមុនតែងតែធ្វើចំណាក ស្រុកទៅរកការងារនៅឯប្រទេសថៃនោះ ងាកមកប្រកបរបរដាំដំណាំដំឡូងមី នៅក្នុងមូលដ្ឋានស្រុករបស់ខ្លួនវិញ ដើម្បីកាត់ បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ទៅរកការងារធ្វើ។

ប្រជាពលរដ្ឋក្នុងភូមិនេះ បានយល់ឃើញថា បច្ចុប្បន្ននេះ ការងារនៅក្នុងស្រុក ក៏អាចជួយរកប្រាក់កម្រៃបានច្រើនគួរសមដែរ សម្រាប់យកមកផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ បើទោះបីជាការងារមួយចំនួនមានការលំបាកបន្តិចក្ដី។ អ្នកភូមិឈ្មោះ ម៉ៅ សឹត រស់ក្នុងភូមិទឹកថ្លា ឃុំបុសស្បូវ ក្រុងសំរោង បានឲ្យដឹងថា កន្លងមក គ្រួសាររបស់គាត់តែងតែទៅធ្វើការងារជាកម្មករសំណង់នៅឯប្រទេសថៃ ដោយទទួលបានប្រាក់ចំនួន២០០បាតក្នុងមួយថ្ងៃ តែទូទាត់លើការចំណាយផ្សេងៗ គឺនៅសល់តិចណាស់ ពុំបានសល់ប្រាក់កាក់ច្រើនទេ ពេលគាត់ត្រលប់ មកផ្ទះវិញម្ដងៗ នោះទេ ទើបគាត់បានសម្រេចចិត្តងាកមកប្រកបរបរកសិកម្ម ដាំដំណាំដំឡូងមី នៅជិតផ្ទះវិញម្ដង លើផ្ទៃដីចំនួន១ហិកតា កន្លះ ដោយក្នុងមួយឆ្នាំៗ គាត់អាចប្រមូលផលដំណាំរបស់គាត់បានចំនួន២ដង នៃការដាំដំណាំដំឡូងមីនេះ ដោយរយៈ ពេល១ឆ្នាំ ជាង គាត់ធ្វើបានពី៨តោនទៅ១០តោន សម្រាប់ដីមួយហិកតា បើសិនជាអាកាសធាតុអំណោយផលល្អ។

កសិកររូបនេះ បានឲ្យដឹងថា ឆ្នាំតម្លៃដំឡូងមីបានហក់ឡើងខ្ពស់ជាងឆ្នាំមុន គឺលក់បានថ្លៃ៥បាតកន្លះ ក្នុងមួយគីឡូ ក្រាម ខណៈឆ្នាំមុនលក់បានថ្លៃតែ២បាតទៅ៣បាតប៉ុណ្ណោះ ដែលសឹងតែមិនរួចថ្លៃដើមទុនផង។ គាត់បាន

បញ្ជាក់ថា ការដំណាំនេះ គឺមានមន្ត្រីជំនាញកសិកម្ម និងអង្គការមួយចំនួន បានចុះមកធ្វើការណែនាំពីវិធី សាស្ត្រផ្សេងៗដល់រូបគាត់ផងដែរ ទើបអាចទទួលបានផលល្អដូច្នេះ និងធ្វើឲ្យពួកគាត់មិនចាំបាច់ធ្វើចំណាកស្រុកទៅធ្វើ ការងារនៅប្រទេសថៃដូចមុនឡើយ។ គាត់មានមហិច្ឆតា ពង្រីកផ្ទៃដីដាំដំឡូងមីនេះ បន្ថែមទៀតទៅពេលអនាគត។

លោក សូត្រ ស៊ីសុឃាង ប្រធានមន្ទីរកសិកម្ម ខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា ជារៀងរាល់ខែ លោកតែងតែបញ្ជូន មន្ត្រីជំនាញចុះទៅអប់រំ និងផ្សព្វផ្សាយពីវិធីសាស្ត្រផ្សេងៗដល់ពលរដ្ឋនៅតាមសហគមន៍ ឲ្យពួកគេមានការយល់ដឹង កាន់តែច្បាស់ អំពីរបៀបនៃការធ្វើកសិកម្ម និងការដាំដំណាំផ្សេងៗនៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីកាត់បន្ថយការធ្វើ ចំណាកស្រុកទៅក្រៅប្រទេសដោយប្រថុយប្រថាន៕

## តុលាកំពូលបង្វិលសំណុំរឿង នាំមនុស្សរៀបការប្ដីចិនមកឧទ្ធរណ៍វិញ

http://www.postkhmer.com/ ភ្នំពេញប៉ុស្តិ៍ Thu, 4 January 2018 គឹម សារុំ

ភ្នំពេញៈ តុលាការកំពូលកាលពីម្សិលមិញបានបង្វិលសំណុំរឿង និងបង្គាប់ឲ្យសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញនូវសំណុំរឿងស្ត្រីជាប់ចោទម្នាក់ពាក់ព័ន្ធនឹងការនាំនារីខ្មែរ ២ នាក់ទៅរៀបការប្ដីចិន បន្ទាប់ពីជម្រះកាលពីថ្ងៃទី ២៥ ខែធ្នូ ខណៈរឿងនេះធ្លាប់ត្រូវបានសាលាឧទ្ធរណ៍បន្ថយទោសពី ៩ ឆ្នាំមក ៨ ឆ្នាំ។ តាមសាលដីកាដែលអានដោយលោក ចៅក្រម គង់ ស្រ៊ីម ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខស្ត្រីជាប់ចោទឈ្មោះ អ៊ុក វ៉ាន់នី អាយុ ៦២ ឆ្នាំថា ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងមេធាវីជនជាប់ចោទ និងតាមសំអាងហេតុថា នារីទាំង ២ នាក់ពិតជាមានចេតនាទៅរៀបការប្ដីនៅចិនមែន។ លោកថ្លែងបញ្ជាក់ថាៈ «អង្គហេតុនេះពុំមានធាតុផ្សំគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនជាប់ចោទទេ ។ ដូច្នេះតុលាការកំពូលបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្វិលទៅសាលាឧទ្ធរណ៍ឲ្យជំនុំជម្រះរឿងនេះឡើងវិញ»។

គួររំឭកថាកាលពីថ្ងៃជំនុំជម្រះលោក កៅ សុភ័ត្រា មេធាវីការពារសិទ្ធិឲ្យស្ត្រីជាប់ចោទបានប្រាប់ចៅក្រមថាកូនក្ដីលោកបានឆ្លើយគ្រប់ដំណាក់កាលថាគាត់មិនបានប្រព្រឹត្តទេ តែពួកនារីរងគ្រោះចង់ទៅខ្លួនឯង។ ចំណុចនេះបញ្ជាក់ថាកូនក្ដីលោកមិនបានធ្វើអ្វីឲ្យខូចខាតដល់នារីរងគ្រោះទេ ខ្ញុំសូមតុលាការបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ជម្រះឡើងវិញ។

ស្ត្រីជាប់ចោទបានឆ្លើយកាលពីថ្ងៃបើកសវនាការថានារីរងគ្រោះ ឈ្មោះ សំ ស្រីទូច គឺត្រូវជាកូនធម៌របស់ខ្លួន ហើយពេលនោះនាងខឹងអ្នកស្រីហាមមិនឲ្យនិយាយទូរស័ព្ទច្រើនហើយក៏ប្ដឹងសមត្ថកិច្ចថាអ្នកស្រីនាំនាងទៅចិនតែម្ដងទៅ។ ចំណែកនារីទៀតឈ្មោះ វ៉ាត់ លី គឺម្ដាយនាងសុំឲ្យអ្នកស្រីជួយណែនាំទៅធ្វើការនៅចិនព្រោះម្ដាយគាត់ដឹងថាអ្នកស្រីមានកូនស្រី ២ នាក់នៅចិន។

តាមកំណត់ហេតុថាស្ត្រីឈ្មោះ អ៊ុក វ៉ាន់នី បានលួងលោមនារីខ្មែរ ២ នាក់ថាទៅធ្វើការនៅចិនបានប្រាក់ខែ ៨០០ ដុល្លារ។ បន្ទាប់ពីនារីរងគ្រោះយល់ព្រមស្ត្រីជាប់ចោទក៏ចេញលុយ ១៥០ ដុល្លារឲ្យដើម្បីរត់ការឯកសារ។ កំណត់ហេតុក៏បានកត់ត្រាដែរថាបន្ទាប់ពីរត់ការឯកសារបានហើយកូនប្រុសរបស់ស្ត្រីជាប់ចោទ ឈ្មោះ អ៊ុក ចំរើន បានឱបនារីរងគ្រោះមកផ្ទះរបស់ស្ត្រីជាប់ចោទក្នុងបំណងនាំចេញតាមច្រកព្រំដែនវៀតណាម តែក៏ត្រូវនគរបាលឃាត់ខ្លួននៅថ្ងៃទី ២៤ ខែមិថុនាឆ្នាំ ២០១៥ នៅភូមិត្រពាំងអណ្ដូង សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ។

សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញផ្ដន្ទាទោសស្ត្រីជាប់ចោទដាក់ពន្ធនាគារ ៩ ឆ្នាំនៅថ្ងៃទី ៥ ខែមេសាឆ្នាំ ២០១៦ ចោទពីបទ «ប៉ុនប៉ងនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» និងបង្គាប់ឲ្យសងប្រាក់ទៅនារីរងគ្រោះម្នាក់ ២ លានរៀល។ ឯឈ្មោះ អ៊ុក ចំរើន ឲ្យរួចខ្លួន។ ប៉ុន្តែស្ត្រីជាប់ចោទបានប្ដឹងជំទាស់មកសាលាឧទ្ធរណ៍ហើយត្រូវសាលាឧទ្ធរណ៍បន្ថយទោសមកត្រឹម ៨ ឆ្នាំវិញ និងរក្សាប្រាក់សំណងដដែល ៕

## យុទ្ធនាការផ្សព្វផ្សាយប្រយុទ្ធប្រឆាំងជួញដូរមនុស្ស និងធ្វើចំណាកស្រុកនៅឃុំស្នាមព្រះ ស្រុកបាកាន

http://ann.com.kh/site/news/ ថ្ងៃព្រហស្បតិ៍ 4 ខែមករា 2018 11:25 ព្រឹក

អង្គការអោជ្រាកម្ពុជាប្រចាំខេត្តពោធិ៍សាត់ ក្រោមការគាំទ្រថវិកាពីជំនួយរដ្ឋាភិបាលអូស្ត្រាលី និងអង្គការអោជ្រាអូស្ត្រាលីបាន រៀបចំយុទ្ធនាការផ្សព្វផ្សាយអំពីការប្រឆាំងអំពើរជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅភូមិអណ្តូងសំប្បិរឃុំស្នាម ព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ នាព្រឹកថ្ងៃទី០៣ ខែមករាឆ្នាំ២០១៨ដោយមានអ្នកចូលរួម៣០០នាក់មាន៦ភូមិគឺភូមិអណ្តូងសំប្បិ អន្លង់មៀន ស្តុកស្វាយ ភ្នៅ សាមគ្គី និងភូមិអារ៉ែន។

លោក រិទ្ធ សារ៉ាយ ប្រធានគម្រោងរបស់អង្គការអោជ្រាកម្ពុជាប្រចាំខេត្តពោធិ៍សាត់ មានប្រសាសន៍ថា យុទ្ធនាការនេះមានគោលបំណងនិងប្រធានបទចំនួន៣សំខាន់ គឺ១-បង្កើនការយល់ដឹងអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ២-ចូលរួមទប់ស្កាត់ការជួញដូរមនុស្សនៅក្នុងសហគមន៍ ៣-បញ្ឈប់ការជក់បារី ។ គម្រោងជម្រើសសម្រាប់កុមារនេះចាប់ផ្តើមនៅឆ្នាំ២០១៤ និងបញ្ចប់នៅឆ្នាំ២០១៩ គ្របដណ្តប់៦០ ភូមិ ៥ឃុំនៅក្នុងស្រុកបាកានមានឃុំខ្នាទទឹង រំលេច បឹងបត់កណ្តោល ត្រពាំងជង និងឃុំស្នាមព្រះមាន ប្រជាពលរដ្ឋ៦ពាន់គ្រួសារស្មើនឹងជាង១៤ពាន់នាក់។ លោកបានលើកឡើងទៀតថា តាមរយៈបទពិសោធន៍និងសកម្មភាពបានបង្ហាញថា ប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅបានចំណាក ស្រុកនៅតែមានការកើនឡើង។ជាក់ស្តែងក្នុងចំណោម៧គ្រួសារមាន៥គ្រួសារឪពុក ម្តាយ បានធ្វើចំណាកស្រុក ទុកកូនឱ្យយាយ តាឬបងប្អូនមើលថៃ ធ្វើឱ្យប៉ះពាល់ដល់ដល់កុមារ ដូចជាខ្វះភាពកក់ក្តៅ អាហាមិនបានគ្រប់គ្រាន់ ខ្វះអនាម័យប្រឈមការលួត លាស់ ការរំលោភបំពានលើរាងកាយ និងផ្លូវភេទជាដើម។

ជាមួយគ្នានោះដែរអង្គការអោជ្រាក៏មានកម្មវិធីផ្នែកសុខភាព ដោយសំខាន់ទៅលើផលប៉ះពាល់បណ្តាលមកពីថ្នាំជក់ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៧បានចូលរួមតស៊ូមតិបង្កើតច្បាប់តំបន់គ្មានផ្សែងបារី ក្នុងនោះបានបញ្ចូលក្នុងកម្មវិធីសិក្សាសាលារដ្ឋថ្នាក់ទី៨ដល់ទី១២ទទួលបានភាពជោគជ័យ។

មានប្រសាសន៍ក្នុងឱកាសនោះលោក សឺន សាក់សារ៉ាន់ អភិបាលរងនៃគណៈអភិបាលស្រុកបាកាន បានថ្លែងអំណរគុណ ដល់អង្គការអោជ្រាកម្ពុជាប្រចាំខេត្តពោធិ៍សាត់និងម្ចាស់ផ្តល់ជំនួយដែលបានជ្រើសរើសស្រុកបាកានជាតំបន់គោលដៅក្នុងការជម្រុញ ផ្សព្វផ្សាយអំពីការប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនិងផលប៉ះពាល់នៃការជក់បារី ។ប្រធាន បទទាំង៣នេះពិតជាមានសារៈសំខាន់ ហើយក៏ជាសារមួយសម្រាប់ឱ្យប្រជាពលរដ្ឋយើង គប្បីយកចិត្តទុកដាក់ សិក្សាស្វែងយល់ស៊ីជម្រៅឱ្យបានគ្រប់ជ្រុងជ្រោយ ចៀសវាងចាញ់ល្បិចជនខិលខូច នាំឱ្យខាតបង់ថវិកា និងពេលវេលា។ ដូចនេះក្នុងនាមរដ្ឋបាលស្រុក សូមឱ្យប្រជាជនយើងចូលរួមថែរក្សាការពារនូវរាល់សមិទ្ធផលដែលមាននៅក្នុងមូលដ្ឋានឱ្យបានគង់វង្សយូរអង្វែងប្រយោជន៍ដល់កូន ចៅយើងជំនាន់ក្រោយៗទៀត។ នៅក្នុងយុទ្ធនាការផ្សព្វផ្សាយនោះបុគ្គលិកអង្គការអោជ្រា បានរៀបចំការសម្តែងរឿង និងសំណួរ ចម្លើយពាក់ព័ន្ធទៅនឹងប្រធានបទទាំង៣នោះផងដែរ ៕ សួន ឈឿន

## រដ្ឋបាលខេត្តឧត្តរមានជ័យ ជូនដំណឹងស្តីពីការដំណើរការអនុវត្តន៍ប័ណ្ណព្រំដែនកម្ពុជា-ថៃគំរូថ្មី

http://www.akp.gov.kh/kh/ AKP ឧត្តរមានជ័យ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨

រដ្ឋបាលខេត្តឧត្តរមានជ័យ បានចេញសេចក្តីជូនដំណឹងស្តីពីការចាប់ដំណើរការអនុវត្តន៍ប័ណ្ណព្រំដែនកម្ពុជា-ថៃគំរូថ្មី នៅថ្ងៃថ្ងៃពុធ ២រោជ ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨។ សេចក្តីជូនដំណឹងនេះបានឱ្យដឹងថា ដោយអនុលោមតាមស្មារតីអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីប័ណ្ណព្រំដែនកម្ពុជា-ថៃ និងលិខិតលេខ១៤៧៧ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ រដ្ឋបាលខេត្តឧត្តរមានជ័យមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ព្រះតេជគុណ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា មន្ត្រីរាជការ

កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង បងប្អូនប្រជាពលរដ្ឋទូទាំងខេត្តឧត្តរមានជ័យឱ្យបានជ្រាបថា រដ្ឋបាលខេត្តឧត្តរមានជ័យ នឹងការចាប់ដំណើរការអនុវត្តន៍ប័ណ្ណព្រំដែនកម្ពុជា-ថៃគំរូថ្មីនេះ ស្របការណែនាំចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៨នេះតទៅ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងខេត្តឧត្តរមានជ័យ អាចដាក់ពាក្យសុំប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅសាលាខេត្តឧត្តរមានជ័យរៀងរាល់ម៉ោងធ្វើការ ដោយសាមីខ្លួនផ្ទាល់ត្រូវភ្ជាប់មកជាមួយនូវ ៖

១-ពាក្យស្នើសុំប័ណ្ណព្រំដែនចំនួន០១ច្បាប់ ដោយបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំរបស់សាមីខ្លួននៅលើពាក្យស្នើសុំ(ពាក្យស្នើសុំមានផ្តល់ជូននៅសាលាខេត្ត)។

២-រូបថតសាមីខ្លួនបច្ចុប្បន្នទំហំ ៤×៦ ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតា ចំនួន២សន្លឹក។

៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើតដែលជាច្បាប់ដើម ឬច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម។

៤- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

ចំពោះកុមារដែលមានអាយុក្រោម១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុក ឬម្តាយ ឬអាណាព្យាបាល។ ដោយឡែកចំពោះកុមារអាយុក្រោម ១២ឆ្នាំអាចដាក់បញ្ចូលជាមួយប័ណ្ណព្រំដែនរបស់ឪពុក ឬម្តាយ ឬអាណាព្យាបាល ដោយភ្ជាប់មកជាមួយនូវឯសារពាក់ព័ន្ធ។

ចំពោះប័ណ្ណព្រំដែនប្រភេទចាស់ដែលបានផ្តល់ជូនរួចហើយ នឹងនៅបន្តប្រើប្រាស់រហូតដល់អស់សុពលភាព។ មន្ត្រីរដ្ឋបាលខេត្តឧត្តរមានជ័យក៏បានឱ្យដឹងថា រដ្ឋបាលខេត្តនឹងបង្កលក្ខណៈងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងការធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃគំរូថ្មី៕ ដោយទិត ស្រ៊

## វិចារណកថា: បទល្មើសឆ្លងដែន នៅតែកើតឡើង យ៉ាងពេញបន្ទុក

https://www.dap-news.com/kh/ ព្រហស្បតិ៍, 04 មករា ២០១៨ 08:29 ដោយ: វាសនាជាវរិជ័យ ID:012

ប្រភពពីប្រជាពលរដ្ឋ រស់នៅតាមតំបន់ព្រំដែន ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា នៅច្រករបៀងអូរបីជាន់ សព្វថ្ងៃនេះមានឈ្មួញ នាំចូលជ្រូករស់ មាន់ទា រស់ ក្នុង មួយថ្ងៃៗរាប់ ពាន់រាប់ម៉ឺនក្បាល ហើយមន្ត្រីជំនាញ និងសមត្ថកិច្ចពាក់ព័ន្ធមិនចាត់វិធានការទប់ស្កាត់នោះទេ ។ ការដែលឈ្មួញអាចធ្វើអ្វីៗស្រេចតែអំពើចិត្តគឺមានការឃុបឃិតបើកដៃពីសមត្ថកិច្ចប្រចាំច្រករបៀងអូរបីជាន់ និងចៅហ្វាយនាយរបស់ពួកគេ ដែលជាឧត្តមសេនីយ៍យោធា២រូប ដូចដែលបណ្តាញព័ត៌មាននានាបានចុះផ្សាយជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ ម៉ូតូគេចពន្ធនិងទំនិញគេចពន្ធជាច្រើនប្រភេទត្រូវឈ្មួញនាំចូលតាមច្រករបៀងអូរបីជាន់យ៉ាងលួនដូចមុនដដែល ហើយមន្ត្រីអាជ្ញាធរ និងសមត្ថកិច្ចខេត្តបន្ទាយមានជ័យ មិនទាន់ចាត់វិធានការទប់ស្កាត់ឲ្យស្របទៅតាមបទបញ្ជារបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃនៅឡើយទេ ។

គួររំលឹកដែរថា កាលពីប៉ុន្មានខែមុននេះ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃបានចេញបទបញ្ជាឲ្យបិទច្រករបៀងទាំងអស់ក្នុងខេត្តបន្ទាយមានជ័យ ដែលជាប់ព្រំប្រទល់ជាមួយប្រទេសថៃ ដើម្បីពង្រឹងសន្តិសុខនៅតាមព្រំដែន ក៏ដូចជាទប់ស្កាត់បទល្មើសឆ្លងដែន។ ក៏ប៉ុន្តែជាក់ស្តែងច្រករបៀងអូរបីជាន់ និងច្រករបៀងមួយចំនួនទៀតនៅស្រុកអូរជ្រៅ ស្រុកស្វាយចេក ស្រុកម៉ាឡៃ និងស្រុកថ្មពួក នៅតែដំណើរការយ៉ាងលួនដដែល។ នៅច្រករបៀងចំការគ ឃុំស្លក្រាម ស្រុកស្វាយចេក នៅតែមានសេចក្តីរាយការណ៍ជាបន្តបន្ទាប់រឿងឈ្មួញលួចនាំចូលម៉ូតូគេចពន្ធ រថយន្តចង្កូតស្តាំ និងទំនិញគេចពន្ធជាច្រើនប្រភេទទៀត យ៉ាងពេញបន្ទុកដដែល។ នៅតាមច្រករបៀងខ្លះមានការឃុបឃិតឲ្យពលរដ្ឋខ្មែរឆ្លងដែនចូលកាប់ឈើគ្រញូងលើទឹកដីថៃ និងបើកឲ្យពលករខ្មែរឆ្លងដែនខុសច្បាប់ ទៅរកការងារធ្វើលើទឹកដីថៃ ហើយត្រូវសមត្ថកិច្ចថៃ ចាប់បញ្ជូនត្រឡប់មកវិញរាប់ពាន់រាប់ម៉ឺននាក់។

ការដែលច្រករបៀងមួយចំនួនតាមព្រំដែនកម្ពុជា-ថៃក្នុងខេត្ត បន្ទាយមានជ័យ នៅតែអាចដំណើរការយ៉ាងរលូនគឺដោយសារតែ មន្ត្រីអាជ្ញាធរខេត្តបន្ទាយមានជ័យ និងសមត្ថកិច្ចក្នុងខេត្តនេះមិនយកចិត្តទុកដាក់អនុវត្តន៍ តាមបទបញ្ជារបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។ នៅតាមច្រករបៀងខ្លះឈ្មួញកំពុងបន្តនាំចូលរថយន្តចង្កូតស្តាំ ម៉ូតូគេចពន្ធ និងទំនិញគេចពន្ធពីទឹកដីថៃយ៉ាងអនាធិបតេយ្យ ហើយថែមទាំងមានការនាំចូលឈើគ្រញូងពីទឹកដីថៃផងដែរ។ តាមច្រករបៀងខ្លះទៀតឈ្មួញអាចនាំចូលទំនិញជាប្រភេទចំណីអាហារខូចគុណភាពមានលាយសារជាតុគីមី ដូចជាសាច់មាន់ ឆ្អឹងមាន់ ស្លាបមាន់ គ្រឿងក្នុងមាន់ គ្រឿងក្នុងជ្រូក និងប្រហិតជាច្រើនមុខពីទឹកដីថៃមកលក់ចែកចាយលើទីផ្សារកម្ពុជា។ ប្រការនេះកំពុងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពពលរដ្ឋខ្មែរដែលទិញគ្រឿងឧបភោគ បរិភោគទាំងនោះយកទៅទទួលទាន។

នៅតាមច្រកព្រំដែននិងច្រករបៀង ជាច្រើនកន្លែងក្នុងខេត្តបាត់ ដំបង ដូចជានៅស្រុកសំឡូត ស្រុកសំពៅលូន ស្រុកភ្នំព្រឹក និងស្រុកកំរៀង ឈ្មួញនៅតែអាចនាំចូលទំនិញគេចពន្ធ ទំនិញបង់ពន្ធមិនគ្រប់ និងទំនិញខុសច្បាប់យ៉ាងពេញបន្ទុក។ ជាពិសេសផលិតផលពីសត្វ ដូចជាសាច់មាន់ សាច់ជ្រូក គ្រឿងក្នុងមាន់ គ្រឿងក្នុងជ្រូក និងប្រហិតច្រើនប្រភេទត្រូវ ឈ្មួញនាំចូលពីទឹកដីថៃយ៉ាងពេញបន្ទុក ហើយមន្ត្រីជំនាញ និងសមត្ថកិច្ចនៅច្រកភ្នំដី និងច្រកអូររំដួលជាដើមគិតតែពីរឿងប្រមូលលុយដាក់ហោប៉ៅយ៉ាងសុខស្រួល។ កន្លងមកសមត្ថកិច្ចតាមច្រកព្រំដែនក្នុងខេត្តបាត់ដំបង បង្ក្រាបតែឈ្មួញតូចតាចដែលនាំចូលផលិតផលពីសត្វតិចតួច ហើយរឹបអូសយកចំណីអាហារខូចគុណភាពទាំងនោះទៅកម្ទេចចោល ដើម្បីបង្ហាញស្នាដៃ។ ចំណែកក្រុមឈ្មួញធំៗដែលនាំចូលទំនិញជាចំណីអាហារខូចគុណភាព និងមានលាយសារជាតុគីមីរាប់សិបតោនមកចែកចាយដល់ទីផ្សារក្នុងរាជធានីភ្នំពេញមិនឃើញសមត្ថកិច្ច និងមន្ត្រីជំនាញពាក់ព័ន្ធបង្ក្រាបឡើយ។

សរុបសេចក្តីមក តាមតំបន់ព្រំដែនកម្ពុជា-ថៃ នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន និងខេត្តឧត្តរមានជ័យ នៅតែមានបទល្មើសឆ្លងដែនកើតឡើងយ៉ាងពេញបន្ទុក ហើយមន្ត្រីអាជ្ញាធរ និងសមត្ថកិច្ចនៃបណ្តាខេត្តទាំងនេះ មិនអនុវត្តន៍តាមបទបញ្ជារបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃនៅឡើយទេ។ ជាពិសេសនៅខេត្តបន្ទាយមានជ័យ បទល្មើសឆ្លងដែននៅតែកើតឡើងយ៉ាងរាលដាលដូចជានៅច្រកអូរបីជាន់ និងច្រករបៀងចំការគជាដើម ហើយករណីពលករខ្មែរឆ្លងដែនខុសច្បាប់ចូលទៅរកការងារធ្វើលើទឹកដីថៃនៅតែកើតឡើងឥតឈប់ឈរ។ អ្នករកស៊ីនាំចូលម៉ូតូគេចពន្ធ រថយន្តចង្កូតស្តាំ និងទំនិញគេចពន្ធតាមច្រករបៀងច្រើនកន្លែងក្នុងខេត្តបន្ទាយមានជ័យ មានទាំងសាច់ញាតិរបស់មន្ត្រីជាន់ខ្ពស់ក្នុងខេត្តបន្ទាយមានជ័យផងដែរ ដោយមានការឃុបឃិតបើកដៃពីសមត្ថកិច្ចនៅតាមព្រំដែនចាំជួយសម្របសម្រួលបើកផ្លូវ។ ដូច្នេះក្រសួង និងស្ថាប័នពាក់ព័ន្ធគួរពិនិត្យឡើងវិញនឹងចាត់វិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព ដើម្បីកុំឲ្យបទល្មើសឆ្លងដែននៅតែបន្តកើតឡើងយ៉ាងរាលដាលពេញបន្ទុកដូចសព្វថ្ងៃនេះទៀត៕

### ពលករខ្មែររងគ្រោះ៥៦រូបត្រូវបានជួយសង្គ្រោះនៅម៉ាឡេស៊ី វៀតណាម និងថៃ

http://www.rfa.org/khmer/news/ ដោយ ហេង សកល 2018-01-03

ក្រសួងការបរទេសកម្ពុជាចេញសេចក្តីប្រកាសថា ពលរដ្ឋ និងពលករខ្មែរចំនួន៥៦នាក់ ដែលរងគ្រោះនៅប្រទេសម៉ាឡេស៊ី វៀតណាម និងថៃ ត្រូវបានជួយសង្គ្រោះ និងបញ្ជូនមកដល់កម្ពុជាវិញ កាលពីចុងខែធ្នូ ឆ្នាំ២០១៧។ មន្ត្រីសង្គមស៊ីវិលស្នើឲ្យរដ្ឋាភិបាល ជួយបណ្តុះបណ្តាល និងជ្រោមជ្រែងពលកររងគ្រោះធ្វើយ៉ាងណាឲ្យមានការងារ និងប្រាក់ខែសមរម្យ នៅក្នុងស្រុកខ្មែរ ដើម្បីកុំឲ្យពួកគាត់សម្រេចចិត្តធ្វើចំណាកស្រុកទាំងប្រថុយប្រថានម្តងទៀត។ ថ្វីត្បិតប្រទេសខ្មែរតូច និងមានប្រជាជនតិចក្តី ប៉ុន្តែប្រជាពលរដ្ឋខ្មែរត្រូវបានគេសង្កេតឃើញថា ពួកគាត់រងគ្រោះគ្រប់ទីកន្លែង និងគ្រប់ជំពូក ដោយសារតែការស្វែងរកការងារធ្វើនៅក្រៅប្រទេស ដើម្បីចិញ្ចឹមក្រពះ។

សេចក្ដីប្រកាសរបស់ក្រសួងការបរទេសកម្ពុជា ដែលចេញផ្សាយនៅថ្ងៃទី៣ ខែមករា ឲ្យដឹងថា ប្រជា ពលរដ្ឋ និងពលករខ្មែរចំនួន៥៦រូប ដែលរងគ្រោះនៅប្រទេសម៉ាឡេស៊ី វៀតណាម និងថៃ ត្រូវបានស្ថានទូតខ្មែរប្រចាំនៅប្រទេសទាំងនេះ ជួយសង្គ្រោះ និងបានបញ្ជូនមកកម្ពុជាវិញជាបន្តបន្ទាប់កាលពីចុងខែធ្នូ ឆ្នាំ២០១៧ កន្លងទៅ។ សេចក្ដីប្រកាសនោះ បញ្ជាក់ថា ក្នុងចំណោមពលរដ្ឋ និងពលករ៥៦រូបនោះ មាន៥នាក់រងគ្រោះនៅ ប្រទេសម៉ាឡេស៊ី បានបញ្ជូនមកដល់កម្ពុជា កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ ចំណែកពលរដ្ឋ២៩ នាក់ក្នុងនោះកុមារចំនួន២១នាក់ រងគ្រោះនៅប្រទេសវៀតណាម ដោយសារទៅរកស៊ីលក់ឆ្នោតនោះ ត្រូវបានបញ្ជូនមកដល់កម្ពុជាថ្ងៃទី២៧ និង២៩ ខែធ្នូ ឆ្នាំ២០១៧។ សម្រាប់ពលរដ្ឋខ្មែរ២២រូបទៀត ដែលត្រូវអាជ្ញាធរថៃចាប់ខ្លួននៅលើទូកនេសាទខុសច្បាប់នោះ ត្រូវបានបញ្ជូនមកដល់កម្ពុជា នៅថ្ងៃ ទី២៣ ខែធ្នូ ឆ្នាំ២០១៧។

ប្រធានផ្នែកស្ត្រីនៃសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) អ្នកស្រី ធន សុគន្ធា មានប្រសាសន៍ថា បញ្ហារងគ្រោះទាំងនេះ គឺពលរដ្ឋចំណាកស្រុកភាគច្រើន ពុំបានស្វែងយល់អំពីបញ្ហាប្រឈមនោះទេ ដោយពួកគាត់តែងរំពឹងថា ការងារនៅក្រៅប្រទេសទូលំទូលាយ និងរកបានប្រាក់ចំណូលខ្ពស់ជាងកម្ពុជា សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារដែលជួបការលំបាក និងជំពាក់បំណុលធនាគារ។ ទោះយ៉ាងណាក្ដី អ្នកស្រី ធន សុគន្ធា ស្នើឲ្យក្រសួងសង្គមកិច្ច និងរដ្ឋាភិបាល ជួយបណ្ដុះបណ្ដាល ពលកររងគ្រោះ ធ្វើយ៉ាងណាឲ្យមានការងារ និងប្រាក់ខែសមរម្យនៅក្នុងស្រុកខ្មែរ ជាពិសេសកុមារតែម្ដង ដែលត្រូវការពារពួកគាត់ឲ្យទទួលបានការអប់រំខ្ពស់ ដើម្បីកុំអោយពួកគាត់ សម្រេចចិត្តធ្វើចំណាកស្រុកទាំងប្រថុយប្រថានម្ដងទៀត។

ក្នុងរយៈពេល ៦ខែដំបូងឆ្នាំ២០១៧ ស្ថានទូតកម្ពុជា បានបញ្ជូនពលករកម្ពុជាប្រមាណ ១៣៤នាក់ មកពីប្រទេសម៉ាឡេស៊ី បន្ទាប់ពីស្ថានភាពការងាររបស់ពួកគេជួបការលំបាក។ ថ្វីបើប្រជាពលករខ្មែរ តែងតែងរងគ្រោះនៅក្រៅប្រទេសជាបន្តបន្ទាប់ក្ដី ប៉ុន្តែរដ្ឋាភិបាល នៅតែមានគម្រោង និងពេញចិត្តបញ្ជូនពលការិនីទៅធ្វើការជាមេផ្ទះនៅក្រៅប្រទេសឲ្យបាន ១ពាន់នាក់ក្នុងឆ្នាំ២០១៨ ខាងមុខ ជាពិសេសប្រទេសដែលធ្លាប់មានកេរ្តិ៍ឈ្មោះអាស្រូវរឿងធ្វើបាបពលករដូចជាប្រទេសម៉ាឡេស៊ីជាដើម។

កាលពីថ្ងៃទី២៧ ខែធ្នូ ក្រសួងការងារបានបញ្ជូនក្រុមពលការិនីលើកទីមួយចំនួន ១៤នាក់ ដើម្បីទៅធ្វើការជាអ្នកជំនួយការមេផ្ទះនៅតំបន់រដ្ឋបាលពិសេសនៅទីក្រុងហុងកុង។ ក្រៅពីហុងកុង រដ្ឋាភិបាល នឹងបញ្ជូនស្ត្រីខ្មែរប្រមាណ ៣០០នាក់ទៀត ទៅបម្រើការងារនៅតាមផ្ទះក្នុងប្រទេសម៉ាឡេស៊ី ជាថ្មីម្ដងទៀត នៅខែមីនា ឆ្នាំ២០១៨ ខាងមុខ បន្ទាប់ពីបានផ្អាកកាលពីឆ្នាំ២០១១ ក្រោយពេលមានពលករខ្មែរមួយចំនួន ត្រូវបានថៅកែជនជាតិម៉ាឡេស៊ីវាយ និងរំលោភបំពាន។

ប្រធានផ្នែកស្ត្រីនៃសមាគមការពារសិទ្ធិមនុស្សអាដហុក ស្នើឲ្យរដ្ឋាភិបាលកម្ពុជា គួរតែព្យាយាម បង្កើតទីផ្សារការងារឲ្យមានតុល្យភាពជាមួយនឹងចំនួនមនុស្សដែលពេញកំពុងរកការងារធ្វើ។ ចំណែកប្រាក់បៀវត្សរ៍វិញ ត្រូវជានាឲ្យមានតុល្យភាពជាមួយនឹងការចំណាយដើម្បីទប់ទល់នឹងស្ថានភាព ជីវភាពរស់នៅរបស់ពួកគាត់។ ទន្ទឹមគ្នានេះ រដ្ឋាភិបាលត្រូវរកទីផ្សារ និងបង្កើនតម្លៃផលិតផលកសិកម្មដែលបច្ចុប្បន្ននេះ កំពុងតែជួបបញ្ហាប្រឈម៕

## តុលាការកោះហៅស្ត្រីឆបោកយកមកសាកសួរ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៨ម៉ោង ១៤:០៤ប៊ុង ឆដា

ខេត្តកណ្ដាល ៖ នៅព្រឹកថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ លោកស្រី ស៊ុន យីត ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល បានចេញដីកាកោះហៅស្ត្រីឆបោកឈ្មោះ អៀត សារឹម ឲ្យចូលមកតុលាការ ដើម្បីសាកសួរបណ្ដឹង

ពលរដ្ឋជាង៣០នាក់ នៅស្រុកកៀនស្វាយ ពាក់ព័ន្ធការឆបោកប្រាក់ជានាទៅធ្វើពលករនៅប្រទេសជប៉ុន ។ បច្ចុប្បន្ន ជនជាប់ចោទរូបនោះ កំពុងស្ថិតក្រោមការសាកសួររបស់លោកស្រី ស៊ុន ឃីត ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល ។ សូមជម្រាបថា កាលព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ពលរដ្ឋជាង៣០នាក់ មកពីស្រុកកៀនស្វាយ បានមកដាក់ពាក្យបណ្តឹង ទៅលើស្ត្រី ឆបោក ឈ្មោះ អៀត សារឹម ដែលបានឆបោកប្រាក់ពួកគាត់ ថាជានាទៅធ្វើពលករនៅប្រទេសជប៉ុន ចូលសាលាដំបូងខេត្តកណ្តាល ដើម្បីសុំឲ្យតុលាការមេត្តាជួយដោះស្រាយតាមច្បាប់ ។

ពលរដ្ឋជាច្រើនបានប្រាប់ឲ្យដឹងថា ពួកគាត់ត្រូវបានស្ត្រីឈ្មោះ អៀត សារឹម បានឆបោកពួកគាត់ ដោយលួងលោមថា បើចង់ទៅធ្វើការនៅប្រទេសជប៉ុន បានប្រាប់ខែច្រើន ចាំខ្លួនជានាយកទៅ ឲ្យតែប្រគល់ប្រាក់ឲ្យខ្លួនម្នាក់ ១,០០០ដុល្លារ ទៅ២,០០០ដុល្លារ បានទៅហើយ ។ តែអ្វីដែលពួកគាត់ខំទុកចិត្តនោះ គឺបានត្រឹមតែត្រូវស្ត្រីឆបោក អៀត សារឹម យកលុយពីពួកគាត់យកទៅចាយអស់ ពោលគឺលុយក៏អស់ មនុស្សក៏អត់បានទៅ ។ ពលរដ្ឋបានប្រាប់បន្ថែមទៀតថា ពួកគាត់មកដាក់ពាក្យបណ្តឹង គឺសូមឲ្យតុលាការមេត្តាជួយដោះស្រាយតាមច្បាប់ ។ ដែលបច្ចុប្បន្ន ស្ត្រីឆបោកឈ្មោះ អៀត សារឹម កំពុងជាប់ឃុំឃាំងនៅពន្ធនាគារខេត្តកណ្តាល ។

សូមរំឭកថា កាលពីល្ងាចថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ នេះ ក្រោយគេចខ្លួនជាង២ខែ តាមដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ប្រធានសាលាដំបូងខេត្តកណ្តាល ។ ប្រភពព័ត៌មានបញ្ជាក់ថា ស្ត្រីឆបោក អៀត សារឹម ត្រូវបានកម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល សហការជាមួយនគរបាលខណ្ឌដង្កោ ចាប់ខ្លួននៅចំណុចក្នុងបុរីមួយកន្លែង ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ហើយត្រូវបានបញ្ជូនភ្លាមៗ មកស្នងការដ្ឋាននគរបាលខេត្តកណ្តាល ដើម្បីបន្តនីតិវិធី ៕

## ត្រៀម បើកឲ្យពលករគ្មានឯកសារ ចុះឈ្មោះម្តងទៀតនៅពេលឆាប់ៗខាងមុខនេះ

http://www.pheaktraprak.com January 3, 2018

លោករដ្ឋមន្ត្រីក្រសួងការងារថៃបញ្ជាក់ត្រៀមបើកអោយពលករគ្មានឯកសារ ចំនួន៩សែននាក់ទៀតចុះឈ្មោះសារថ្មីម្តងទៀត កាលពីថ្ងៃពុធទី០៣ ខែមករា ឆ្នាំ២០១៨នេះ លោកអាដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃ បានមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានកាលពីព្រឹកមិញនៅមុខរដ្ឋសភាជាតិថៃអោយដឹងថា នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីព្រឹកនេះ ក្រសួងការងារនឹងស្នើសុំទៅគណៈរដ្ឋមន្ត្រីថៃអោយពន្យាររយៈពេលស្នាក់នៅបន្តដល់ពលករបរទេសដែលមិនទាន់បានត្រួតសញ្ជាតិរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ខាងមុខទៀត។ ក្នុងនោះដែរលោករដ្ឋមន្ត្រីក្រសួងការងារបានបញ្ជាក់បន្ថែមផងដែរថា នឹងបើកអោយពលករដែលមិនបានចុះបញ្ជីឈ្មោះប្រមាណជាង៩សែននាក់ទៀតចូលមកចុះបញ្ជីឈ្មោះម្តងទៀតក្នុងពេលឆាប់ខាងមុខនេះ។ ដកស្រង់ព័ត៌មាន:.matichon.co.th/

## ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៨
## តុលាការផ្តន្ទាទោសស្ត្រីម្នាក់ ដាក់ពន្ធនាគារ ៧ឆ្នាំ ករណីធ្វើមេអណ្តើក នាំនារីខ្មែរទៅរៀបការ នៅចិន

https://www.dap-news.com/kh/ សុក្រ, 05 មករា ២០១៨ 12:45 ដោយ: គិរី ID:039

ភ្នំពេញ៖ ប្រធានក្រុមប្រឹក្សាមជំនុំ ជម្រះសាលាដំបូង រាជធានីភ្នំពេញ លោក ម៉ុង មុនីសោភា នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ ប្រកាសសាលក្រម ផ្តន្ទាទោសស្ត្រីម្នាក់ ដាក់ពន្ធនាគារ៧ឆ្នាំ ពីបទការនាំចេញមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ព្រមទាំងសងសំណងចិត្ត ដល់ជនរងគ្រោះចំនួន ៣០០០ដុល្លារ ។

ជនជាប់ចោទឈ្មោះ ផៃ ចន្ថា អាយុ ៣៤ឆ្នាំ ឆ្លើយក្នុងពេលសវនាការកន្លងទៅថា ខ្លួននិងនារីរងគ្រោះ រស់នៅក្នុងភូមិជាមួយគ្នា ដោយខ្លួនមានប្តីនៅប្រទេសចិន ។ នៅពេលខ្លួនមកលេង ស្រុកកំណើតជនរងគ្រោះ បានសុំឱ្យខ្លួននាំទៅការប្តីនៅប្រទេសចិនដែរ ។ ក្រោយមកខ្លួនបានជួយជនរងគ្រោះឱ្យទៅការប្តីនៅប្រទេសចិន បានសម្រេចដោយបានលុយ ១២០០ដុល្លារ ពីប្តីចិន។ លុយនោះខ្លួនរត់ការធ្វើឯកសារយកនាងទៅ អស់ ៧០០ដុល្លារ និងឱ្យថ្លៃទឹកដោះទៅម្តាយនាង ២០០ដុល្លារ ។

ចំណែកជនរងគ្រោះបានបញ្ជាក់ថា ក្រោយពេលដែលខ្លួនរៀបការជាមួយប្តីចិនរួច នៅក្នុងរយៈពេល៣ ខែដំបូងមិនមាន រឿងអ្វីកើតឡើងទេ ។ ប៉ុន្តែក្រោយមកប្តីចិនចេះតែរករឿង និងបង្ខំរួមភេទ ទាំងពេលមានរដូវ ។ នាងបន្តថា ប្តីចិននោះនិយាយប្រាប់ថា គេបានចំណាយប្រាក់អស់ ២២០០០ដុល្លារ ដើម្បីយកខ្លួនទៅដល់ប្រទេសចិន និងបានឱ្យលុយទៅឈ្មោះ ផៃ ចន្ថា ចំនួន ៧០០០ដុល្លារ ដើម្បីយកឱ្យម្តាយជាថ្លៃទឹកដោះ តែតាមការពិត ម្តាយខ្លួនមិនបានទទួលនោះទេ ។ ក្រោយពីទ្រាំនឹងការធ្វើ បាបរបស់ប្តីចិននោះមិនបានទើប ជនរងគ្រោះ ឱ្យម្តាយនៅស្រុកខ្មែរផ្ញើលុយ ៣៥០០ដុល្លារ ដើម្បីធ្វើដំណើរមកស្រុកខ្មែរ ដោយមានស្ត្រីខ្មែរម្នាក់នៅប្រទេសចិន ជាអ្នកជួយឱ្យបានត្រលប់មកវិញ ក្រោយមកដល់ប្រទេសកម្ពុជា ជនរងគ្រោះបាន ប្តឹងទៅសមត្ថកិច្ចឱ្យ តាមចាប់ជនជាប់ចោទ ៕

## ទើបបែកធ្លាយរឿងថៅកែវ័យក្មេងក្នុងស្រុកត្រពាំងប្រាសាទ គៀងគរពលករឆ្លងដែនទៅថៃកាប់ឈើក្រញូងជិតមួយទសវត្ស

http://ann.com.kh/site/news/ ANN ថ្ងៃសុក្រ, 5 ខែមករា 2018 9:27 ព្រឹក

ខេត្តឧត្តមានជ័យ៖ សកម្មភាពពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃកាប់ឈើក្រញូងនៅតែបន្តឥតឈប់ឈរដោយគ្មានសមត្ថកិច្ចឬអាជ្ញាធរមំណាទប់ស្កាត់ និងបង្ក្រាបឡើយ។ នេះបើយោងតាមសេចក្តីរាយការណ៍ពីឃុំអូស្វាយ ស្រុកត្រពាំងប្រសាទ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨។

បើតាមសេចក្តីរាយការណ៍បានឲ្យដឹងថា បច្ចុប្បន្ននេះបទល្មើសឈើក្រញូងនៅតែមានភាពគគ្រើកគគ្រេដោយធ្វើការប្រមូលទិញ និងគៀងគរពលករឆ្លងដែនយ៉ាងអនាធិបតេយ្យពីសំណាក់ក្រុមឈ្មួញដុះស្លែក្រាក់ៗនៅតំបន់ផ្លូវយុទ្ធសាស្រ្តសម៌ភូមិមុខទិសទីពីស្រុកត្រពាំងប្រាសាទ។ ថៅកែដែលធ្វើសកម្មភាពខាងលើត្រូវបានគេស្គាល់ទី១ឈ្មោះ ហង្ស ជាប្រជាការពារភូមិ ទី២ឈ្មោះ ប្រុស អ្នកទាំងពីររស់នៅភូមិទំនប់អភិវឌ្ឍន៍ ឃុំអូរស្វាយ។ ពួកគេធ្វើការប្រមូលទិញឈើក្រញូង និងគៀងគរពលករឆ្លងដែនជាច្រើនឆ្នាំមកហើយមិនដែលត្រូវបានបង្ក្រាបពីសមត្ថកិច្ចម្តងណាឡើយ។ ស្រាប់តែពេលនេះបែកធ្លាយពីពលករថាឈ្មោះឈ្មួញឈើក្រញូងទាំងពីរនាក់ខាងលើជាថៅកែប្រមូលទិញ និងដាក់ទុនឲ្យពួកគាត់ឆ្លងដែនទៅប្រទេសថៃលួចកាប់ឈើក្រញូងយកមកលក់ឲ្យថៅកែខាងលើ។

ប្រភពពីសមត្ថកិច្ចតូចតាចបានលួចខ្សឹបប្រាប់ថា ថៅកែវ័យក្មេងទាំងពីររូបខាងលើរកស៊ីឈើក្រញូងជិត១០ឆ្នាំមកហើយតាំងពីបាតដៃទទេរហូតមកដល់បច្ចុប្បន្ននេះគេមានផ្ទះថ្ម និងរថយន្តទំនើបជិះក៏ដោយសារមុខជំនួញខាង

លើនោះផងដែរ បើនិយាយអំពីសមត្ថកិច្ចដែលឈរជើងនៅតំបន់នោះមិនអាចបន្ទោសពួកគាត់បានឡើយដោយឈ្មួញទាំងពីរូបនេះមានខ្សែធំណាស់ទើបពួកគាត់មិនហ៊ានបង្ក្រាប។

ពាក់ព័ន្ធករណីនេះភ្នាក់ងារយើងមិនអាចសុំការបំភ្លឺពីឈ្មោះ ប្រុស និងឈ្មោះ ហង្ស បានទេ។ ចំណែកលោក ស៊ុនប៊ូរ៉ាន់ មេបញ្ជាការយោធាសឹករងស្រុកត្រពាំងប្រាសាទ ក៏មិនអាចទំនាក់ទំនងបានដែរ។

ដោយឡែកលោក អ៊ុន រីម នាយប៉ុស្តិ៍នគបាលរដ្ឋបាលឃុំអូរស្វាយ បានឲ្យដឹងថា បញ្ហាខាងលើលោកកំពុងធ្វើការស្រាវជ្រាវរកការពិត៕ អត្ថបទដោយ៖ ឱម សារឿន

## ក្រសួងការងារថៃ និងចាត់វិធានការយ៉ាងដាច់ខាតចំពោះ អាជ្ញាធរថៃដែលជំរិតទារប្រាក់ពីពលករ

www.pheaktraprak.com ដំណឹងពលករខ្មែរ January 5, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃ ប្រកាសចាត់វិធានការចំពោះ យ៉ាងដាច់ខាតចំពោះអាជ្ញាធរថៃដែល ជាប់ពាក់ព័ន្ធនឹងករណីជួញដូរមនុស្សនិងជំរិតទារប្រាក់ពីពលករស្របច្បាប់។ លោអាដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃ បានប្រកាសចាត់វិធានការយ៉ាងដាច់ខាតចំពោះកម្លាំងអាជ្ញាធរថៃ, សមត្ថកិច្ចតម្រួត, ទាហានថៃ,ដែលជាប់ពាក់ព័ន្ធនឹងករណីអំពើជួញដូរមនុស្សឬជំរិតយកប្រាក់ពីពលករបរទេសគ្រប់កណីទាំងអស់។

កាលពីថ្ងៃព្រហស្បតិ៍ទី០៤ ខែមករា ឆ្នាំ២០១៨នេះ លោករដ្ឋមន្ត្រីក្រសួងការងារថៃបានកិច្ចប្រជុំត្រីភាគីពិភាក្សាលើបញ្ហាអំពើជួញដូរមនុស្សនិងបញ្ហាពលករចំណាកខុសច្បាប់នៅក្នុងប្រទេសថៃ។ ក្នុងកិច្ចប្រជុំនេះដែរលោករដ្ឋមន្ត្រីក្រសួងការងារថៃបានព្រមានចាត់វិធានការយ៉ាងដាច់ចំពោះមន្ត្រីខិលខូចដែលតែងប្រព្រឹត្តិអំពើល្មើសច្បាប់ជំរិតទារប្រាក់ពីពលករដែលមានឯកសារស្របច្បាប់ ហើយក្នុងនោះដែរលោករដ្ឋមន្ត្រីបានអំពាវនាវឲ្យថៅកែថៃឬពលករដែលរងគ្រោះដោយសារករណីសម្តកិច្ចថៃជំរិតទារប្រាក់និងអំពើជួញដូរមនុស្ស ឲ្យនាំភស្តុតាងយកទៅប្រគល់ជូនអាជ្ញាធរមានមានសម្តកិច្ច ឬភ្នាក់ងារដែលពាក់ព័ន្ធដើម្បីចាត់វិធានការតាមផ្លូវច្បាប់លើមន្ត្រីបំពាន់ច្បាប់អស់ទាំងនោះ។

## រដ្ឋមន្ត្រី(ក.ខ) ប្រជុំពិភាក្សាបញ្ហាជួញដូរមនុស្សខុសច្បាប់

www.pheaktraprak.com ដំណឹងពលករខ្មែរ January 4, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃ បើកកិច្ចប្រជុំដោះស្រាយបញ្ហាបទល្មើសការជួញដូរមនុស្ស ព្រមទាំងជួយអន្តរាគមន៍ដល់ជនរងគ្រោះដោយសារអំពើការជួញដូរមនុស្សខុសច្បាប់។ កាលពីថ្ងៃព្រហស្បតិ៍ទី០៤ ខែមករា ឆ្នាំ២០១៨ នេះ លោកឧត្តមសេនីយ៍ Adul Sangsingkeo រដ្ឋមន្ត្រីក្រសួងការងារថៃ បានបើកកិច្ចប្រជុំពិភាក្សាលើបញ្ហាជួញដូរមនុស្ស។ កិច្ចប្រជុំនេះបានព្រមព្រៀងកែសម្រួលផែនការសកម្មភាពជំរុញនិងកំណែទម្រង់ដោះស្រាយការជួញដូរមនុស្សនិងពលកម្មខុសច្បាប់។ ដោយផ្តោតលើការជំរុញសកម្មភាពសំខាន់ៗដូចជារៀបចំនិងគ្រប់គ្រងពលករបរទេស ការពន្លឿនការត្រួតពិនិត្យករណីជួញដូរមនុស្សនិងករណីពាក់ព័ន្ធ ធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យការងារដោយស្តង់ដារអន្តរជាតិ រួមទាំងការបង្កើតយន្តការដើម្បីការពារជនរងគ្រោះនៃការជួញដូរមនុស្សនិងពលកម្មខុសច្បាប់។ ព្រមក៏ផ្តល់នូវផែនការសកម្មភាពថ្មីផងដែរស្របជាមួយប្រទេសថៃនិងសហភាពអឺរ៉ុប (ក្នុងផែនការងារ) ។

# ក្រសួងមហាផ្ទៃ-ក្រសួងការងារ ប្រកាស ពីការចេញ ដកហូត បដិសេធ លិខិតធ្វើដំណើរ ពលករកម្ពុជា ធ្វើការនៅបរទេស

https://www.dap-news.com/kh/ ព្រហស្បតិ៍, 04 មករា ២០១៨ 17:03 ដោយ: ដើមអម្ពិល ID:013

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងមហាផ្ទៃ

លេខ: ៥០៨៥ ប្រក

ក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រកាសអន្តរក្រសួង
## ស្តីពី
## នីតិវិធី និងបែបបទ នៃការចេញ ការដកហូត ការបដិសេធ លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- យោងតាមសំណូមពរចាំបាច់នៃការងារ។

១

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងបែបបទ នៃការចេញ ការដកហូត ការបដិសេធ និងការធ្វើមោឃភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស សំដៅបង្កភាពងាយស្រួលដល់ពលករកម្ពុជាទទួលបានឯកសារ សម្រាប់ធ្វើដំណើរឆ្លងដែនពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសដែលពលករកម្ពុជាទទួលការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការជាផ្លូវការ។

**ប្រការ ២.-**

ពលករកម្ពុជាទៅធ្វើការផ្លូវការនៅបរទេស សំដៅដល់ពលករដែលមានកិច្ចសន្យាការងារ ដែលបញ្ជាក់ទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្របច្បាប់ជាធរមាន។

**ប្រការ ៣.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈប្រគល់ភារកិច្ចជូនអគ្គនាយកដ្ឋានការងារ ក្រសួងមហាផ្ទៃប្រគល់ភារកិច្ចជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីរៀបចំយន្តការការងារក្នុងទីតាំងរួមជាមួយគ្នានៅរាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួនតាមការចាំបាច់ក្នុងការចេញឯកសារបញ្ជាក់ទទួលស្គាល់ពលករកម្ពុជាធ្វើការងារនៅបរទេស ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងបំពេញបែបបទផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជា។

អគ្គនាយកដ្ឋានការងារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវចាត់តាំងមន្ត្រីជំនាញឱ្យទៅបំពេញភារកិច្ចនៅទីតាំងដែលនឹងត្រូវរៀបចំ។

**១. មន្ត្រីជំនាញអគ្គនាយកដ្ឋានការងារ មានភារកិច្ច៖**

- ពិនិត្យ និងសម្រេចក្នុងការចេញឯកសារបញ្ជាក់ទទួលស្គាល់ពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសជូនពលករកម្ពុជា
- ផ្តល់បង្កាន់ដៃជូនពលករសម្រាប់ការទទួលយកប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស
- រៀបចំសំណុំបែបបទស្នើសុំលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ជូនពលករកម្ពុជាបន្ទាប់ពីទទួលសំណុំឯកសារពីទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីបញ្ជូនទៅមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

**២. មន្ត្រីជំនាញអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មមានភារកិច្ច៖**

- ពិនិត្យ និងសម្រេចក្នុងការផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជាតាមសំណុំឯកសារស្នើសុំរបស់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានការងារ
- បំពេញសំណុំបែបបទស្នើសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- បញ្ជូនទិន្នន័យដែលបំពេញរួចទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដើម្បីបោះពុម្ពលិខិតធ្វើដំណើរ
- ផ្តល់បង្កាន់ដៃជូនពលករសម្រាប់ការទទួលយកលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស។

**ប្រការ៤.-**

ដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ពលករត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម (ក្នុងករណីប្រើប្រាស់សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ត្រូវភ្ជាប់ជាមួយនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ច្បាប់ដើម)
- កិច្ចសន្យាការងារ ដែលបញ្ជាក់ទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បំពេញសំណុំបែបបទសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដោយផ្ទាល់ ដូចជា បំពេញពាក្យស្នើសុំផ្តល់លិខិតធ្វើដំណើរ ផ្តិតខ្មៅម្រាមដៃ ចុះហត្ថលេខា ថតរូប វាស់កម្ពស់ យកភិនភាគស្លាកស្នាម និងសម្គាស។

**ប្រការ ៥.-**

ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ត្រូវផ្តល់ជូនពលករកម្ពុជាដែលបានបំពេញបែបបទស្នើសុំរួច រយៈពេលមិនអោយលើស០៣ថ្ងៃ នៃថ្ងៃធ្វើការ។

ការបង់ថ្លៃសេវាសម្រាប់ទ្រទ្រង់ការងារចេញប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងការចេញលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជា ជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសឯកជន ។

កន្លែងបើកផ្តល់ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស មានទីតាំងនៅរាជធានីភ្នំពេញ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើការដកហូតរក្សាទុកលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដែលបានផ្តល់ជូនពលករកម្ពុជា ក្នុងករណីដូចខាងក្រោម៖

- មានសំណើពីស្ថាប័នមានសមត្ថកិច្ចជំនាញពាក់ព័ន្ធ
- មានសេចក្តីសម្រេចពីស្ថាប័នតុលាការ
- អ្នកកាន់កាប់ប្រើប្រាស់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ជាពិរុទ្ធជន ទណ្ឌិត ឬជនមានដីកាកំពុងស្វែងរកចាប់ខ្លួន ឬកំពុងហាមឃាត់មិនឱ្យចេញក្រៅប្រទេស
- អ្នកកាន់កាប់ ប្រើប្រាស់មិនមែនជាពលរដ្ឋដែលមានសញ្ជាតិខ្មែរ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើការបដិសេធ ឬមោឃភាពចំពោះលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងករណីដូចខាងក្រោម៖

- មានសំណើពីស្ថាប័នមានសមត្ថកិច្ច
- លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសក្លែងក្លាយ

- លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដែលបានបាត់។

**ប្រការ ៧.-**

ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និង ទទួលទោសតាមច្បាប់ជាធរមានចំពោះជនណាដែល៖

- ផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- ក្លែង កោស លុប ឬសរសេរត្រួតលើលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- មានចេតនាជួយសម្រួលសំណុំបែបបទ ឬសម្រេចផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដល់ជនណាដែលមិនមែនជាពលករកម្ពុជាត្រូវទៅធ្វើការជាផ្លូវការនៅបរទេស។

**ប្រការ ៨.-**

ប្រកាសលេខ ៣៦៩៦ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ

# ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨

## តុលាការតម្កល់សាលក្រមរឿងជួលឲ្យពពោះ

http://www.postkhmer.com/ ប្រភពភ្នំពេញប៉ុស្តិ៍ Mon, 8 January 2018 គីម សារុំ

ស្ត្រីជនជាតិអូស្ត្រាលីឈ្មោះ TAMMY ALAYNE CHALES អាយុ ៤៩ ឆ្នាំដែលជាប់ចោទពាក់ព័ន្ធជួលស្ត្រីខ្មែរឲ្យពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស នៅថ្ងៃទី ៨ មករានេះ តុលាការបានប្រកាសសាលដីកាបដិសេធបន្ធូរបន្ថយទោសដល់ស្ត្រីជាប់ចោទអូស្ត្រាលីម្នាក់បន្ទាប់ពីជំនុំជម្រះកាលពីថ្ងៃទី ២៧ ខែធ្នូកន្លងមក។

នៅចំពោះមុខស្ត្រីជាប់ចោទ លោកស្រីចៅក្រម គីម ដានី បានថ្លែងថា សំណុំរឿងស្ត្រីជាប់ចោទឈ្មោះ TAMMYALAYNE CHALES ក្រោយពីបានជំនុំជម្រះមកក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាសំណុំរឿងនេះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មិនអាចបន្ថយទោសដល់ស្ត្រីជាប់ចោទបានទេ ព្រោះទណ្ឌកម្មទោសដែលសាលាដំបូងរាជធានីភ្នំពេញដាក់ ១ ឆ្នាំ ៦ ខែនេះ មានលក្ខណៈសមរម្យហើយ ដូច្នេះក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

ស្ត្រីជាប់ចោទបានទទូចសុំក្នុងបន្ទប់សវនាការនៅសាលាឧទ្ធរណ៍ឲ្យចៅក្រមបន្ថយទោសដល់រូបគេខណៈត្រូវតុលាការថ្នាក់ក្រោមផ្ដន្ទាទោស១ឆ្នាំ៦ខែ។

តាមអង្គហេតុស្ត្រីជាប់ចោទ TAMMY ALAYNE CHALES បានទាក់ទងជនជាតិខ្មែរ ២ នាក់ ម្នាក់ឈ្មោះ ពេជ្រ រិទ្ធី ភេទប្រុសអាយុ ២៨ ឆ្នាំមុខរបរមិនពិតប្រាកដ ស្នាក់នៅសង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក និង សំរិទ្ធ ចាន់ចរិយ៉ា ភេទ ស្រី អាយុ ៣០ ឆ្នាំ មុខរបរធ្មបស្នាក់នៅសង្កាត់វាលវង់ ខណ្ឌ ៧ មករា ដើម្បីពពោះនិង បញ្ជូនក្មេងដែលកើតនោះទៅបរទេសព្រោះអតិថិជនជាជនបរទេស ៕

## កម្ពុជាដាក់ឲ្យប្រើប្រាស់ទីស្នាក់ការ ផ្ដល់លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជា ធ្វើការនៅបរទេសពាកន្លែង ដើម្បីពន្លឿនការផ្ដល់សេវាជូនពលករ

http://www.freshnewsasia.com/ 2018-01-08

**(ភ្នំពេញ)៖** ក្រសួងមហាផ្ទៃ រួមជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឯកភាពគ្នាបង្កើតឲ្យមានទីស្នាក់ការផ្តល់ លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេស ចំនួនពាកន្លែងផ្សេងគ្នា ហើយបានប្រកាសដាក់ឲ្យប្រើប្រាស់ ជាផ្លូវការ នាថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ដើម្បីសម្រួល និងពន្លឿនការផ្តល់សេវាជូនពលករកម្ពុជា ដែលទៅធ្វើការនៅ ប្រទេសថៃ។

គួរបញ្ជាក់ថា លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេសនេះ មានសារសំខាន់ណាស់ ព្រោះវាអាចឲ្យពលករ កម្ពុជាធ្វើការ ដោយស្របច្បាប់ នៅប្រទេសថៃ ហើយគ្រាន់តែកាន់បណ្ណនេះ ពួកគេអាចធ្វើដំណើរបានគ្រប់រាជធានី-ខេត្ត ក្នុងប្រទេសថៃផងដែរ។ ចំណែកឯទីស្នាក់ការផ្តល់លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេស ទាំងពាកន្លែងនោះ គឺមាននៅរាជធានីភ្នំពេញ ក្នុងផ្សារស្ទឹងមានជ័យថ្មី (ជាន់ទី២) នៅខេត្តបាត់ដំបង និងនៅខេត្តបន្ទាយមានជ័យ។ ពិធីបើកដំណើរជាផ្លូវការនេះ ធ្វើឡើងក្រោមអធិបតីភាពនាយឧត្តមសេនីយ៍សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ លោក សេង សក្កា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ នៅផ្សារស្ទឹងមានជ័យថ្មី។

លោក សេង សក្កា បានឲ្យដឹងថា គោលបំណងនៃការបង្កើតទីស្នាក់ការផ្តល់លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេសនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ពលករ ដែលចង់ទៅបំពេញបែបបទឯកសារទៅធ្វើការនៅប្រទេសថៃ ហើយជាកន្លែងមួយច្បាស់លាស់ ក្នុងការបំពេញបែបបទនីតិវិធី សម្រាប់ឲ្យបានឯកសារស្របច្បាប់ទៅ

ធ្វើការនៅបរទេស។ លោកអគ្គនាយកបានបន្តថា បើគិតទាំង៣កន្លែងនេះ មន្ត្រីអាចធ្វើលិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេសជូនពលករ បានប្រមាណ៣ពាន់នាក់ ក្នុងមួយខែ ហើយបណ្ណទាំងនេះមានសុពលភាព ៥ ឆ្នាំ និងគ្មានការពន្យារពេលនោះទេ។

នាយឧត្តមសេនីយ៍សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា បានបញ្ជាក់ថា ការងារនេះក៏ជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការទប់ស្កាត់បញ្ហាពលករចាញ់ បោកមេខ្យល់ ចំណាកស្រុកខុសច្បាប់ ការចំណាយថវិកាច្រើន ខ្ជះខ្ជាយពេលវេលា និងទប់ស្កាត់ការចេញទៅធ្វើការនៅក្រៅប្រទេស គ្មានឯកសារស្របច្បាប់ ពោលនឹងជួយដោះស្រាយបញ្ហាជូនប្រជាពលករបានច្រើន។ នាយឧត្តមសេនីយ៍បានបញ្ជាក់ថា ដើម្បីធ្វើលិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេសនេះបាន ប្រជាពលរដ្ឋកម្ពុជា ត្រូវបំពេញតាម លក្ខខណ្ឌគតិយុត្តមួយចំនួន ដូចជា ត្រូវមានកិច្ចសន្យាការងារពីនិយោជកថៃ តាមរយៈទីភ្នាក់ងារដែលបញ្ជូនពួកគេទៅធ្វើការងារនៅទីនោះត្រូវមាន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (បើមានអត្តសញ្ញាណបណ្ណគំរូថ្មីរឹតតែល្អ) បើគ្មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទេ ត្រូវមានសេចក្តីចំលងសំបុត្របញ្ជាក់កំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ភ្ជាប់ជាមួយសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលច្បាស់លាស់ត្រឹមត្រូវ។

ត្រង់ចំណុចនេះ លោកបញ្ជាក់ទៀតថា បើពលករមិនទាន់មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៅឡើយទេ ពួកគាត់អាចទំនាក់ទំនងជាមួយមន្ត្រីជំនាញនៅក្នុង ទីស្នាក់ការផ្តល់លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេសនេះ ដើម្បីឲ្យមន្ត្រីទាំងនោះ ទំនាក់ទំនងនាំទៅធ្វើអត្តសញ្ញាណបណ្ណ ជូនថែមទៀតផង។

តំណាងក្រសួងទាំងពីរ ក៏បានសំណូមពរដល់ទីភ្នាក់ងារជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសផងដែរ កុំឲ្យកំណត់ថ្លៃសេវាខ្ពស់ហួសពេក ព្រោះរាជរដ្ឋាភិបាលបានរិះរក និងធ្វើគ្រប់វិធីដើម្បីសម្រួល និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ កម្មករ ពលករជាដើម ប៉ុន្តែបើផ្នែកឯកជនមិនជួយសហការក្នុងការសម្រួលជូនប្រជាពលរដ្ឋ ក៏ដូចជាពលករទេនោះ ការខិតខំគ្រប់បែបយ៉ាងនឹង មិនអាចទទួលបានការស្វាគមន៍ និងគាំទ្រពីប្រជាពលរដ្ឋនោះឡើយ។ គណៈអធិបតីទាំងពីរ ក៏បានណែនាំផ្តាំផ្ញើដល់មន្ត្រីក្រោមឱវាទរបស់ខ្លួនផងដែរ ត្រូវខិតខំបម្រើសេវាជូនប្រជាពលរដ្ឋឲ្យបានជិតដល់ កុំមានការព្រងើយកន្តើយ កុំប្រើពាក្យសម្តីគំរោះគំរើយដាក់ប្រជាពលរដ្ឋឲ្យសោះ ហើយរួបរួមសាមគ្គីគ្នា សហការគ្នាឲ្យបានជិតស្និទ្ធ ដើម្បីសម្រេចការងារទាំងឡាយឲ្យមានប្រសិទ្ធភាព និងតម្លាភាព៕

## អង្គការ AIM ប្តេជ្ញាបន្ត ជួយស្ត្រី និងកុមារដែលរងគ្រោះដោយសារអំពើជួញដូរនៅកម្ពុជា

http://wmc.org.kh/ ប្រភព wmc ថ្ងៃសុក្រ ទី៥ ខែមករា ឆ្នាំ២០១៨ដុំ ដោគជាតា

បទសម្ភាសៈ អង្គការមេត្រីអន្តរជាតិ AIM ដែលធ្វើការទប់ស្កាត់ និងជួយសង្គ្រោះស្ត្រី និងកុមារពីអំពើជួញដូរ បានលើកឡើងថា មួយឆ្នាំមកនេះអង្គការបាន ធ្វើសកម្មភាពជាច្រើនជួយ ទប់ស្កាត់ ការជួយដូរស្ត្រីនិងកុមារ ដោយរកឃើញ ៤១៦ករណី។ សម្រាប់ឆ្នាំ២០១៨នេះអង្គការមេត្រីអន្តរជាតិ បានដាក់ផែនការបន្តសកម្មភាពការងារជួយទៅដល់ស្ត្រីដែលរងគ្រោះដោយសារអំពើជួញដូរ ហើយនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជាស្វែងរកកុមារ និងស្ត្រីដែលប្រឈមនឹងអំពើជួញដូរនេះ។

តើ នៅឆ្នាំ ២០១៨នេះ អង្គការមេត្រីអន្តរជាតិ (AIM) នឹងបន្តការងាររបស់ខ្លួនយ៉ាងដូចម្តេចខ្លះដើម្បីចូលរួមចំណែកទប់ស្កាត់អំពើជួញដូរលើស្ត្រី និងកុមារ?

## អង្គការAIMៈអំពើជួញដូរស្ត្រីឆ្នាំ ២០១៧ ទប់ស្កាត់បានល្អដោយសារកិច្ចសហការពីសមត្ថកិច្ច

http://wmc.org.kh/ ថ្ងៃសុក្រ ទី៥ ខែមករា ឆ្នាំ២០១៨ ជុំ ជោគជាតា

ភ្នំពេញៈ លោកស្រី ខេង ស៊ីសាវ៉ាត់ នាយករងនៃអង្គការមេត្រីអន្តរជាតិAIM បានឱ្យដឹងថា អង្គការមេត្រីអន្តរជាតិ បានជួយ សង្គ្រោះស្ត្រីដែលងាយរងគ្រោះ និងរងគ្រោះដោយសារអំពើជួញដូរនៅឆ្នាំ ២០១៧ មានប្រសើរជាងឆ្នាំ ២០១៦ ដោយសារមានកិច្ចសហប្រតិបត្តិការល្អជាមួយននឹងសមត្ថកិច្ច។ ក្នុងបទសម្ភាសជាមួយវិទ្យុស្ត្រីកាលពីថ្ងៃទី ៤មករា លោកស្រី ខេង ស៊ីសាវ៉ាត់ បាននិយាយថា ដោយសារកិច្ចសហការល្អបាននាំឱ្យមានការទប់ស្កាត់ករណីជួញដូរស្ត្រីបានច្រើនជាងបណ្តាឆ្នាំមុនៗ។

លោកស្រី ខេង ស៊ីសាវ៉ាត់ ៖« *សម្រាប់អង្គការមេត្រីអន្តរជាតិ យើងទទួលបាន ៤១៦ករណី បើប្រៀបធៀបឆ្នាំ ២០១៦ ដែលចំនួនតួលេខនេះ គឺកើនឡើង គឺដោយសារតែយើងមានសហប្រតិបត្តិការល្អជាមួយអាជ្ញាធរ ហើយយើងចុះជួយធ្វើការងារនេះបានច្រើនជាងមុន*»។

នាយិការងប្រចាំប្រទេសនៃអង្គការមេត្រីអន្តរជាតិ AIM បញ្ជាក់ថា នៅឆ្នាំ ២០១៦ មាន ៣២៨ ករណី។ តាមតួលេខនេះ ស្ត្រីដែលងាយរងគ្រោះ និងរងគ្រោះនៅក្នុងអំពើជួញដូរនៅតែបន្តកើតមាន ។ នៅក្នុងសេចក្តីព្រាងរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការទប់ស្កាត់និងបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទរយៈពេល ១០ គឺឆ្នាំ ២០១៧ ក្រសួងមហាផ្ទៃបានបង្ហាញថា ស្ថានភាពនៃការជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ មានការបង្ក្រាបបានច្រើនគួរឲ្យកត់សម្គាល់ ។

តែយ៉ាងណានៅក្នុងរបាយការណ៍នេះក៏បានបង្ហាញថា ស្ត្រីនៅតែប្រឈមនឹងការជួញដូរ និងរងអំពើអាជីវកម្មផ្លូវភេទ។តែបែបនេះក្តីអ្នកធ្វើការផ្នែកស្ត្រីយល់ឃើញថា ការប្រឈមមុខរបស់ស្ត្រីនៅក្នុងបញ្ហានេះ បណ្តាលមកពីកង្វះការយកចិត្តទុកដាក់ពីរដ្ឋាភិបាល៕

## ពលករខ្មែរ៣នាក់ ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន ករណីលួចចូលកាប់ឈើក្រញូង

http://ann.com.kh/site/news/ ប្រភព ann ថ្ងៃចន្ទ, 8 ខែមករា 2018 8:47 ព្រឹក

ខេត្តបាត់ដំបងៈ ពលករខ្មែរចំនួន៣នាក់ទៀត ក្នុងចំណោមបក្ខពួកសរុបជាង២០នាក់ ដែលលួចចូលកាប់ឈើ ក្នុងតំបន់ឧទ្យានជាតិ ប្រទេសថៃ ត្រូវបានសមត្ថកិច្ចថៃ សហការជាមួយកំលាំងជំនាញរដ្ឋបាលព្រៃឈើ ធ្វើការឃាត់ខ្លួន ជាមួយនឹងឈើក្រញូងចំនួន ១៧២ដុំ។ ករណីនេះ កើតឡើងកាលពីរសៀល ថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨ កន្លងទៅ ត្រង់ចំណុចចុងភូមិតាលីងឆាន់ ឃុំចាំខេហិន ស្រុកខនបុរី ខេត្តនគររាជសីមា ប្រទេសថៃ។

សមត្ថកិច្ចថៃ បានឲ្យដឹងថា ក្រោយពីឃាត់ខ្លួនពលករខ្មែរទាំង៣នាក់រួច មកកម្លាំងជំនាញនៃប្រទេសថៃ បានធ្វើការដកហូតឈើគ្រញូងសរុបចំនួន ១៧២ដុំ ដែលចងជាបាច់ដាក់ចូលក្នុងសាកាដូ ជាមួយនឹងរណាយន្តចំនួន៣គ្រឿងទៀតផងដែរ។

ពលករខ្មែរម្នាក់ បានសារភាពថា ពួកគេត្រូវបានមេខ្យល់នាំផ្លូវចូលទៅក្នុងព្រៃចំនួន២ក្រុម ដោយក្រុមរបស់ខ្លួនមានគ្នាសរុបចំនួន២០នាក់ ជាអ្នកលីសែង និងក្រុមមួយទៀត ជាក្រុមកាប់ឈើមានគ្នាប្រមាណជាង១០០នាក់ ហើយពេលនេះពួកគេមួយចំនួនបានរត់គេចខ្លួនចូលទៅក្នុងព្រៃអស់ហើយ។

បច្ចុប្បន្នជនសង្ស័យដែលជាពលករខ្មែរទាំង៣នាក់នោះ ត្រូវបានសមត្ថកិច្ចថៃ កំពុងឃាត់ខ្លួន។ ដោយឡែកឈើក្រញូងទាំងអស់ ត្រូវបានដឹកយកទៅរក្សាទុកនៅទីតាំងឧទ្យានជាតិ ថាប់ឡានទី៣ ក្នុងភូមិសាស្រ្ត ភូមិខ្លងណាំម៉ាន់ ឃុំគោកក្រាក់ឆាយ ស្រុកខនបុរី ខេត្តនគររាជសីមា ប្រទេសថៃ៕

## ឡើងជញ្ជាំងថ្ម ប្រុងចូលទៅធ្វើការនៅថៃ ត្រូវតម្រួតចាប់ខ្លួនបាន

http://www.prakpheaktra.com/ ប្រភពដំណឹងពលករស្រុកថៃ January 8, 2018

ពលរដ្ឋខ្មែររស់នៅខេត្តតាកែវនិងបាត់ដំបង ចំនួន 5នាក់ ត្រូវកម្លាំងអាជ្ញាធរថៃ ឃាត់ខ្លួនខណៈពេលកំពុងឡើងតាមជញ្ជាំងរបងថ្មជាប់ព្រំដែន ដើម្បីចូលទៅស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ។ កាលពីម៉ោង09ព្រឹក ថ្ងៃអាទិត្យទី07 ខែមករា ឆ្នាំ2018 កម្លាំងអាជ្ញាធរតម្រួតអន្តោប្រវេសន៍ថៃ ប្រចាំស្រុកអារញ្ញយាប្រថេត ខេត្តស្រះកែវ ប្រទេសថៃ បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន05 នាក់ ខណៈពេលកំពុងនាំគ្នាឆ្លងដែនខុសច្បាប់ ដោយប្រើវិធីឡើងតាមជញ្ជាំងរបងថ្ម តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃក្បែរផ្សារលុងក្លឿស្រុកអារញ្ញ ដើម្បីចូលទៅធ្វើការខុសច្បាប់ក្នុងប្រទេសថៃ។

ក្នុងព្រឹត្តិការណ៍ខាងលើនេះកម្លាំងអាជ្ញាធរថៃ បានធ្វើការឃាត់ខ្លួនបានពលរដ្ឋខ្មែរគ្មានឯកសារស្នាក់នៅក្នុងប្រទេសថៃចំនួន 05នាក់ ក្នុងនោះមានបុរស03នាក់ និងនារី 02នាក់ យោងតាមរបាយការណ៍សមត្ថកិច្ចថៃបានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង05នាក់ រស់នៅក្នុងខេត្តតាកែវ និងខេត្តបាត់ដំបង ប្រទេសកម្ពុជា។ តាមចម្លើយសារភាពរបស់ពលរដ្ឋខ្មែរទាំងប្រាំនាក់បានប្រាប់ថា ពួកគេទាំងអស់គ្នាបានធ្វើដំណើរមកក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រួចហើយមានខ្យល់នាំចូលផ្លូវឆ្លងដែនចូលទៅខាងផ្សារថៃ ដោយបង់ថ្លៃនាំផ្លូវក្នុងម្នាក់500បាត ដើម្បីឡើងជញ្ជាំងរបងព្រំដែន ដើម្បីចូលទៅធ្វើការនៅក្នុងឆាក់ឈើងសៅ និងទីក្រុងបាងកកប្រទេសថៃ។ ក្រោយពេលឃាត់ខ្លួនពលរដ្ឋខ្មែរទាំង05នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនខ្លួនទៅកាន់អធិការដ្ឋានប៉ូលិសអន្តោប្រវេសន៍ស្រុកអារញ្ញ ដើម្បីធ្វើប្រវត្តិរូបចូលក្នុងបញ្ជីខ្មៅ(បុគ្គលហាមឃាត់) រួចបញ្ជូនខ្លួនអោយវិលត្រឡប់ទៅស្រុកកំណើតវិញតាមរយៈច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

## ស្ត្រីខ្មែរ ២នាក់រួមនឹងបុរស ៣នាក់ត្រូវបានចាប់ខ្លួនខណៈលូនក្នុងលូសបន្លាឆ្លងព្រំដែនថៃ

http://wmc.org.kh/khmer-labor-ok/ ថ្ងៃចន្ទ ទី៨ ខែមករា ឆ្នាំ២០១៨ ដុំ ជោគជាតា

ប៉ូលិសអន្តោប្រវេសន៍ថៃបានចាប់ខ្លួន ស្ត្រីខ្មែរ ២នាក់ និងបុរស ៣នាក់ ខណៈពួកគេកំពុងលូតតាមលូសបន្លា ដើម្បីឆ្លងដែនចូលទឹកដីថៃរកការងារធ្វើ។ពលរដ្ឋខ្មែរក្រីក្រនេះ ត្រូវបានចាប់ខ្លួនកាលពីព្រឹកថ្ងៃអាទិត្យទី ៧មករា នៅតាមព្រំដែននៅស្រុកអារ៉ាយ៉ាប្រាថេតនៅខេត្តសាកែវ ។

តាមកាសែតថៃ The Nation ដែលស្រង់សម្ដីប៉ូលិសថៃ ពលរដ្ឋខ្មែរដែលបានចាប់ខ្លួននោះ គឺពួកគេឆ្លងដែនទៅរកការងារធ្វើនៅទីក្រុងបាងកក។ ពួកគេបានប្រាប់ថា គេបានបង់ប្រាក់ទៅឱ្យ អ្នកនាំផ្លូវជាពលរដ្ឋខ្មែរម្នាក់នូវទឹកប្រាក់ ៥០០បាត។ តាមប្រភពដដែលបញ្ជាក់ថា អ្នកនាំផ្លូវខាងលើបានរត់គេចខ្លួនបាត់ហើយបន្ទាប់ពីប៉ូលិសចាប់បានអ្នកទាំងប្រាំរូបខាងលើ។ តាមសម្ដីសមត្ថកិច្ច ពលរដ្ឋខ្មែរដែលត្រូវប៉ូលិសថៃចាប់ខ្លួនបាននេះ អាចប្រឈមនឹងការឃុំឃាំង ឬនិរទេសខ្លួន។ តាមកាសែតថៃដែលបានចុះផ្សាយដដែលនេះ ស្ត្រីម្នាក់អាយុ ២៤ឆ្នាំគឺនាង ឡយ ដារា រួមនឹងស្វាមី អាយុ៣២ឆ្នាំ លោក សាយ គឹមថាក៏ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនដែរទាក់ទងនិងការចូលទឹកដីថៃដោយខុសច្បាប់ ។ ពួកគេទាំងពីររូបខាងលើចូលទឹកដីដើម្បីរកការងារធ្វើដូចពលរដ្ឋខ្មែរឯទៀតដែរ។

តាមសម្ដីសមត្ថកិច្ច នាង ឡយ ដារា ត្រូវបានសមត្ថកិច្ចថៃនាំខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យអារាញ់ប្រាថេត ហើយពួកគេទាំងពីរនឹងបញ្ជាឱ្យនាំខ្លួនត្រឡប់មកកម្ពុជាវិញក្នុងពេលឆាប់ៗ ។ ពលរដ្ឋខ្មែរទាំងស្រីទាំងប្រុស ជារឿយៗត្រូវតែម្រួតថៃចាប់ខ្លួន ហើយធ្វើទារុណកម្ម មុនកាត់ទោស និងនិរទេសពួកគេ។ មានពេលខ្លះពួកគេរងការបាញ់សម្លាប់ក្រោមបទចោទថា បានលួចចូលព្រំដែនទៅកាប់ឈើក្រញូងនិងការលួចចូលដោយខុសច្បាប់។ ពលរដ្ឋខ្មែរធ្វើការងារនៅប្រទេស ថៃ ជាងមួយលាននាក់ក្នុងនោះមាន ការងារកម្មករសំណង់ កម្មករនេសាទ និងកម្មករកាត់ ដេរ។

## កប៉ាល់ដឹកទំនិញបុកគ្នាជាមួយទូកនេសាទថៃ បណ្តាលអោយពលករខ្មែរធ្វើការនៅចំនួន4នាក់បានស្លាប់បាត់បង់ជីវិត

http://www.prakpheaktra.com/ January 6, 2018

កាលពីថ្ងៃសៅរ៍ ទី០៦ ខែមករា ឆ្នាំ២០១៨ នេះមានករណីទូកនេសាទត្រីរបស់ជនជាតិថៃមួយគ្រឿងត្រូវកប៉ាលដឹកទំនិញធុនធំមិនស្គាល់អត្តសញ្ញាណមួយគ្រឿងបានបុកចំពេញទំហឹង បណ្តាលឲ្យទូកនេសាទត្រីរបស់ជនជាតិថៃលិចភ្លាមៗនៅកន្លែងកើតហេតុ។ យោងតាមប្រភពព័ត៌មានពីកងអន្តរាគមជើងទឹកថៃ បានអោយដឹងថា ក្នុងករណីឧបទ្ទវហេតុកប៉ាល់ដឹកទំនិញបុកជាមួយទូកនេសាទត្រីនេះ បណ្តាលឱ្យមានពលករសញ្ជាតិខ្មែរចំនួន០៤បានស្លាប់ និងមនុស្សចំនួន០៣ផ្សេងទៀតទៀតបានរងរបួសធ្ងន់ ក្រោយពេលកើតហេតុជនរងគ្រោះត្រូវគេបញ្ជូនតាមអេលីកុបទ័រទៅសង្គ្រោះនៅមន្ទីរពេទ្យអាផាកៀតទីវង្ស្រុកសាត់ហ៊ីបខេត្តឈុនបុរី។

## សាកសពពលករខ្មែររងគ្រោះដោយសារកប៉ាល់ដឹកទំនិញបុកទូកនេសាទត្រីលិចត្រូវបានបញ្ជូនមកលើគោកហើយ

http://www.prakpheaktra.com/ ប្រភពដំណឹងពលករស្រុកថៃ January 6, 2018

នៅល្ងាចថ្ងៃសៅរ៍ ទី០៦ ខែមករា ឆ្នាំ២០១៨ សាកសពពលករខ្មែរចំនួន 4នាក់ ដែលបានស្លាប់ដោយសារគ្រោះថ្នាក់ឧបទ្ទវហេតុកប៉ាល់ដឹកទំនិញបុកទូកនេសាទថៃនៅតំបន់សមុទ្រស្រុកសាត់ហ៊ីប ខេត្តឈុនបុរី ត្រូវបានអាជ្ញាធរថៃបញ្ជូនមកដល់លើគោកហើយ បន្ទាប់ពីស្វែងរកអស់រយៈពេលជាច្រើនម៉ោង។

## ប័ត្រស៊ីជម្ពូថ្មី, និងចាប់ដំណើរការគ្រប់ខេត្តក្រុងទូទាំងប្រទេសថៃ.! ក្នុងពេលឆាប់ៗខាងមុខនេះហើយ.

http://www.prakpheaktra.com/ ប្រភពដំណឹងពលករស្រុកថៃ January 6, 2018

យោងតាមសារលិខិតបន្ទាន់មួយរបស់ក្រសួងការងារថៃ បានធ្វើកាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨នេះដើម្បីបញ្ជូនទៅកាន់មន្ទីរការងារថៃគ្រប់ខេត្តក្រុងទូទាំងប្រទេសថៃ ស្តីពីសេចក្តីព្រៀងច្បាប់មួយដែលកំពុងស្ថិតក្នុងការរង់ចាំការពិចារណាពីគណៈរដ្ឋមន្ត្រីថៃ ឬហៅថា (ក.ស.ធ.) ដើម្បីអនុម័តអោយមន្ទីរការងារនៅក្នុងខេត្តនីមួយៗដំណើរការបើកចុះអត្តសញ្ញាណពលករបរទេសដែលកំពុងធ្វើការស្នាក់នៅក្នុងប្រទេសថៃម្តងទៀត តាមសេចក្តីសម្រេចដែលបានចែងដូចក្នុងសារលិខិតខាងក្រោមដោយសារៈសំខាន់ចំនួន 4 (៤) ដូចខាងក្រោម៖

១.បងប្អូនពលករដែលកាន់ប័ណ្ណស៊ីជម្ពូនេសាទប្រែរូបសត្វទឹក ដែលអស់សុពលភាពថ្ងៃទី០១/១១/២០១៧។

២.បងប្អូនពលករដែលកាន់ប័ណ្ណស៊ីជម្ពូអស់សុពលភាពថ្ងៃទី៣១/០៣/២០១៨។

៣.បងប្អូនពលករដែលកាន់លិខិតបញ្ជាក់ទំនាក់ទំនងរវាងថៅកែនិងពលករ។

៤.បងប្អូនពលករដែលធ្វើការដោយខុសច្បាប់គ្មានឯកសារអ្វីសោះ។

*ទាំងបួនចំណុចសំខាន់នេះកំពុងស្ថិតក្នុងការពិចារណាគណៈរដ្ឋមន្ត្រីថៃ ដូចច្នេះបងប្អូនពលករបរទេសសូមមេត្តារក្សាភាពស្ងប់ស្ងាត់ ដើម្បីរង់ចាំសេចក្តីអនុម័តចេញមកជាផ្លូវការសិន ដូច្នេះហើយសូមបងប្អូនពលករបរទេសទាំងអស់រង់ចាំតាមដានដំណឹងនេះនៅពេលឆាប់ៗខាងមុខនេះទាំងអស់គ្នា។

## លិចទូកដឹកជនចំណាកស្រុកនៅជិតប្រទេសលីប៊ី បណ្ដាលឲ្យមនុស្ស៨នាក់ស្លាប់

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 08/01/2018

អ៊ីតាលី ៖ ឆ្មាំសមុទ្រប្រទេសអ៊ីតាលីបាននិយាយថា ជនចំណាកស្រុកយ៉ាងតិច៨នាក់បានស្លាប់ ហើយចំនួន ៨៦នាក់ទៀតត្រូវបានជួយសង្គ្រោះកាលពីចុងសប្ដាហ៍មកនេះក្រោយពីទូកកៅស៊ូដឹកជនចំណាកស្រុកមួយគ្រឿងបាន លិចនៅសមុទ្រមេឌីទែរ៉ាណេជិតឆ្នេរសមុទ្រប្រទេសលីប៊ី។

ក្រុមអ្នកជួយសង្គ្រោះកំពុងបន្តស្វែងរកមនុស្សមួយចំនួនទៀតដោយសារគេជឿថា ជនចំណាកស្រុករាប់សិប នាក់ទៀតអាចបាត់ខ្លួននៅឡើយ។ ចំណែកមន្ត្រីអាជ្ញាធរប្រទេសលីប៊ីបាននិយាយថា ជនចំណាកស្រុកយ៉ាងតិច២៥ នាក់បានស្លាប់នៅក្នុងគ្រោះថ្នាក់នេះប៉ុន្តែឆ្មាំសមុទ្រប្រទេសអ៊ីតាលីមិនទាន់បញ្ជាក់ច្បាស់ពីតួលេខនេះនៅឡើយទេ។ ឆ្មាំសមុទ្រប្រទេសអ៊ីតាលីបានប្រទះឃើញហេតុការណ៍នេះនៅពេលពួកគេកំពុងបើកនាវានិងឧទ្ធម្ភាគចក្រល្បាតដែន សមុទ្រអន្តរជាតិនៅជិតឆ្នេរសមុទ្រប្រទេសលីប៊ីដោយមានកិច្ចសហការជាមួយក្រុមអ្នកជួយសង្គ្រោះនៅតំបន់អឺរ៉ុប ផ្សេងទៀត៕

## ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៨

## ស្នងការរងខេត្តរតនគិរីថាករណីចាប់រំលោភក្មេងជារឿងយល់ច្រឡំ តែហេតុអ្វីបង់ប្រាក់ឲ្យ ក្មេងស្រី២នាក់រហូតដល់១២.០០០ដុល្លារ?

http://nokorwatnews.com/ ប្រភពពីគេហទំព័រនគរវត្ត ចុះថ្ងៃទី ០៨-០១-២០១៨

ខេត្តរតនគិរី៖ លោកស្រី កែវ ដាវី ស្នងការរងនគរបាលខេត្តរតនគិរីទទួលបន្ទុក ផ្នែកជួញដូរ និងការពារអនីតិ ជនបានថ្លែងថា ករណីដែលអាណាព្យាបាលកុមារជន ជាតិដើម២នាក់ចោទប្រកាន់ថា លោក មាស សោភ័ណ្ឌ ជាមន្ត្រី នគរបាលស្រុកអូរ យ៉ាដាវបានលួងលោមកូនស្រីទៅរំលោភនៅផ្ទះសំណាក់ឃីហៅម៉េងលីននោះជា រឿងមិនពិតនោះ ទេពោលវាជារឿងយល់ច្រឡំតែប៉ុណ្ណោះ ។ លោកស្រីបានបន្តថា ដោយសាររឿង នេះមិនមែនជាបទល្មើសជក់ស្ដែង លោកស្រីបានកោះហៅជនរងគ្រោះទាំង២នាក់ មកសាកសួរ និងកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលា ដំបូងខេត្តរតនគិរីហើយ និងរង់ចាំសេចក្ដីសម្រេចត្រឡប់មកវិញ ។

ទោះជាយ៉ាងណាលោកស្រីស្នងការ រងខេត្តបានទទួលស្គាល់ថា លោក មាស សោភ័ណ្ឌ ពិតជាបាននាំយក ក្មេងស្រីទាំង ២នាក់ទៅជាមួយមែន ព្រោះជាសាច់ញាតិនឹងគ្នាលោកស្រីអះអាងថា ពេលនាំទៅ នោះលោក មាស សោភ័ណ្ឌ យកក្មេងទាំង ២នាក់ទៅទិញអីវ៉ាន់តែប៉ុណ្ណោះ។ ដោយ មានការយល់ច្រឡំទើបម្ដាយឪពុកជនរងគ្រោះប្ដឹង សមត្ថកិច្ចតែម្ដងទៅ ។ លោកស្រីស្នងការបន្ថែមថា ករណីនេះ មន្ត្រីជំនាញរបស់លោកស្រីមិនបានយក កុមារីរងគ្រោះ ទាំង២នាក់ទៅពិនិត្យស្លាកស្នាមថាពិតជាមានការចាប់រំលោភ ឬមិនមាននោះទេដោយលោកស្រីគ្រាន់តែបញ្ជាក់ ថា បច្ចុប្បន្នកូនៗជនជាតិដើមភាគតិច អាយុជាង១០ឆ្នាំចេះអីៗគ្នាអស់ហើយ ។

យោងតាមប្រភពពីមន្ត្រីសមត្ថកិច្ចខេត្តរតនគិរីបានបង្ហើបប្រាប់ក្រុមអ្នកសារព័ត៌មានថា ករណីរំលោភនេះត្រូវ បានលោក មាស សោភ័ណ្ឌ សងសំណងជំងឺចិត្តទៅ ឲ្យឪពុកម្ដាយជនរងគ្រោះចំនួន១២.០០០ ដុល្លារដើម្បីសុំឱ្យដក ពាក្យបណ្ដឹងនិងបញ្ចប់រឿងហើយ ។

យោងតាមការបញ្ជាក់របស់ម្ដាយឪពុកជនរងគ្រោះបានឱ្យដឹងថា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧កន្លងទៅ កូនស្រីពួកគាត់ ទាំង២នាក់បានបាត់ពីផ្ទះទើបធ្វើឱ្យមានការចោឡោដើររកក្នុងភូមិតែរកមិនឃើញ។ លុះដល់ម៉ោង ប្រមាណ១០យប់ថ្ងៃដដែលទើបរកឃើញពួកគេទាំង២នៅភូមិប៉ក់តូច ដែលមានចម្ងាយ២គីឡូម៉ែត្រពីផ្ទះគាត់ ។ ពួក គាត់បានបន្តថា ក្រោយពីរកឃើញ កូនពួកគាត់បានសួរនាំពីដំណើររឿងស្រាប់តែធ្លាយចេញរឿងលោក មាស សោភ័

ណ្ណ មន្ត្រីនគរបាលស្រុកអូរយ៉ាដាវល្បួងលោម ថា នាំមកទិញខ្សែកនិងទូរស័ព្ទឲ្យនៅផ្សារបានលុង។ ក្រោយសួរដេញដោលខ្លាំងទើប ធ្លាយចេញរឿងលោក មាស សោភ័ណ្ឌ នាំកូនស្រីរបស់ពួកគាត់ទៅរំលោភនៅក្នុងផ្ទះសំណាក់ឃីហោម៉េងលីន។ បន្ទាប់មកពួក គាត់ក៏បានទៅប្តឹងមេភូមិ មេឃុំ និងមេប៉ុស្តិ៍ ប៉ក់ញ៉ែប៉ុន្តែគ្មានអ្នកណាអើពើនោះទេ ។

ទាក់ទងនឹងករណីនេះយើងនៅមិនទាន់អាចសុំការបញ្ជាក់ពីលោកព្រះរាជអាជ្ញារង ហាក់ ហ៊ាន់ អ្នកនាំពាក្យអយ្យការអម សាលាដំបូងខេត្តរតនគិរីបាននៅឡើយទេ ដោយទូរស័ព្ទលោកហៅចូលប៉ុន្តែគ្មានអ្នកទទួល ។

យោងតាមមាត្រា៤២នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើអាជីវ កម្មផ្លូវភេទបានចែងថា បទអំពើរួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំទៅ១០ឆ្នាំ ។

មហាជនរង់ចាំមើលថា តើសំណុំរឿងនៅប្រែពណ៌ទៅជាយ៉ាងណាទៀតនៅពេល ដែលនគរបាលយុត្តិធម៌មួយរូបដែលយល់ដឹងពីច្បាប់បែរជាធ្វើអំពើបំពានច្បាប់បែបនេះ? មជ្ឈដ្ឋាននានាបានចោទសួរថា បើមន្ត្រីនគរបាលនោះមិនពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើមិនគប្បីចំពោះក្មេងស្រីទាំង២នាក់នោះ ហេតុអ្វីចាំបាច់សងជំងឺចិត្តរហូតដល់ ១២.០០០ ដុល្លារសម្រាប់ពួកគេធ្វើអ្វី? ករណីនេះគួរតែលោកស្រីស្នងការរងនៃ ស្នងការដ្ឋាននគរបាលខេត្តរតនគិរីពិចារណា ឲ្យបានច្បាស់លាស់ ឬមួយថាវាជាប្រាក់ នៃការរាប់អានគ្នា? ប្រសិនបើគ្មានអំពើ មិនគប្បីណាមួយនោះគេជឿថា មន្ត្រីនគរ បាលម្នាក់នោះប្រាកដជាមិនចំណាយប្រាក់ រហូតដល់១២.០០០ដុល្លារទទេៗយ៉ាង ដូច្នេះឡើយ ។ ដូច្នេះលោកស្រីស្នងការរងគួរប្រើខួរ ក្បាលពិចារណាលើករណីមួយនេះឲ្យបាន ច្បាស់លាស់ មុននឹងនិយាយអំពីករណី ខាងលើនេះ ៕ ហេង សូរិយា

## តុលាការលើកពេលប្រកាសសាលក្រមរឿង ជនជាតិចិននាំពលរដ្ឋខ្មែរ ទៅលក់នៅចិន រាប់សិបនាក់

http://ann.com.kh/site/news/ ថ្ងៃអង្គារ, 9 ខែមករា 2018 10:52 ព្រឹក

រាជធានីភ្នំពេញ៖ មិនដូចជាអ្វីដែលបានគ្រោងទុកនោះទេ នៅព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨នេះ លោកស្រី ថ្លាង ផាណែត ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ មិនទាន់អាចបើកសវនាការប្រកាសសាលក្រម ផ្តន្ទាទោសបុរសជនជាតិចិនម្នាក់ និងបុរសខ្មែរម្នាក់ មានតួនាទីនាយកវិទ្យាស្ថាន IPAT ពាក់ព័ន្ធករណីនាំនិស្សិតខ្មែរទៅ លក់ឱ្យធ្វើជាកម្មកររោងចក្រនៅប្រទេសចិន នៅឡើយទេ ដោយលើកទៅថ្ងៃក្រោយ មិនទាន់កំណត់កាលបរិច្ឆេទ។ ការលើកពេលប្រកាសសាលក្រមនេះ ត្រូវបានលោកស្រី ថ្លាង ផាណែត ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ បញ្ជាក់ថា មកពីអវត្តមាននៃចៅក្រមប្រឹក្សា។

សូមបញ្ជាក់ថា លោក រៀល សុភិន ជាតំណាងអយ្យការ បានចោទប្រកាន់លើជនជាប់ចោទ ទី១.ឈ្មោះ អ៊ិន ស៊ីម៉ាណាន់ ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរជានាយកវិទ្យាស្ថាន បណ្តុះបណ្តាល គណនេយ្យ វិជ្ជាជីវៈ (IPAT) និងទី២.ឈ្មោះ Liu Wing Hing ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិចិន ពីបទនាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន ប្រព្រឹត្តអំឡុងចុងឆ្នាំ២០១៥ យោងតាមមាត្រា១១ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

នៅក្នុងសវនាការកាលពីរសៀល ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ កន្លងទៅ ជនជាប់ចោទឈ្មោះ អ៊ិន ស៊ីម៉ាណាន់ បានសារភាពថា ខ្លួនពិតជាបាន ផ្សព្វផ្សាយជ្រើសរើសនិស្សិត ឱ្យទៅរៀននៅសាកលវិទ្យាល័យ ច្នៃម៉ូតសម្លៀកបំពាក់ ផ្នែកច្នៃម៉ូតសម្លៀកបំពាក់ ក្នុងប្រទេសចិន ដោយតម្រូវឱ្យនិស្សិត បង់លុយពី២,៥០០ដុល្លារ ទៅ៤,៥០០ដុល្លារ។ ជនជាប់ចោទបន្តថា នៅពេលទៅដល់ប្រទេសចិន និស្សិតអាច មានការងារធ្វើក្រៅម៉ោង បានប្រាក់ខែចន្លោះពី ៥០០ ទៅ ៦០០ដុល្លារ ខ្លួនមិនបានបោកប្រាស់និស្សិតយកទៅលក់ឱ្យធ្វើជាកម្មករ នៅរោងចក្រក្នុងប្រទេសចិនឡើយ។ ចំណែកជនជាប់ចោទឈ្មោះ Liu Wing Hing បានបដិសេធថា ខ្លួនមិនបានដឹងរឿងអ្វីទេ គឺគ្រាន់តែជួយរត់ការឯកសារនាំនិស្សិត ទាំងអស់ទៅប្រទេសចិនតែប៉ុណ្ណោះ។

ជនរងគ្រោះដែលបានចូលរួមក្នុងសវនាការបាន អះអាងថា មាននិស្សិតចំនួន ២២នាក់ ដែលត្រូវចាញ់បោក ជនជាប់ចោទទាំងពីរនាក់ខាងលើ អស់ប្រាក់ពីចន្លោះ ២,៥០០ដុល្លារ ទៅ៤,៥០០ដុល្លារក្នុងម្នាក់ៗ។ជនជាប់ចោទបាន បញ្ជូនពួកគេ ទៅធ្វើជាកម្មកររោងចក្រកាត់ដេរ ដោយធ្វើការពី៨ ទៅ១០ម៉ោងក្នុង១ថ្ងៃ ដោយគ្មានពេលសម្រាក និងទទួលបានប្រាក់ខែតែ ១០០ ទៅ១២០ដុល្លារតែប៉ុណ្ណោះ មិនដូចជាអ្វីដែលជនជាប់ចោទបានសន្យានោះទេ។ ក្រោយពីពួកគេដឹងខ្លួនថា ត្រូវចាញ់បោកគេ ជនជាតិចិនបាន ដកហូតលិខិតឆ្លងដែនរបស់បពួកគេទុក និងបង្ខាំងពួកគេឱ្យធ្វើការ គ្មានពេលសម្រាក។ ក្រោយមកដោយទ្រាំមិនបាន បពួកគេក៏បាននាំគ្នារត់ទៅរកស្ថានទូតខ្មែរឱ្យជួយអន្តរាគមន៍ និងបញ្ជូនមកប្រទេសកម្ពុជាវិញ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺក្រោយពីសាកសួរដេញដោលចប់សព្វគ្រប់ លោក រៀល សុភិន ជាតំណាងអយ្យការ ដែលជាចោទប្រកាន់លើជនជាប់ចោទផ្ទាល់ បែរជាស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើជនជាប់ចោទជាជនជាតិឈ្មោះ Liu Wing Hing ទៅវិញ។

គួររំលឹកថា ជនជាប់ចោទ ទាំង២នាក់ខាងលើ ធ្លាប់ត្រូវបានតុលាការក្រុងភ្នំពេញ ប្រកាសសាលក្រមផ្តន្ទាទោស ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល៧ឆ្នាំ កាលពីអំឡុងចុងខែកញ្ញា ឆ្នាំ២០១៧កន្លងទៅ ប៉ុន្តែជនជាប់ចោទ ឈ្មោះ Liu Wing Hing ជាជនជាតិចិន បានប្តឹងទាស់នឹងសាលក្រម។

មហាជនកំពុងរង់ចាំមើលថា តើសំណុំរឿងនេះ អាចប្រែព័ណ៌តាមការស្នើសុំរបស់លោកតំណាងអយ្យការដែរឬទេ? ខណៈដែល ជនជាប់ចោទ បាននាំពលរដ្ឋខ្មែរទៅលក់នៅប្រទេសចិន រាប់សិបនាក់បែបនេះ៕ **៖ ឡុក សំរិត**

## កម្លាំងតម្រួត តាមចាប់កប៉ាល់ដែលបុកទូកនេសាទ បណ្តាលឲ្យពលករខ្មែរស្លាប់

http://kleykley.sabay.com.kh/ ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨ ម៉ោង 08:47

កម្លាំងតម្រួតចរាចរផ្លូវទឹក នឹងចុះទៅ ចំណុចបរិវេណកោះស៊ីឆៃ ដែលជាផែកប៉ាល់របស់ខេត្តធុនបុរី ដើម្បីពិនិត្យ និងរកមើលកប៉ាល់ដឹកទំនិញណាមួយ ដែលមានការពាក់ព័ន្ធនឹងករណីគ្រោះថ្នាក់ កប៉ាល់ដឹកទំនិញធុនធំមួយគ្រឿង បុកកាណូតនេសាទ ដែលបណ្តាលឲ្យពលករខ្មែរ ២នាក់ និងថៃ ២នាក់ស្លាប់កាលពីថ្ងៃទី៧មករា ឆ្នាំ២០១៨ ដើម្បីនាំយកមកដោះស្រាយតាមផ្លូវច្បាប់។

ហេតុការណ៍នេះ បានកើតឡើងនៅវេលាម៉ោង១រសៀល ថ្ងៃទី៦ ខែមករា ឆ្នាំ ២០១៨ ដែលមានចម្ងាយពីប្រាំង ក្នុងស្រុកសត្វហ៊ីប ខេត្តធុនបុរី ប្រមាណជាង ៦១ គីឡូម៉ែត្រ ។ លោកឧត្តមសេនីយ៍ បាន់ចុប ពោធិដែង មេបញ្ជាការកងទ័ពជើងទឹកតំបន់១ ដែលមាននាទី ទំនាក់ទំនងការងារ និងការរក្សាសុវត្ថិភាពលើផ្ទៃទឹក បានទទួលព័ត៌មានពីកម្លាំងតម្រួតចរាចរផ្លូវទឹកថា កាណូតនេសាទនោះមានមនុស្សចំនួន ៨ នាក់ ( ថៃ ៣នាក់ ខ្មែរ៥នាក់ ) រីឯកប៉ាល់ដឹកទំនិញនោះមិនស្គាល់អត្តសញ្ញាណច្បាស់លាស់ឡើយ។

បន្ទាប់ពីបានដាក់កម្លាំងឲ្យចុះទៅពិនិត្យទីតាំងកើតហេតុរួចមក គឺមនុស្ស ចំនួន៤នាក់ត្រូវបានសង្គ្រោះអោយរួចផុតពីសេចក្តីស្លាប់ ចេញពីផ្ទៃទឹក ដែលក្នុងនោះមានពលករខ្មែរចំនួន៣នាក់ និងថៃម្នាក់ ព្រមទាំងបានបញ្ជូនទៅ សង្គ្រោះនៅក្នុងមន្ទីរពេទ្យ សម្តេចព្រះនាង សិរិគិត ដែលជាមន្ទីរពេទ្យរបស់ កងទ័ពជើងទឹក ក្នុងខេត្តធុនបុរី។ ដោយឡែក កម្មករនេសាទចំនួន ៤ នាក់ទៀត បានបាត់ខ្លួននៅក្នុងទឹកសមុទ្រនោះ ដែលមានពលករខ្មែរចំនួន២នាក់ និងថៃ ចំនួន ២នាក់ (ខ្មែរសុរិន្ទម្នាក់)៕ អត្ថបទ៖ សោភា

## ឡានដឹកពលករខ្មែរទៅធ្វើការ ជួបគ្រោះថ្នាក់តាមផ្លូវ បណ្តាលឲ្យពលករ 13នាក់ រងរបួស

http://www.prakpheaktra.com/ January 9, 2018

រថយន្តដឹកពលករកម្ពុជាទៅធ្វើការនៅចំការម្ចាស់ ជួបឧបទ្ទវហេតុក្រឡាប់ផ្ងារជើងនៅក្បែរផ្លូវ បណ្តាលកម្មករខ្មែរជិះនៅខាងក្រោយចំនួន13នាក់រងរបួស។ កាលពីវេលាម៉ោង08:30នាទីព្រឹក ថ្ងៃច័ន្ទទី08 ខែមករា ឆ្នាំ2018 មានករណីគ្រោះថ្នាក់ដោយឧបទ្ទវហេតុក្រឡាប់រថយន្តpik up មួយគ្រឿងម៉ាក(អ៊ីស៊ុយស៊ុយ)ពណ៌សរ ពាក់ស្លាកលេខ

(បម2356)ក្រុងថេប នៅលើផ្លូវជាតិ(បាយផាត់36-វ៉ាក់យ៉ង)ស្ថិតក្នុងភូមិ1 សង្កាត់និគមផាតណា ស្រុកនិគមផាត់ណា ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ។

ក្នុងករណីគ្រោះថ្នាក់ខាងលើនេះ បានណ្តាលឲ្យមានមនុស្សជិះលើរថយន្តកើតហេតុសរុប ចំនួន15នាក់ ក្នុងនោះមានពលករខ្មែរចំនួន13នាក់ មានបុរស9នាក់ ស្ត្រី៤នាក់ និង2នាក់ទៀតជាជនជាតិថៃ ក្រោយពេលកើតហេតុជនរងគ្រោះទាំងអស់ត្រូវបានកម្លាំងភ្នាក់ងារសង្គ្រោះស្រុកនិគមផាត់ណា បញ្ជូនជនរងគ្រោះទាំងអស់ទៅព្យាបាលនៅមន្ទីរពេទ្យស្រុកនិគមផាត់ណា ។ ចំណែកឯកមូលហេតុដែលបង្កឲ្យកើតគ្រោះថ្នាក់លើកនេះបើកនេះខាងសមត្ថកិច្ចថៃកំពុងតែធ្វើការស៊ើបអង្កេត។

## ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៨

## ការអត់ឱនចំពោះការស៊ីឈ្នួលពពោះជំនួស បានផុតកំណត់ហើយ

http://www.postkhmer.com/ Wed, 10 January 2018 យន់ ស៊ីនាត, គង់ មេត្តា and Erin Handley

**ភ្នំពេញ:** ជាមួយនឹងកែវភ្នែកស្រទន់ និងស្នាមញញឹមពព្រាយអ្នកស្រី ម៉ាលីស កំពុងអង្គុយបត់ជើងយកដៃឱបពោះដែលមានទម្ងន់នៅក្នុងផ្ទះរបស់អ្នកស្រី ក្នុងភូមិក្រីក្រដាច់ស្រយាលមួយក្នុងប្រទេសកម្ពុជា។ អ្នកស្រីមានផ្ទៃពោះ ៦ ខែហើយដោយកូននៅក្នុងផ្ទៃរបស់អ្នកស្រីគឺជាកូនស្រី។ អ្នកស្រីមិនបានដឹងអំពីឪពុកម្តាយរបស់ក្មេងនោះទេដោយគ្រាន់តែដឹងថា ពួកគេគឺជាជនជាតិចិន។ គ្រាន់តែទ្រនិចនាឡិកាដើរដល់វេលារំលងអធ្រាត្រឈានចូលថ្ងៃទី ៩ ខែមករា ស្ត្រីរូបនេះដឹងខ្លួនថាមានបញ្ហាផ្លូវច្បាប់សម្រាប់ការចូលរួមនៅក្នុងករណីពពោះជំនួសនេះ។

តាមច្បាប់អន្តរជាតិករណី «ជួលពពោះជំនួស» ត្រូវបានដាក់ឱ្យស្ថិតនៅក្រៅច្បាប់នៅក្នុងខែតុលាឆ្នាំ ២០១៦ ហើយនៅថ្ងៃទី ៨ ខែមករាឆ្នាំ ២០១៨ នេះគឺជាថ្ងៃផុតកំណត់ ឱសានវាទរបស់ក្រសួងមហាផ្ទៃក្នុងការលើកលែងទោសករណីពពោះជំនួស។ ម្តាយដែលពពោះជំនួសដែលផ្តល់កំណើតកូននៅមុនថ្ងៃទី ៨ ខែមករា និងត្រូវប្រគល់កូននោះទៅឱ្យឪពុកម្តាយដែលជួលឲ្យពពោះនោះដើម្បីអាចគេចផុតពីការកាត់ទោស ខណៈឪពុកម្តាយត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យស្នើសុំទៅតុលាការកម្ពុជាដើម្បីទទួលបានទិដ្ឋាការនាំកូនចេញពីប្រទេសកម្ពុជា។ ឪពុក ម្តាយ ឈ្មួញកណ្តាល និងម្តាយដែលពពោះជំនួសដែលផ្តល់កំណើតកូន នៅក្រោយថ្ងៃកាលបរិច្ឆេទនោះអាចនឹងត្រូវប្រឈមមុខនឹងវិធានការផ្លូវច្បាប់។

ក្រសួងមហាផ្ទៃបានព្រមានបែបនេះនៅក្នុងគោលការណ៍ណែនាំ ដែលបានផ្សព្វផ្សាយជាផ្លូវការទៅកាន់ស្ថានទូតនានាកាលពីខែកក្កដាឆ្នាំមុន។ ប៉ុន្តែការអនុវត្តការហាមឃាត់នេះនៅតែបន្តហើយករណីអ្នកស្រី ម៉ាលីស អាយុ ៣៥ ឆ្នាំគឺជាភស្តុតាងមួយ។ អ្នកស្រី ម៉ាលីស មានកូនផ្ទាល់ខ្លួនពីរនាក់រួចហើយគឺប្រុសទាំង ២ ដែលមានអាយុ ៨ ឆ្នាំ និង ១៥ ឆ្នាំ។ អ្នកស្រីថ្លែងថា៖ «ខ្ញុំសម្រេចចិត្តធ្វើវាពីព្រោះខ្ញុំគ្មានលុយ។ គ្មាននរណាម្នាក់ដាក់សម្ពាធ ឬបង្ខំខ្ញុំទេ ខ្ញុំសម្រេចចិត្តដោយខ្លួនឯង»។ អ្នកស្រីជំពាក់បំណុលគេចំនួន ៤០០០ ដុល្លារ បន្ទាប់ពីអ្នកស្រីបានទិញផ្ទះ និងដី។ ការងារពីមុនរបស់អ្នកស្រីគឺជាកម្មការិនីរោងចក្រកាត់ដេរដែលទទួលបានប្រាក់ខែ ១៥៣ ដុល្លារក្នុងមួយខែ។ សម្រាប់ការយល់ព្រមពពោះកូនឲ្យគេនេះ អ្នកស្រីទទួលបានប្រាក់ចំនួន ៨០០០ ដុល្លារ។ ចិត្តមួយស្ត្រីរូបនេះចង់រក្សាកូននេះទុក ប៉ុន្តែអ្នកស្រីក៏មានការភ័យខ្លាចប៉ូលិសមកសាកសួរផងដែរ។

កាសែតភ្នំពេញប៉ុស្តិ៍សូមរក្សាឈ្មោះ និងទីកន្លែងពិតប្រាកដរបស់អ្នកស្រី ម៉ាលីស ជាសម្ងាត់ដោយសារតែនៅ ៣ ខែទៀតទើបអ្នកស្រី ម៉ាលីស សម្រាលកូនដូច្នេះអ្នកស្រីអាចប្រឈមនឹងផលវិបាកផ្លូវច្បាប់ធ្ងន់ធ្ងររួមទាំងការជាប់ពន្ធនាគារជាច្រើនឆ្នាំផងដែរ។

រដ្ឋាភិបាលមិនទាន់បានធ្វើសេចក្តីព្រាងច្បាប់ស្តីពីករណីស៊ីឈ្នួលពពោះជំនួសនៅឡើយទេ ដូច្នេះហើយឪពុកម្តាយឈ្មួញកណ្តាល និងម្តាយដែលស៊ីឈ្នួលពពោះជំនួសអាចត្រូវបានផ្តន្ទាទោសតាមច្បាប់ដែលបានបង្កើតឡើង

ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ នៅពេលទាក់ទងកាលពីម្សិលមិញអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សលោកស្រី ជូ ប៊ុនអេង បានថ្លែងថា ប្រកាសនឹងចេញក្នុងពេលឆាប់ៗនេះដែលរៀបរាប់លម្អិតអំពីការដាក់ទណ្ឌកម្មចំពោះអ្នកដែលពាក់ព័ន្ធនឹងករណីពពោះជំនួស ប៉ុន្តែលោកស្រីកំពុងរង់ចាំរបាយការណ៍ពីក្រសួងកិច្ចការនារី។ ទន្ទឹមនេះដែរលោកស្រីបានចង្អុលបង្ហាញថាការពពោះជំនួសនៅតែបំពានក្រមព្រហ្មទណ្ឌកម្ពុជាហើយនឹងត្រូវកាត់ទោសផងដែរ។ លោកស្រីបន្តថា៖ «គោលការណ៍ណែនាំនេះក៏ហាមប្រាមផងដែរមិនឲ្យមានករណីពពោះជំនួសថ្មី [ហើយជនល្មើស] នឹងប្រឈមមុខចំណាត់ការផ្លូវច្បាប់តាមក្រមព្រហ្មទណ្ឌ»។

លោកស្រីថ្លែងថាមានមនុស្ស ២ ក្រុមដែលនឹងរងប៉ះពាល់គឺអ្នកដែលដើររកស្ត្រីពពោះកូន និងម្តាយដែលពពោះជំនួសតែម្តង។ «ដោយសារស្ត្រីនោះផ្តល់កំណើតដល់កូននាងជាម្តាយ ហើយប្រសិនបើនាងបោះបង់ [កូនខ្លួន] នាងនឹងបំពានច្បាប់ស្តីពីការទទួលខុសត្រូវរបស់ម្តាយ ហើយប្រសិនបើស្ត្រីនោះពាក់ព័ន្ធនឹងការលក់កូនខ្លួនឯងទៅអ្នកដទៃគាត់នឹងត្រូវទទួលទោស»។ តាមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ «ជនដែលលក់ ទិញ ឬដោះដូរមនុស្សម្នាក់ទៀតនឹងត្រូវដាក់ពន្ធនាគារពី ២ ទៅ ៥ ឆ្នាំ»។ ការកាត់ទោសដាក់ពន្ធនាគារនោះអាចមានរយៈពេលហូតដល់ ១៥ ឆ្នាំ ប្រសិនបើជននោះ «ត្រូវបានលក់» សម្រាប់គោលបំណងសុំកូនយកទៅចិញ្ចឹម និងម្តងទៀតហូតដល់ ២០ ឆ្នាំប្រសិនបើជនរងគ្រោះជាអនីតិជន។ លោកស្រី ប៊ុនអេង បន្តថា៖ «ស្ត្រីដែលមានផ្ទៃពោះមិនខុសច្បាប់ទេ ប៉ុន្តែប្រសិនបើពួកគេមានផ្ទៃពោះហើយបោះបង់សិទ្ធិជាម្តាយនោះពួកគេនឹងខុស»។

គោលការណ៍ណែនាំដូចគ្នាទាំងនោះដែលចេញកាលបរិច្ឆេទផុតកំណត់ត្រឹមថ្ងៃទី ៨ ខែមករាចំពោះការ « លើកលែងទោស» ការពពោះជំនួសក៏បានណែនាំឪពុកម្តាយឲ្យចុះបញ្ជីបំណងរបស់ពួកគេក្នុងការទាមទារសិទ្ធិយកកូនរបស់ខ្លួនទៅតុលាការ។ លោកស្រី ជូ ប៊ុនឡេង បានថ្លែងថាមានករណីតែ ១២ ប៉ុណ្ណោះបានដាក់ទៅតុលាការក្នុងចំណោមការពពោះដែលសង្ស័យថាមានរាប់រយ។

គិតមកត្រឹមចុងខែធ្នូ «តុលាការមិនទាន់ធ្វើសេចក្តីសម្រេចណាមួយនៅឡើយទេ» នៅក្នុងករណីទាំងនោះ។ នេះបើតាមលោក សួស វិជ្ជារានឌី អនុប្រធានរដ្ឋបាលនៅសាលាដំបូងរាជធានីភ្នំពេញ។

លោក សុខ វាសនា ប្រធាននាយកដ្ឋានទូទៅនៃអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃបានថ្លែងថាមិនទាន់មានទិដ្ឋាការចេញណាមួយសម្រាប់កូនទើបកើតតាមរយៈការពពោះជំនួសត្រូវបានចេញឲ្យនៅឡើយទេ ចាប់តាំងពីគោលការណ៍ណែនាំទាំងនេះត្រូវបានផ្សព្វផ្សាយជាផ្លូវការកាលពីខែកក្កដា។ លោក វាសនា ថ្លែងកាលពីថ្ងៃចន្ទថា៖ «យើងមិនទាន់បានចេញទិដ្ឋាការណាមួយនៅឡើយទេយើងនៅកំពុងរង់ចាំលិខិត ដែលចុះហត្ថលេខាដោយក្រសួងមហាផ្ទៃ ឬលោកស្រី ជូរ ប៊ុនអេង»។

លោក Sam Everingham នៅទីភ្នាក់ងារគ្រួសារតាមរយៈការពពោះជំនួសបានថ្លែងថាចំនួនចុះបញ្ជីតិចគឺគ្មានអ្វីភ្ញាក់ផ្អើលទេ។ លោកថ្លែងថា៖ «ខ្ញុំជឿថាគ្រួសារតិចតួចណាស់ដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាលដោយសារការមិនទុកចិត្តរដ្ឋាភិបាលកម្ពុជា និងការភ័យខ្លាចថារដ្ឋាភិបាលកម្ពុជានឹងរារាំងជាជាងជួយដល់ដំណើរការនេះ»។ លោកបន្ថែមថាទីភ្នាក់ងារពពោះជំនួសក៏ទំនងជាមិនលើកទឹកចិត្តឪពុកម្តាយទាំងនោះឲ្យចុះបញ្ជីដែរ។

លោកស្រី រស់ សុភាព នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជាថ្លែងថាឱសានវាទថ្ងៃទី ៨ មករាគឺមិនគ្រប់គ្រាន់ទេសម្រាប់ស្ត្រីពពោះជំនួសដែលភាគច្រើនជាអ្នកក្រ គ្មានការអប់រំ និងរស់នៅតំបន់ដាច់ស្រយាល។ លោកស្រីបន្តថា៖ «ខ្ញុំមិនយល់ស្របនឹងអាជីវកម្មពពោះជំនួសទេ ប៉ុន្តែត្រូវការពេលវេលាដើម្បីដោះស្រាយបញ្ហានេះ។ ពួកគេពិតជាមិនមានជម្រើស... ពួកគេសុខចិត្តធ្វើជាម្តាយពពោះជំនួសគឺដោយសារពួកគេក្រីក្រ»។ «ខ្ញុំគិតថា មេខ្យល់នឹង

ដឹង ប៉ុន្តែជនរងគ្រោះមិនដឹងអំពី [កាលបរិច្ឆេទផុតកំណត់] ទេ។ ប្រសិនបើដាក់ទោសទណ្ឌម្តាយពពោះជំនួស វាហាក់បីដូចជាធ្វើឲ្យពួកគេក្លាយជាជនរងគ្រោះទ្វេដង»៕ NS/PS

## សង្គមស៊ីវិលបង្ហាញការទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារខណៈពលករចំណាក់ស្រុកជួយសង្គ្រោះកាន់តែច្រើន

http://wmc.org.kh/ ថ្ងៃអង្គារ ទី៩ ខែមករា ឆ្នាំ២០១៨ធូ វីរៈ

ភ្នំពេញៈ អង្គការសង្គមស៊ីវិលបង្ហាញភាពវិជ្ជមានចំពោះលទ្ធផលនៃការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារនៅឆ្នាំ២០១៧មានលក្ខណៈល្អប្រសើរ។ ស្របពេលពលករចំណាកស្រុកខ្មែរដោយខុសច្បាប់៥៦នាក់ត្រូវបានផ្ទាធរជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតនៅដើមឆ្នាំ២០១៨នេះ។ យ៉ាងតិចពលករចំណាកស្រុកខ្មែរ៥៦នាក់ត្រូវបានរដ្ឋាភិបាលជួយសង្គ្រោះក្រោយពេលពួកគេធ្វើដោយខុច្បាប់នៅប្រទេសម៉ាឡេស៊ី ថៃ និងវៀតណាម។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជាចេញផ្សាយនៅថ្ងៃទី៣ ខែមករា ឆ្នាំ ២០១៨។ ពលករខ្មែរចំនួន២៩នាក់ជួយសង្គ្រោះពីប្រទេសវៀតណាម គឺ៥នាក់មកពីប្រទេសម៉ាឡេស៊ី និង ពលករខ្មែរធ្វើការលើទូកនេសាទនៅប្រទេសថៃចំនួន២២នាក់បញ្ជូនត្រឡប់មកស្រុកកំណើតវិញបន្ទាប់ពីតុលាការថៃកាត់ទោសពីបទនេសាទខុសច្បាប់។

ការបញ្ជូនពលករចំណាកស្រុកមកប្រទេសកម្ពុជាវិញជាបន្តបន្ទាប់នេះគឺ ស្របពេលអង្គការមេត្រីអន្តរជាតិហៅកាត់(AIM)បង្ហាញភាពវិជ្ជមានចំពោះការជួយសង្គ្រោះស្ត្រី និងកុមាររងគ្រោះ និងងាយរងគ្រោះពីអំពើជួញដូរមនុស្សមានលក្ខណៈល្អប្រសើរនៅឆ្នាំ២០១៧នេះ។ លោកស្រី ខេង ស៊ីសារ៉ាត់ នាយិការងប្រចាំប្រទេសនៃអង្គការមេត្រីអន្តរជាតិ(AIM)ប្រាប់វិទ្យុស្ត្រីថា អង្គការរបស់លោកស្រីជួយសង្គ្រោះស្ត្រី និងកុមារងាយរងគ្រោះពីអំពើការជួញដូរផ្លូវភេទចំនួន៣៦៨នាក់ និងជួយសង្គ្រោះស្ត្រីរងគ្រោះទៅរៀបការជាមួយបុរសជនជាតិចិនចំនួន៤៨នាក់។ លោកស្រី ស៊ីសារ៉ាត់ បន្ថែមថាអង្គការមេត្រីអន្តរជាតិជួយសង្គ្រោះស្ត្រីនិងកុមាររងគ្រោះនិងងាយរងគ្រោះមានចំនួនច្រើននៅឆ្នាំ២០១៧គឺ៤១៦ករណី។ ខណៈដែលឆ្នាំ២០១៦ជួយសង្គ្រោះពីការជួញដូរមានត្រឹម៣២៨ករណី។«សម្រាប់អង្គការមេត្រីអន្តរជាតិយើងទទួលបាន៤១៦ករណីបើប្រៀបធៀបឆ្នាំ២០១៦ គឺយើងកើនឡើងដោយសារយើងមានកិច្ចសហប្រតិបត្តិការណ៍ល្អជាមួយអាជ្ញាធរហើយយើងចុះជួយធ្វើការងារនឹងបានច្រើនជាងមុន។»

អ្នកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រីនិងកុមារនៅសមាគមអាដហុកឲ្យដឹងនៅអំឡុងខែតុលា ឆ្នាំ២០១៧ថា យ៉ាងតិចលោកស្រីទទួលបានពាក្យបណ្តឹងពីសាច់ញាតិជនរងគ្រោះប្រមាណ២០នាក់ក្នុងមួយខែ នៃករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម កេងប្រវ័ញ្ចផ្លូវភេទ និងការរៀបការដោយបង្ខំជាមួយជនជាតិចិន។

បើតាមរបាយការណ៍ថ្មីមួយ ស្តីពីទាសភាពសម័យទំនើបគឺក្នុងចំណោមមនុស្ស៤លាន៨សែននាក់ត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទក្នុងឆ្នាំ២០១៦។ ជនរងគ្រោះ ៩៩ ភាគរយជាស្ត្រី ហើយម្នាក់ក្នុងចំណោមប្រាំនាក់ជាកុមារ។ ស្ត្រីនិងកុមារ៨៤ភាគរយនៃចំនួនប្រជាជន១៥៤លាននាក់ត្រូវបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។៥៩ភាគរយត្រូវបានធ្វើការងារដោយបង្ខំពីវិស័យឯកជន។ ស្ត្រីនិងកុមារីត្រូវបានចាត់ចូលគ្រប់ផ្នែកនៃទម្រង់ទាសភាពសម័យទំនើបលើកលែងតែពលកម្មបង្ខំឱ្យធ្វើការងារដោយស្ថាប័នរដ្ឋ។

បើយោងតាមរបាយការណ៍ ស្តីពីការជួញដូរមនុស្សចេញដោយក្រសួងការបរទេសអាមេរិកចេញផ្សាយកាលពីនៅខែកក្កដា ឆ្នាំ ២០១៧ បញ្ជាក់ថាប្រជាពលរដ្ឋខ្មែរនៅតែបន្តជួញដូរកម្លាំងពលកម្មទៅធ្វើការនៅក្រៅប្រទេសដោយក្រសួងការងារមិនបានពិនិត្យមើលភ្នាក់ងារជ្រើសរើសពលករឲ្យមានប្រសិទ្ធភាព និងកង្វះធនធានមនុស្ស។ របាយការណ៍នេះបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាបានកាត់ទោសជនល្មើសទាក់ទងនឹងការជួញដូរមនុស្ស៩៣នាក់ បើធៀបទៅនឹងឆ្នាំ២០១៥ មាន៦៩នាក់។ រដ្ឋាភិបាលកម្ពុជាបានជួយសង្គ្រោះជនរងគ្រោះពីការជួញដូរមនុស្ស២៧២នាក់ពីប្រទេសម៉ាឡេស៊ី ១៣៩ពីប្រទេសថៃ និង៦៤នាក់ពីប្រទេសចិន៕

## កម្ពុជា-ថៃ ប្តេជ្ញាពង្រឹងសន្តិសុខ តាមព្រំដែន

https://www.dap-news.com/kh/ ថ្ងៃអង្គារ, 09 មករា ២០១៨ 18:07 ដោយ: ដើមអម្ពិល ID:049

ភ្នំពេញ៖លោក សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ និងភាគីថៃលោក ផនផុច ផេនផាត អភិបាលខេត្តស្រះកែវ បានប្តេជ្ញាយ៉ាងមត់មាំក្នុងកិច្ចការពង្រឹងសន្តិសន្តម តាមបន្ទាត់ព្រំដែន រវាងប្រទេសទាំងពីរ ឲ្យបានកាន់តែប្រសើរឡើងថែមទៀត ។ លោក សួន បវរ បានលើកឡើង ក្នុងជំនួបជាមួយភាគីថៃ នៅថ្ងៃទី៩ ខែមករា ឆ្នាំ ២០១៨ នេះថា ខេត្តបន្ទាយមានជ័យ មាន៩ស្រុក-ក្រុងហើយមាន៦ ស្រុក/ក្រុងជាប់ព្រំដែនកម្ពុជា-ថៃមាន ស្រុកម៉ាឡៃ ស្រុកអូរជ្រៅ ក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកស្វាយចេក ស្រុកថ្មពួក។ លោកបន្តថា កិច្ចសហប្រតិបត្តិការ អន្តរជាតិរវាងខេត្តទាំងពីរ ពិសេសសម្ព័ន្ធភាពកម្ពុជាខេត្តបន្ទាយមានជ័យ ភាគីថៃខេត្តស្រះកែវរក្សាបាននិងគោរព យ៉ាងខ្ជាប់ខ្ជួននូវឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី និងមានការទំនាក់ទំនងល្អ វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម សិក្សាធិការ សុខាភិបាល ទេសចរណ៍ វប្បធម៌ កីឡា សាសនា។

លោក សួន បវរ បានបញ្ជាក់ថា កន្លងមកភាគីទាំងពីរតែងតែមានកិច្ចប្រជុំប្តូរ វេនគ្នាការធ្វើទស្សកិច្ចសិក្សា និងការពិភាក្សាដោះស្រាយ ដើម្បីទប់ស្កាត់នូវបទល្មើសឆ្លងដែន ដូចឆ្លងដែនខុសច្បាប់ ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន ការរត់ពន្ធទំនិញខុសច្បាប់ និងគុណភាពជាដើម។ លោកបានបញ្ជាក់ថា ដើម្បីអោយច្រកទ្វារតំបន់ព្រំដែន៤៣អាចដំណើរការទៅបាន រដ្ឋបាលខេត្តបន្ទាយមានជ័យស្នើរសុំអោយមានការចូលរួមពីភាគីថៃ ដើម្បីអោយភាគីខាងកម្ពុជាអាចតភ្ជាប់ផ្លូវទៅដល់ចំណុចដែលត្រូវបើកច្រកនិងស្នើអោយភាគីទាំងពីរអាចធ្វើដំណើរចេញចូលជាធម្មតាតាមផ្លូវនេះវិញមុនដំណើរការបើកច្រកជាផ្លូវការ។ លោក សួន បវរ បានលើកឡើងថាជុំវិញការប្រើប្រាស់បណ្ណព្រំដែន (BorderPass) កម្ពុជា-ថៃគំរូថ្មី យោងតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពីការឆ្លងការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ។ ដើម្បីសម្រួលនិងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋកម្ពុជាដែលមានទីលំនៅអចិន្ត្រៃយ៍នៅខេត្តជាប់ជាយដែនកម្ពុជាថៃ ។ នេះបើយោងតាមការចុះផ្សាយរបស់អគ្គស្នងការនគរបាលជាតិ៕

## សាកសពជនជាតិខ្មែរ២នាក់ ដែលស្លាប់ នៅទឹកដីថៃ បានបញ្ជូនមកកម្ពុជា

https://www.dap-news.com/kh/ អង្គារ, 09 មករា ២០១៨ 17:27 ដោយ: ធី លីថូ ID:049

ភ្នំពេញ៖អាជ្ញាធរកម្ពុជា ប្រចាំប្រទេសថៃ បានធ្វើការសម្របសម្រួលជាមួយអាជ្ញាធរថៃ បញ្ជូនសាកសពពលករខ្មែរចំនួន២នាក់ ដែលបានស្លាប់ ក្នុងហេតុការណ៍ នាវាដឹកទំនិញប៉ាគីស្ថានបុកទូកនេសាទថៃ កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកដល់ប្រទេសកម្ពុជា តាមច្រកទ្វាអន្តរជាតិបានឡែមដូង។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃកាលពីថ្ងៃទី៨ ខែមករា ឆ្នាំ ២០១៨ ដែលទើបផ្សព្វផ្សាយជាសាធារណៈ នៅថ្ងៃទី៩ ខែមករា នេះ បានឲ្យដឹងថា សាកសពពលករខ្មែរទាំង២នាក់ ត្រូវបានបញ្ជូនចេញពីមូលនិធិសារ៉ាំងរ៉ូចចាក់ណាក់ថាំ ដែលស្ថិតនៅក្នុងខេត្តឈុនបុរី ប្រទេសថៃ ទៅប្រទេសកម្ពុជា តាមច្រកទ្វាអន្តរជាតិបានឡែមដូង ។

គួរបញ្ជាក់ថា ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ កំពុងសហការជាមួយ និយោជកក្នុងការបន្តនីតិវិធីតាមផ្លូវច្បាប់ ដើម្បីទាមទារសំណង ពីនាវាដឹកទំនិញប៉ាគីស្ថាន ដែលបានបង្កហេតុនោះ ដើម្បីឲ្យធ្វើការជូនសំណងទៅឲ្យក្រុមគ្រួសារនៃសពទាំង២នាក់។ សូមរំលឹកថា កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០១៨ មានឧបទ្ទវហេតុមួយបានកើតឡើងដោ

យាសារនាវាដឹកទំនិញរបស់ប៉ាគីស្ថាន បុកទូកនេសាទថៃ Choke Chuchai នៅចំណុច ឆ្នេរសមុទ្រសាត់តា ហ៊ីប ខេត្តឈុនបុរី ប្រទេសថៃ បណ្តាលឲ្យទូក នេសាទថៃលិចចូលក្នុងសមុទ្រ និងធ្វើឲ្យមនុស្សចំនួន៤នាក់ស្លាប់ ក្នុងនោះមានពលករខ្មែរ២នាក់ និងជនជាតិថៃ២នាក់៕

## កម្លាំងអាជ្ញាធរថៃ ចុះបង្ក្រាបរោងចក្រផលិតចាហួយដូង រកឃើញពលករខុសច្បាប់ចំនួន 30នាក់

http://www.prakpheaktra.com January 9, 2018

កម្លាំងអាជ្ញាធរខេត្តណាខនប៉ាធុម ប្រទេសថៃ ចុះបង្ក្រាបរោងចក្រផលិតចាហួយដូង 2កន្លែង រកឃើញពលករខុសច្បាប់ចំនួន 30នាក់។ កាលពីថ្ងៃអង្គារទី09 ខែមករា ឆ្នាំ2018 កម្លាំងអាជ្ញាធរមូលដ្ឋានខេត្តណាខនប៉ាធុមប្រទេសថៃ ដឹកនាំកម្លាំងដោយលោកអភិបាលខេត្តណាខនប៉ាធុម និងកម្លាំងទាហានថៃចំនួន30នាក់ បើកកិច្ចព្រឹត្តិការណ៍កចុះបង្ក្រាបទីតាំងផលិតចាហួយដូងចំនួនពីរកន្លែង ស្ថិតនៅក្នុងសង្កាត់ស៊ីសាក់ថង ស្រុកណាខនឆៃស៊ី ខេត្តណាខនប៉ាធុម ។ ក្នុងកិច្ចសហប្រតិបត្តិការចុះបង្ក្រាបទីតាំងទាំងពីរកន្លែងខាងលើនេះ កម្លាំងអាជ្ញាធរថៃ បានរកឃើញពលករចំណាកស្រុកខុសច្បាប់គ្មានឯកសារ ធ្វើការនៅក្នុងប្រទេសថៃ ចំនួន 30នាក់ ក្នុងនោះមានជនជាតិខ្មែរ ចំនួន 10នាក់ ជនជាតិភូមា 11នាក់ និងជនជាតិឡាវ ចំនួន 05នាក់ ។ ក្រោយពេលឃាត់ខ្លួនពលករខុសច្បាប់ទាំងអស់ត្រូវបានកម្លាំងអាជ្ញាធរបញ្ជូនទៅធ្វើការសាកសួរនៅអធិការដ្ឋានប៉ូលិសខេត្តណាខនប៉ាធុម ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ថៃស្លាប់ 1នាក់ ពលករខ្មែររងរបួស 08នាក់

http://www.prakpheaktra.com January 9, 2018

ពលករខ្មែរ08នាក់ ធ្វើការនៅខេត្តឈុនបុរី ជួលរថយន្តឈ្នួលធ្វើដំណើរទៅព្រំដែនខ្មែរ តែកើតឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរបុកគូទរថយន្តដឹកហ្គាស បណ្តាលឱ្យមានជនជាតិថៃស្លាប់1នាក់ នៅកន្លែងកើតហេតុ និងពលករខ្មែរចំនួន08នាក់ទៀតរងរបួសធ្ងន់និងស្រាល។ ករណីនេះបានកើតឡើងកាលពីវេលាម៉ោង11ថ្ងៃត្រង់ ថ្ងៃអង្គារទី09 ខែមករា ឆ្នាំ2018 នៅលើផ្លូវជាតិ311 (សាត់ហ៊ីប-ណាខនផានុមមហាសាខាម)ស្ថិតនៅត្រង់ចំណុចផ្លូវបំបែក(ប៉ាក់ធុងឆៃ) សង្កាត់ហួរសាំរោង ស្រុកប្រែងយ៉ាវ ខេត្តឆាកឈើងសៅ ប្រទេសថៃ។ ក្រោយពេលកើតហេតុជនរងគ្រោះទាំងអស់ត្រូវបានកម្លាំងសមត្ថកិច្ចថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យប្រែងយ៉ាវ ខេត្តឆាកឈើងសៅ។

## ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៨

## កិច្ចប្រជុំផ្សព្វផ្សាយក្រុមប្រតិបត្តិយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ស្នងការដ្ឋាននគរបាលជាតិ

http://cambodiapolice.com/ 10:49 am 11 មករា 2018

កំពង់ចាម៖ នាព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយក្រុមប្រតិបត្តិយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ស្នងការដ្ឋាននគរបាលជាតិ ក្រោមអធិបតីភាពលោកស្រី ឧត្តមសេនីយ៍ត្រី អៀម វណ្ណី ស្នងការរង និងជាប្រធានក្រុមការងារយេនឌ័រ ដោយមានការអញ្ជើញចូលរួមពីលោក លោកស្រីនាយរងការិយាល័យ នាយ នាយរងផ្នែក លោកអធិការ អធិការរង ដែលជាសមាជិកក្រុមការងារយេនឌ័រ សរុបចំនួន២២នាក់ ។

## តុលាការអាមេរិក ច្រានចោលបណ្តឹងរបស់ពលរដ្ឋកម្ពុជា

http://www.postkhmer.com/ **Wed, 10 January 2018 Leonie Kijewski**

ភ្នំពេញៈ តុលាការសហព័ន្ធអាមេរិកមួយបានច្រានចោលពាក្យបណ្តឹងប្រឆាំងនឹងក្រុមហ៊ុនថៃចំនួន ២ និងក្រុមហ៊ុនអាមេរិក ២ ដែលពលរដ្ឋកម្ពុជា ៧ នាក់បានប្តឹងដោយអះអាងថាពួកគេគឺជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងឲ្យធ្វើការដោយបង្ខំ។ ចៅក្រម John F Walter នៃតុលាការសហព័ន្ធប្រចាំរដ្ឋកាលីហ្វ័រនីញ៉ាកាលពីថ្ងៃព្រហស្បតិ៍

សប្តាហ៍មុនបានច្រានចោលរឿងក្តីនេះ បើទោះជាការកាត់ក្តីមិនមានហេតុផលក៏ដោយ។ លោក Walter បានលើកឡើងអំពីករណីនេះកាលពីថ្ងៃទី ២១ ខែធ្នូឆ្នាំមុនដោយថាខ្វះយុត្តាធិការ។

ពាក្យបណ្តឹងនេះត្រូវបានប្តឹងកាលពីខែមិថុនាឆ្នាំ ២០១៦ ដោយមានជនរងគ្រោះជាជនជាតិខ្មែរ ៧ នាក់ក្នុងនោះមានស្ត្រី ២ នាក់។ ក្នុងពាក្យបណ្តឹងនោះជនរងគ្រោះបានបញ្ជាក់ថាពួកគេត្រូវបានក្រុមហ៊ុនជ្រើសរើសពលករក្នុងស្រុកមកបញ្ចុះបញ្ចូលឱ្យទៅធ្វើការនៅក្រុមហ៊ុនគ្រឿងសមុទ្រថៃ Phatthana Seafood Co. Ltd. ចន្លោះឆ្នាំ ២០១១ ដល់ ២០១២ ហើយបានប្រឈមនឹងការបង្ខំឱ្យធ្វើការងារលើសកម្លាំង ហើយគ្រឿងសមុទ្រទាំងនោះសម្រាប់នាំចេញទៅសហរដ្ឋអាមេរិក។ ពាក្យបណ្តឹងនោះបានបញ្ជាក់ថាការធ្វើដំណើរទៅកាន់ប្រទេសថៃគឺជាទុក្ខលំបាកមួយ។ ដើមបណ្តឹងឈ្មោះបាន និងឈ្មោះ ណាគ្រី ត្រូវបានគេនាំយកទៅធ្វើការនៅទីនោះដោយពួកគាត់បានខ្ចីបុលគេ ហើយត្រូវធ្វើដំណើរតាមរថយន្តភីកអាប់មួយគ្រឿងដែលដាក់មនុស្សណែន និងត្រូវបានគំរាមកំហែងដោយការវាយដំផងដែរ។ ដើមបណ្តឹងឈ្មោះបាន និងណាគ្រីសម្លឹងមើលដោយការភ័យខ្លាចនៅពេលដែលកម្មកររួមការងារជាមួយគ្នាត្រូវបានវាយដំដោយខ្សែភ្លើងពីពួកអ្នកជ្រើសរើសពលករ។

ប៉ុន្តែបន្ទាប់ពីពួកគេទៅដល់ទីនោះអ្វីៗហាក់មិនបានល្អឡើយ។ ពលករមួយចំនួនមិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញម្ហូបអាហារបរិភោគទេ ហើយជារឿយៗពួកគេត្រូវរស់ទាំងស្រេកឃ្លាន។ ឧទាហរណ៍ ដើមបណ្តឹងឈ្មោះបាន និងណាគ្រីត្រូវឆ្លៀតពេលដើររកចាប់ត្រីក្តាម ខ្យងនៅតាមវាលស្រែក្បែរៗនោះដើម្បីយកទៅធ្វើម្ហូបចម្អែតក្រពះ។ លើសពីនេះទៀតដើមបណ្តឹងជាច្រើនបាននិយាយថា ពួកគេត្រូវបានគេចាត់ឱ្យធ្វើការជាមួយសារជាតុគ្លរីនដោយគ្មានឧបករណ៍ការពារគ្រប់គ្រាន់ដែលនាំឱ្យពួកគេមានបញ្ហាផ្លូវដង្ហើមផងដែរ។ ពាក្យបណ្តឹងនោះបានបន្ថែមថានៅពេលដែលកម្មករចង់ចាកចេញពួកគេត្រូវបានថៅកែប្រាប់ថាពួកគេមិនអាចទទួលបានលិខិតឆ្លងដែនពួកគេទេគឺរហូតទាល់តែពួកគេរកលុយសងបំណុលថ្លៃសេវាជ្រើសរើសពលកររួចរាល់អស់សិន ប៉ុន្តែនេះជាអ្វីដែលពួកគេគ្មានលទ្ធភាពដោយសារប្រាក់ខែទាបជាងការសន្យាឆ្ងាយខ្លាំងណាស់។ ពាក្យបណ្តឹងនោះបានចោទប្រកាន់ក្រុមហ៊ុនអាហារសមុទ្រ Phatthana Seafood, SS Frozen Food, Doe Corporations, Rubicon Resources និង Wales & Co ថាពួកគេត្រូវទទួលខុសត្រូវចំពោះការបង្កាបការបង្ខំឱ្យធ្វើការដោយបង្ខំ និងការជួញដូរមនុស្សដោយអចេតនាដោយសារតែពួកគេជា «អ្នកចូលហ៊ុនរួមគ្នាដែលបានបំពានច្បាប់សហរដ្ឋអាមេរិកដែលពួកគេបានទទួលប្រយោជន៍ពីការនាំចូលគ្រឿងសមុទ្រដូចជាបង្គាជាដើមដែលគ្រឿងសមុទ្រទាំងនោះរកបានដោយពលករដែលគេជួញដូរ និងកេងប្រវ័ញ្ច»។

ប៉ុន្តែក្នុងសាលក្រមដំណើរការរឿងក្តីនេះត្រូវបានចៅក្រមអះអាងថាមិនមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងក្រុមហ៊ុនសហរដ្ឋអាមេរិក និងការជួញដូរមនុស្សដើម្បីផ្តល់ជាយុត្តាធិការដល់តុលាការសហរដ្ឋអាមេរិកលើសំណុំរឿងនេះទេ។ យោងតាមពាក្យបណ្តឹង ដើមបណ្តឹងបានចោទប្រកាន់ថាក្រុមហ៊ុន S.S Frozen Food បានទទួលផលប្រយោជន៍ពីដើមបណ្តឹងម្នាក់ដែលត្រូវបានគេឱ្យធ្វើការងារទាំងបង្ខំ ទោះបីជាដើមបណ្តឹងទើបតែបានទៅធ្វើការនៅទីនោះគឺបន្ទាប់ពីមានបញ្ជាទិញពីក្រុមហ៊ុនអាមេរិកក្តី។ ពាក្យបណ្តឹងនោះក៏បានបញ្ជាក់ពីការជាប់ទាក់ទងជាមួយនឹងភ្នាក់ងារជ្រើសរើសពលករ CDM Trading Manpower ផងដែរនៅក្នុងដំណើរការជួញដូរ។

អ្នកស្រី Lim Vouchna ដែលជាមន្ត្រីម្នាក់របស់ក្រុមហ៊ុននេះបានថ្លែងថាអ្នកស្រីមិនអាចផ្តល់ព័ត៌មានបន្ថែមអំពីករណីនេះបានទេ ប៉ុន្តែថាអ្នកស្រីបានចាប់ផ្តើមធ្វើការក្នុងក្រុមហ៊ុននេះបន្ទាប់ពីរឿងក្តីនេះបានកើតឡើងរួចហើយ។ លោកស្រីថាក្រុមហ៊ុន CDM Trading Manpower ឈប់ធ្វើការជាមួយក្រុមហ៊ុន Phatthana ទៀតហើយ។

លោក DyThe Hoya មន្ត្រីអង្គការសិទ្ធិការងារ Central បានថ្លែងថាដំណើរការតុលាការមានភាពស្មុគស្មាញណាស់សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្សហើយថាក្រុមហ៊ុនជាច្រើនតែងតែបានឈ្នះក្តីនៅតុលាការដោយសារវិសមភាពធនធាន។ លោកបានបញ្ជាក់ថា៖ «វាមិនយុត្តិធម៌សម្រាប់ពលករនោះទេ»៕ NS

## អាណិតណាស់ព្រាត់ប្រាស ប្តី-កូន ដល់ទៅជាង១៣ឆ្នាំ

https://kohsantepheapdaily.com.kh/ កោះសន្តិភាព ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៨ម៉ោង ១២:៥៧សហការី

រាជធានីភ្នំពេញ៖ ស្ត្រីជាពលករម្នាក់ បន្ទាប់ពីបានចាញ់បោកគេអស់រយៈពេល១៣ឆ្នាំ ទៅធ្វើការនៅអារ៉ាប៊ីអូសាឌីតបានវិលត្រលប់មកកម្ពុជាវិញហើយ កាលពីព្រឹកមិញថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ នៅអាកាសយានដ្ឋានអន្តរ

ជាតិភ្នំពេញ ។ ស្ត្រីរងគ្រោះខាងលើឈ្មោះ អេង ពៅ អាយុ៣៨ឆ្នាំ ជនជាតិខ្មែរអីស្លាម មានទៅលំនៅភូមិពង្រ ឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ ដែលបានចាញ់បោកក្រុមហ៊ុនទៅបម្រើការងារតាំងពីឆ្នាំ២០១៤មកម្ល៉េះ ។ ជនរងគ្រោះបាន ទម្លាយឲ្យដឹងថា ក្រុមហ៊ុនលោក អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវជននិតិសម្បទា ដែលត្រូវបានបញ្ចប់តំណែងកាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧កន្លងទៅ ។

លោកសា ឡុក ម៉ាន អាយុ ៦៦ឆ្នាំត្រូវជាប្តីបានឲ្យដឹងថា លោករិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីជួយ ប្រពន្ធដែលរងគ្រោះជាង១៣ឆ្នាំ ប៉ុន្តែគ្មានតម្រុយទាល់តែសោះ រហូតដល់ឆ្នាំ២០១៤លោកបានទៅធ្វើការនៅក្រុមហ៊ុនខាងលើនៅអារ៉ាប៊ីអូសាឌីត ធ្វើជាអ្នកបើករថយន្ត ហើយនៅផ្សេងគ្នាពីប្រពន្ធ រហូតចប់កុងត្រាជាមួយក្រុមហ៊ុនខាងលើ ក៏បានវិលត្រលប់មកខ្មែរវិញ ដើម្បីរកមធ្យោបាយជួយប្រពន្ធ ។ លោកបានសន្សំប្រាក់ជាច្រើន រួចចេញទៅធ្វើការនៅផ្ទះដដែល កាលពីឆ្នាំ២០១២ នៅទីបំផុតលោកបានជួបប្រពន្ធមែន តែគ្មានលទ្ធភាពជួយបាន ព្រោះស្ត្រីជាប្រពន្ធគ្មានលិខិតឆ្លងដែន និងឯកសារពាក់ព័ន្ធអ្វីឡើយ ។

ទន្ទឹងរងចាំវាសនាអស់រយៈពេល៥ឆ្នាំលោកបានជួបប្រពន្ធម្តងម្កាល ដោយពិបាកពេក កាលពីខែកុម្ភៈ ឆ្នាំ ២០១៧ ទើបលោកសម្រេចចិត្តលា ប្រពន្ធមកស្រុកខ្មែរម្តងទៀត ដើម្បីដើររកជំនួយបន្ត ។ បន្ទាប់ពីមានការណែនាំពីមន្ត្រីនៅតាមមូលដ្ឋានឲ្យមកទំនាក់ទំនងអន្តរាគមន៍ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទើបសម្រេចចិត្តដើម្បីសុំជួប និងអន្តរាគមន៍ពីលោក អ៊ូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអម នាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិកាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទើបលោកបានជួយប្រពន្ធគាត់បាន ។

នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញស្ត្រីរងគ្រោះបានរួចពីរងគ្រោះមកដល់ស្រុកខ្មែរវិញបានបញ្ជាក់ឲ្យដឹងថា ក្នុងកំឡុងពេលជាង១៣ឆ្នាំ គឺខ្លួនមិនបានទទួលប្រាក់បៀវត្សនោះឡើយ ហើយក៏មិនមានតំណាងក្រុមហ៊ុនដែលបញ្ជូនខ្លួនទៅមកទាក់ទងគាត់ដែរ និយាយរួមគឺជាការបោកប្រាស់ យកពលករទៅលក់សុទ្ធសាត ។ ស្ត្រីរងគ្រោះ និងក្រុមគ្រួសារបានអំពាវនាវឲ្យអាជ្ញាធរសូមមេត្តាជួយរកយុត្តិធម៌ឲ្យគ្រួសារគាត់ផង ជាពិសេសឲ្យជួយដោះស្រាយជនបង្កហេតុមកទទួលទោសតាមទង្វើនេះផង ៕

## បើក,ត visa 2ឆ្នាំ ជូនពលករមានប័ត្រស៊ីជម្ពូ(TD) ស្នាក់នៅក្នុងខេត្តនុនថាកបុរី

http://www.prakpheaktra.com ប្រភពដំណឹងពលករខ្មែរ January 11, 2018

មន្ទីរការងារខេត្តនុនថាកបុរី ប្រទេសថៃ ចេញសេចក្តីប្រកាស តាមរយៈវេបសាយមន្ទីរការងារខេត្ត ជូនដំណឹងដល់បងប្អូនពលករខ្មែរ, ភូមា, ឡាវ, ដែលកាន់ប័ត្រស៊ីជម្ពូផុតកំណត់ 31.03.2018 ហើយបាន បញ្ជាក់អត្តសញ្ញាណរួចរាល់ព្រមទាំងទទួលបានលិខិតឆ្លងដែនធ្វើការ និងវីសាការងារ( Non-LA) ហើយនោះ។ បងប្អូនពលករខ្មែរអោយនិយោជកនាំទៅដំណើរការស្នើសុំទិដ្ឋាការ(Visa ការងារបន្ត ) ដើម្បីអាចបន្តការនៅក្នុងប្រទេសថៃបាន ចាប់តាំងពីថ្ងៃទី31 ខែមីនា ឆ្នាំ2018 នេះតទៅ។ ដោយតំរូវអោយពលករត្រូវទៅត្រួតពិនិត្យសុខភាព និងស្នើសុំទិដ្ឋាការVisaការងារនៅ(តម៉) ដោយសុពលភាព(visa) នេះមានរយៈពេលស្នាក់នៅធ្វើការក្នុងប្រទេសថៃ រហូតដល់ថ្ងៃទី31 ខែមីនា ឆ្នាំ 2020 អាស្រ័យហេតុនេះសូមបងប្អូនពលករខ្មែរ ទាំងអស់ដែលមានលិខិតឆ្លងដែនធ្វើការ ហើយកំពុងធ្វើការនៅក្នុងខេត្តនុនថាកបុរី ប្រទេសថៃ សូមមេត្តាប្រញាប់រួសរាន់ទៅធ្វើស្នើសុំVisa 2 ឆ្នាំ អោយបានទាន់ពេលវេលាពេលកំណត់។

## ពលរដ្ឋខ្មែរម្នាក់ត្រូវអាជ្ញាធរថៃដោះលែងឱ្យមានសេរីភាពវិញ

https://kohsantepheapdaily.com.kh/ កោះសន្តិភាព ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៨ម៉ោង ១៣:៣៤ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អាជ្ញាធរថៃបានធ្វើការដោះលែងពលរដ្ឋខ្មែរម្នាក់ឱ្យមានសេរីភាព បន្ទាប់ពីឃាត់ខ្លួនកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដោយចោទពីបទឆ្លងដែនសុខច្បាប់ នាំខ្លួនយកមកប្រគល់ឱ្យអាជ្ញាធរកម្ពុជាវិញ តាមមាត់ច្រកទ្វារអន្តរជាតិជាំ កាលពីវេលាម៉ោង០១រសៀល ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

យោងតាមសម្តីពលរដ្ឋខ្មែរដែលក្រុមអាជ្ញាធរថៃធ្វើការដោះលេងនោះឈ្មោះ តាន់ ភាន់ ភេទប្រុស អាយុ៣៨ ឆ្នាំ រស់នៅភូមិស្រែតាគុយ ឃុំពោធិចំរើន ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺបានឱ្យដឹងថា ដោយសារតែខ្លួនក្រីក្រពេក ទើបឆ្លងដែនចូលទៅក្នុងទឹកដីថៃរុករកកាប់ឈើគ្រញូងយកមកលក់ ដើម្បីដោះស្រាយនូវជីវភាពក្នុងគ្រួសារ ។ រូបគាត់

បញ្ជាក់ថា មូលហេតុដែលអាជ្ញាធរថៃប្រញាប់ធ្វើការដោះដោយសារតែរូបខ្លួនមិនមានវត្ថុតាងដូចជា រណា កាំបិត ពូថៅ ឬឈើនៅជាប់នឹងខ្លួន ។

មន្ត្រីបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិបានឱ្យដឹងថា ក្រោយពីបានទទួលប្រជាពលរដ្ឋខ្មែរ សមត្ថកិច្ចបានធ្វើការអប់រំ រួចឱ្យវិលត្រលប់ទៅជួបជុំក្រុមគ្រួសារវិញក្នុងថ្ងៃដដែល ៕

## ទូតខ្មែរប្រចាំប្រទេសថៃ នឹងផ្អាកផ្តល់លិខិតឆ្លងដែន និងប័ណ្ណពលករ ចាប់ពីថ្ងៃទី១៥មករា

https://www.dap-news.com/kh/ ព្រហស្បតិ៍, ១១ មករា ២០១៨ 08:19 ដោយ: ដើមអម្ពិល ID:013

ភ្នំពេញ៖ ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ បានជូនដំណឹងដល់បងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ថា ការិយាល័យបើកផ្តល់លិខិតឆ្លងដែន /លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជា ទៅធ្វើការនៅបរទេស (OCWC) ប្រចាំខេត្តរ៉ាក់យ៉ង និងឆាក់ឈើងសាវ នៃគណៈកម្មការផ្តល់ភាពស្របច្បាប់ ជូនដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងផ្អាកដំណើរការ ចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ នេះតទៅ។

ព្រះរាជាណាចក្រកម្ពុជា
ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០២៩ /១៨/សកប៤

**សេចក្តីជូនដំណឹង**

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ជ្រាបថា ការិយាល័យបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ប្រចាំខេត្តរ៉ាក់យ៉ង និងឆាក់ឈើងសាវនៃគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងផ្អាកដំណើរការ **ចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨** នេះតទៅ។ អាស្រ័យហេតុនេះសម្រាប់បងប្អូនពលករដែលបានដាក់ពាក្យស្នើសុំដកលិខិតឆ្លងដែន/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) នៅការិយាល័យខេត្តទាំងពីរខាងលើរួចហើយ និងបងប្អូនពលករដែលមិនទាន់ដាក់ពាក្យស្នើសុំ អាចបន្តមកទំនាក់ទំនង និងដាក់ពាក្យស្នើសុំដកឯកសាររបស់ខ្លួនជាធម្មតា នៅលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ដែលមានទីតាំងស្ថិតក្នុងបរិវេណស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានអាស័យដ្ឋាននៅអាគារលេខ ៥១៨/៤ ផ្លូវប្រាឆាអ៊ុធីត (រ៉ាមកាំហែង ច្រកលេខ៣៩) សង្កាត់វ៉ាំងថុងឡាង ខ័ណ្ឌវ៉ាំងថុងឡាង ទីក្រុងបាងកក ប្រទេសថៃ។

ក្នុងករណីបងប្អូនពលករកម្ពុជា មានចង្ងល់ពាក់ព័ន្ធនឹងបញ្ហានេះ សូមទំនាក់ទំនងមកមន្ត្រីលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ តាមរយៈលេខទូរស័ព្ទ ០៨២ ៤២២ ០០៤៤ ០៨២ ៤២២ ០០១១ ០៨២ ៤២២ ០០៥៥ ០៨២ ៤២២ ០០៦៦ និង០៨២ ៤២២ ០០៧៧។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ៩កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅបាងកក ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៨

អាស័យដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
ទូរស័ព្ទ: (៦៦-២) ៥៤៧ ៥៨៥១/៥៤៧ ៥៨៥២ ទូរសារ:(៦៦-២) ៥៤៧ ៥៨៥០ អ៊ីម៉ែល: camemb.tha@mfa.gov.kh

# ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៨

## មន្ត្រីជំនាញក្រសួងមហាផ្ទៃ កំពុងស្រាវជ្រាវរកមុខអ្នករត់ការធ្វើបណ្ណព្រំដែន កម្ពុជា-ថៃ

https://www.dap-news.com/kh/ ប្រភពដើមអំពិល ព្រហស្បតិ៍, ១១ មករា ២០១៨ 16:19 ដោយ: ខា ដា ID:049

បន្ទាយមានជ័យ ៖ បន្ទាប់ពីមានការរត់ការធ្វើបណ្ណព្រំដែនកម្ពុជា-ថៃ ឲ្យប្រជាពលរដ្ឋនៅក្រៅខេត្តក្នុងម្នាក់យកតម្លៃ ១៥០,០០០រៀល ពេលនេះមន្ត្រីជំនាញក្រសួងមហាផ្ទៃ បាននិងកំពុងស្រាវជ្រាវ រកមុខអ្នករត់ការនោះយកមកចាត់ការតាមច្បាប់ ។

យោងតាមគេហទំព័ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ បានឲ្យដឹងថា នៅព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨នេះ មានប្រជាពលរដ្ឋប្រមាណជា ១៥ទៅ២០នាក់ រងចាំធ្វើបណ្ណព្រំដែនកម្ពុជា-ថៃ នៅមុខសាលាខេត្តបន្ទាយមានជ័យ ខ្លះចងអង្រឹងដេកចាំ និងមានអីវ៉ាន់ពួកគាត់ប្រាប់ថា មករងចាំធ្វើបណ្ណព្រំដែនកម្ពុជា-ថៃនេះ ខ្លះជិត១សប្តាហ៍មកហើយ ដែលភាគច្រើនអ្នកនៅខេត្តឆ្ងាយមករងចាំធ្វើ ដើម្បីបន្តដំណើរ ទៅធ្វើការងារប្រទេសថៃ ។

ជាមួយគ្នានោះប្រជាពលរដ្ឋដែលរងចាំបានស្នើសុំឲ្យរាជរដ្ឋាភិបាល ឬក្រសួងជំនាញអនុញ្ញាតឲ្យប្រជាពលរដ្ឋខេត្តដទៃធ្វើបណ្ណព្រំដែនកម្ពុជា-ថៃ ដើម្បីឲ្យប្រជាពលរដ្ឋមានសិទ្ធិទៅរកការងារធ្វើនៅប្រទេសថៃ ដោយស្របច្បាប់ សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចប្រជាពលរដ្ឋខេត្តជាប់ជាយដែន ។

ពាក់ព័ន្ធនឹងបញ្ហានេះដែរ មន្ត្រីសាលាខេត្តម្នាក់បានបង្ហើបប្រាប់ថា "ការធ្វើបណ្ណព្រំដែនកម្ពុជា-ថៃនេះ មានអ្នករត់ការធ្វើឲ្យប្រជាពលរដ្ឋនៅក្រៅខេត្តធ្វើក្នុងម្នាក់យកតម្លៃ ១៥០,០០០រៀល ហើយមន្ត្រីជំនាញកំពុងស្រាវជ្រាវរកមុខដើម្បីចាត់ការតាមច្បាប់បើសិនរកឃើញ" ។

សូមបញ្ជាក់ថា រដ្ឋបាលខេត្តបន្ទាយមានជ័យ បានជូនដំណឹងដល់ប្រជាពលរដ្ឋទូទៅដែលមានទីលំនៅអចិន្ត្រៃយ៍ ក្នុងខេត្តអំពីការផ្តល់សេវា ឲ្យកាន់តែមានប្រសិទ្ធភាពដល់អង្គភាពច្រកចេញចូលតែមួយ នៃសាលាខេត្តបន្ទាយមានជ័យ តម្រូវឲ្យបងប្អូនដែលប្រើប្រាស់បណ្ណព្រំដែនកម្ពុជា-ថៃគំរូថ្មី ។

ទន្ទឹមគ្នានេះការ បំពេញលក្ខខណ្ឌបែបបទ និងនីតិវិធីត្រូវធ្វើលក្ខខណ្ឌមួយចំនួន៖ ១-ពាក្យស្នើសុំបណ្ណព្រំដែន១ច្បាប់ ដោយមានបិតរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំ របស់សម៊ីខ្លួននៅលើពាក្យស្នើសុំ ២-រូបថតសម៊ីខ្លួនបច្ចុប្បន្នទំហំ ៤X៦ ថតចំពីមុខ គ្មានពាក់មួកឬវ៉ែនតាចំនួន ២សន្លឹក ៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងចំនួន១ច្បាប់ ៤-សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតចំនួន ១ច្បាប់ ៥-សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់ នៅចំនួន ១ច្បាប់ ៦-រូបថតកូនទំហំ ៤X៦ ចំនួន២សន្លឹកក្នុងម្នាក់ (ករណីមានកូនអាយុក្រោម ១២ឆ្នាំដំណើរជាមួយ) ៧.កម្រៃសេវាក្នុង ១ច្បាប់ នៃបណ្ណព្រំដែនចំនួន២០,០០០រៀល និង៨-រយៈពេលនៃការផ្តល់សេវាយ៉ាងយូរ ៥ថ្ងៃបន្ទាប់ ពីទទួលពាក្យស្នើសុំ ៕

## បុរសប៉ាគីស្ថាន ២នាក់ ឪពុកកូននិងស្ត្រីខ្មែរម្នាក់ត្រូវឧទ្ធរណ៍បន្ថយទោស

http://www.postkhmer.com/ ប្រភពភ្នំពេញប៉ុស្តិ៍ Thu, 11 January 2018 គឹម សារុំ

ភ្នំពេញៈ បុរសជនជាតិប៉ាគីស្ថាន២នាក់ឪពុក និងកូនប្រុស នៅព្រឹកថ្ងៃទី ១១ មករា នេះត្រូវបានសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍សម្រេចបន្ថយទោសម្នាក់ ១ ឆ្នាំ ខណៈស្ត្រីខ្មែរម្នាក់ទៀតបន្ថយទោស ៣ ឆ្នាំពាក់ព័ន្ធនឹងករណីជួញដូរមនុស្សទៅប្រទេស អារ៉ាប៊ីសាអ៊ូឌីត កាលពីឆ្នាំ២០១៦។

លោកចៅក្រម ស៊ិន វិសាល បានអានសាលដីកាចំពោះមុខជនជាប់ចោទទាំង ៣ នាក់ថា ឈ្មោះ NIAZ AHMED អាយុ ៥៥ ឆ្នាំនិងកូនប្រុសគាត់ឈ្មោះ YAZEO AHMED អាយុ ២៤ ឆ្នាំ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសម្នាក់ៗ ៧ ឆ្នាំចោទពីបទ «នាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» តាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរនិងធ្វើអាជីវកម្មផ្លូវភេទ» ។ ប៉ុន្តែ ដោយយល់ឃើញថា ជនជាប់ចោទ ២ នាក់ មិនទាន់បានសម្រេច

ផលក្នុងអំពើនាំពលករនិងមិនទាន់ធ្វើឲ្យខូចខាតអ្វីនោះ ក្រុមប្រឹក្សាសម្រេចបន្ថយទោស ពួកគេ មកនៅ ៦ ឆ្នាំវិញ និងកែប្រែបទចោទពី «នាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» មកជា «ប៉ុនប៉ងនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែនវិញ»។

ឯស្ត្រីខ្មែរឈ្មោះ ប៊ិនញ៉ អាយុ ៦៥ ឆ្នាំ កាត់ឲ្យជាប់ពន្ធនាគារ៥ឆ្នាំតែបន្ថយមកជាប់ ១ ឆ្នាំ ៦ ខែវិញ ហើយទោសសល់ត្រូវព្យួរនិងប្ដូរចោទពីបទពី «នាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» មកជាបទ «សមគំនិតក្នុងការប៉ុនប៉ងនាំចេញ ដោយមិនស្របច្បាប់សម្រាប់ឆ្លងដែនវិញ»។

តាមអង្គហេតុជនជាប់ចោទទាំង ៣ នាក់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅផ្សាររាត្រី (ផ្សារចាស់) រាជធានីភ្នំពេញ ខណៈកំពុងធ្វើដំណើរតាមម៉ូតូកង់បី កាលពីថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៦៕

## បុរសបំពានផ្លូវភេទនៅអាមេរិក ត្រូវចាប់ខ្លួននៅកម្ពុជា

http://www.postkhmer.com/ ប្រភពភ្នំពេញប៉ុស្តិ៍ Thu, 11 January 2018 សុទ្ធ គឹមសឿន

ខេត្តកំពត: បុរសជនជាតិអាមេរិកម្នាក់ត្រូវបានបញ្ជូនមកនាយកដ្ឋានអន្តោប្រវេសន៍ក្រោយចាប់ខ្លួនពីម្សិលម៉្ងៃនៅចំណុចផ្សារត្រីលើទឹកក្នុងភូមិ ១ ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ពាក់ព័ន្ធនឹងករណីបំពានផ្លូវភេទលើកុមារអាមេរិករួចភៀសខ្លួនមកដល់កម្ពុជា។

លោក ម៉ៅ ច័ន្ទមធុរិទ្ធិ ស្នងការនគរបាលខេត្តកំពតបានឲ្យដឹងពីម្សិលមិញថា ជនសង្ស័យនោះឈ្មោះ Samuel Douglas Lovejoy អាយុ ៣១ ឆ្នាំកាន់លិខិតឆ្លងដែនលេខ ៥៤៨-៥៥២៥០។ គេបានគេចមកកម្ពុជាក្នុងនាមជាភ្ញៀវទេសចរ និងស្នាក់នៅផ្ទះសំណាក់ក្រុងកំពតក្រោយប្រព្រឹត្តល្មើសនៅអាមេរិក។ លោកបន្តថា ការឃាត់ខ្លួននេះបានធ្វើឡើងក្រោយមានការស្នើឲ្យជួយពីសមត្ថកិច្ចអាមេរិក។ លោកថា៖ «យើងបានឃាត់ខ្លួនជនល្មើសតាមសំណើរបស់សហរដ្ឋអាមេរិកដែលគេបានឲ្យតម្រុយមកហើយយើងក៏ឃាត់ខ្លួនបានភ្លាមៗដែរ ហើយក៏មិនបានសួរនាំអ្វីដែរ។ ពួកខ្ញុំក៏បញ្ជូនជនសង្ស័យទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីដោះស្រាយតាមនីតិវិធី»។

លោក សុខ ផល អគ្គស្នងការរងនគរបាលជាតិ និងជាអគ្គនាយកនៃអគ្គនាយកអន្តោប្រវេសន៍បានឲ្យដឹងតាមសារអេឡិចត្រូនិកពីម្សិលមិញថា លោកមិនទាន់បានដឹងពីករណីនេះនៅឡើយទេ តែលោកថានឹងចាំទទួលប្រសិនបើមានមែននោះ។

លោក អ៊ុក ហៃសីឡា ប្រធាននាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍មិនអាចទាក់ទងសុំបញ្ជាក់ពីករណីនេះបានទេកាលពីម្សិលមិញដោយសារទូរស័ព្ទគ្មានអ្នកទទួល។

យ៉ាងណាក្តីករណីនេះមានពាក្យចចាមអារ៉ាមថា មានអ្នកជួយរត់ការឲ្យដោះលែងជនសង្ស័យវិញ ប៉ុន្តែលោក Josar David អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំកម្ពុជាមិនបានបញ្ជាក់បន្ថែមទេដោយឲ្យសួរទៅអាជ្ញាធរកម្ពុជា។ យ៉ាងណាក្តីលោក Josar David បញ្ជាក់ថា៖ «រដ្ឋាភិបាលអាមេរិកនៅមានទំនាក់ទំនងរឹងមាំ និងសហការជាមួយមន្ត្រីអនុវត្តច្បាប់នៅកម្ពុជា។ មន្ត្រីអនុវត្តច្បាប់អាមេរិកបានធ្វើការដោយជោគជ័យជាមួយសមភាគីកម្ពុជាក្នុងការចាប់មនុស្សខុសច្បាប់ បញ្ឈប់អ្នកជួញថ្នាំញៀន និងចាប់ខ្លួនអ្នករួមភេទជាមួយកុមារ និងឧក្រិដ្ឋកម្មផ្សេងទៀត»។

ចំពោះករណីថាមានអ្នករត់ការឲ្យដោះលែងនេះលោក ម៉ៅ ច័ន្ទមធុរិទ្ធិ ថា លោកមិនបានដឹងរឿងនេះទេដោយលោកបញ្ជាក់ថាសមត្ថកិច្ចលោកគ្រាន់តែសហការជាមួយអាមេរិក ដើម្បីឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅកាន់នាយកដ្ឋានអន្តោប្រវេសន៍ភ្លាមៗប៉ុណ្ណោះ៕

# ក្រសួងការងារ ជួយសង្គ្រោះស្ត្រី ខ្មែរឥស្លាមម្រើការងារតាមផ្ទះម្នាក់ទៀតហើយ បន្ទាប់ពីបាត់ខ្លួនជាង១៣ឆ្នាំ នៅអារ៉ាប៊ីសាអូឌីត ព្រោះចេញទៅធ្វើការតាមរយៈក្រុមហ៊ុនមិនស្របច្បាប់

http://nokorwatnews.com/ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៨

ភ្នំពេញ៖ ពលករិនីជនជាតិខ្មែរឥស្លាមម្នាក់ ត្រូវបានសង្គ្រោះឲ្យបានត្រឡប់មកដល់កម្ពុជាវិញនៅព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ បន្ទាប់ពីត្រូវបានចាញ់បោកក្រុមហ៊ុនខុសច្បាប់ក្នុងស្រុកមួយបញ្ជូនទៅ បម្រើការងារជាស្ត្រីមេផ្ទះនៅអារ៉ាប៊ីសាអូឌីត ហើយបាត់ដំណឹងសូន្យឈឹង ជាង១៣ឆ្នាំមកហើយ ។

តាមចម្លើយ ឲ្យដឹងពីស្ត្រី ជនរងគ្រោះ ឈ្មោះ អេង ពៅ អាយុ៣៨ ឆ្នាំ ជនជាតិខ្មែរឥស្លាមថា៖ ខ្ញុំទៅធ្វើការ នៅប្រទេសអារ៉ាប៊ីសាអូឌីត តាមរយៈក្រុមហ៊ុនរបស់ លោក អះម៉ាត់ យ៉ះយ៉ា អតីតរដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា តែឥឡូវលឺថា ត្រូវបានប្រមុខរដ្ឋស្តីទីចេញព្រះរាជក្រឹត្យឲ្យបញ្ចប់តំណែងកាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧កន្លងទៅហើយ ។ អ្នកស្រី អេង ពៅ អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរឥស្លាម មានទីលំនៅភូមិស្វាយឃ្លាំង ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ហើយត្រូវបានចាញ់បកក្រុមហ៊ុនមិនស្របច្បាប់ឲ្យទៅបម្រើការងារជាស្ត្រីមេផ្ទះនៅអារ៉ាប៊ីសាអូឌីត តាំងពីឆ្នាំ២០០៤ មកម្លេះ។

តាមការបញ្ជាក់របស់ លោក សាឡុក ម៉ាន អាយុ ៦១ឆ្នាំ ត្រូវជាប្តី បានឲ្យដឹងថា ដើម្បីជួយសង្គ្រោះដល់ប្រពន្ធដែលរងគ្រោះជាង១៣ឆ្នាំនេះ លោកបានរិះរកមធ្យោបាយគ្រប់បែបយ៉ាង ប៉ុន្តែគ្មានតំរុយទាល់តែសោះ ដែលកាលពីឆ្នាំ២០០៤នោះ រូបលោកក៏បានចេញទៅធ្វើការតាមក្រុមហ៊ុននោះដែរនៅអារ៉ាប៊ីសាអូឌីតជាអ្នកបើកបររថយន្ត ហើយនៅផ្សេងគ្នាពីប្រពន្ធ តែក្រោយមកក៏បាត់ដំណឹងសូន្យឈឹង រហូតចប់កុងត្រា ក៏ត្រឡប់មកស្រុកខ្មែរវិញ ដើម្បីរកមធ្យោបាយជួយរកប្រពន្ធ ព្រោះកាលខ្លួននៅបម្រើការងារនៅប្រទេសនេះ គឺបានខំប្រឹងរកមធ្យោបាយជួយដែរតែគ្មានលទ្ធផល។ ដោយមិនអស់ចិត្ត លោក ឡុក ម៉ាន បានសន្សំប្រាក់ចេញទៅធ្វើការនៅម្ចាស់ផ្ទះដដែល កាលពីឆ្នាំ២០១២ ដើម្បីបន្តរុករកប្រពន្ធ ហើយទីបំផុតក៏ប្រទះឃើញប្រពន្ធតាមការប្រឹងប្រែងមែន ប៉ុន្តែខ្លួនជាប្តីនៅតែគ្មានលទ្ធភាពជួយសង្គ្រោះប្រពន្ធដដែល ព្រោះស្ត្រីរងគ្រោះជាប្រពន្ធគ្មានលិខិតឆ្លងដែន រឺឯកសារ លិខិតស្នាមអ្វីទាំងអស់ ។

លោក សាឡុង ម៉ាន បានបន្តថា៖ រូបលោកខំធ្វើការងារទាំងលំបាក ព្រោះអាណិតប្រពន្ធកំសត់ ដែលកំពុងរស់នៅបម្រើគ្រួសារមួយគ្រាន់តែចិញ្ចឹមក្រពះ ទន្ទឹងរងចាំវាសនាថាតើថ្ងៃណាទើបខ្លួនត្រូវបានសង្គ្រោះវិញ ខណៈខ្លួនជាប្តីបានត្រឹមតែលួចទៅជួបប្រពន្ធម្តងម្កាលតែប៉ុណ្ណោះ ហើយអូសបន្លាយពេលរហូត៥ឆ្នាំក្រោយ គឺកាលពីខែគុម្ភៈ ឆ្នាំ២០១៧ ទើបសម្រេចលាចាកប្រពន្ធមកស្រុកខ្មែរដើររកជំនួយបន្តទៀត។ លោក ឡុក ម៉ាន បានបញ្ជាក់ដែរថា៖ ក្នុងនាមជាប្តី លោកមិនសុខចិត្តជាមួយនឹងទង្វើដែលក្រុមខាងលើបានធ្វើបែបនេះដាក់គ្រួសារ មិនតែប៉ុណ្ណោះក្រៅពីការមិនបានទទួលប្រាក់ខែរយៈពេល១៣ឆ្នាំ លោកក្នុងនាមជាប្តីក៏បានចំណាយទាំងពេលវេលា និងថវិកាមិនតិចម៉ឺនដុល្លារឡើយដើម្បីពុះពាររកប្រពន្ធរបស់ខ្លួន។ បន្ទាប់ពីមានការណែនាំពីមន្ត្រីនៅមូលដ្ឋានឲ្យមកទំនាក់ទំនងសុំអន្តរាគមន៍ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទើបចុងក្រោយនេះក៏សម្រេចចិត្តដើម្បីសុំជួបនិងអន្តរាគមន៍ពី លោក អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ក្រោមការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំក្រសួងជាពិសេស មានកិច្ចអន្តរាគមន៍យ៉ាងខ្លាំងផងដែរ ដោយលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណៈរដ្ឋអេហ្ស៊ីប មានលោក ស្មាន ម៉ាណាន ជាឯកអគ្គរាជទូត គឺភាគីក្រសួងទាំងពីរបានស្វះស្វែង និងអន្តរាគមន៍ជាមួយភាគីរដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត និងសង្គ្រោះស្ត្រីរងគ្រោះខាងលើ បានសម្រេចជាស្ថាពរ និងបានវិលត្រឡប់មកជួបក្រុមគ្រួសារវិញនៅព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨នេះហើយ។

នៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្ត្រីរងគ្រោះ ឈ្មោះ អេង ៣៧ បានបញ្ជាក់ឲ្យដឹងថា ក្នុងកំឡុងពេលជាង១៣ឆ្នាំមកនេះ គឺខ្លួនមិនដែលបានទទួលប្រាក់បៀវត្សនោះឡើយ ហើយក៏មិនដែលមានតំណាងភាគីក្រុមហ៊ុនដែលបញ្ជូនខ្លួនគាត់ទៅមកទាក់ទងសួរនាំពីការបាត់ខ្លួនរបស់គាត់ទេ និយាយរួមវាគឺជាការបោកប្រាស់ យកពលករទៅលក់ចោលសុទ្ធសាត ដែលក្នុងនាមជនរងគ្រោះមិនសុខចិត្តនូវទង្វើទុច្ចរិតមួយនេះ ដែលបានបៀតបៀនដល់ខ្លួនគាត់ដល់គ្រួសារ ហើយបង្កការខាតបង់យ៉ាងច្រើនដល់សេដ្ឋកិច្ចគ្រួសាររបស់គាត់ ជាពិសេសគឺបានធ្វើឲ្យគាត់ព្រាត់ប្រាស់គ្រួសារប្តីនិងកូនៗ រួមជាមួយសាច់ញាតិផងដែរ។ ទាំងស្ត្រីរងគ្រោះ និងក្រុមគ្រួសារបានអំពាវនាវឲ្យអាជ្ញាធរមានសមត្ថកិច្ច សូមមេត្តាជួយរកយុត្តិធម៌ជូនគ្រួសារគាត់ផង ជាពិសេសគឺទទួចស្នើឲ្យធ្វើយ៉ាងណាដោះស្រាយឲ្យជនបង្កហេតុមកទទួលខុសត្រូវលើទង្វើនេះផងដែរ។

សូមបញ្ជាក់ថា៖ នេះជាស្ត្រីរងគ្រោះទី២ហើយ ដែលត្រូវបានចាញ់បោក្រុមហ៊ុនតែមួយខាងលើ ហើយត្រូវបានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងការបរទេសកម្ពុជាបានផ្តល់អន្តរាគមន៍សង្គ្រោះឲ្យបានមកដល់កម្ពុជាវិញ ខណៈស្ត្រីរងគ្រោះទី១ ឈ្មោះ ម៉ាត់ សាណាស់ ហៅ (រ៉ទស់) ក៏ជួបបញ្ហាដូចគ្នា ដែលត្រូវបានក្រសួងទាំងពីរខាងលើ អន្តរាគមន៍ឲ្យបានត្រឡប់មកកម្ពុជាវិញដោយសុវត្ថិភាពកាលពី ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧ ។

តាមការទម្លាយឲ្យដឹងពី លោក អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈថា នៅមានស្ត្រីរងគ្រោះជាច្រើននាក់ទៀត កំពុងបាត់ខ្លួនកំឡុងពេលជាង១០ឆ្នាំ ខណៈខ្លះទៀតកំពុងទាក់ទងសុំអន្តរាគមពីក្រសួងជាបន្តបន្ទាប់ ដែលអ្នកទាំងអស់គ្នាសុទ្ធតែរងគ្រោះដោយការចាញ់បោកក្រុមហ៊ុនដដែលខាងលើ។ លោករដ្ឋលេខាធិការបានបន្តថា តាមពិតនៅអារ៉ាប៊ីសាអូឌីត មានពលករបរទេសដល់ទៅជាង១០លាននាក់ឯណោះ ដែលកំពុងបំពេញការងារដោយស្របច្បាប់ ហើយបានទទួលកម្រៃប្រាក់ឈ្នួលល្មមសមរម្យ និងបានចូលរួមជួយជ្រោមជ្រែងសេដ្ឋកិច្ចគ្រួសារ និងប្រទេសនិមួយៗដែលបញ្ជូនពលករទាំងនោះ។ តែដោយឡែកសម្រាប់ក្រុមហ៊ុនដែលមានបញ្ហាមិនស្របច្បាប់ទៅវិញ ដែលបានបង្កបញ្ហាស្មុគស្មាញ ដល់ពលករ ដល់ក្រសួងអាជ្ញាធរមានសមត្ថកិច្ច និងសង្គមទាំងមូលផងដែរ។

ដើម្បីធានាសុវត្ថិភាពពលករកម្ពុជា លោករដ្ឋលេខាធិការក្រសួងការងារ បានអំពាវនាវដល់ពលរដ្ឋកម្ពុជា ដែលមានបំណងទៅបំពេញការងារនៅក្រៅប្រទេស សូមផ្តោតសំខាន់ទៅលើក្រុមហ៊ុនណាដែលមានអជ្ញាបណ្ណត្រឹមត្រូវ ក្រុមហ៊ុនដែលមិនធ្លាប់លេចលឺបញ្ហាផ្សេងៗ ៕ ដោយ៖ សំរិត

## ផ្តន្ទាទោសស្ត្រីខ្មែរ និងបុរសចិនម្នាក់ ដាក់គុកម្នាក់ៗ ៨ឆ្នាំ រឿងនាំស្ត្រីខ្មែរលក់នៅចិន

http://www.yobminh.com/ បញ្ញា | January 11, 2018

ភ្នំពេញ៖ នៅព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨នេះ លោក អ៊ី ថាវរៈ ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការប្រកាសសាលក្រមផ្តន្ទាទោស ជនជាប់ចោទទី១ឈ្មោះ ស្រាប លី អេង ភេទ ស្រី អាយុ ៣៤ ឆ្នាំ និង ទី២ឈ្មោះ ជឿង ខាន់ឡុង ភេទប្រុស អាយុ៤៥ឆ្នាំ ជាជនជាតិចិន ដាក់ពន្ធនាគារកំណត់រយៈពេលម្នាក់ ៨ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្តទៅដើមបណ្តឹងឈ្មោះ យ.ប.ញ ភេទស្រី ចំនួន ២០លានរៀល ពីបទការនាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅប្រព្រឹត្តនៅរាជធានីភ្នំពេញ អំឡុងឆ្នាំ២០១៥ ដល់ ២០១៧ យោងតាមមាត្រា ១០ នៃច្បាប់ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

សូមបញ្ជាក់ថា នៅសវនាការកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧កន្លងទៅ ជនជាប់ចោទទាំង ២នាក់បានទទួលស្គាល់ថាពួកគេបពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការមែន។ គួររំលឹកថា ជនជាប់ចោទទាំង២នាក់ខាងលើ ត្រូវបានសមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃឃាត់ខ្លួនកាលពីព្រឹក ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៧ នៅបន្ទប់ជួលលេខ២៦ ផ្លូវលំ ក្បែរស្ទូនកាណាឌីយ៉ា ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ៕

# កត្តាជីវភាពជាមូលហេតុចម្បងដែលពលករធ្វើចំណាកស្រុកទៅប្រទេសថៃ

http://www.rfa.org/khmer/news/ ដោយ ម៉ៅ សុធានី 2018-01-11

ពលករខ្មែរមួយចំនួនដែលកំពុងធ្វើការនៅក្នុងប្រទេសថៃបានត្អូញត្អែរពីកត្តាជីវភាពថា ពួកគាត់ពិបាករកប្រាក់កម្រៃទើបសម្រេចចិត្តចាកចោលប្រពន្ធ និងកូនទៅធ្វើការជាកម្មករសំណង់ក្នុងប្រទេសថៃ។ ពួកគាត់អះអាងថា ការងារនៅក្នុងប្រទេសថៃ ពិបាកជាងការងារនៅក្នុងប្រទេសកំណើត ប៉ុន្តែដើម្បីអាចរស់បាន ពួកគាត់ត្រូវតែបង្ខំចិត្តរត់ទៅធ្វើការនៅថៃ ដោយសង្ឃឹមថា ថ្ងៃណាដែលមានប្រាក់គ្រប់គ្រាន់ អាចវិលទៅរស់នៅជួបជុំគ្នាក្នុងប្រទេសកំណើតវិញ។

ពលករខ្មែរមួយចំនួនបានលើកឡើងពីមូលហេតុដែលពួកគេទៅធ្វើការនៅប្រទេសថៃ ទាំងលំបាកលំបិន គឺដោយសារតែជីវភាពរស់នៅខ្វះខាត កសិផលលក់មិនគ្រប់ការហូបចុកប្រចាំឆ្នាំ ពិបាករកការងារនៅក្នុងស្រុក និងជំពាក់បំណុលធនាគារ។ ពួកគាត់រំលឹកថា ដើមឡើយពួកគាត់គឺជាកម្មករសំណង់ កម្មកររោងចក្រ និងកសិករធ្វើស្រែចម្ការ ប៉ុន្តែនៅពេលដែលការរស់នៅប្រចាំថ្ងៃបានប្រឈមនឹងជីវភាពកាន់តែលំបាកទៅៗ ពួកគាត់បានទៅធ្វើពលករនៅក្រៅប្រទេស ជាពិសេស គឺនៅប្រទេសថៃ ដោយសារនៅកៀកគ្នានឹងប្រទេសកំណើត។

ពលករម្នាក់ធ្វើការនៅទីក្រុងបាងកក ជាកម្មករសំណង់ ឈ្មោះ ភាន បានប្រាប់ពីមូលហេតុដែលលោកត្រូវចាកចោលគ្រួសារ គឺការទទួលបានប្រាក់កម្រៃតិចតួចសម្រាប់កម្មករសំណង់ក្នុងប្រទេស។ លោកថា នៅប្រទេសថៃរូបគាត់អាចទទួលបានប្រាក់កម្រៃខ្ពស់ជាងនៅប្រទេសខ្មែរ ប៉ុន្តែពិបាករស់នៅណាស់មិនដូចប្រទេសកំណើតខ្លួនឡើយ៖ «»។

ពលករម្នាក់ទៀតជាកម្មករសំណង់ក្នុងប្រទេសថៃដែរ ជាមួយពលករឈ្មោះ ភាន គឺលោកស្រី ឡាន អូន។ ក្នុងវ័យ ៣៨ឆ្នាំ លោកស្រី ឡាន អូន ត្អូញត្អែរថា លោកស្រីពិបាករកការងារនៅក្នុងប្រទេស ហើយការងារនៅតាមរោងចក្រខ្លះ មិនទទួលយកស្ត្រីដែលមានវ័យចំណាស់ដូចលោកស្រីទេ៖ «»។

ចំណែកពលករម្នាក់ទៀតដែលជាអតីតកសិករ បានប្រាប់ថា តម្លៃកសិផលបានធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ គឺជាដើមហេតុដែលគាត់សម្រេចចិត្តបោះបង់ចោលស្រែចម្ការ រត់មកធ្វើជាកម្មករសំណង់ដូចអ្នកផ្សេងទៀតដែរ។ លោកបន្តថា កម្មករសំណង់នៅប្រទេសថៃ ទទួលបានប្រាក់កម្រៃពីចន្លោះ ៤០០ ទៅ ៥០០បាត គឺប្រហាក់ប្រហែលនឹង ៥ ទៅ ៦ម៉ឺនរៀល៖ «»។

បើទោះជាកម្មករសំណង់ក្នុងប្រទេសថៃ ទាំងនេះអះអាងថា ពួកគាត់អាចរកបានប្រាក់កម្រៃច្រើនជាងការងារនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែពួកគាត់រៀបរាប់ទាំងទឹកភ្នែករលីងរលោងថា រាល់ថ្ងៃគាត់មិនចង់ចាកចោលគ្រួសារនៅស្រុកកំណើតនោះទេ។ ពលករខ្លះ បង្ខំចិត្តទុកកូនតូចៗ នៅជាមួយឪពុកម្ដាយដែលមានវ័យចាស់ជរាឲ្យមើលថែរក្សា ខណៈមានពលករខ្លះ គឺជាអ្នកទើបរៀបការហើយថ្មីថ្មោង។ ពួកគាត់ប្រាប់ថា គោលបំណងសំខាន់បំផុតមកធ្វើការនៅស្រុកគេ ដើម្បីរកប្រាក់ផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារនៅស្រុកកំណើត។

ពាក់ព័ន្ធនឹងពលករនៅប្រទេសថៃ ស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ បានប្រកាសផ្អាកផ្ដល់លិខិតឆ្លងដែន និងប័ណ្ណពលករធ្វើការងារក្រៅប្រទេសនៅសប្ដាហ៍ក្រោយនេះ។ ក្នុងសេចក្ដីជូនដំណឹងកាលពីទី១០ មករា ស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ បានឲ្យដឹងថា ការិយាល័យផ្ដល់លិខិតឆ្លងដែន ឬលិខិតធ្វើដំណើរ ហៅកាត់ថា TD និងប័ណ្ណពលករកម្ពុជា ទៅធ្វើការនៅបរទេស (OCWC) ប្រចាំនៅខេត្តប៉ាក់យ៉ង និងឆាក់ឈើងសាវ នឹងផ្អាកផ្ដល់លិខិតឆ្លងដែន និងប័ណ្ណធ្វើការដល់ពលករខ្មែរធ្វើការនៅក្រៅប្រទេសចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ នេះទៅ។

ស្ថានទូតកម្ពុជា បានអំពាវនាវទៅដល់ពលករខ្មែរកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ទាំងអស់ដែលមិនទាន់ដាក់ពាក្យស្នើសុំនោះ អាចបន្តទំនាក់ទំនង និងដាក់ពាក្យស្នើសុំដកឯកសាររបស់ខ្លួននៅលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការផ្ដល់ភាពស្របច្បាប់ដែលមានទីតាំងនៅស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ៕

# ពលរដ្ឋស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យជាច្រើននាក់ជិះគោយន្តឆ្លងដែនទៅធ្វើការនៅប្រទេសថៃ

http://www.rfa.org/khmer/news/ ដោយ សេក បណ្ឌិត 2018-01-11

ប្រជាពលរដ្ឋខ្មែររស់នៅតាមជាប់ព្រំដែនថៃ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ជាច្រើននាក់ បាននាំគ្នាជិះគោយន្តឆ្លងដែនតាមច្រករបៀងទាំងប្រចុះប្រចាន ដើម្បីទៅស៊ីឈ្នួលធ្វើការងារនៅប្រទេសថៃ ដោយខុសច្បាប់។ ការងារទាំងនោះ គឺអ្នកភូមិត្រូវធ្វើដំណើរចេញទៅនៅពេលព្រឹក ហើយត្រឡប់មកផ្ទះវិញពេលរសៀល និងអាចបានប្រាក់ចំណូលពីការងារឆ្លងដែននោះ ប្រមាណ ២ម៉ឺន ៥ពាន់រៀល (២៥.០០០) ក្នុងមួយថ្ងៃ។

អ្នកភូមិនៅរស់នៅជាប់ព្រំដែននៃស្រុកអូរជ្រៅ លើកឡើងថា ការស្វែងរកការងារធ្វើដោយឆ្លងដែនទាំងប្រចុះប្រចាននឹងគ្រោះថ្នាក់ និងប្រឈមនឹងផ្លូវច្បាប់នេះ មិនអាចបានប្រាក់ធ្វើមានបាននោះទេ គឺបានចំណូលគ្រាន់តែសម្រាប់ដោះទាល់ដើម្បីរស់មួយរយៈពេលប៉ុណ្ណោះ។ ពលរដ្ឋម្នាក់រស់នៅក្បែរច្រករបៀងទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ លោកស្រី សន ថៃល ថ្លែងថា សព្វថ្ងៃនេះយ៉ាងហោចណាស់មានពលរដ្ឋជិះគោយន្តឆ្លងដែនទៅធ្វើការនៅប្រទេសថៃ តាមច្រកព្រំដែនតាមគោយន្តប្រមាណ ៦គ្រឿង ក្នុងមួយថ្ងៃ ដោយពួកគាត់ចេញដំណើរនៅម៉ោង ៦ព្រឹក ហើយត្រឡប់មកផ្ទះវិញនៅម៉ោង ៦ល្ងាច។ លោកស្រីអះអាងទៀតថា មូលហេតុដែលអ្នកភូមិឆ្លងដែនទៅធ្វើការប្រទេសថៃ ដោយសារនៅស្រុកខ្មែរគ្មានការងារធ្វើ ហើយការនាំគ្នាជិះគោយន្តទៅស៊ីឈ្នួលនៅថៃ នោះគឺដកដំឡូងមី និងកាប់អំពៅឲ្យថៅកែថៃ ដោយថៅកែជនជាតិថៃ ចាំទទួលនៅច្រកព្រំដែនតែម្តង៖ «គេមានការងារបន្តបន្ទាប់មិនដាច់ទេ ពេលនេះគេទៅកាប់អំពៅរហូតដល់ចូលឆ្នាំខ្មែរ ពេលរួចបុណ្យចូលឆ្នាំទៅស៊ីឈ្នួលដាំបន្តទៀត។ អ្នកខ្លះមានម៉ែទៅយកកូនទៅជាមួយដែរ ហើយអ្នកនៅឆ្ងាយគេដេកនៅដីថៃ បើអ្នកជិតគេមកវិញ ក្មេងៗគេទៅអស់ នៅតែមនុស្សចាស់ៗទេក្នុងភូមិ»។

ចំណែកអ្នកលក់ចាប់ហួយនៅជាប់ព្រំដែនថៃ ក្បែរច្រករបៀងទំនប់ដាច់ លោកស្រី គឹម ស្រីតូច ឲ្យដឹងថា ចំនួនពលរដ្ឋឆ្លងដែលទៅធ្វើការនៅប្រទេសថៃ នៅតែមានច្រើន បើទោះបីជាក្រុមយុវជនមួយចំនួនបានទៅធ្វើការងាររោងចក្រនៅក្រុងប៉ោយប៉ែត ខ្លះក្តី។ លោកស្រីបន្ថែមថា នៅតាមផ្ទះរបស់ពលរដ្ឋតំបន់ព្រំដែនមានសភាពស្ងប់ស្ងាត់នៅពេលថ្ងៃ និងមានសភាពអ៊ូអរឡើងវិញនៅពេលរសៀល និងពេលព្រឹក ព្រោះជាពេលដែលអ្នកភូមិត្រឡប់មកពីធ្វើការនៅប្រទេសថៃ។ លោកស្រីឲ្យដឹងទៀតថា ចំពោះពលរដ្ឋដែលទៅធ្វើនៅប្រទេសថៃ ដោយអ្នកខ្លះធ្វើការគិតតម្លៃឈ្នួលមួយថ្ងៃដែលមានតម្លៃប្រមាណពី ២ម៉ឺន ៥ពាន់ ទៅ ៣ម៉ឺនរៀលក្នុង (៣០.០០០) និងអ្នកខ្លះទៀតមៅការកាប់អំពៅរាប់បាច់ឲ្យថៃ ជាដើម៖ «អ្នកទៅស៊ីឈ្នួលថៃ គេតែងប្រាប់ខ្ញុំថាគេកាប់អំពៅរាប់បាច់ ដោយ ១០០បាច់បានប្រមាណ ១ម៉ឺន ៥ពាន់រៀល។ ឥឡូវគេទៅធ្វើការរោងចក្រខ្លះ បើអត់ទាន់មានរោងចក្រទៅច្រើន បើមិនទៅស៊ីឈ្នួលថៃនៅនេះអត់មានមុខរបរអីរកប្រាក់ចំណូលទេ»។

តំបន់ដែលពលរដ្ឋទៅធ្វើការក្នុងទឹកដីថៃនោះ គាត់ច្រើនគឺនៅជាប់នឹងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលនៅមិនឆ្ងាយពីព្រំដែនខ្មែរ-ថៃ ប៉ុន្មាននោះទេ ដោយកន្លែងខ្លះចម្ងាយប្រមាណពី៣ ទៅ ៥គីឡូម៉ែត្រពីច្រកព្រំដែន។ ម្យ៉ាងទៀតពលរដ្ឋភាគច្រើនធ្វើដំណើរដោយគោយន្ត និងអ្នកខ្លះទៀតដោយម៉ូតូផ្ទាល់ខ្លួន ជិះតាមច្រករបៀងទំនប់ដាច់ចូលទៅដល់ប្រទេសថៃ តែម្តង។

មន្ត្រីឃោជាប្រចាំការនៅច្រកទំនប់ដាច់ លោក រ័ត្ន នាសនា មានប្រសាសន៍ថា ប្រជាពលរដ្ឋឆ្លងដែលទៅធ្វើការប្រទេសថៃ តាមច្រករបៀងប្រចាំការមានចំនួនច្រើនជាងគេក្នុងតំបន់ច្រកព្រំដែននៃស្រុកអូរជ្រៅ គឺមានប្រមាណពី ៣០ ទៅ ៦០នាក់ក្នុងមួយថ្ងៃ ចំណែកឯច្រកព្រំដែនផ្សេងទៀត មានប្រមាណពី ២០ ទៅ ៣០នាក់ក្នុងមួយថ្ងៃ។ លោកអះអាងទៀតថា ចំពោះពលរដ្ឋដែលឆ្លងដែន អ្នកខ្លះមកពីខេត្តឆ្ងាយ និងមួយចំនួន គឺជាប្រជាពលរដ្ឋរស់នៅតំបន់ព្រំដែន ហើយរដូវដែលសំបូរការងារច្រើន គឺចន្លោះពីខែវិច្ឆិកា ដល់មេសា ជារៀងរាល់ឆ្នាំ៖ «ពួកគាត់ទៅអំពៅនៅជិតៗព្រំដែននេះឯង ពួកគាត់មិនហ៊ានទៅឆ្ងាយទេ ព្រោះអត់មានលិខិតឆ្លងដែនធ្វើការងារទេ ខ្លាចគេចាប់។ ខ្លះបានច្រើន ខ្លះ

បានតិច ដោយអ្នកខ្លះមេការបានច្រើន ប្រមាណពី៤ ទៅ ៥ម៉ឺនរៀល ចំណែកអ្នកដែលមិនចេះអី មានប្រហែល ៣ម៉ឺនរៀលក្នុងមួយថ្ងៃ ហើយខែច្រូតគាត់អាចរកបានច្រើនជាងនេះ ដោយមួយថ្ងៃបានប្រមាណ ៥ម៉ឺនរៀល»។ លោកបន្ថែមទៀតថា ប្រមាណ ៦ខែចុងក្រោយនេះ ពុំមានករណីសមត្ថកិច្ចចាប់ពលរដ្ឋឆ្លងដែនទៅធ្វើការងារព្រឹកត្រឡប់មកវិញល្ងាចនោះទេ ទំនងដោយសារភាគីថៃយល់ថា ពួកគាត់ធ្វើការមិនឆ្ងាយពីព្រំដែនខ្មែរ ហើយត្រូវវិលត្រឡប់មកផ្ទះវិញ។ ម្យ៉ាងទៀតពួកគាត់ក៏ពុំបានបង្កបញ្ហាដល់ពលរដ្ឋថៃ ដែរ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា កត់សំគាល់ថា ប្រជាពលរដ្ឋទៅធ្វើការវិលល្ងាចនៅប្រទេសថៃ មានគ្រប់ច្រករបៀងក្នុងខេត្តបន្ទាយមានជ័យ ដោយមួយកន្លែងមានប្រមាណ ២០ ទៅ ៧០នាក់។ មន្ត្រីសង្គមស៊ីវិលរូបនេះ លើកឡើងថា ពលរដ្ឋឆ្លងដែនទៅប្រទេសថៃ បើទោះបីជាទៅព្រឹកវិលល្ងាចក៏ដោយ គឺពួកគាត់ប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត ព្រមទាំងប្រឈមនឹងការចាប់ដាក់គុកពីសមត្ថកិច្ចថៃ គ្រប់ពេល ព្រោះពួកគាត់ឆ្លងដែនដោយខុសច្បាប់៖ «កន្លងមកយើងមានការព្រួយបារម្ភពីសុវត្ថិភាពរបស់ពួកគាត់ មួយវិញទៀតយើងគិតថា ជាការសោកស្ដាយមួយនៅតាមព្រំដែនជាប់ថៃដែរបែរជាយើងក្លាយជាកម្មកររបស់គេ គួរតែយើងជាអ្នកជំនួញដូចគេដែរ ហើយយើងគួរតែខ្មាសប្រទេសជិតខាងផង»។

ខេត្តជាប់ព្រំដែនថៃ ដែលពលរដ្ឋខ្មែរ និយមឆ្លងដែនទៅស្វែងរកការងារធ្វើនៅប្រទេសថៃ មានដូចជាខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ជាដើម ដោយសារខេត្តទាំងនោះមានច្រករបៀងច្រើន ដែលធ្វើឲ្យពលរដ្ឋងាយស្រួលក្នុងការឆ្លងទៅក្រៅប្រទេស។ លោក ស៊ុំ ច័ន្ទគា មានប្រសាសន៍ថា ដើម្បីកាត់បន្ថយកុំឲ្យពលរដ្ឋឆ្លងដែនទៅធ្វើការនៅប្រទេសថៃ លុះត្រាតែរដ្ឋាភិបាលកម្ពុជាបង្កើនការងារនៅតាមព្រំដែនឲ្យបានច្រើន ហើយត្រូវស្វែងរកទីផ្សារលក់កសិផលរបស់កសិករឲ្យមានតម្លៃសមរម្យទើបពួកគាត់អាចកាត់បន្ថយមិនធ្វើចំណាកស្រុកទៅក្រៅប្រទេស៕

## ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៨

## ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ៖ ដើម្បីឲ្យប្រតិបត្តិការទទួលបានជោគជ័យមន្ត្រីអនុវត្តច្បាប់ត្រូវមានសមត្ថភាព ជំនាញ និងការយល់ដឹងខ្ពស់ផ្នែកច្បាប់

http://cambodiapolice.com/ 10:57 am 15 មករា 2018

**ភ្នំពេញ ៖** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការអនីតិជន លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង លើកឡើងថា ដើម្បីឲ្យប្រតិបត្តិការទទួលបានជោគជ័យមន្ត្រីអនុវត្តច្បាប់ត្រូវមានសមត្ថភាព ជំនាញ និងការយល់ដឹងខ្ពស់ផ្នែកច្បាប់ ។ នៅក្នុងវគ្គបណ្ដុះបណ្ដាល ស្ដីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ នាព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការអនីតិជន មានប្រសាសន៍ថា វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណងសំខាន់ គឺដើម្បីពង្រឹងសមត្ថភាពផ្នែកច្បាប់ និងជំនាញក្នុងការប្រើប្រាស់អាវុធ ដូចនេះដើម្បីឲ្យប្រតិបត្តិការក្នុងការបង្ក្រាបបទល្មើសទទួលជោគជ័យទៅបានកម្លាំងនគរបាលត្រូវមានសមត្ថភាព និងការយល់ដឹងពីនីតិវិធី ព្រមទាំងការអនុវត្តជាក់ស្ដែងលើបច្ចេកទេស ការប្រើប្រាស់ឧបករណ៍ សម្ភារៈ ដែលត្រូវបម្រើឲ្យការងារប្រតបត្តិការ ក្នុងការចាប់ចងជនល្មើស សង្គ្រោះជនរងគ្រោះ និងវិធីសាស្ត្រការពារខ្លួន ។

លោកឧត្តមសេនីយ៍ទោបន្តថា អំពើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារបានប្ដូររូបភាពពីចំហរមកជាការលួចលាក់ ហើយជ្រកក្រោមរូបភាពស្របច្បាប់ ដូច្នេះហើយមន្ត្រីរបស់យើងត្រូវមានសមត្ថភាពជំនាញទាំងការស៊ើបអង្កេត និងប្រមូលព័ត៌មាន ដើម្បីឈានទៅដល់ការចាប់ខ្លួនជនល្មើស និងជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។ លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង សង្ឃឹមថា ឆ្លងតាមវគ្គបណ្ដុះបណ្ដាលនៅពេលនេះ ពិតជាបានផ្ដល់នូវចំណេះ

ដឹងបទពិសោធន៍ថ្មីៗតាមរយៈ នៃការហ្វឹកហាត់ផ្ទាល់សំដៅរកភាពរីកចម្រើន និងសហប្រតិបត្តិការល្អ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ពិសេសការបង្ក្រាបចាប់ជនសង្ស័យបញ្ជូនទៅតុលាការ និងជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។

ក្នុងឱកាសនេះដែរ លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការមេត្រីអន្តរជាតិ (AIMSWAT) ដែលជានិច្ចកាលតែងតែមានកិច្ចសហប្រតិបត្តិការគ្នាកន្លងមកបានល្អ ជាមួយនាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ទាំងការប្រមូលព័ត៌មានស៊ើបអង្កេត ប្រមូលភស្តុតាង ការបង្ក្រាប និងការជួយសង្គ្រោះជនរងគ្រោះ ហើយសង្ឃឹមជឿជាក់ថា អង្គការមេត្រីអន្តរជាតិ (AIMSWAT) នៅតែបន្តកិច្ចសហប្រតិបត្តិការលើការងារស៊ើបអង្កេត ក៏ដូចជាការជួយគាំទ្រលើការងារពង្រឹងសមត្ថភាព និងការផ្តល់សម្ភារៈដល់នគរបាលជាតិកម្ពុជាបន្ថែមទៀត ។ លោកឧត្តមសេនីយ៍ទោ ក៏បានផ្តាំផ្ញើឲ្យសិក្ខាកាមទាំងអស់ត្រូវគោរពវិន័យឲ្យបានម៉ឺងម៉ាត់ ត្រូវប្រើពេលវេលាដ៏មានតម្លៃនេះក្រេបយកចំណេះដឹង និងបទពិសោធន៍ថ្មីទៅបម្រើអង្គភាពរបស់ខ្លួនទទួលបានជោគជ័យ ៕

## កម្ពុជាគ្រោងបញ្ជូន កម្មសិក្សាការី ១000នាក់ ទៅបំរើការនៅ ប្រទេសជប៉ុន

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ១៥ មករា ២០១៨ 12:45 ដោយ: ហង្ស ទេព ID:049

ភ្នំពេញ៖តាមរយៈការចុះហត្ថលេខាលើ អនុស្សារណៈយោគយល់គ្នា រវាង ក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ ជាមួយ ខេត្តអ៊ីហេមិ កម្ពុជាគ្រោងនឹងបញ្ជូន កម្មសិក្សា ការីរបស់ខ្លួនចំនួន១០០០នាក់ ទៅបំរើការងារ នៅប្រទេសជប៉ុន ក្នុងឆ្នាំ២០១៨នេះ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានមានប្រសាសន៍ ប្រាប់ក្រុមអ្នកសារព័ត៌មាន នៅថ្ងៃទី១៥មករានេះ ក្រោយពិធីចុះMOU ថាជំហានដំបូងនេះកម្ពុជា នឹងបញ្ជូនកម្មសិក្សាការីប្រមាណ ១០០០នាក់ បន្ទាប់មកនឹងពិនិត្យលទ្ធភាពដើម្បីបញ្ជូនជាបន្តបន្ទាប់តាមតម្រូវការរបស់ក្រុមហ៊ុននៅជប៉ុន និងទីភ្នាក់ងារបញ្ជូនរបស់កម្ពុជា។ លោក អ៊ិត សំហេង បញ្ជាក់ថា បច្ចុប្បន្នកម្មសិក្សាការីកម្ពុជាកំពុងបំរើការងារនៅប្រទេសជប៉ុន ប្រមាណជាង ៦ពាន់នាក់ ហើយនៅឆ្នាំក្រោយទៀតនឹងខិតខំ ធ្វើយ៉ាងណាឱ្យចំនួនពលករនៅជប៉ុនមានការកើនឡើង អាចរហូតដល់មួយម៉ឺននាក់។ លោករដ្ឋមន្ត្រីបញ្ជាក់ថា កម្មសិក្សាការីកម្ពុជាក្រោយពីបានទៅបំរើការងារនៅប្រទេសជប៉ុន ពួកគេនឹងទទួលបានប្រាក់បៀវត្សខ្ពស់ អាចចាប់ពី១០០០ដុល្លារ ឡើងទៅក្នុង១ខែ ក្រៅពីនោះ ពួកគេក៏នឹងទទួលបានបទពិសោធន៍ ចំណេះដឹង ភាសារ ទំនៀមទំលាប់វប្បធម៌ និងការស្វែងយល់ពីការរស់នៅពីគ្នាទៅវិញទៅមក ដើម្បីបង្កើនសមត្ថភាពបន្ថែម ក្រោយពេលត្រឡប់មកប្រទេសវិញ។

ចំណែកលោក ណាកាម៉ូរ៉ា អភិបាលខេត្ត អ៊ីហេមិ បានអះអាងថា ក្រោពីបានមកដល់ប្រទេសកម្ពុជា ដោយផ្ទាល់ទើបលោកដឹងថា កម្ពុជាកំពុងមានការរីកចំរើន ហើយប្រទេសមានកំណើនសេដ្ឋកិច្ចល្អ ប្រជាជនមានភាពរួសរាយរាក់ទាក់ មានកម្លាំងពលកម្មច្រើន និងមានការតស៊ូខ្ពស់ ដែលប្រទេសជប៉ុនកំពុងតែត្រូវការ។ ពិសេសប្រជាជនកម្ពុជាមានការស្រលាញ់និងចូលចិត្ត ប្រជាជននិងប្រទេសជប៉ុនផងដែរ ដែលពួកគេអាចរស់នៅធ្វើការជាមួយគ្នាបានយ៉ាងល្អពីពេលបច្ចុប្បន្ននិងទៅថ្ងៃខាងមុខ។ ចំពោះលក្ខខណ្ឌការងារវិញលោកថា ជប៉ុនមិនមានតម្រូវការជំនាញខ្ពស់ ឬ ច្បាស់លាស់ពេកទេ សំខាន់កម្មសិក្សាការី ត្រូវចេះភាសាបឋម ជំនាញបឋម ដែលភាគីជប៉ុន និងកម្ពុជា បានឯកភាពគ្នាមុនពេលបញ្ជូន។ នៅពេលទៅដល់ ក៏នឹងមានការតាមមើលថែទាំ ពួកគាត់យ៉ាងល្អបន្ថែមទៀត។ លោកបញ្ជាក់ថា សម្រាប់កម្មសិក្សាការីកម្ពុជា ដែលត្រូវទៅបំរើការងារនៅខេត្ត អ៊ីហេមិ មានដូចជា ផ្នែកកសិកម្ម ឧស្សាហកម្មនេសាទ និងសេវាកម្មមួយចំនួនទៀត៕

## រដ្ឋមន្ត្រី អ៊ិត សំហេង៖ កម្ពុជានឹងបញ្ជូនកម្មសិក្សាការីទៅធ្វើកម្មសិក្សានៅជប៉ុន ឲ្យបានរាប់ម៉ឺននាក់ ខណៈជប៉ុនក៏ពេញចិត្តការងាររបស់កម្ពុជាផងដែរ

http://www.freshnewsasia.com/ 2018-01-15

**(ភ្នំពេញ)៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានថ្លែងថា កម្ពុជានឹងជំរុញឲ្យមានការជ្រើសរើស បណ្ដុះបណ្ដាល និងបញ្ជូនកម្មសិក្សាការីរបស់ខ្លួន ទៅធ្វើការកម្មសិក្សា និងបម្រើការងារនៅជប៉ុនឲ្យបានរាប់ម៉ឺននាក់នាប៉ុន្មានឆ្នាំខាងមុខខណៈបច្ចុប្បន្នកម្មសិក្សាការីកម្ពុជានៅជប៉ុនមានចំនួន៦១៧១នាក់។ លោករដ្ឋមន្ត្រីថ្លែងបែបនេះ ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈ ស្ដីពីការបញ្ជូនកម្មសិក្សាការីបច្ចេកទេសកម្ពុជា ទៅធ្វើកម្មសិក្សា និងធ្វើការងារនៅខេត្តអិហ៊ិមិ ប្រទេសជប៉ុន ដែលធ្វើឡើងរវាងលោក សេង សក្ដា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ ជាមួយលោក មីណូរ៉ូ ណូដា ប្រធានសមាគមសហជីពកម្មសិក្សាការីបរទេសខេត្តអិហ៊ិមិ នាព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ។

លោកបានឲ្យដឹងថា បច្ចុប្បន្នកម្ពុជាបានបញ្ជូនពលករ និងកម្មសិក្សាការីទៅធ្វើកម្មសិក្សា និងបម្រើការងារនៅប្រទេសចំនួន៦ មានប្រទេសថៃ ជប៉ុន កូរ៉េខាងត្បូង ម៉ាឡេស៊ី សិង្ហបុរី និងនៅតំបន់រដ្ឋបាលពិសេសហុងកុង ដែលមានពលករ និងកម្មសិក្សាការីសរុបប្រមាណ ១,២០០,០០០នាក់ ដោយក្នុងមួយឆ្នាំៗ ពួកគេបានផ្ញើថវិកាជាង២ពាន់លានដុល្លារអាមេរិក ដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារ ក៏ដូចជាចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិផងដែរ។ លោក អ៊ិត សំហេង បានបន្តថា កម្ពុជាបានបញ្ជូនកម្មសិក្សាការីរបស់ខ្លួន ទៅធ្វើកម្មសិក្សា និងបម្រើការងារនៅជប៉ុន ចាប់ពីឆ្នាំ២០០៧ ហើយរហូតដល់ចុងឆ្នាំ២០១៧ កម្មសិក្សាការីកម្ពុជានៅប្រទេសជប៉ុនមានចំនួន ៦១៧១នាក់ហើយ។ លោកបានថ្លែងយ៉ាងដូច្នេះថា «**ខ្ញុំក៏មានមហិច្ឆតា ចង់ឃើញកម្ពុជាមានកម្មសិក្សាការីនៅជប៉ុនកាន់តែច្រើន មានពលរដ្ឋរបស់ខ្លួននៅជប៉ុន ទៅធ្វើការកាន់តែច្រើន ហើយជាពិសេសនៅខេត្តអិហ៊ិមិ ដែលយើងចុះអនុស្សរណៈនាពេលនេះ។ ក្នុងប៉ុន្មានឆ្នាំខាងមុខ នៅពេលដែលការអនុវត្តរបស់យើងរលូនទៅមុខ ខ្ញុំក៏សង្ឃឹមថា ចំនួនកម្មសិក្សាការីកម្ពុជាឡើងទៅដល់រាប់ម៉ឺននាក់ មិនមែនរាប់ពាន់ទៀតទេ**»។

តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ ជាមួយសមាគមសហជីពកម្មសិក្សាការីបរទេសខេត្តអិហ៊ិមិ នាពេលនេះ លោករដ្ឋមន្ត្រីបានបង្ហាញភាពជឿជាក់ថា និយោជកជប៉ុននឹងពិនិត្យ និងទទួលយកកម្មសិក្សាការីកម្ពុជាទៅធ្វើកម្មសិក្សា និងបម្រើការនៅទីនោះ ឲ្យបានច្រើនថែមទៀត។

ជាមួយគ្នានោះ អភិបាលខេត្តអិហ៊ិមិ នៃប្រទេសជប៉ុន លោក ណាកាមូរ៉ា តាគិហ៊ីរ៉ា បានបញ្ជាក់ថា តាមរយៈការទទួលកម្មសិក្សាកការីកម្ពុជាឲ្យទៅធ្វើកម្មសិក្សា និងបម្រើការងារនៅជប៉ុន ក៏ដូចជានៅខេត្តអិហ៊ិមិ កន្លងមក ឃើញថា កម្មសិក្សាការីកម្ពុជាមានភាពស្មោះត្រង់ មានភាពអំណត់អត់ធន់នឹងការងារ មានភាពរួសរាយរាក់ទាក់ ពិសេសមានស្មារតីយកចិត្តទុកដាក់នឹងការងារជាងកម្មសិក្សាការីជនជាតិដទៃ ពោលនិយោជកនៅជប៉ុន មានការពេញចិត្តចំពោះកម្មសិក្សាការីកម្ពុជាយ៉ាងខ្លាំង ហើយលោកក៏បានប្ដេជ្ញានឹងជំរុញនិយោជកនៅជប៉ុន បង្កើនការទទួលកម្មសិក្សាការីកម្ពុជាឲ្យបានច្រើនទៀតផងដែរ៕

## អាជ្ញាធរថៃ,កំពុងបើកយុទ្ធនាការប្រយុទ្ធ ប្រឆាំង អំពើជួញដូរមនុស្ស និងពលករចំណាកខុសច្បាប់

http://www.prakpheaktra.com/ January 12, 2018

លោកឧបនាយករដ្ឋមន្ត្រីថៃ បានប្រកាសដាក់បញ្ជាឲ្យ មន្ត្រីថ្នាក់ក្រោមចាត់វិធានការ លើករណីអំពើជួញដូរមនុស្ស និងជនអន្តោប្រវេសន៍ខុសច្បាប់នៅក្នុងប្រទេសថៃ។ កាលពីថ្ងៃព្រហស្បតិ៍ទី11 ខែមករា ឆ្នាំ2018 កន្លងទៅនេះលោកឧបនាយករដ្ឋមន្ត្រីថៃ ប្រាវីត វង្សសុវណ្ណ បានប្រកាសបញ្ជាឱ្យកម្លាំងអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រោមទូទាំង

ប្រទេស ចុះបង្ក្រាបករណីអំពើជួញដូរមនុស្សខុសច្បាប់ និងជនអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងស្នាក់នៅក្នុងប្រទេសថៃ ដោយគ្មានច្បាប់អនុញ្ញាតអោយមានប្រសិទ្ធភាពខ្ពស់បំផុត។ ព្រមទាំងប្រកាសចាត់វិធានយ៉ាងដាច់ខាតចំពោះបុគ្គលណាដែលប្រព្រឹត្តិបទល្មើសលើជួញដូរមនុស្ស និងគ្រប់គ្រងពលករចំណាកស្រុកខុសច្បាប់ដោយគ្មានការលើកលែងឡើយ។

**ក្រុងប៉ោយប៉ែត,ត្រៀមបើកទីតាំងត្រួតសញ្ជាតិ,ផ្តល់លិខិតឆ្លងដែន(TD) ជូនពលករកម្ពុជា ក្នុងប្រទេសថៃ**

http://www.prakpheaktra.com/ January 13, 2018

ដំណឹងពលករឆ្លងដែនចំពោះបងប្អូនពលករខ្មែរ ដែលមិនបានត្រួតសញ្ជាតិ នៅពេលនេះឆាប់ៗខាងមុខនេះនៅក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងបើកកន្លែងផ្តល់លិខិតឆ្លងដែនធ្វើការ(TD) ជូនបងប្អូនពលករខ្មែរនៅក្នុងប្រទេសថៃ។ យោងតាមប្រភពព័ត៌មានក្រៅផ្លូវការមួយបានអោយដឹងថា ចាប់តាំងពីថ្ងៃទី15 ខែមករា ឆ្នាំ2018 ខាងមុខនេះ ទីតាំងបញ្ជាក់អត្តសញ្ញាណផ្តល់លិខិតឆ្លងដែនថ្មីជូនបងប្អូនពលករខ្មែរកំពុងធ្វើការនៅក្នុងប្រទេសថៃ និងចាប់ផ្តើមបើកអោយដំណើរការនៅក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៃប្រទេសកម្ពុជាយើង។ ទីតាំងខាងលើនេះ បើកធ្វើលិខិតឆ្លងដែនជូនចំពោះតែបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនិងស្នាក់នៅក្នុងប្រទេសថៃ ហើយមានប័ត្រស៊ីជម្ពូ តែមិនទាន់បានបញ្ជាក់អត្តសញ្ញាណឬហៅថាត្រួតសញ្ជាតិតែប៉ុណ្ណោះ។ ដូច្នេះបើសិនជាបងប្អូនពលករខ្មែរដែលកំពុងរង់ចាំត្រួតសញ្ជាតិតែមិនទាន់បានលេខរៀង សូមរង់ចាំតាមដានស្តាប់ព័ត៌មានបន្តទៀតហើយបើសិនជាដំណឹងនេះជាការពិតមែននោះបងប្អូននឹងមានសង្ឃឹមត្រួតសញ្ជាតិ ទាន់ពេលវេលាដែលប្រទេសថៃបានកំណត់។

**ពលរដ្ឋខ្មែរ,រស់នៅក្នុងខេត្តសៀមរាប 1នាក់ត្រូវអាជ្ញាធរថៃ ចាប់ខ្លួនក្នុងករណីបទល្មើសព្រៃឈើ**

http://www.prakpheaktra.com/ January 13, 2018

ពលរដ្ឋកម្ពុជា1នាក់ រស់នៅក្នុងខេត្តសៀមរាប ត្រូវបានកម្លាំងអាជ្ញាធរខេត្តសុរិន្ទ ប្រទេសថៃ ចាប់ខ្លួនក្នុងករណីបទល្មើសព្រៃឈើ នៅក្នុងប្រទេសថៃ។ កាលពីថ្ងៃសុក្រទី12 ខែមករា ឆ្នាំ2018 អាជ្ញាធរខេត្តសុរិន្ទប្រទេសថៃ បានបើកធ្វើសន្និសីទកាសែត ក្នុងករណីចាប់ខ្លួនពលរដ្ឋខ្មែរ 1នាក់ ឈ្មោះ ឡាយ សីហា ភេទប្រុស អាយុ 29ឆ្នាំ ស្រុកកំណើតរស់នៅក្នុងភូមិដកប៉ូ ឃុំស្លក្រាម ស្រុកស្លក្រាម ខេត្តសៀមរាប បន្ទាប់ពីព្រឹត្តិបទល្មើសរួមជាមួយបក្សពួកដឹកជញ្ជូនឈើគ្រញូងចំនួន 4ដុំ នៅក្នុងខេត្តសុរិន្ទ កាលពីយប់ថ្ងៃពុធទី10 ខែមករា ឆ្នាំ2018 កន្លងទៅ។ បច្ចុប្បន្នពលករខ្មែរខាងលើត្រូវបានកម្លាំងអាជ្ញាធរថៃកំពុងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីអោយធ្វើការដាក់ទោសតាមផ្លូវច្បាប់។

**ត្រៀមខ្លួន, នាំគ្នានៅត្រួតសញ្ជាតិធ្វើប៉ាស្ព័រ(TD) នៅក្នុងប្រទេសកម្ពុជាយើង**

http://www.prakpheaktra.com/ January 15, 2018

នៅសប្តាហ៍ខាងមុខនេះបងប្អូនពលករខ្មែរកំពុងធ្វើការនៅក្នុងប្រទេសថៃ ប្រហែលជាមានអារម្មណ៍ធូរស្រាលជាងមុន បន្ទាប់ពីក្រសួងការងារកម្ពុជា បើកការិយាល័យបញ្ជាក់អត្តសញ្ញាណថ្មីនៅក្នុងទឹកដីកម្ពុជាចំនួនបីកន្លែង ១-នៅក្រុងភ្នំពេញ ២-នៅក្នុងខេត្តបាត់ដំបង ៣-នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ យោងតាមប្រភពព័ត៌មានក្នុងប្រទេសកម្ពុជាបានចុះផ្សាយនាពេលកន្លងមកបានអោយដឹងថា ទីតាំងបីកន្លែងខាងលើនិងចាប់បើកដំណើរការនៅថ្ងៃទី១៥ខែមករាឆ្នាំ២០១៨នេះ។ ចំពោះបងប្អូនពលករខ្មែរនៅធ្វើការនៅក្នុងប្រទេសថៃ អាចទៅបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័របាននោះត្រូវមានលិខិតបញ្ជាក់ទំនាក់ទំនងរវាងពលករ និងថៅកែថៃ, និងប័ត្រស៊ីជម្ពូ ដែលមានសុពលភាពផុតកំណត់នៅថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៨។

ចំពោះឯកសារះ

1.ប័ត្រប្រាក់ឆាឈុនថៅកែ(ច្បាប់ថតចម្លង)

2.តៀ្បតបានថៅកែ(ច្បាប់ថតចម្លង)

3.ណាំងស៊ឺរ៉ាប់រ៉ងពីក្រុមហ៊ុន(ចំពោះករណីធ្វើការនៅតាមរោងចក្រ, សហគ្រាស)

4.ប៉ៃកូតា
5.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, សៀវភៅគ្រួសារ, សំបុត្រកំណើត. ផ្សេងទៀត
6.ប័ត្រស៊ីជម្ពូ, លិខិតលុងបៀនថ្មី
7.លិខិតម៉បអំណាចពីថៅកែ
8.លិខិតធ្វើដំណើរទៅបញ្ជាក់អត្តសញ្ញាណ

ក្រោយពីបងប្អូនពលករខ្មែរបានបញ្ជាក់អត្តសញ្ញាណនៅទីតាំងក្នុងប្រទេសកម្ពុជាយើងរួច គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជានឹងផ្តល់ជូនលិខិតឆ្លងដែនធ្វើការ(TD) ដើម្បីអោយបងប្អូនយកទៅវ៉ៃត្រាវីសារ និងច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃ។

## ចង់ប្តូរថៅកែថ្មី,ចង់ប្តូរការងារថ្មី ត្រូវអានអត្ថបទនេះ(ពលករខ្មែរ)

http://www.prakpheaktra.com/ January 15, 2018

ចង់ប្តូរថៅកែថ្មី និងប្តូរការងារថ្មី, សូមអានអត្ថបទខាងក្រោមនេះ ដើម្បីឲ្យបានយល់ច្បាស់ អំពីការប្តូរថៅកែថ្មីទាំងពលករប័ត្រស៊ីជម្ពូ, ពលករ MOU, ពលករលុងបៀនថ្មី។ ក្នុងពេលបច្ចុប្បន្ននេះបញ្ហាប្តូរថៅកែរបស់ពលករខ្មែរធ្វើការនៅក្នុងប្រទេសថៃ កំពុងតែកើនឡើងជាបន្តបន្ទាប់ដោយសារតែបញ្ហាមួយចំនួន។ ក៏ប៉ុន្តែអ្វីដែលពលករខ្មែរទាំងអស់នោះមិនទាន់បានយល់ច្បាស់នោះគឺលក្ខខ័ណ្ឌច្បាប់នៃការប្តូរថៅកែថ្មី ដែលក្រសួងការងារថៃបានកំណត់នៅក្នុងច្បាប់ការងារ។ ឥឡូវយើងចូលមកមើលទាំងអស់គ្នាតើពលករប្រភេទណាខ្លះ? ដែលច្បាប់ការងារថៃអនុញ្ញាតឲ្យប្តូរថៅកែថ្មី៖
១.ថៅកែទទួលមរណភាព។
២.ក្រុមហ៊ុនដែលកំពុងធ្វើការត្រូវបានបិទទ្វារ(ក្ស័យធន)។
៣.ករណីថៅកែធ្វើទារុណកម្មលើពលករ។ ល។
៤.ថៅកែមិនគោរពកិច្ចសន្យាការងារ។ ល។
៥.បង្ខិតបង្ខំឲ្យពលករធ្វើការប្រថុយនឹងគ្រោះថ្នាក់។ល៕

ក្នុងករណីខាងលើនេះ ពលករខ្លួនឯងត្រូវទំនាក់ទំនងមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ឬភ្នាក់ងារមានសមត្ថកិច្ចថៃ ដើម្បីសុំអោយជួយអន្តរាគមន៍ដើម្បីដោះស្រាយ។ បន្ទាប់មកទៀតក្នុងករណីពលករចង់ប្តូរថៅកែថ្មី នៅក្នុងពេលបច្ចុប្បន្នដោយហេតុផលផ្សេងបាននោះ លុះត្រាតែពលកររូបនោះកំពុងកាន់ប័ត្រស៊ីជម្ពូតែប៉ុណ្ណោះ ទើបអាចសុំប្តូរថៅកែថ្មីបាន.! តែត្រូវមានលិខិតបញ្ជាក់ចេញពីថៅកែចាស់ជាមុនសិន ទើបអាចយកទៅដំណើរការប្តូរថៅកែថ្មីបាន។ ដូច្នេះហើយបើសិនជាពលករចង់ប្តូរថៅកែថ្មី ទាល់តែពលករខ្លួនឯងទៅទំនាក់ទំនងជាមួយក្រុមហ៊ុនទទួលរត់ការរឿងឯកសារប្តូរថៅកែ ទើបគេមានវិធីសាស្ត្រក្នុងការទំនាក់ទំនងទៅថៅកែដើម ដើម្បីអោយគេស៊ីញ៉េរលិខិតបញ្ជាក់ ឬហៅថា(ប៉ៃយ៉ាយអក)អោយបាន។ ចំពោះតំលៃសេវាកម្មក្នុងការប្តូរថៅកែថ្មីវិញ គឺអាស្រ័យទៅលើក្រុមហ៊ុនជាអ្នកទាំងពីរពលករ ដូច្នេះពលករអាចត្រូវចំណាយប្រាក់ប្តូរថៅកែថ្មីអស់រហូតដល់ខ្ទង់ម៉ឺនក៏ថាបាន។

ហើយចំពោះពលករដែលទើបនឹងលុងបៀនថ្មីកាលពីថ្មីៗកន្លងទៅនេះ ទាំងត្រួតសញ្ជាតិហើយ, ទាំងវ៉ៃវីសារហើយ,ឬក៏មិនទាន់បានត្រួតសញ្ជាតិ÷ បច្ចុប្បន្ននេះក្រសួងការងារថៃមិនទាន់មាននយោបាយបើកអោយពលករដែលទើបលុងបៀនថ្មី អាចធ្វើការប្តូរថៅកែថ្មីបានឡើយ ទោះបីជាក្នុងករណីណាក៏ដោយ ដូច្នេះហើយបើសិនជាពលករដែលលុងបៀនថ្មីចង់ប្តូរថៅកែថ្មីនោះ គឺមានវិធីតែមួយគត់ គឺត្រូវទៅធ្វើប៉ាស្ព័រ MOU សាជាថ្មីពីខាងប្រទេសរបស់ខ្លួនមកវិញ តែបញ្ហានៅត្រង់តំលៃសេវាកម្ម MOU មានតម្លៃខ្ពស់ហើយប្រើរយៈពេលយូរអាចធ្វើឲ្យពលករត្រូវសមត្ថកិច្ចថៃចាប់នៅពេលកំពុងរង់ចាំប៉ាស្ព័រ MOU មកដល់។

ដូច្នេះពលករខ្លួនឯងត្រូវពិចារណាអោយបានល្អិតល្អន់សិនមុននឹងសម្រេចចិត្តប្ដូរថៅកែថ្មី ព្រោះរឿងប្ដូរថៅកែថ្មីត្រូវចំណាយពេលវេលា និងលុយកាក់ជាច្រើន ហើយអាចនឹងប្រថុយប្រថាននូវត្រូវសមត្ថកិច្ចចាប់ អំឡុងពេលដែលកំពុងប្ដូរថៅកែមិនទាន់ចប់សព្វគ្រប់និងមិនទាន់ដំណើររឿងចប់សព្វគ្រប់។

## ពលករចំណាកស្រុកខុសច្បាប់ចំនួន១៤ នាក់ ត្រូវកម្លាំងអាជ្ញាធរថៃឃាត់ខ្លួន

http://www.prakpheaktra.com/ January 13, 2018

ពលករចំណាក់ខុសច្បាប់ ចំនួន ១៤នាក់ ដេកគរគ្នាពេញគូទឡានយ៉ាងវេទនាដោយសារចង់ឆ្លងដែនចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ។ កម្លាំងអាជ្ញាធរតម្រួត ខេត្តកាណាក់បុរី ប្រទេសថៃស្ទាក់ឃាត់រថយន្តដឹកពលករខុសច្បាប់សញ្ជាតិភូមា ចំនួន១៤ នាក់ ខណៈពេលកំពុងឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ តាមរយៈរថយន្តPikUp ដេកគលើគ្នាយ៉ាងវេទនា។ ករណីខាងលើនេះបានកើតឡើងកាលពីថ្ងៃសៅរ៍ទី១៣ខែមករាឆ្នាំ២០១៨ ស្ថិតនៅក្បែរភូមិទំនប់ទឹក ក្នុងឃុំបង់តី ស្រុកឆៃយ៉ូ ខេត្តកាចាណាក់បុរី ប្រទេសថៃ ។

## ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៨

## ឃាត់ខ្លួនស្ត្រីម្នាក់ ពីបទលក់ដូរមនុស្សដោយមានគោលដៅយកទៅ ប្រទេសម៉ាឡេស៊ី

http://cambodiapolice.com/ 10:04 am 16 មករា 2018

បាត់ដំបង៖ នៅថ្ងៃច័ន្ទ ១៤រោច ខែបុស្ស ឆ្នាំរការ នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៨ វេលាម៉ោង ១៦និង៥៥នាទី នៅចំនុចភូមិស្លពរ២ ឃុំអំពិលប្រាំដើម ស្រុកបវេល កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានអនុវត្តតាមបញ្ជាលោកព្រះរាជអាជ្ញា នួន សាន បង្គាប់អោយនាំឈ្មោះ យឿន ភាព ភេទស្រី អាយុ ៤៥ឆ្នាំ រស់នៅភូមិ.ឃុំខាងលើ ត្រូវបានចោទប្រកាន់ពីបទ លក់ដូរមនុស្សដោយមានគោលដៅយកទៅប្រទេសម៉ាឡេស៊ី ប្រព្រឹត្តនៅភូមិ.ឃុំខាងលើ កាលពីឆ្នាំ២០១៦ ។ បច្ចុប្បន្នសមត្ថកិច្ចជំនាញក្រោយអនុវត្តរួចកំពុងរៀបចំសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ដើម្បីចាត់ការបន្តតាមនិតិវិធីច្បាប់ ៕

## ស្ត្រីខ្មែរមួយចំនួនជ្រើសរើសការធ្វើចំណាកស្រុកដើម្បីជីវភាពគ្រួសារ

http://wmc.org.kh/ ថ្ងៃចន្ទ ទី១៥ ខែមករា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ស្ត្រីខ្មែរភាគច្រើននៅតែជ្រើសរើសការធ្វើចំណាកស្រុក ដើម្បីរកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ បើទោះអ្នកខ្លះធ្លាប់បានជួបប្រទះការធ្វើទុក្ខបុកម្នេញពេលដែលទៅធ្វើការនៅក្រៅប្រទេស។ ស្ត្រីខ្មែរ មិនថាអ្នកមិនទាន់រៀបការ ឬអ្នករៀបការហើយនោះទេ ពួកគេបានសម្រេចចិត្តចាកចេញពីប្រទេសកំណើតរបស់ខ្លួន ដើម្បីទៅធ្វើការងារនៅក្រៅប្រទេស បំណងរកប្រាក់ចិញ្ចឹមកូន និងឪពុក ម្ដាយ។ ពួកគេបានអះអាងថា បើទោះជាការងារលំបាកយ៉ាងណា ក៏អាចធ្វើបានដែរ ឲ្យតែកូនបានរៀន និងឪពុកម្ដាយ បានរួចផុតការលំបាកខ្វះមុខ ខ្វះក្រោយ។

ខណៈនេះយន្តហោះមួយបានរំកិលខ្លួនបន្តិចម្ដងៗ មករកទីតាំងមួយដើម្បីដឹកអ្នកដំណើរដែលត្រូវទៅកាន់ទីក្រុងហុងកុង ដែលជាតំបន់សេដ្ឋកិច្ចស្វយ័តរបស់ ប្រទេសចិន។ ពេលនេះហើយ ជាការចាកចេញរបស់ពលការិនីខ្មែរត្រូវឡើងយន្តហោះនេះ ទៅធ្វើការងារតាមផ្ទះនៅទីក្រុងពាណិជ្ជកម្មដ៏ធំនៅអាស៊ីមួយនេះ។

កាលពីថ្ងៃទី២៧ ធ្នូឆ្នាំ២០១៧ កម្មការិនីខ្មែរជាង ១០នាក់ ត្រូវបានបញ្ជូនទៅកាន់ទីក្រុងហុងកុង ជាលើកដំបូងដើម្បីធ្វើការជាជំនួយការមេផ្ទះ។ តែទោះជាការបញ្ជូនស្ត្រីខ្មែរទៅធ្វើការងារនៅទីក្រុងហុងកុង ជាលើកដំបូងក្ដី ក៏ប៉ុន្តែវាមិនមែនជាលើកទី១ទេ ដែលកម្ពុជា អនុញ្ញាតឲ្យពលរដ្ឋ ចេញទៅធ្វើការនៅក្រៅប្រទេស។ ក្រៅពីទីក្រុងហុងកុង កម្ពុជា ក៏បានអនុញ្ញាតឲ្យស្ត្រីខ្មែរ ទៅធ្វើការងារនៅប្រទេសកូរ៉េ ថៃ ម៉ាឡេស៊ី សិង្ហបុរី និងប្រទេសជប៉ុនផងដែរ។

អ្នកស្រី ស៊ុម សារ៉េត មានស្រុកកំណើតមកពីខេត្តកំពង់ចាម ដែលបច្ចុប្បន្នអ្នកស្រីមានអាយុ ៣៣ឆ្នាំ។ អ្នកស្រីឈរវង់ចាំនៅខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ជាទីដែលអ្នកស្រីរង់ចាំចេញដំណើរតាមយន្តហោះ ឆ្ពោះទៅកាន់ទីក្រុងហុងកុង ជាទឹកដីដែលអ្នកស្រី ត្រូវទៅធ្វើការជាជំនួយការមេផ្ទះ។ អ្នកស្រី បានផ្ដល់សម្ភាសន៍ឲ្យវិទ្យុស្ត្រីដឹង

ថា មូលហេតុដែលអ្នកស្រីសម្រេចចិត្តទៅធ្វើការងារក្រៅប្រទេស ពីព្រោះតែកត្តាប្រាក់បៀវត្ស ។ អ្នកស្រី បន្តថា ប្រាក់បៀវត្សដែលអ្នកស្រីធ្វើការងារតាមរោងចក្រក្នុងស្រុកខ្មែរ គឺមិនគ្រប់គ្រាន់សម្រាប់ការផ្គត់ផ្គង់ តម្រូវការប្រចាំថ្ងៃរបស់អ្នកស្រី នឹងកូនៗបានទេ។ អ្នកស្រី សារ៉េត រំពឹងថា ការទៅធ្វើការងារនៅក្រៅប្រទេសនេះ នឹងអាចធ្វើឲ្យជីវភាពគ្រួសាររបស់អ្នកស្រីបានល្អប្រសើរជាងសព្វថ្ងៃ។ អ្នកស្រី ស៊ិម សារ៉េត ៖«មកពីជីវភាពខ្ញុំខ្វះខាត ហើយជីវភាពវាខ្សត់ខ្សោយ ហើយទៅវាបានប្រាក់ខែខ្ពស់ អញ្ចឹងបានចង់ទៅហ្នឹង ហើយទៅហ្នឹងរំពឹងថា ខ្ញុំទៅធ្វើការឲ្យគេបានមួយអាណត្តិពីរឆ្នាំហ្នឹង យកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារខ្ញុំ»។

ដូចគ្នាដែរ សម្រាប់អ្នកស្រី ផេង សុជា អាយុ ២៨ឆ្នាំ មានស្រុកកំណើតមកពីខេត្តកំពង់ធំ អ្នកស្រីជាកម្មការិនីម្នាក់ក្នុងចំណោមកម្មការិនីជាច្រើនទៀត ដែលកំពុងរង់ចាំដើម្បីធ្វើដំណើរទៅកាន់គោលដៅ នៃការស្វែងរកថវិកាផ្គត់ផ្គង់ជីវភាពឪពុកម្តាយ ដែល រស់នៅក្នុងភាពក្រីក្រនៅឯស្រុក។ អ្នកស្រី សុជា បានលើកហេតុផលចំនួន ៣ចំណុ ដែលជំរុញទឹកចិត្តអ្នកស្រីឲ្យសម្រេចចិត្ត ដាក់ពាក្យទៅបម្រើការងារនៅក្រៅប្រទេស។ អ្នកស្រី ផេង សុជា ៖«ខ្ញុំចង់ទៅដោយសារទី១ ជាចំណុចល្អគឺវាមានប្រាក់ខែខ្ពស់ ទី២ ខ្ញុំមានជំនឿចិត្តលើរាជរដ្ឋាភិបាល ទី៣ គឺក្រសួងការងារ តម្រូវឲ្យខ្ញុំទៅដោយមិនមានការបង្ខិតបង្ខំពីក្រុមហ៊ុន។ លើសពីនេះក្រុមហ៊ុន ក៏បានណែនាំល្អៗជាច្រើនសម្រាប់ពួកខ្ញុំ មុនពេលខ្ញុំទៅ»។

ការងារនៅក្រៅប្រទេស គឺមិនថាផ្នែកអ្វីនោះទេ ពិតណាស់ កម្រៃគឺបានខ្ពស់ជាងក្នុងស្រុកទ្វេគុណ ព្រោះតែកម្រៃខ្ពស់នេះហើយ ទើបធ្វើឲ្យស្ត្រីខ្មែរភាគច្រើន តែងតែមានចិត្តចង់ទៅរកការងារធ្វើនៅក្រៅ ដោយសង្ឃឹមថា ក្រោយវិលមកវិញ ឪពុក ម្តាយ របស់ពួកគេ នឹងបានរស់នៅសុខ ស្រួល មិនហត់នឿយ និងលំបាកដូចបច្ចុប្បន្ន។ ស្ត្រីភាគច្រើន សុខចិត្តលំបាកខ្លួនឯង ឲ្យតែគ្រួសារពួកគេ ចៀសផុតពីក្តីទុក្ខ។ តែយ៉ាងនេះ ស្ត្រីខ្មែរ ធ្វើការនៅតាមផ្ទះ នៃប្រទេសខ្លះ តែងធ្លាក់ចូលក្នុងស្ថានភាព រងទុក្ខទោស ហើយត្រូវបង្ខំចិត្ត ត្រឡប់មកវិញ ដោយមិនសល់ប្រាក់កាក់អ្វីឡើយ ដោយសារការងាររបស់ពួកគេ មិនមានការច្បាប់ការពារ ឬ ក៏ពុំមានកិច្ចព្រមព្រៀងដាក់លាក់ ពីរដ្ឋាភិបាលនៃប្រទេសទាំង២ ។ កាលពីជាង ១០ឆ្នាំមុន ស្ត្រីខ្មែរភាគច្រើន ត្រូវបានមេខ្យល់បោក យកទៅលក់ ឲ្យធ្វើការងារនៅក្រៅប្រទេស និងខ្លះទៀតត្រូវបានមេខ្យល់នាំយកទៅលក់ឲ្យធ្វើប្រពន្ធឬបម្រើសេវាផ្លូវភេទ ដែលករណីនេះ នាំឱ្យរដ្ឋាភិបាលកម្ពុជា សើរើច្បាប់ របស់ខ្លួននិង ពិនិត្យកិច្ចព្រមព្រៀងទ្វេភាគីឡើងវិញ។

ចំណុចនេះ មិនមែនអ្នកស្រី សុជា មិនធ្លាប់ឮ នោះទេ ក៏ប៉ុន្តែអ្នកស្រីគិតថា កាលពីមុននឹងបច្ចុប្បន្ននេះ គឺមិនដូចគ្នាឡើយ ដោយអ្នកស្រីបន្តថា ការសម្រេចចិត្តទៅធ្វើការងារក្រៅប្រទេសរបស់អ្នកស្រីនេះ គឺនឹងមិនមានបញ្ហាត្រូវបានគេបោកបញ្ឆោតដូចកាលពីមុនឡើយ ព្រោះតែសព្វថ្ងៃនេះ មានការផ្សព្វផ្សាយជាច្រើនអំពីព័ត៌មាន ពីការងារចំណាកស្រុកទៅធ្វើការងារក្រៅប្រទេស រួមផ្សំនឹងព័ត៌មានមួយចំនួនទៀត ដែលអ្នកស្រីទទួលបានតាមបណ្តាញសង្គមហ្វេសប៊ុក។ អ្នកស្រី ផេង សុជា ៖«ទី១ ខ្ញុំគិតថា ពេលហ្នឹងមកពីគាត់អត់បានដឹង ហើយភាគច្រើនកើតឡើងនៅតាមភូមិ។ តែឥឡូវគេដឹងច្រើនហើយ ដោយសារយើងមានសង្គមហ្វេសប៊ុក ហើយទី២ មានបណ្តាញផ្សព្វផ្សាយជាច្រើនដែលគេផ្សព្វផ្សាយ»។

ចំណែកអ្នកស្រី ឈិន សុជាវី ដែលកំពុងត្រៀមខ្លួនធ្វើដំណើរទៅកាន់ទីក្រុងហុងកុងដូចគ្នាទៅកម្មការិនីទាំងពីររូបនេះដែរ បាននិយាយថា អ្នកស្រីធ្លាប់ជាកម្មការិនីមួយរូប ដែលបានទៅធ្វើការងារជាជំនួយការមេផ្ទះ នៅប្រទេសម៉ាឡេស៊ី រយៈពេល៥ឆ្នាំ។ អ្នកស្រី បានជួបផលលំបាកជាច្រើន ពីការធ្វើទុក្ខបុកម្នេញ ការប្រើឲ្យធ្វើការស្ទើរតែ រកពេលឈប់សម្រាកគ្មាន និងការទទួលបានប្រាក់បៀវត្សមិនគ្រប់ចំនួន ក្រោយពេលអ្នកស្រី វិលមកស្រុកកំណើតវិញ។ តែយ៉ាងណាអ្នកស្រី ទទួលស្គាល់ថា កាលពីពេលដែលអ្នកស្រី ចេញទៅធ្វើការងារនៅក្រៅប្រទេសកាលនោះ អ្នកស្រីមិនបានដឹងព័ត៌មានអ្វីឡើយ ហើយការចាកចេញរបស់អ្នកស្រី គឺធ្វើទៅតាមតែការឮតៗគ្នា តែប៉ុណ្ណោះ។

អ្នកស្រី ឈិន សុជាវី ៖«ខ្ញុំធ្វើការងារនៅជាមួយថៅកែរហូត ជូនកាលជូតផ្ទះគាត់អីហើយអញ្ចឹងទៅ គាត់យកទៅជូតផ្ទះបងប្អូនគាត់ ម៉ែលាងឡាន ៤ ទៅ៥ ថ្ងៃអាទិត្យ មុជទឹកឲ្យឆ្កែទៀត។ ពេលទំនេរអញ្ចឹង អាទឹកមាត់ត្រចៀកកាំហ្នឹងគាត់ឲ្យខ្ញុំអង្គុយបេះទឹកមាត់ត្រជៀកកាំហ្នឹងទៀតទៅ ជួនកាលខ្ញុំចូលដេកម៉ោង ១០ ម៉ោងអីទៅ»។ ក្តី

ទុក្ខវេទនា ដែលបានឆ្លងកាត់ព្រោះតែការចំណាកស្រុកដោយប្រថុយប្រថាននេះ បានធ្វើឲ្យអ្នកស្រី សុធារី មានអារម្មណ៍ខ្លាចរអានៅពេលដែលឮដំណឹងពីការបញ្ជូនពលករទៅធ្វើការងារក្រៅប្រទេសម្តងៗ។ ក៏ប៉ុន្តែស្ត្រីរូបនេះ នៅតែមានបំណងចង់ចេញទៅក្រៅប្រទេសដើម្បីរកការងារធ្វើការ ទទួលបានប្រាក់កម្រៃខ្ពស់យកមកផ្គត់ផ្គង់ជីវភាពគ្រួសារ។

អ្នកស្រី បានសម្រេចចិត្តជាថ្មីទៀត ដើម្បីទៅធ្វើការងារនៅក្រៅប្រទេស ក្រោយពីកញ្ញាបានចំណាយពេល ៣ ខែ ចូលសិក្សាវគ្គបណ្តុះបណ្តាលពីក្រុមបញ្ជូនពលករទៅក្រៅប្រទេស ដែលមានក្រសួងការងារ ជាសេនាធិការ។ អ្នកស្រីបាននិយាយថា ការទៅកាន់ទីក្រុងហុងកុងលើកនេះ នាងរំពឹងថា នឹងមិនជួបបញ្ហាអកុសលដូចកាលពីទៅប្រទេសម៉ាឡេស៊ីនោះទេ។ អ្នកស្រី ឈិន សុធារី ៖«ខ្ញុំអត់មានគិតថា ស្ថានភាពដូចកាលទៅម៉ាឡេទៀតទេ ព្រោះថាកាលទៅម៉ាឡេខ្ញុំអត់ដែលបានចូលក្រសួងការងារ បានមកជួបបងៗអញ្ចឹងទេ។ កាលទៅហ្នឹងគឺទៅហោះនៅស្រុកយួនឯណោះ ទៅហោះនៅស្រុកយួនហ្នឹង ជិះឡាន ទម្រាំទៅដល់ល្ងាច។ កាលទៅហ្នឹងអត់មានបានទៅជួបសម្ភាសន៍អីទេ តែដល់មកហ្នឹងគឺហ្នឹងពឹង ដូចថាបានជួបក្រសួងជួបអី ដែលគេណែនាំយើងថា ក្រុមហ៊ុនហ្នឹង គឺស្របច្បាប់ស្របអីអញ្ចឹង»។

ស្ត្រីខ្មែរ បានចាកចេញពីភូមិកំណើត ដើម្បីទៅធ្វើការនៅក្រៅប្រទេស អ្នកខ្លះធ្វើការងារដោយបានផលល្អ ដែលមិនមានការធ្វើបាប ឬកេញប្រវ័ញ្ចកម្លាំងពលកម្មអ្វីឡើយ។ ក៏ប៉ុន្តែស្ត្រីខ្មែរខ្លះទៀត បានចេញទៅធ្វើការងារក្រៅប្រទេស ត្រូវបានថៅកែ ធ្វើបាប នឹងស្ត្រីខ្លះទៀត ត្រូវបានម្ចាស់ផ្ទះធ្វើទារុណកម្ម និងចាប់រំលោភជាដើម។ ជាក់ស្តែងកាលពីឆ្នាំ២០១១ ប្រទេសកម្ពុជា បានសម្រេចបញ្ឈប់ការបញ្ជូនស្ត្រីខ្មែរ ទៅបម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ក្រោយពេលដែលមានរបាយការណ៍ នឹងបណ្តឹងជាច្រើន ដែលបង្ហាញពីការរំលោភសិទ្ធិការងារ ការធ្វើទុក្ខបុកម្នេញ ការបង្ខំរំលោភ និងការធ្វើទារុណកម្មរ លើស្ត្រីខ្មែរ ពីសំណាក់ម្ចាស់ផ្ទះ។

តែយ៉ាងណាការបញ្ជូនស្ត្រីខ្មែរ ទៅបម្រើតាមផ្ទះ ជាជំនួយការមេផ្ទះនៅទីក្រុងហុងកុង លើកដំបូងនាពេលនេះ ត្រូវបានលោក ងុយ រិទ្ធ អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រាប់អ្នកសារព័ត៌មាន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មុនពេលនាំកម្មការិនី ចេញទៅកាន់ទីក្រុងហុងកុងថា ស្ត្រីខ្មែរ ដែលទៅបម្រើការងារ នៅទីក្រុងហុងកុងនេះ ពួកគេនឹងមិនជួបបញ្ហាដូចកាលពីទៅប្រទេសម៉ាឡេស៊ីឡើយ។ លោកអះអាងថា ទីក្រុងហុងកុង មានការអនុវត្តច្បាប់តឹងរ៉ឹង នឹងបានផ្តល់សិទ្ធិពេញលេញដល់ពលករក្រៅប្រទេស ដូចទៅនឹងពលរដ្ឋ របស់គេដែរ។

លោក ងុយ រិទ្ធ ៖«ច្បាប់របស់ហុងកុង គឺផ្តល់សិទ្ធិសេរីភាព ហើយនឹងការការពារពលករបរទេសហ្នឹង ដូចពលកររបស់ហុងកុងហ្នឹង ហើយពលកររបស់ប្រទេសដទៃ គឺមានសិទ្ធិស្មើគ្នា គឺដូចគ្នា មិនខុសគ្នាទេ»។ តែយ៉ាងណាកាលពីខែធ្នូ ឆ្នាំ២០១៧ កន្លងទៅនេះ ទីភ្នាក់ងារសារព័ត៌មានអន្តរជាតិ រ៉យទ័រ បានចេញផ្សាយអត្ថបទមួយ ដោយសរសេរថាពលករហ្វីលីពិនភាគច្រើនបំផុតបានទទួលរងការធ្វើបាប ការរំលោភសិទ្ធិការងារពីក្រុមម្ចាស់ផ្ទះនៅទីក្រុងហុងកុង។ កាលពីចុងឆ្នាំ២០១៧ ក្នុងរបាយការណ៍រួមគ្នារបស់អង្គការពលកម្មអន្តរជាតិ ហៅកាត់ថា (ILO) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ហៅកាត់ថា (IOM) បានរកឃើញថា ពលករចំណាកស្រុកខ្មែរ ៨នាក់ក្នុងចំណោម ១០នាក់ត្រូវបានរំលោភបំពានសិទ្ធិការងារ និង ៧នាក់ក្នុងចំណោម ១០នាក់ បានកើតជំងឺផ្លូវចិត្ត។ ពលករខ្មែរចំណាកស្រុកទៅក្រៅប្រទេសត្រូវបានឲ្យដឹងថា មានចំនួន ១លាន ១សែន ៥ម៉ឺននាក់ ដែលក្នុងចំនួននេះ ពលរដ្ឋខ្មែរមានវត្តមាននៅប្រទេសថៃជាង១លាននាក់។ តាមរបាយការណ៍ដដែលនេះ ពលការិនីបម្រើការងារតាមផ្ទះ ត្រូវបានរំលោភសិទ្ធិការងារ និងជួបប្រទះការកើតជំងឺផ្លូវចិត្តធ្ងន់ធ្ងរក្រោយពេលពួកគេត្រឡប់មកកាន់ទឹកដីកំណើតវិញ។

លោក អំ សំអាត មន្ត្រីជាន់ខ្ពស់ផ្នែកស៊ើបអង្កេតអង្គការសម្ព័ន្ធ ខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ធ្លាប់បានប្រាប់វិទ្យុស្ត្រីកន្លងទៅនេះថា ក្នុងនាមសង្គមស៊ីវិលដែលធ្វើការងារការពារសិទ្ធិមនុស្សនៅកម្ពុជា លោកនៅតែមានក្តីបារម្ភពីសុវត្ថិភាពស្ត្រីខ្មែរ ដែលត្រូវបាននាំទៅធ្វើការងារជាជំនួយការមេផ្ទះនៅក្រៅប្រទេស។ តាមមន្ត្រីជាន់ខ្ពស់អង្គការលីកាដូដដែលបានបន្តថា ស្ត្រីខ្មែរដែលទៅធ្វើការងារនៅក្រៅប្រទេស ភាគច្រើនតែងតែរងទុក្ខបុកម្នេញ ការរំលោភបំពានសិទ្ធិ និងផ្លូវភេទ។

ទន្ទឹមនឹងមានបទពិសោធន៍ជាច្រើនជុំវិញ ពីការរំលោភបំពានសិទ្ធិ មកលើស្ត្រីខ្មែរ ដែលចេញទៅបម្រើការងារជាជំនួយការមេផ្ទះ នៅក្រៅប្រទេសដូចនេះ។ ចំពោះការបញ្ជូនស្ត្រីខ្មែរ ទៅកាន់ទីក្រុងហុងកុង ជាលើកនេះ ក្នុងឆ្នាំ ២០១៧ ក្រុមហ៊ុន អេលីត មេនផាវ័រ អេជិនស៊ី និងក្រុមហ៊ុន អ៊ឹងរិទ្ធីគ្រុប ដែលជាក្រុមហ៊ុនស្វែងរកការងារឲ្យពលករខ្មែរ ធ្វើនៅក្រៅប្រទេស បានអះអាងថា ការបញ្ជូនស្ត្រីខ្មែរទៅធ្វើការងារនៅក្រៅប្រទេសនេះ នឹងមិនមានបញ្ហារំលោភសិទ្ធិ ឬក៏បញ្ហាជាផលអាក្រក់អ្វីផ្សេងៗកើតឡើងនោះទេ។ ក្រុមហ៊ុនបានបញ្ជាក់ថា ព្រោះតែការបញ្ជូនទៅនេះ គឺមានការដឹងឮ នឹងមានកិច្ចសន្យាត្រឹមត្រូវ ទាំងភាគីក្រសួងការងារកម្ពុជា និងភាគីអាជ្ញាធរ នៃទីក្រុងហុងកុង។

ដោយសារ តែមានទំនុកចិត្តដូចនេះហើយ បានជា ម្តាយ ឪពុក និងគ្រួសារដែលជូនដំណើរកូនឡើងយន្តហោះទៅធ្វើការនៅ ក្រុងហុងកុងម្នាក់ៗហាក់មានទំនុកចិត្តជាងមុនដែលថា កូនស្រីរបស់ខ្លួននឹងរស់នៅ និងធ្វើការងារតាមផ្ទះនៅក្រុងហុងកុង នឹងប្រកបដោយសុវត្ថិភាព និងជួយផ្តល់ប្រាក់ចំណូល មកឲ្យគ្រួសារនៅប្រទេសកំណើត៕

## កម្ពុជាស្នើឲ្យជប៉ុនបន្តទទួលយកពលករជំនាញកម្ពុជាទៅប្រទេសជប៉ុន

http://cambodiapolice.com/ 5:02 pm 15 មករា 2018

ភ្នំពេញះសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ នារសៀលថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ បានជួបពិភាក្សា ការងារជាមួយអភិបាលខេត្ត Ehime របស់ប្រទេសជប៉ុន។ ក្នុងជំនួបនោះភាគីកម្ពុជា បានស្នើដោយត្រង់ទៅភាគីជប៉ុនឲ្យបន្តជួយទទួលយកពលករជំនាញរបស់កម្ពុជាទៅធ្វើការនៅខេត្ត Ehime របស់ប្រទេសជប៉ុន ខណៈបច្ចុប្បន្ននេះ ចំនួនពលករកម្ពុជាទៅធ្វើការនៅ ខេត្តមួយនេះនៅមានចំនួនតិចនៅឡើយ បើប្រៀបធៀបជាមួយនឹងពលករ នៃប្រទេសដទៃ។

សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា បច្ចុប្បន្ននេះ រាជរដ្ឋាភិ បាលជប៉ុន បានជួយកម្ពុជាយ៉ាងច្រើនដល់វិស័យអប់រំរបស់ប្រទេសកម្ពុជា ដែលធ្វើឲ្យយុវជនកម្ពុជាទទួលបាននូវចំណេះជំនាញ ដើម្បីចូលរួមក្នុងការ កសាងអភិវឌ្ឍប្រទេសកម្ពុជាឲ្យមានការរីកចម្រើន។ ដូច្នេះការទទួលបាន នូវការងារធ្វើ គឺជាកត្តាសំខាន់ដែលជំរុញឲ្យពួកគេអាចទទួលបាននូវបទ ពិសោធន៍ថ្មីៗបន្ថែមទៀត។

ឆ្លើយតបទៅនឹងបញ្ហានេះ ឯកឧត្តម Takihiro Nakamura អភិបាលខេត្ត Ehime របស់ប្រទេសជប៉ុន បានឲ្យដឹងថា ខេត្តលោក បានចុះកិច្ចព្រមព្រៀងជាមួយភាគីកម្ពុជាតាមរយៈក្រសួង ការងារកម្ពុជាដើម្បីជ្រើសរើសពលករជំនាញកម្ពុជាទៅធ្វើការនៅប្រទេស ជប៉ុនបន្ថែមទៀត។ ឯកឧត្តមថា ពាក់ព័ន្ធនឹងបញ្ហានេះដែរ លោកបាន ដឹកនាំគណៈប្រតិភូរបស់ជប៉ុនដែលរួមមាន អ្នកជំនាញរបស់ជប៉ុនមកធ្វើ ទស្សនកិច្ចស្វែងយល់អំពីប្រទេសកម្ពុជាផងដែរ ។

ដោយឡែកក្នុងជំនួបនោះដែរ ភាគីកម្ពុជា ក៏បានស្នើឲ្យភាគីជប៉ុនសម្លឹង មើលពីឱកាសនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជាឲ្យកាន់តែច្រើនឡើងថែមទៀតផងដែរ ៕

## ពលករខ្មែរ៥នាក់ ទាហានឈ្មួញខ្មៅថៃ ចាប់បញ្ជូនមកកម្ពុជាវិញ

http://www.arey-news.com/ (ថ្ងៃទី 16 January 2018 ម៉ោង 4:12 am)

បាត់ដំបង: ពលករដែថៃចាប់បាននោះ ទី១.ឈ្មោះ លុន ដារ៉ូត ភេទប្រុស អាយុ២៤ឆ្នាំ ទី២.ឈ្មោះ ហាត់ លាភ ភេទប្រុស អាយុ១៨ឆ្នាំ ទី៣.ឈ្មោះ សៀន ម៉េងហុង ភេទប្រុស អាយុ១៩ឆ្នាំ ទី៤.ឈ្មោះ ប៉ា ចាន់ ភេទប្រុស អាយុ២៥ឆ្នាំ និងទី៥.ឈ្មោះ ផាន់ ផួន ភេទប្រុស អាយុ២៥ឆ្នាំ។ ពួកគេទាំង៥នាក់នេះ មានស្រុកកំណើតនៅភូមិត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។

នាថ្ងៃច័ន្ទ ១៤រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ក៏បានចេញកម្លាំងទៅទទួលពលករខ្មែរទាំង៥នាក់ខាងលើ និងសម្ភារមួយចំនួន វិលត្រឡប់មកទឹកដីប្រទេសកម្ពុជាវិញ តាមច្រកទ្វារតំបន់គីឡូ១៣ (ភ្នំដី) និងបានសាកសួររកប្រភពអ្នកនាំ(មេខ្យល់) ហើយបានធ្វើការអប់រំ រួចឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ៕

## ឃាត់ខ្លួនពលករខុសច្បាប់០៩ នាក់ មកប្រកបមុខរបរស៊ីលក់ដូរដោយខ្លួនឯង,នៅក្នុងក្រុងPattaya

http://www.prakpheaktra.com/ January 15, 2018

នៅព្រឹកថ្ងៃច័ន្ទទី១៥ ខែមករា ឆ្នាំ២០១៨នេះ កម្លាំងអាជ្ញាធរតម្រួតក្រុងប៉ាតាយា ស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ប្រទេសថៃ បានបើកកិច្ចប្រតិបត្តិការណ៍ចុះបង្រ្កាបជនអន្តោប្រវេសន៍ខុសច្បាប់ ដែលកំពុងប្រកបមុខរបររកស៊ីលក់ដូរនៅតាមតំបន់ឆ្នេរសមុទ្រប៉ាតាយា និងឆ្នេរសមុទ្រចមធៀន។ ក្នុងកិច្ចប្រតិបត្តិការណ៍នេះ កម្លាំងអាជ្ញាធរថៃធ្វើការឃាត់ខ្លួនបានពលករអន្តោប្រវេសន៍ខុសច្បាប់ចំនួន០៩នាក់ ក្នុងនោះមានដូចជា, អ្នកលក់ការ៉េម, លក់ផ្លែឈើ, និងផ្សេងទៀត។

យោងតាមប្រភពព័ត៌មានរបស់សមត្ថកិច្ចថៃ បានបញ្ជាក់ឲ្យដឹងថាពលករអន្តោប្រវេសន៍ទាំងអស់ ភាគច្រើនធ្វើការខុសលក្ខខ័ណ្ឌនៃច្បាប់អនុញ្ញាតការងារថៃបានកំណត់ ព្រមទាំងមកដណ្តើមមុខរបររកស៊ីរបស់ពលរដ្ឋថៃ និងមួយចំនួនទៀតស្នាក់នៅក្នុងប្រទេសថៃដោយគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ បច្ចុប្បន្នអាជ្ញាធរតម្រួតក្រុងប៉ាតាយាក្នុងធ្វើការស្រាវជ្រាវ អ្នកដែលផ្តល់កន្លែងស្នាក់នៅដល់ជនអន្តោប្រវេសន៍នេះដើម្បីយកមកចាត់វិធានការតាមផ្លូវច្បាប់។

## ការងារចំនួន, ៣៩ ប្រភេទ ហាមមិនឲ្យពលករខ្មែរធ្វើការ

http://www.prakpheaktra.com/ January 15, 2018

តើបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការរស់នៅក្នុងប្រទេសថៃ មានដំណឹងទេថា ការងារចំនួន៣៩ប្រភេទ ត្រូវបានហាមឃាត់មិនឲ្យពលករខ្មែរ, ភូមាឡាវធ្វើការនៅក្នុងប្រទេសថៃ។ ព្រះរាជក្រឹត្យ ស្តីពីការកំណត់ការងារនិងវិជ្ជាជីវៈដែលហាមមិនអោយពលករបរទេសធ្វើការ ព.ស ២៥២២ ប្រភេទការងារ និងអាជីព ចំនួន៣៩ ហាមមិនឱ្យពលករបរទេស ធ្វើការនៅក្នុងប្រទេសថៃ មានដូចខាងក្រោម៖

| | |
|---|---|
| ១.ការងារធ្វើកម្មករ (ធ្វើបាន) | ២.ការងារធ្វើកសិកម្ម ដាំដុះ នេសាទ (ធ្វើបាន) |
| ៣.ការងារធ្វើសំណង់ (ធ្វើបាន) | ៤.ការងារធ្វើឆ្លាក់ក្បាច់នៅលើផ្ទាំងឈើ |
| ៥.ការងារបើកបររថយន្ត | ៦.ការងារឈរលក់ដូរនៅមុខតូប |
| ៧.ការងារលក់ដូរភាគហ៊ុន ឬផ្ទេរភាគហ៊ុន | ៨.ការងារផ្នែកកាន់បញ្ជី ឬត្រួតពិនិត្យបញ្ជី |
| ៩.ការងារធ្វើជាងឆ្នៃប្រឌិតពេជ្រ | ១០.ការងារសំអាងការ ឬ Salon |
| ១១.ការងារធ្វើត្បាញក្រណាត់ដោយ ប្រើថ្ងៃដៃ | ១២.ការងារ ត្បាញក្រណាត់ |
| ១៣.ការងារធ្វើក្រដាសដោយដៃ | ១៤.ការងារធ្វើគ្រឿងប្រាក់ |
| ១៥.ការងារធ្វើគ្រឿងដន្ត្រីថៃ | ១៦.ការងារធ្វើគ្រឿងថ្វាយ |
| ១៧ការងារធ្វើទាក់ទង,មាសប្រាក់ | ១៨.ការងារធ្វើអំពីថ្ម ដូចជាត្បាល់ថ្ម |
| ១៩.ការងារធ្វើតុក្កតាថៃ | ២០.ការងារធ្វើគ្រែ ពូក សាឡុង |
| ២១.ការងារធ្វើ បាតដាក់ចង្ហាន់ព្រះសង្ឃ | ២២.ការងារធ្វើទាក់ទងនឹង ក្រណាត់សូត្រ |
| ២៣.ការងារធ្វើព្រះពុទ្ធរូប | ២៤.ការងារធ្វើកាំបិត |
| ២៥.ការងារធ្វើឆាតក្រណាត់ ឬ ក្រដាស់ | ២៦.ការងារធ្វើ ស្បែកជើង |
| ២៧.ការងារធ្វើ មួក | ២៨.ការងារធ្វើ អ្នកក្លូកជេរ |
| ២៩.ការងារធ្វើ វិស្វករសំណង់ | ៣០.ការងារធ្វើ បំបាត់ |
| ៣១.ការងារធ្វើ កែច្នៃមូត សម្រាប់តែងខ្លួន | ៣២.ការងារធ្វើ ផ្ទាំងដី |
| ៣៣.ការងារធ្វើ មូលបារី ដោយដៃ | ៣៤.ការងារធ្វើ អ្នកនាំភ្ញៀវទេសចរណ៍ |
| ៣៥.ការងារធ្វើ រែកឥវ៉ាន់ដើរលក់ | ៣៦.ការងារធ្វើ keyboard ភាសាថៃ |
| ៣៧.ការងារធ្វើ ពុតលុតដោយដៃ | ៣៨.ការងារធ្វើ លេខា ឬ ស្មៀន |
| ៣៩.ការងារធ្វើ មេធាវី | |

បញ្ជាក់÷ តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីថៃ ពលករបរទេស សញ្ជាតិ កម្ពុជា ឡាវ និងភូមា ក្នុងចំណោមការងារទាំងអស់ខាងលើនេះ មានតែការងារ ២ប្រភេទប៉ុណ្ណោះដែលពលករបរទេសអាចធ្វើបាន គឺកម្មករ និងការងារតាមផ្ទះ។ ករណីលើកលែងមានដូចជាការងារសំណង់ នេសាទ និងកសិកម្ម។ សូមបងប្អូនពលករខ្មែរទាំងអស់ជ្រាបជាព័ត៌មានជៀសវាងធ្វើការងារខុសទៅនឹងព្រះរាជក្រឹត្យថៃដែលបានកំណត់ ហើយត្រូវសមត្ថកិច្ចថៃចាប់និងផាកពិន័យ។

## ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៨
## សម្ដេចតេជោ ហ៊ុន សែន ជំរុញឱ្យពន្លឿនការផ្ដល់ភាពស្របច្បាប់ ដល់ពលករខ្មែរនៅប្រទេសថៃ ក្រោយប្រាយុទ្ធ ចាន់អូ៊ចា យល់ព្រមពន្យារពេល៦ខែទៀត

http://www.freshnewsasia.com/ 2018-01-17

(ភ្នំពេញ)៖ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងថា ក្នុងជំនួបមុនកិច្ចប្រជុំមេគង្គ-ឡានឆាង នាថ្មីៗនេះ លោក ប្រាយុទ្ធ ចាន់អូ៊ចា នាយករដ្ឋមន្ត្រីថៃ បានយល់ព្រមប្រកាសពន្យារពេល៦ខែទៀត ដល់ពលករខ្មែរដែលធ្វើការ និងស្នាក់នៅមិនទាន់ស្របច្បាប់នៅប្រទេសថៃ ដើម្បីបំពេញឯកសារស្របច្បាប់របស់ខ្លួនឡើងវិញ។ ជាមួយគ្នានេះ សម្ដេចតេជោក៏បានជំរុញឱ្យក្រសួងការងារពន្លឿនការធ្វើបែបបទស្របច្បាប់ ដល់ពលករផងដែរ។ ការអះអាងរបស់សម្ដេចតេជោ ហ៊ុន សែន បានធ្វើឡើង នៅថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨នេះ ក្នុងឱកាសសម្ដេច បន្តចុះជួបសំណេះសំណាល ជាមួយកម្មករ កម្មការិនី សរុបប្រមាណ ១៦,៩០៩នាក់ មកពីរោងចក្រសហគ្រាសចំនួន២០ នៅតំបន់ព្រៃទា ក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

សម្ដេចតេជោ ហ៊ុន សែន បានថ្លែងយ៉ាងដូច្នេះថា៖ «នៅពេលដែលមានការប្រជុំមេគង្គ-ឡានឆាង នៅទីក្រុងភ្នំពេញ នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចាន់អូ៊ចា ក៏បានប្រកាសពន្យារពេល សម្រាប់ការស្នាក់នៅ ដោយមិនទាន់ស្របច្បាប់ រយៈពេល៦ខែទៀត ដូច្នេះក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវបន្តការខិតខំបន្តការងារចំពោះមុខ ដើម្បីឱ្យពលកររបស់យើងដែលកំពុងរស់នៅ ប្រទេសថៃដែលមិនទាន់ស្របច្បាប់ ទៅជាស្របច្បាប់»។ សម្ដេចបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តខិតខំរកការងារឱ្យពលករខ្មែរ នៅក្រៅប្រទេសឱ្យបានកាន់តែច្រើនថែមទៀត ដើម្បីបង្កើតចំណូលរបស់ពលរដ្ឋខ្មែរ។ ជាមួយគ្នានេះ សម្ដេចក៏បានបញ្ជាក់ម្ដងទៀតថា ពលករខ្មែរ ដែលទៅធ្វើការនៅក្រៅប្រទេសត្រូវតែខិតខំក្រេបយកជំនាញឯកទេស ដើម្បីពេលត្រឡប់មកកម្ពុជាវិញ មានជំនាញក្នុងការបំពេញការងារសម្រាប់តម្រូវការក្នុងប្រទេស៕

## សម្ដេច ហ៊ុន សែន រំលឹកឡើងវិញនូវសារសំខាន់ៗ ៨ចំណុច ឲ្យក្រសួងពាក់ព័ន្ធអនុវត្ត

http://kleykley.sabay.com.kh/ ថ្ងៃ១៧ ខែមករា ឆ្នាំ២០១៨ ម៉ោង 10:38

ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករជិត ១ម៉ឺន ៧ពាន់នាក់ នៅរោងចក្រតំបន់ព្រៃទា ក្នុងខណ្ឌពោធិ៍សែនជ័យ នាព្រឹកថ្ងៃទី១៧ ខែមករានេះ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ក្រើនរំលឹកនូវសារសំខាន់ៗ ៨ចំនុចដើម្បីឲ្យក្រសួងពាក់ព័ន្ធអនុវត្តឲ្យមានប្រសិទ្ធភាព។ *សារសំខាន់ៗទាំង ៨ចំណុចនោះរួមមាន៖*

១. ត្រូវអនុវត្តប្រាក់ខែអប្បបរមា ១៧០ដុល្លារ ចាប់ពីថ្ងៃ១ ខែមករា ឆ្នាំ២០១៨ តទៅ។

២. ត្រូវអនុវត្តការចុះពិនិត្យនៅតាមមន្ទីពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាល កម្មករកម្មការិនីរោងចក្រ រួមទាំងកីឡាករ កីឡាការិនី ក្រុមប្រឹក្សាភូមិ ឃុំ ក៏ត្រូវបានអនុវត្តដូចគ្នា។

៣. ត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះសម្រាលកូន គឺនឹងទទួលបានពេលវេលាឈប់សម្រាក ពីការងាររយៈពេល ៣ខែ ហើយនៅទទួលបានប្រាក់ខែ ១២០% (៥០% ដោយក្រុមហ៊ុន និង ៧០% ដោយបេឡាជាតិ)។

៤. ត្រូវអនុវត្ត ចំពោះកម្មការនីសម្រាលបានកូន(១)គឺទទួលថវិកា ៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះដោយឥតគិតថ្លៃ។ បើសម្រាលបានកូនភ្លោះ (២) គឺទទួលបានថវិកា៨០ម៉ឺនរៀល។ បើសម្រាលបានកូន(៣) គឺទទួលបានថវិកា ១លាន ២សែនរៀល ហើយបូកប្រាក់ឧបត្ថម្ភចំនួន ៥លានរៀលទៀតពីសម្តេច ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត។
៥. ត្រូវអនុវត្ត ចំពោះរបបសន្តិសុខសង្គម ដោយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ តទៅ កម្មករ-កម្មការនីមិនចាំបាច់បង់ទៀតទេ គឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០%។
៦. អនុវត្តតាមដានមើលបញ្ហា ទឹក ភ្លើង គឺត្រូវខិតខំបន្ត តទឹកតភ្លើងដល់ផ្ទះរបស់កម្មករ ដែលនៅឆ្ងាយ និងមិនទាន់ទៅដល់ ឲ្យបានគ្រប់គ្រាន់ និងតម្លៃផ្ទះជួលដល់កម្មករ-កម្មការនី កុំឲ្យមានការឡើងថ្លៃក្នុងឆ្នាំ២០១៨។
៧. ត្រូវអនុវត្តប្រាក់សោធននិវត្តន៍ ចាប់ពីឆ្នាំ២០១៩ ទៅកម្មករ និងទទួលបានប្រាក់ ចូលនិវត្តន៍។ ដូច្នេះក្នុងរយៈពេល ១ឆ្នាំ (២០១៨) ត្រូវត្រៀមរៀបចំឲ្យហើយដើម្បីដំណើរការបានល្អនៅក្នុងឆ្នាំ២០១៩ នូវរបបសោធននិវត្តន៍នេះ។
៨. ត្រូវអនុវត្តចូលរួមបន្តយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាផ្សេងៗដល់ពលករទៅក្រៅប្រទេស ជួយសម្រួលនូវបែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានា និងដើម្បីទទួលបាននូវលក្ខខណ្ឌការងារ ល្អប្រសើរ៕

## ស្ត្រីម្នាក់ត្រូវចាប់ខ្លួនរឿងជួញដូរស្ត្រី៥នាក់

http://www.postkhmer.com/ Tue, 16 January 2018 គង់ មេត្តា

បាត់ដំបងៈ ស្ត្រីអាយុ ៤៥ ឆ្នាំម្នាក់ ត្រូវបានចាប់ខ្លួនក្នុងខេត្តបាត់ដំបង កាលពីថ្ងៃចន្ទ ពាក់ព័ន្ធនឹងករណីជួញដូរស្ត្រី៥នាក់ទៅប្រទេសម៉ាឡេស៊ី បន្ទាប់ពីឪពុករបស់ជនរងគ្រោះម្នាក់ បានដាក់ពាក្យបណ្ដឹងទៅនគរបាលខេត្ត។ លោក ប៊ុន វណ្ណារ៉ា ប្រធាននគរបាលប្រឆាំងការជួញដូរមនុស្សប្រចាំខេត្តបានថ្លែងថា អាជ្ញាធរបានចាប់ខ្លួនជនសង្ស័យឈ្មោះ យឿន ភាព អាយុ៤៥ឆ្នាំ ក្នុងឃុំអំពិលប្រាំដើម ស្រុកបវេល។ លោកបានថ្លែងថា អ្នកស្រី ភាព បានទទួលប្រាក់ចំនួន ៤០០ ដុល្លារ ពីមេខ្យល់ សម្រាប់ការជួយជួញដូរស្ត្រី៥នាក់ រួមទាំងកូនស្រីរបស់ខ្លួន ហើយថា មានជនសង្ស័យពីនាក់ទៀត នៅមិនទាន់ចាប់ខ្លួននៅឡើយ។

នៅក្នុងបទសម្ភាសមួយ កាលពីម្សិលមិញ ជនរងគ្រោះ ម៉ៅ មុំ អាយុ២២ឆ្នាំ បានថ្លែងថា នាងបានចាកចេញពីកម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ ២០១៦ ហើយអាចត្រឡប់មកវិញនៅថ្ងៃទី៤ ខែមករា ឆ្នាំនេះ។ អ្នកនាង មុំ ត្រូវបានផ្ទេរឲ្យទៅធ្វើការនៅកន្លែងផ្សេងៗគ្នាចំនួនបី និងមិនដែលទទួលបានប្រាក់ឈ្នួល ហើយទទួលរងការរំលោភបំពាននៅកន្លែងការងារនីមួយៗ។ អ្នកនាងបានថ្លែងបន្តថា និយោជកទីពីររបស់អ្នកនាង ធ្លាប់យកទឹកកករែអ្នកនាង«ត្រង់ថ្ងាស់ ដោយសារអ្នកនាងដាក់ថ្នាំពេទ្យនៅក្នុងទូទឹកកក»។ នាងបានថ្លែងបន្តថា បន្ទាប់ពីត្រូវបានលក់ទៅឲ្យអ្នកលក់ផ្លែឈើ អ្នកនាង មុំ បានទទួលរងការរំលោភបំពានធ្ងន់ធ្ងរបំផុត។ អ្នកនាងត្រូវបានវាយប្រហែលម្តងក្នុងមួយសប្តាហ៍ដោយសារមិនអាចលើកផ្លែឈើចំនួនពី៨០ទៅ៩០គីឡូក្រាម។ នាងបន្តថា នៅទីបំផុត នាងត្រូវបានចាក់សោនៅក្នុងទូទឹកកក។ នាងបានថ្លែងបន្តថាៈ «ខ្ញុំមិនអាចដើរបាន មិនអាចហូបអ្វីបាន។ ខ្ញុំស្ទើរតែស្លាប់»។ «ឥឡូវនេះខ្ញុំនៅមានការពិបាកដកដង្ហើម និងមានអារម្មណ៍ឈឺនៅក្នុងឆ្អឹង»។

និយោជករបស់អ្នកនាងនៅទីបំផុត បានបញ្ជូនអ្នកនាងទៅឲ្យគ្រូពេទ្យពិនិត្យ ហើយបន្ទាប់មកបានបញ្ជូនទៅទីភ្នាក់ងារមួយនៅខែធ្នូ ឆ្នាំ ២០១៧។ អ្នកនាងបានថ្លែងបន្តថាៈ «ក្នុងរយៈពេលទាំងនេះ ខ្ញុំមិនដែលទទួលបានប្រាក់ខែណាទេ»។ អ្នកនាងបានបន្ថែមថា ខ្ញុំមិនចង់ឲ្យជនសង្ស័យជាប់ពន្ធនាគារទេ «គ្រាន់តែសងលុយខ្ញុំចំពោះការងារដែលខ្ញុំបានធ្វើទៅបានហើយ»៕ PS

## ពលករខ្មែរ ០២នាក់ និងនារីសញ្ជាតិភូមា០១នាក់ត្រូវបានកម្លាំងអាជ្ញាធរថៃចាប់ខ្លួន

http://www.prakpheaktra.com/ January 17, 2018

ពលករខ្មែរចំនួន០២នាក់ ប្រកបមុខរបរលក់ខ្សែរ៉ាត់នៅក្នុងតំបន់ ទេសចរណ៍ឆ្នេរសមុទ្រថៃ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនកាលពីម្សិលមិញ។ កាលពីថ្ងៃអង្គារទី១៦ ខែមករា ឆ្នាំ២០១៨ ពលករខ្មែរចំនួន ០២នាក់ និងនារីសញ្ជាតិភូមា០១នាក់ទៀតត្រូវបានកម្លាំងអាជ្ញាធរទាហានថៃប្រចាំតំបន់ទេសចរណ៍ភូកេត ខេត្តភូកេត ប្រទេសថៃ ចាប់ខ្លួន បន្ទាប់ពីអាជ្ញាធរថៃបើកយុទ្ធនាការបង្ក្រាបជនអន្តោប្រវេសន៍ និងពលករខុសច្បាប់នៅក្នុងប្រទេសថៃ យោងតាមប្រភព

ព័ត៌មានរបស់ថៃបានឲ្យដឹងថា អាជ្ញាធរថៃនឹងរឹតបន្តឹងលើបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ពលករចំណាកស្រុកខុសច្បាប់ ដែលកំពុងតែចូលមកដណ្តើមមុខរបររកស៊ីពីពលរដ្ឋថៃ។ យុទ្ធនាការបង្ក្រាបជនអន្តោប្រវេសន៍ខុសច្បាប់នេះ បានចាប់ផ្តើមតាំងពីដើមខែមករាឆ្នាំ២០១៨ ម្ល៉េះតាមនយោបាយទប់ស្កាត់អំពើជួញដូរមនុស្សការប្រើប្រាស់កម្លាំងពលកម្មលើអនីតិជន និងពលករចំណាកស្រុកខុសច្បាប់នៅក្នុងប្រទេសថៃ។

## ថៃប្រកាសចាត់វិធានការចំពោះជនជាតិវៀតណាម,ខ្មែរ, ភូមា,ឥណ្ឌា រកស៊ីលក់ដូរដោយខ្លួនឯងក្នុងប្រទេសថៃ

http://www.prakpheaktra.com/ January 17, 2018

រដ្ឋមន្ត្រីក្រសួងការងារថៃ បានដាក់បញ្ជាអោយចាត់វិធានការយ៉ាងដាច់ខាតចំពោះករណីជនជាតិវៀតណាម, ខ្មែរ, ភូមា,ឥណ្ឌា មកប្រកមមុខរបរកស៊ីលក់ដូរដោយខ្លួនឯង។ បន្ទាប់ពីមានករណីកម្លាំងអាជ្ញាធរតម្រួតក្រុងប៉ាតាយាស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ប្រទេសថៃ ចុះធ្វើការបង្ក្រាបក្រុមជនអន្តោប្រវេសន៍ស្នាក់ខុសច្បាប់ និងពលករបរទេសដែលឆ្លងដែនមកប្រកបមុខរបរកស៊ីលក់ដូរនៅឆ្នេរសមុទ្រ ក្រុងប៉ាតាយ៉ា កាលពីម្សិលមិញ និងត្រូវកម្លាំងអាជ្ញាធរក្រុងប៉ាតាយាឃាត់ខ្លួនបានចំនួន០៩នាក់រួចមកនោះ។

នៅថ្ងៃអង្គារទី១៦ ខែមករា ឆ្នាំ២០១៨ លោក អាដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃ បានដាក់បញ្ជាអោយមន្ត្រីក្រសួងការងារថ្នាក់ក្រោម ចុះចាត់វិធានការយ៉ាងដាច់ខាតចំពោះថៅកែថៃ ដែលធ្វើឯកសារអោយពលករបរទេសអស់ទាំងនោះ ដែលមកប្រកបមុខរបររកស៊ីដោយខុសពីច្បាប់អនុញ្ញាតដែលស្នើសុំ ព្រមទាំងស្នើអោយកម្លាំងសមត្ថកិច្ចតាមស្រាវជ្រាវ ចាប់ខ្លួនម្ចាស់ផ្ទះដែលផ្តល់កន្លែងស្នាក់នៅដល់ពលករខុសច្បាប់អស់ទាំងនោះផងដែរ។ ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់ ដោយសារតែរឿងនេះធ្វើអោយប៉ះពាលដល់អាជីពរបស់ប្រជាពលរដ្ឋថៃ ហើយត្រូវព្រះរាជក្រឹត្យហាមឃាត់មិនអោយពលករធ្វើផងដែរ។

## រាជរដ្ឋាភិបាលថៃ កែសម្រួលបញ្ហាពលករមានប័ត្រស៊ីជម្ពូដាច់, ប៉ាស្ព័រវ៉ៃត្រាវីសារអត់បាន, និងវីសារហួស១៥ថ្ងៃ នៅពេលឆាប់ៗខាងមុខនេះ.!

http://www.prakpheaktra.com/ January 16, 2018

រាជរដ្ឋាភិបាលថៃសម្រេចអនុម័តសំណើរចំនួនបី(៣) របស់ក្រសួងការងារថៃ ដើម្បីពន្យារពេលស្នាក់នៅដល់ពលករមិនបានត្រួតសញ្ជាតិរួច និងអ្នកមានលិខិតឆ្លងដែនវ៉ៃត្រាវីសារអត់បាននាពេលកន្លងមក។ បន្ទាប់ពីកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រីថៃកាលពីព្រឹកថ្ងៃអង្គារទី១៦ ខែមករា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលថៃបានសម្រេចអនុម័តសំណើរចំនួន៣(៣) របស់ក្រសួងការងារមានដូចខាងក្រោម៖

១-ពន្យារពេលស្នាក់នៅបន្តដល់ពលករ (លុងបៀនថ្មី) និងប័ត្រស៊ីជម្ព អោយបានត្រួតសញ្ជាតិចប់សព្វគ្រប់ដល់ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៨។

២-បើកអោយពលករមានប័ត្រស៊ីជម្ពូធ្វើការនេសាទ និងផ្នែកការងារសមុទ្រ ដែលមានប័ត្រស៊ីជម្ពូដាច់កាលពីថ្ងៃទី០១ ខែ១១ ឆ្នាំ២០១៧ អាចទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័របាននៅក្នុងការិយាល័យផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃទាំងបីកន្លែងក្នុងប្រទេសថៃ។

៣-បើកសូន្យវ៉ាន់ស្តប់ស៊ីវិត(OSS,OneStopService)គ្រប់ខេត្តក្រុង,ដើម្បីវ៉ៃត្រាវីសារអោយពលករ (លុងបៀនថ្មី) និងវីសាហួស១៥ថ្ងៃ, និងអ្នកមានប័ត្រស៊ីជម្ពូនេសាទដាច់ តែវ៉ៃត្រាវីសារអត់បាននាពេលកន្លង។ ដោយក្រសួងការងារថៃនឹងសហការជាមួយតម្រួត(តម៉), ពេទ្យត្រួតពិនិត្យសុខភាព,ធ្វើវីសារ និងច្បាប់ការងារ និងក្នុងសូន្យវ៉ាន់ស្តប់ស៊ីវិត និងតែម្តង។ ដូច្នេះចំពោះពលករដែលបានបញ្ជាក់ទាំងបីក្រុមខាងលើ ត្រូវត្រៀមខ្លួនដើម្បីត្រួតសញ្ជាតិ,ពិនិត្យសុខភាព,សុំវីសារ,ច្បាប់ការងារ អោយបានត្រឹមត្រូវតាមនយោបាយរបស់រាជរដ្ឋាភិបាលថៃដែលបានកំណត់។

បញ្ជាក់÷ចំពោះពលករអន្តោប្រវេសន៍ខុសច្បាប់ រាជរដ្ឋាភិបាលថៃមិនបានពន្យារអោយស្នាក់នៅក្នុងប្រទេសថៃទៀតទេ ហើយក៏មិនបើកអោយចុះឈ្មោះធ្វើថ្មីទៀតដែរ ដូច្នេះពលករខុសច្បាប់គួរតែធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ហើយចូលមកធ្វើការក្នុងប្រទេសថៃតាមរយៈច្បាប់ការងារMOUអោយបានត្រឹមត្រូវ។

# ស្ថានទូតកម្ពុជា ប្រចាំប្រទេសនានា អន្តរាគមន៍ ជួយពលរដ្ឋខ្មែរ ២៩នាក់

https://www.dap-news.com/kh ថ្ងៃពុធ, ១៧ មករា ២០១៨ 11:43 ដោយ: ដើមអម្ពិល ID:013

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

## ស្ថានទូតកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរចំនួន២៩នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរម៉ាឡេស៊ី ជួយសង្គ្រោះពលករខ្មែរចំនួន**១១នាក់** ដែលរងគ្រោះដោយការជួញដូរកម្លាំងពលកម្មទៅធ្វើការលើទូកនេសាទបរទេស។ ពលករទាំង១១នាក់នេះ ត្រូវបានមេខ្យល់នាំទៅធ្វើការនៅលើទូកនេសាទកាលពីឆ្នាំ២០១៥ ហើយបានលួចរត់ចេញពីទូក នៅពេលមកដល់កំពង់ផែនៅរដ្ឋសារ៉ាវ៉ាក់(Sarawak) ប្រទេសម៉ាឡេស៊ី នៅខែឧសភា ឆ្នាំ២០១៧ ដោយសារពុំអាចទ្រាំនឹងការងារលំបាកខ្លាំងបាន។ អាជ្ញាធរម៉ាឡេស៊ី បានចាត់ទុកករណីនេះជាការជួញដូរមនុស្ស និងបានបញ្ជូនពលករទាំងអស់ទៅស្នាក់នៅក្នុងមណ្ឌលការពារក្នុងរដ្ឋម៉ាឡាកា(Malaka) ដើម្បីធ្វើការស៊ើបអង្កេតតាមនីតិវិធី។ ក្នុងរយៈពេលស៊ើបអង្កេត ស្ថានទូតបានផ្តល់អ្នកបកប្រែ ផ្តល់លិខិតធ្វើដំណើរជូន និងចាត់មន្ត្រីទៅសួរសុខទុក្ខពលករទាំង១១នាក់នៅមណ្ឌលការពារផងដែរ។ សំណុំរឿងនេះ បានបញ្ចប់នៅដើមខែមករា ឆ្នាំ២០១៨។

ពលករទាំង១១នាក់ បានមកដល់កម្ពុជា នៅថ្ងៃទី**១៥** ខែ**មករា** ឆ្នាំ**២០១៨** វេលាម៉ោង**១៧:៣០** នាទី ដោយអង្គការអន្តរជាតិទេសន្តប្រវេសន៍(IOM)ឧបត្ថម្ភសំបុត្រយន្តហោះជូន តាមការស្នើរបស់ស្ថានទូត។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**១១នាក់** ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង១១នាក់នេះ បានមកដល់កម្ពុជាវិញជាបន្តបន្ទាប់ នៅថ្ងៃទី**០៦** ទី**១៤** និងទី**១៦** ខែ**មករា** ឆ្នាំ**២០១៨**។

៣. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**វៀតណាម** បានសហការជាមួយអាជ្ញាធរទីក្រុងហាណូយ ជួយសង្គ្រោះស្ត្រីខ្មែរ**៧នាក់** (៦នាក់មកពីខេត្តពោធិ៍សាត់ និង១នាក់មកពីខេត្តកំពត) ដែលត្រូវបានមេខ្យល់ល្បួងបម្រុងយកទៅរៀបការនៅប្រទេសចិន ដោយឆ្លងកាត់តាមប្រទេសវៀតណាម។ ស្ត្រីទាំង៧នាក់ បានធ្វើដំណើរដោយម៉ូតូពីកម្ពុជាតាមខេត្តតាកែវ រួចបន្តឆ្លងកាត់ខេត្តអានយ៉ាងរហូតដល់ទីក្រុងហូជីមិញ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ ដោយពុំមានលិខិតឆ្លងដែន បម្រុងឡើងរថយន្តបន្តដំណើរទៅព្រំដែនវៀតណាម-ចិន ប៉ុន្តែត្រូវបាននគរបាលទីក្រុងហាណូយឃាត់ខ្លួនទាន់ដើម្បីសាកសួរ។ ស្ថានទូត បានសហការជាមួយការិយាល័យអន្តោប្រវេសន៍ទីក្រុងហាណូយ នាំស្ត្រីរងគ្រោះទៅស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលគាំពារសង្គមនៅទីក្រុងហាណូយ។

ស្ត្រីរងគ្រោះទាំង៧នាក់ បានមកដល់កម្ពុជាវិញ កាលពីថ្ងៃទី**១២** ខែ **មករា** ឆ្នាំ **២០១៨** ដោយមានអាជ្ញាធរកម្ពុជារង់ចាំទទួល និងចាត់ចែងបញ្ជូនទៅស្រុកកំណើត។

ថ្ងៃ ពុធ ១កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៨
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

# ទូតកម្ពុជាប្រចាំប្រទេសនានា ជួយពលរដ្ឋខ្មែររងគ្រោះជិត១ពាន់នាក់ នៅឆ្នាំ២០១៧

https://www.dap-news.com/kh ថ្ងៃពុធ, ១៧ មករា ២០១៨ 15:30 ដោយ: ខា ដា ID:014

ភ្នំពេញ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបង្ហាញថា រយៈពេល ១ឆ្នាំ នៃឆ្នាំ២០១៧ ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា នៅក្រៅប្រទេសបានជួយអន្តរាគមន៍ និងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ជិត១ពាន់នាក់ ។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេសខ្មែរ នៅរសៀលថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨នេះ បានឲ្យដឹងថា ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជានៅក្រៅប្រទេស បានយកចិត្តទុកដាក់ខ្ពស់ ក្នុងការការពារផលប្រយោជន៍ពលរដ្ឋខ្មែរ នៅក្រៅប្រទេស ដូចជា ជួយសម្របសម្រួល ក្នុងការបញ្ជូនពលករ-ពលការិនី ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស និងចរចាសម្របសម្រួល ជាមួយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសតាំងនៅ ក្នុងការផ្តល់ប័ណ្ណការងារ និងទិដ្ឋាការ/ប័ណ្ណស្នាក់នៅ ជូនពលករ-ពលការិនីខ្មែរ ។ សេចក្តីប្រកាសបន្តថា ជាក់ស្តែងក្រសួងការបរទេស បានណែនាំគ្រប់ស្ថានតំណាង ក្រៅប្រទេស យកចិត្តទុកដាក់ខ្ពស់ ចំពោះការដោះស្រាយនូវរាល់ បញ្ហាដែលកើតមានឡើង ចំពោះពលរដ្ឋ-ពលការិនី/ស្ត្រីខ្មែរនៅក្រៅប្រទេស និងផ្តល់ការណែនាំក្នុងករណី ជាក់លាក់នីមួយៗផងដែរ ។

សេចក្តីប្រកាសបញ្ជាក់ថា "ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រសួងការបរទេស ហើយនិងស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា នៅក្រៅប្រទេស បានជួយដោះស្រាយ បញ្ហាជូនពលរដ្ឋ ពលករ-ពលការិនី និងស្ត្រីខ្មែរ នៅប្រទេសចំនួន ១០ ក្នុងនោះមានពលរដ្ឋចំនួន ២១៩៩នាក់" ។ សេចក្តីប្រកាសបន្ថែមថា ប្រទេសទាំង ១០ ដែលក្រសួងការបរទេស ហើយនិងស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា បានជួយនោះរួមមាន៖ ថៃ អន្តរាគមន៍ផ្ទាល់ និងរៀបចំមាតុភូមិនិវត្តន៍ របស់ពលរដ្ឋខ្មែរចំនួន ២៨៨នាក់ (ប្រុស ១៦៥នាក់ និងស្រី១២៣នាក់) ។ ជាមួយគ្នានោះ សម្របសម្រួលជាមួយអាជ្ញាធរថៃ ក្នុងការរៀបចំមាតុភូមិនិវត្តន៍ របស់ពលរដ្ឋ-ពលករខ្មែរ ដែលត្រូវបានអាជ្ញាធរថៃ ចាប់ឃាត់ខ្លួនពីបទរស់នៅ និងធ្វើការដោយខុសច្បាប់ ក្នុងប្រទេសថៃ តាមច្រកព្រំដែនអន្តរជាតិ ប៉ោយប៉ែតចំនួនជាមធ្យមប្រមាណពី ១០០០ ទៅ១២០០នាក់ក្នុងមួយសប្តាហ៍ ។

វៀតណាម ជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ ជូនពលរដ្ឋកម្ពុជា ចំនួន១៧១នាក់ (ប្រុស៥២នាក់ និងស្រី១១៩នាក់) ។ ឡាវ ធ្វើមាតុភូមិនិវត្តន៍ ជូនពលរដ្ឋខ្មែរ ចំនួន៤៩នាក់ (ប្រុស៤៥នាក់ និងស្រី៤នាក់ ។ មីយ៉ាន់ម៉ា បានសម្រួលមាតុភូមិនិវត្តន៍ របស់ពលករខ្មែរចំនួន ៣នាក់ ដែលជួបការ លំបាកក្នុងការងារ ។

ម៉ាឡេស៊ី បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ ជូនដល់ពលរដ្ឋនិងពលករ-ពលការិនីខ្មែរ ដែលឆ្លងដែនខុសច្បាប់ ជួបការលំបាកក្នុងការងារ ចាញ់បោកមេខ្យល់នាំទៅធ្វើការ និងរងគ្រោះ ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្មពីនិយោជក ចំនួន៣៨២នាក់ (ប្រុស១៣៧នាក់ និងស្រី២៤៥នាក់)។

ឥណ្ឌូណេស៊ី បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ ជូនពលរដ្ឋខ្មែរចំនួន ២៣នាក់ (ប្រុស២១នាក់ និងស្រី២នាក់) ក្នុងនោះ ២១នាក់ ជាពលកររងគ្រោះ ដោយការជួញដូរកម្លាំង ពលកម្មលើទូកនេសាទបរទេស។ សិង្ហបុរី៖ បានជួយសម្រួល ការធ្វើមាតុភូមិនិវត្តន៍ របស់ពលរដ្ឋខ្មែរចំនួន ៥នាក់ ក្នុងនោះ៤នាក់ ជាពលការិនីជួបការលំបាកក្នុងការងារ និង១នាក់ ជាពលករលើទូកនេសាទ។ ចិន សម្រួលការធ្វើមាតុភូមិនិវត្តន៍ ជូនពលរដ្ឋខ្មែរជាស្ត្រីចំនួន ៥៣នាក់ និងជប៉ុន បានអន្តរាគមន៍ ជួយទាមទារប្រាក់សំណងពីនិយោជក និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ ជូនដល់កម្មសិក្សាការីខ្មែរ ចំនួន១២ នាក់ ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយនិងស្ថានទូតនិងស្ថានអគ្គកុងស៊ុលកម្ពុជានៅក្រៅប្រទេស បានយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅក្រៅប្រទេសជាអាទិ៍៖

- ជួយសម្របសម្រួលក្នុងការបញ្ជូនពលករ-ពលការិនី ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស និងចរចាសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសតាំងនៅ ក្នុងការផ្តល់ប័ណ្ណការងារ និងទិដ្ឋាការ/ប័ណ្ណស្នាក់នៅ ជូនពលករ-ពលការិនីខ្មែរ។
- តាមដាននិងលើកកម្ពស់ស្ថានភាពរស់នៅ ការថែទាំសុខភាព និងលក្ខខណ្ឌការងាររបស់ពលករ-ពលការិនីខ្មែរនៅក្រៅប្រទេស ដើម្បីបង្ការកុំឲ្យមានគ្រោះថ្នាក់ឬការបាត់បង់ជីវិត។
- អន្តរាគមចំពោះការរំលោភបំពានផ្សេងៗពីសំណាក់និយោជក ឬជនបរទេស មកលើពលករ-ពលការិនី ឬពលរដ្ឋខ្មែរ តាមរយៈការជួយសង្គ្រោះ ការផ្តល់ការគាំទ្រផ្នែកច្បាប់ និងការទាមទារសំណង ឬប្រាក់បៀវត្សដែលនៅសេសសល់។
- ជួយឧបត្ថម្ភ និងតាមដានសុខទុក្ខរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសដែលជួបការលំបាក ឬមានគ្រោះថ្នាក់ផ្សេងៗ និងផ្តល់ការគាំទ្រផ្នែកច្បាប់ដល់ពលរដ្ឋខ្មែរដែលត្រូវបានអាជ្ញាធរនៃប្រទេសតាំងនៅ ចោទប្រកាន់ពីការប្រព្រឹត្តបទល្មើស ឬត្រូវបានចាប់ខ្លួន និងឃុំឃាំង។
- ផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ព្រមទាំងរៀបចំមាតុភូមិនិវត្តន៍ជូនពលរដ្ឋ និងពលករ-ពលការិនីខ្មែរ ដែលជួបការលំបាកហើយចង់ត្រឡប់មកមាតុប្រទេសវិញ និងស្ត្រីរងគ្រោះដោយការបោកបញ្ឆោត ឬការជួញដូរផ្សេងៗ ។ល។

ជាក់ស្តែងក្នុងឆ្នាំ២០១៧ (ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយនិងស្ថានទូតនិងស្ថានអគ្គកុងស៊ុលកម្ពុជានៅក្រៅប្រទេស បានជួយដោះស្រាយបញ្ហាជូនពលរដ្ឋ ពលករ-ពលការិនី និងស្ត្រីខ្មែរ ដូចខាងក្រោម៖

១- <u>ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ</u>

- ណែនាំគ្រប់ស្ថានតំណាងក្រៅប្រទេស យកចិត្តទុកដាក់ខ្ពស់ចំពោះការដោះស្រាយនូវរាល់បញ្ហាដែលកើតមានឡើងចំពោះពលរដ្ឋ/ពលករ-ពលការិនី/ស្ត្រីខ្មែរនៅក្រៅប្រទេស ហើយនិងផ្តល់ការណែនាំក្នុងករណីជាក់លាក់នីមួយៗ។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141

- ជួយសម្រួលស្នើសុំទិដ្ឋាការជូនពលករ-ពលការិនីកម្ពុជា ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស។
- ទទួលពាក្យបណ្តឹងនានាពីប្រជាពលរដ្ឋ អង្គការ និងអាជ្ញាធរក្នុងប្រទេស ដែលស្នើអោយជួយធ្វើអន្តរាគមន៍ និងជួយសង្គ្រោះពលរដ្ឋខ្មែរ ដែលជួបបញ្ហានៅក្រៅប្រទេស ព្រមទាំងជូនព័ត៌មានទៅក្រុមគ្រួសារ និងអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា អំពីករណីពលរដ្ឋ/ពលករខ្មែរនៅក្រៅប្រទេស ជួបការលំបាក និងរងគ្រោះដោយសារបញ្ហាផ្សេងៗ ហើយនិងអំពីមាតុភូមិនិវត្តន៍របស់ពួកគេ។

## ២- ព្រះរាជាណាចក្រថៃ

ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តសាកែវ បាន៖

- អន្តរាគមផ្ទាល់និងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន២៨៨នាក់(ប្រុស១៦៥នាក់ និងស្រី១២៣នាក់) ក្នុងនោះ២៦០នាក់ ចាញ់បោកមេខ្យល់នាំទៅធ្វើការដោយខុសច្បាប់ ១៤នាក់ជាពលករដែលត្រូវបានក្រុមហ៊ុនបញ្ជូនពលករបំពានកិច្ចសន្យាការងារ ៦នាក់ជាកុមាររងគ្រោះដោយការជួញដូរមនុស្ស ៤នាក់ត្រូវបាននិយោជកដកហូតលិខិតឆ្លងដែននិងមិនបើកប្រាក់ខែឲ្យ និង៤នាក់ទៀតជាជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្មលើទូកនេសាទ។ លើសពីនេះ ស្ថានទូតបានសហការជាមួយអាជ្ញាធរថៃ អាជ្ញាធរសូម៉ាលី និងអង្គការអន្តរជាតិទេសន្តប្រវេសន៍(IOM) ជួយសង្គ្រោះនិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករនេសាទខ្មែរចំនួន១៨នាក់ដែលរងគ្រោះដោយការជួញដូរទៅធ្វើការលើទូកនេសាទបរទេស។
- សម្របសម្រួលជាមួយអាជ្ញាធរថៃ ក្នុងការរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋ/ពលករខ្មែរ ដែលត្រូវបានអាជ្ញាធរថៃចាប់ឃាត់ខ្លួនពីបទរស់នៅ និងធ្វើការដោយខុសច្បាប់ ក្នុងប្រទេសថៃ តាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ចំនួនជាមធ្យមប្រមាណពី ១០០០ ទៅ១២០០ នាក់ក្នុងមួយសប្តាហ៍។
- អន្តរាគមដោះស្រាយ និងផ្តល់ការគាំទ្រផ្នែកច្បាប់ នៅពេលមានការរំលោភបំពានផ្សេងៗ ពីសំណាក់និយោជកមកលើពលករខ្មែរ ព្រមទាំងទាមទារសំណងផ្សេងៗ ជូនពលករ-ពលការិនី ដែលរងការបំពាន រងរបួស ឬបាត់បាត់ជីវិត ដោយសារគ្រោះថ្នាក់ការងារ។
- តាមដានសុខទុក្ខ និងជួយឧបត្ថម្ភដល់ពលរដ្ឋ/ពលករខ្មែរ ដែលជួបការលំបាក ឬមានគ្រោះថ្នាក់ផ្សេងៗ ។

## ៣- ប្រទេសវៀតណាម

ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាម និងស្ថានអគ្គកុងស៊ុលកម្ពុជានៅទីក្រុងហូជីមិញ បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋកម្ពុជា ចំនួន**១៧១នាក់** (ប្រុស៥២នាក់ និងស្រី១១៩នាក់) ក្នុងនោះ១៤៨នាក់រស់នៅនិងធ្វើការដោយខុសច្បាប់ ២០នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្សឆ្លងកាត់តាមប្រទេសវៀតណាម និង៣នាក់ រៀបការខុសច្បាប់។

## ៤- ប្រទេសឡាវ

ស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ និងស្ថានអគ្គកុងស៊ុលកម្ពុជានៅទីក្រុងប៉ាក់សេ បានសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរ ចំនួន**៤៩នាក់** (ប្រុស៤៥នាក់ និងស្រី៤នាក់) ក្នុងនោះ ៣៤នាក់ ត្រូវមេខ្យល់នាំចូលធ្វើការក្នុងប្រទេសឡាវដោយខុសច្បាប់ ៩នាក់រៀបការនិងរស់នៅខុសច្បាប់ និង៦នាក់ទៀតឆ្លងដែនខុសច្បាប់ចូលប្រទេសឡាវ។

## ៥- ប្រទេសមីយ៉ាន់ម៉ា

ស្ថានទូតកម្ពុជាប្រចាំប្រទេសមីយ៉ាន់ម៉ា បានសម្រួលមាតុភូមិនិវត្តន៍របស់ពលករខ្មែរចំនួន**៣នាក់** ដែលជួបការលំបាកក្នុងការងារ។

## ៦- ប្រទេសម៉ាឡេស៊ី

ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនដល់ពលរដ្ឋនិងពលករ-ពលការិនីខ្មែរ ដែលឆ្លងដែនខុសច្បាប់ ជួបការលំបាកក្នុងការងារ ចាញ់បោកមេខ្យល់នាំទៅធ្វើការ និងរងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្មពីនិយោជក ចំនួន**៣៨២**នាក់ (ប្រុស១៣៧នាក់ និងស្រី២៤៥នាក់)។

## ៧- ប្រទេសឥណ្ឌូណេស៊ី

ស្ថានទូតកម្ពុជាប្រចាំប្រទេសឥណ្ឌូណេស៊ី បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរចំនួន**២៣នាក់** (ប្រុស២១នាក់ និងស្រី២នាក់) ក្នុងនោះ២១នាក់ ជាពលកររងគ្រោះដោយការជួញដូរកម្លាំងពលកម្មលើទូកនេសាទបរទេស។

## ៨- ប្រទេសសិង្ហបុរី

ស្ថានទូតកម្ពុជាប្រចាំប្រទេសសិង្ហបុរី បានជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៥**នាក់ ក្នុងនោះ៤នាក់ ជាពលការិនីជួបការលំបាកក្នុងការងារ និង១នាក់ជាពលករលើទូកនេសាទ។

## ៩- ប្រទេសចិន

ស្ថានទូតកម្ពុជាប្រចាំប្រទេសចិន ព្រមទាំងស្ថានអគ្គកុងស៊ុលកម្ពុជានៅទីក្រុងសៀងហៃ ទីក្រុងក្វាងចូវ ទីក្រុងណាននីង និងទីក្រុងឆុងឈីង បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរជាស្ត្រីចំនួន **៥៣នាក់** ដោយក្នុងនោះ ៤១នាក់ ជានារីដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការខុសច្បាប់ជាមួយបុរសចិន ៨នាក់រស់នៅមិនចុះសម្រុងជាមួយប្តីជនជាតិចិន ៣នាក់ឆ្លងដែនខុសច្បាប់ និង១នាក់មានទិដ្ឋការហួសសុពលភាព។

## ១០ ប្រទេសជប៉ុន

ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន បានអន្តរាគមជួយទាមទារប្រាក់សំណងពីនិយោជក និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនដល់កម្មសិក្សាការីខ្មែរ ចំនួន**១២** នាក់។

១១- <u>សាធារណរដ្ឋកូរ៉េ</u>

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសាធារណរដ្ឋកូរ៉េ បាន៖

- សួរសុខទុក្ខនិងផ្សព្វផ្សាយវិធីសាស្ត្រថែទាំសុខភាពដល់ពលករ-ពលការិនីដែលបំពេញការងារនៅសាធារណរដ្ឋកូរ៉េ។
- ទាមទារប្រាក់ជានាវ៉ាប់រង ជូនពលករ-ពលការិនី ដែលរងរបួស ឬបាត់បាត់ជីវិត ដោយសារគ្រោះថ្នាក់ការងារ។
- ដោះស្រាយការរំលោភបំពានផ្សេងៗពីសំណាក់និយោជក មកលើពលករខ្មែរ ។ល។

ថ្ងៃ ពុធ ១ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មករា ឆ្នាំ ២០១៨

**តើទីតាំងម៉ាស្សាកន្លែងផ្សេង មានបង្កប់សេវាផ្លូវភេទបែបហ្នឹងអត់?**

https://kohsantepheapdaily.com.kh/ កោះសន្តិភាព ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៨ម៉ោង ២១:៤៩ម៉ម លីហេង

រាជធានីភ្នំពេញ ៖ នៅវេលាម៉ោង៨យប់ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨នេះ កម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ បានធ្មក់ចុះបង្ក្រាបទីតាំងម៉ាស្សា បង្កប់សេវាផ្លូវភេទមួយកន្លែងយីហោ "ម៉ាស្សាកោសជប់ 3$" ដែលមានទីតាំងនៅចំណុចផ្ទះលេខ6F ក្នុងបុរីលឹមឈាងហាក់៣ ស្ថិតក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ការចុះបង្ក្រាបធ្វើឡើងដោយមានការដឹកនាំកម្លាំងពីសំណាក់ លោកឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងមានការសម្របសម្រួលពីព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ លោក គុជ គឹមឡុង។ ជាលទ្ធផលចំពោះមុខ កម្លាំងសមត្ថកិច្ចបានរកឃើញមាន ស្រោមអនាម័យមួយចំនួនធំ នៅក្នុងបន្ទប់ម៉ាស្សា ទាំងប្រើរួច និងមិនទាន់បានប្រើ។ ក្រោយការរកឃើញវត្ថុតាងមួយចំនួនហើយនោះ សមត្ថកិច្ចបានសម្រេចឃាត់ខ្លួនមនុស្ស៦នាក់ ក្នុងនោះមានស្ត្រីម្នាក់ជាមេការ និង៥នាក់ទៀតជានារីម៉ាស្សា។ ក្រោយការឃាត់ខ្លួន ពួកគេទាំង៦នាក់ ត្រូវបានបញ្ជូនទៅកាន់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីបន្តនីតិវិធី៕

## សមត្ថកិច្ចបញ្ជូនជនសង្ស័យម្នាក់ទៅតុលាការករណីជួញដូរស្ត្រីខ្មែរទៅម៉ាឡេស៊ី

http://wmc.org.kh/ ថ្ងៃពុធ ទី១៧ ខែមករា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ ប៉ូលិសប្រឆាំងការជួញដូរមនុស្សក្នុងខេត្តបាត់ដំបងនឹងបញ្ជូនសំណុំរឿងជនសង្ស័យម្នាក់ទៅតុលាការករណីជួញដូរស្ត្រីខ្មែរទៅប្រទេសម៉ាឡេស៊ីកាលពីឆ្នាំ២០១៦។ លោក ប៊ុន វណ្ណារ៉ា ប្រធានការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សប្រចាំខេត្តបាត់ដំបង បានប្រាប់វិទ្យុស្ត្រីថាតាមការចង្អុលបង្ហាញពីឯកឧត្តមស្នងការនគរបាលខេត្តឲ្យបង្ក្រាប់ការជួញដូរមនុស្សដោយចាប់ឃាត់ខ្លួន និងបញ្ជូនជនសង្ស័យម្នាក់ឈ្មោះ យឿន ភាព អាយុ ៤៥ ឆ្នាំក្នុងសំណុំរឿងអំពើជួញដូរស្ត្រីខ្មែរទៅប្រទេសម៉ាឡេស៊ីទៅសាលាដំបូងខេត្តនៅថ្ងៃទីពុធទី១៧ ខែមករានេះ។ លោក ប៊ុន វណ្ណារ៉ា ពិណ៌នាថា មេខ្យល់បានទាក់ទងអ្នកស្រី យឿន ភាព ឲ្យជួយរកស្ត្រីខ្មែរទៅបម្រើការងារនៅប្រទេសម៉ាឡេស៊ីដោយប្រកាសថា បម្រើការងារនៅក្រៅប្រទេសទទួលបានប្រាក់ខែប្រមាណ១ពាន់ដុល្លារ។

## អាជ្ញាធរថៃ ចុះបង្ក្រាបពលករខ្មែរ, ភូមា, ឡាវ ដែលកំពុងលក់ដូរនៅតាមផ្សារ

http://www.prakpheaktra.com/ January 17, 2018

កម្លាំងអាជ្ញាធរថៃខេត្តសាមុតសារខនបើកយុទ្ធនាការបង្ក្រាបពលករចំណាកស្រុកធ្វើការខុសច្បាប់នៅតាមផ្សារថៃកាលពីថ្ងៃពុធទី១៧ ខែមករា ឆ្នាំ២០១៨។ លោកអភិបាល ខេត្តសាមុតសាខន ប្រទេសថៃ ដឹកនាំកម្លាំងអាជ្ញាធរមូលដ្ឋាន និងតម្រួត(តម៉) ចុះត្រួតពិនិត្យ និងបង្ក្រាបបញ្ហាពលករបរទេសធ្វើការលក់ដូរនៅក្នុងផ្សារខ្លងគ្រុរ និងផ្សាររោងម៉ៃ ស្ថិតនៅក្នុងភូមិ៧ ឃុំថាសាយ ស្រុកមឿង ខេត្តសាមុតសាខន ។ យោងតាមប្រភពព័ត៌មានបានឲ្យដឹងថាកម្លាំងអាជ្ញាធរថៃកំពុងបើកកិច្ចព្រឹត្តិការណ៍បង្ក្រាបពលករខ្មែរ, ភូមា, ឡាវ, ឥណ្ឌា និងជនជាតិផ្សេងទៀតដែលកំពុងប្រកបមុខរកស៊ីនៅក្នុងប្រទេសថៃ បន្ទាប់ពីអាជ្ញាធរថៃ ប្រកាសប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងបញ្ហាពលករចំណាកខុសច្បាប់ ដែលកំពុងចូលមកដណ្តើមមុខរបររកស៊ីរបស់ពលរដ្ឋថៃ។

### ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៨

## កាត់ក្តី២ដងម្តងកាត់ទោសដាក់គុក៧ឆ្នាំ និងកាត់ក្តីម្តងទៀតលើកលែងបទចោទ ពិតជាប្រែប្រួលមេឃនិងដីយីលោកអ្នកច្បាប់ឡូយម្លេះ

http://www.yobminh.com/ បញ្ញា | January 18, 2018

ភ្នំពេញ៖ ជារឿងគួរឱ្យហួសចិត្តបំផុតដែល ជនជាប់ចោទជនជាតិចិនម្នាក់ដែលធ្លាប់ត្រូវបានតុលាការក្រុងភ្នំពេញ ប្រកាសសាលក្រមផ្តន្ទាទោសដាក់គុក ៧ឆ្នាំ រួចហើយ បែរជាត្រូវ លោកស្រី ថ្លាង ផាណែត ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ ប្រកាសលើកលែងបទចោទ និងតម្រូវឱ្យដោះលែងជនជាប់ចោទ ឱ្យមានសេរីភាព វិញក្រោយពី ជនជាប់ចោទបានប្តឹងទាស់ នឹងសាលក្រមចាស់ និងមានការស្នើសុំឱ្យលើកលែង របស់តំណាងអយ្យការ ពាក់ព័ន្ធករណី នាំនិស្សិតខ្មែរ រាប់សិបនាក់ទៅលក់ឱ្យធ្វើកម្មកររបស់រោងកាត់ដេរនៅប្រទេសចិន។

ដោយសារតែជនជាប់ចោទជាជនជាតិចិនមានឈ្មោះ Liu Wing Hing ភេទប្រុស អាយុ ៤២ឆ្នាំ បានប្តឹងទាស់នឹងសាលក្រម ដែលផ្តន្ទាទោសរូបគេ ដាក់ពន្ធនាគារ ៧ឆ្នាំនោះ លោកស្រី ថ្លាង ផាណែត ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ បើកសវនាការ ជំនុំជម្រះជាសាធារណៈកាលពីរសៀលថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧កន្លងទៅ និងបានពន្យាពេលប្រកាសកាសសាលក្រមម្តងរួចមកហើយ ចុងក្រោយលោកស្រី ចៅក្រមបានសម្រេចលើកលែងបទចោទប្រកាន់លើជនជាប់ចោទតែម្តង ។

សូមបញ្ជាក់ថា លោក រៀល សុភិន ជាតំណាង អយ្យការបានចោទប្រកាន់លើឈ្មោះ Liu Wing Hing ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិចិន ពីបទ នាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន ប្រព្រឹត្តអំឡុងចុងឆ្នាំ២០១៥

យោងតាមមាត្រា ១១ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺក្រោយពីសាកសួរដេញដោលចប់សព្វគ្រប់ លោក រៀល សុភិន ជាតំណាងអយ្យការ ដែលជាចោទប្រកាន់លើជនជាប់ចោទផ្ទាល់ បែរជាស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើជនជាប់ចោទជាជនជាតិឈ្មោះ Liu Wing Hing ទៅវិញ ទីបំផុត តុលាការ ជូនតាមសំណើរ។

នៅក្នុងសវនាការកាលពីរសៀលថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧កន្លងទៅនោះលោក អ៊ិន ស៊ីម៉ាណាន់ ភេទប្រុស អាយុ ៣៤ឆ្នាំ មុខរបរ ជានាយក វិទ្យាស្ថាន បណ្តុះ បណ្តាល គណនេយ្យ វិជ្ជាជីវៈ (IPAT) (ធ្លាប់បានតុលាការផ្តន្ទាទោស ដាក់គុក ៧ឆ្នាំ ជាមួយជនជាប់ចោទឈ្មោះ Liu Wing Hing) បានឆ្លើយក្នុងនាមជាសាក្សីនៃ សំណុំរឿងប្តឹងទាស់ សាលាក្រមនេះរបស់ជនជាប់ចោទឈ្មោះ Liu Wing Hing ថា ខ្លួនពិតជាបាន ផ្សព្វផ្សាយជ្រើសរើសនិស្សិត ឱ្យទៅរៀននៅសាកលវិទ្យាល័យ ច្នៃម៉ូតសម្លៀកបំពាក់ ផ្នែកច្នៃម៉ូតសម្លៀកបំពាក់ ក្នុងប្រទេសចិន ដោយតម្រូវឱ្យនិស្សិតបង់លុយពី ២,៥០០ដុល្លារ ទៅ៤,៥០០ដុល្លារ។

លោកបានសន្យាជាមួយនិស្សិតថា នៅពេលទៅដល់ប្រទេសចិន និស្សិតអាច មានការងារធ្វើក្រៅម៉ោង បានប្រាក់ខែចន្លោះពី ៥០០ ទៅ៦០០ដុល្លារ ខ្លួនមិនបាន បោកប្រាស់និស្សិតយកទៅលក់ឱ្យធ្វើជាកម្មករ នៅរោងចក្រក្នុងប្រទេសចិនឡើយ ។ លោកបញ្ជាក់ថា ជនជាប់ចោទឈ្មោះ Liu Wing Hing ជាអ្នកយកលុយសេវា រត់ការនាំនិស្សិតទៅរៀននៅប្រទេសចិន និងជាអ្នករត់ការឯកសារ សម្របសម្រួល ទំនាក់ទំនង ជាមួយសាលានៅប្រទេសចិនទាំងអស់ពោលគឺ ការនាំនិស្សិតចេញទៅប្រទេសចិន និងរៀបចំទទួលនិស្សិតនៅប្រទេសចិន ជាតួនាទីរបស់ ជនជាប់ចោទឈ្មោះ Liu Wing Hingទាំងអស់ ។ ចំណែកជនជាប់ចោទឈ្មោះ Liu Wing Hing បានបដិសេធថា ខ្លួនមិនបានដឹងរឿងអ្វីទេ គឺគ្រាន់តែយកលុយពីលោក អ៊ិន ស៊ីម៉ាណាន់ ដើម្បីជួយរត់ការឯកសារ និងនាំនិស្សិតទាំងអស់ទៅប្រទេសចិនតែប៉ុណ្ណោះ ។

ជនរងគ្រោះដែលបានចូលរួមក្នុងសវនាការបាន អះអាងថា មាននិស្សិតចំនួន ២២នាក់ដែលត្រូវចាញ់បោកជនជាប់ចោទទាំងពីរនាក់ខាងលើ អស់ប្រាក់ពីចន្លោះ ២,៥០០ដុល្លារ ទៅ៤,៥០០ដុល្លារក្នុងម្នាក់ៗ ។ មិនដូចអ្វីដែលបានសន្យា ជនជាប់ចោទបាន បញ្ជូនពួកគេ ទៅធ្វើជាកម្មកររោងចក្រកាត់ដេរ ដោយធ្វើការពី៨ទៅ១០ម៉ោងក្នុង១ថ្ងៃ ដោយគ្មានពេលសម្រាក និងទទួលបានប្រាក់ខែតែ ១០០ ទៅ ១២០ដុល្លារតែប៉ុណ្ណោះ មិនដូចជាអ្វីដែលជនជាប់ចោទបានសន្យានោះទេ។ ក្រោយពីពួកគេដឹងខ្លួនថា ត្រូវចាញ់បោកគេ ជនជាតិចិនបាន ដកហូតលិខិតឆ្លងដែនរបស់បពួកគេទុកនិងបង្ខាំងពួកគេឱ្យធ្វើការគ្មានពេលសម្រាក។ ក្រោយមកដោយទ្រាំមិនបាន បពួកគេក៏បាននាំគ្នារត់ទៅរកស្ថានទូតខ្មែរឱ្យជួយអន្តរាគមន៍ និងបញ្ជូនមកប្រទេសកម្ពុជាវិញ ។ គួររំលឹកថា ជនជាប់ចោទ ទាំង២នាក់ខាងលើ ធ្លាប់ត្រូវបាន តុលាការក្រុងភ្នំពេញ ប្រកាសសាលក្រមផ្តន្ទាទោស ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ៧ឆ្នាំ កាលពីអំឡុងចុងខែកញ្ញា ឆ្នាំ២០១៧កន្លងទៅ ប៉ុន្តែ ជនជាប់ចោទឈ្មោះ Liu Wing Hing ជាជនជាតិចិនបាន ប្តឹងទាស់នឹងសាលក្រម ៕

## ជនរងគ្រោះខ្មែរចាញ់ក្តីក្រុមហ៊ុនគ្រឿងសមុទ្រថៃ និងអាមេរិកាំង

https://khmer.voanews.com/ 18 មករា 2018 ម៉ែន គឹមសេង

វ៉ាស៊ីនតោន៖ តុលាការសហរដ្ឋអាមេរិកបានកាត់ក្តីឱ្យក្រុមហ៊ុនគ្រឿងសមុទ្រអាមេរិកាំងនិងថៃឈ្នះលើបណ្តឹងស្តីពីការកេងប្រវ័ញ្ចកម្លាំងពលកម្មជនរងគ្រោះកម្ពុជា។ ប៉ុន្តែជនរងគ្រោះ បានប្តឹងបន្តទៅសាលាឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចនេះ។ តុលាការសហព័ន្ធប្រចាំតំបន់ភាគកណ្តាលរដ្ឋកាលីហ្វញ៉ាបានសម្រេចឱ្យក្រុមហ៊ុនគ្រឿងសមុទ្រផាត់ថាណានិងក្រុមហ៊ុនអាហារបង្កក S.S Frozen Food របស់ថៃ និងក្រុមហ៊ុន Rubicon Resources និងក្រុមហ៊ុន Wales

& Co. Universe Ltd. របស់អាមេរិកាំងឈ្នះក្តី ដោយផ្អែកលើហេតុផលថា ដើមបណ្តឹងមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា ក្រុមហ៊ុនបានចូលរួមកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬ បានដឹង និងទទួលផលពីការជួញដូរមនុស្សទេ។

លោក កែវ វដ្ឋា អតីតពលករវងគ្រោះ និងជាដើមបណ្តឹងម្នាក់ក្នុងចំណោម៧នាក់បានបញ្ជាក់ប្រាប់ VOA កាលពីថ្ងៃពុធថា លោកមាន «ការសោកស្តាយយ៉ាងខ្លាំង»ចំពោះការសម្រេចចិត្តនេះ ហើយថា«ជនរងគ្រោះបានខិតខំពុះពារខ្លាំងណាស់ទម្រាំអាចរៀបចំជាបណ្តឹងប្តឹងក្រុមហ៊ុនទាំងនេះបាន»។ លោកបានបន្ថែមថា៖ «ខ្ញុំដូចជាខកចិត្តដែរព្រោះគិតថាតុលាការសហរដ្ឋអាមេរិក នឹងអាចរកយុត្តិធម៌ឱ្យពួកខ្ញុំ ប៉ុន្តែដល់ពេលច្រានចោលពាក្យបណ្តឹងមានការខកចិត្ត ហើយក៏សោកស្តាយខ្លាំងដែរ ហើយក៏មិនដឹងថាត្រូវធ្វើប្រតិកម្មយ៉ាងម៉េចចំពោះតុលាការដែរពីព្រោះវាជានីតិវិធីច្បាប់របស់ខាងហ្នុងខ្ញុំមិនសូវយល់ពីច្បាប់ខាងហ្នុង»។

នៅក្នុងសាលក្រមចុះថ្ងៃទី៤ខែមករាដែល VOA ទទួលបាននៅសប្តាហ៍នេះ លោកចៅក្រម John F. Walter បានសម្រេចថាដើមបណ្តឹង «មិនទទួលបានអ្វីទាំងអស់តាមបណ្តឹងរបស់ពួកគេទេ»។ សាលក្រមបានបន្ថែមថា ការសម្រេចចុងក្រោយផ្តល់ផលប្រយោជន៍ដល់ចុងចម្លើយដែលជាក្រុមហ៊ុនទាំងបួននោះ។ សាលក្រមបានបន្ថែមថា៖ «ដើមបណ្តឹងមិនបានបង្ហាញថាក្រុមហ៊ុនRubicon និង Wales បានដឹងឬគួរតែដឹងថាមានការជួញដូរមនុស្សបានកើតមានឡើងនៅក្នុងរោងចក្ររបស់ក្រុមហ៊ុនផាត់ថាណាដែលស្ថិតនៅក្នុងខេត្តសុងក្លាទេ»។ តុលាការក៏សន្និដ្ឋានថាខ្លួនមិនមានដែនយុត្តាធិការកាត់ក្តីតាមការទាមទាររបស់ជនរងគ្រោះលើក្រុមហ៊ុនថៃផាត់ថាណាផងដែរ។

ជនរងគ្រោះកម្ពុជាចំនួន៧នាក់គឺលោក កែវ វដ្ឋា លោក សែម កុសល និងប្រពន្ធឈ្មោះ ប៊ុន សុភា លោកយ៉ែម បាន និងប្រពន្ធឈ្មោះណុល ណាគ្រី លោកសុក សង និងលោកផាន់ សុភាបានដាក់ពាក្យបណ្តឹងកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ប្រឆាំងនឹងក្រុមហ៊ុនផលិត និងទិញលក់គ្រឿងសមុទ្រទាំងបួនពីបទជួញដូរមនុស្ស ការបង្ខំឱ្យធ្វើពលកម្ម ទាសភាព បំបិទសិទ្ធិដើរហើរនិងសិទ្ធិការងារនិងធ្វើឱ្យជំពាក់បំណុល។ បណ្តឹងនេះអាចធ្វើឡើងបានដោយសារតែក្រុមហ៊ុន Rubicon Resources និងក្រុមហ៊ុនWales គឺជាក្រុមហ៊ុនអាមេរិកាំងដែលច្បាប់តម្រូវឱ្យជនរងគ្រោះអាចប្តឹងបានបើសិនជាក្រុមហ៊ុននេះមានជាប់ពាក់ព័ន្ធនឹងសកម្មភាពកេងប្រវ័ញ្ចកម្លាំងពលកម្មមនុស្សបើទោះបីជានៅក្រៅសហរដ្ឋអាមេរិកក៏ដោយ។

ក្រុមហ៊ុនផាត់ថាណា និងក្រុមហ៊ុន S.S. Frozen Food គឺជាក្រុមហ៊ុនគ្រឿងសមុទ្រថៃ ហើយមានរោងចក្របង្គារនៅខេត្តសុងក្លាដែលស្ថិតនៅភាគខាងត្បូងរបស់ប្រទេសថៃ។ ក្រុមហ៊ុនផាត់ថាណាលក់ផលិតផលបង្គារឱ្យក្រុមហ៊ុន Rubicon Resources ដើម្បីលក់បន្តទៅឱ្យអតិថិជននៅក្នុងសហរដ្ឋអាមេរិកក្នុងនោះមានហាងលក់ទំនិញរាយ Walmart ផងដែរ។ ក្រុមហ៊ុនWales ជាអ្នកពិនិត្យគុណភាពទំនិញពេលក្រុមហ៊ុន Rubicon Resources បញ្ជាទិញ។

ជនរងគ្រោះទាំង៧នាក់ត្រូវបានមេខ្យល់បញ្ឆោះបញ្ចូលឱ្យទៅធ្វើការនៅក្រុមហ៊ុនគ្រឿងសមុទ្រផាត់ថាណា និង S.S. Frozen Food ចន្លោះពីឆ្នាំ២០១០ ដល់២០១២។ ពួកគេបានធ្វើការនៅខេត្តសុងក្លាក្នុងអំឡុងពេលនៃការចោទប្រកាន់ថាមានការកេងប្រវ័ញ្ចនេះ។ ជនរងគ្រោះបានខ្ចីបំណុលគេដើម្បីធ្វើដំណើរ ហើយនៅបន្តជំពាក់គេរហូតដល់សព្វថ្ងៃ និងមានបញ្ហាសុខភាពដោយសារតែស្ថានភាពការងារលំបាកនិងការរស់នៅលំបាកលំបិន។

ដើមបណ្តឹងមិនអាចទទួលបានទិដ្ឋាការដើម្បីមកឆ្លើយបំភ្លឺនៅតុលាការបានដោយផ្ទាល់ទេ។ ប៉ុន្តែការសម្រេចធ្វើឡើងផ្អែកលើការផ្តល់អំណះអំណាងតាមលិខិតជាជាងការធ្វើសវនាការដេញដោលដោយផ្ទាល់មាត់។ ក្រុមមេធាវីការពារជនរងគ្រោះក៏បានសម្តែងការខកចិត្តចំពោះការសម្រេចរបស់តុលាការ។ នៅក្នុងសារជាអ៊ីម៉ែលផ្ញើមក VOA លោកស្រី Agnieszka Fryszman បានបញ្ជាក់បន្ថែមថា៖ «ចុងចម្លើយបានបដិសេធមិនស្នើសុំឱ្យមានសេចក្តីវិនិច្ឆ័យសង្ខេបលើការចោទពីការជួញដូរមនុស្សតាមការអះអាងរបស់ដើមបណ្តឹងជាច្រើននាក់ដែលនេះជាភស្តុតាងគ្រប់គ្រាន់ស្តីពីទាសករបំណុល ពលកម្មដោយបង្ខំ និងការជួញដូរមនុស្សដែលអាចយកមកបើកសវនាការបាន។ យើងជឿថាសេ

ចក្តីសម្រេចរបស់តុលាការដែលថាការអះអាងនេះមិនអាចយកមកកាត់ក្តីបាននៅសហរដ្ឋអាមេរិកគឺជាការខុសឆ្គងពីផ្លូវច្បាប់ហើយយើងមានផែនការនឹងប្តឹងឧទ្ធរណ៍»។

ក្រុមមេធាវីជនរងគ្រោះបានជូនដំណឹងទៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី១០ ខែមករាបង្ហាញពីចេតនាក្នុងការប្តឹងទៅឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចនេះ។ លោកស្រី Agnieszka បានបន្ថែមថា ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅទូទាំងពិភពលោក សហរដ្ឋអាមេរិកបានអនុញ្ញាតឱ្យប្រើប្រាស់ និងពង្រីកវិសាលភាពនៃ«ច្បាប់ការពារជនរងគ្រោះពីការជួញដូរ»ដើម្បីនាំយកជនល្មើសមកកាត់ទោសក្នុងតុលាការសហរដ្ឋអាមេរិកនិងដើម្បីធានាឱ្យមានការទទួលខុសត្រូវនៅគ្រប់ផ្នែកនៃក្រុមជួញដូរ។ លោកស្រីបញ្ជាក់ថា៖ «យើងជឿជាក់ថាសំណុំរឿងនេះមានតម្លៃដូចគ្នាស្របតាមច្បាប់ស្តីពីការការពារជនរងគ្រោះ»។

VOA បានព្យាយាមទាក់ទងក្រុមហ៊ុនមេធាវីSheppard, Mullin, Richer & Hampton ដែលការពារក្តីឱ្យក្រុមហ៊ុនគ្រឿងសមុទ្រទាំងបួនប៉ុន្តែពួកគេមិនបានឆ្លើយតបមកវិញទេ។

នៅក្នុងឯកសារការពារកូនក្តីក្រុមមេធាវីអះអាងថាក្រុមហ៊ុនដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកទាំងពីរគឺ Rubicon និងWales មិនដែលបានទទួលផលអ្វីពីកម្លាំងពលកម្មក្នុងពេលដែលដើមបណ្តឹងធ្វើការនៅក្នុងរោងចក្រផលិតបង្គារបស់ក្រុមហ៊ុនផាត់ថាណានៅខេត្តសុងក្លាទេ។ មេធាវីបន្ថែមថាក្រុមហ៊ុន Wales ធ្លាប់បានពិនិត្យមើលគុណភាពទំនិញរបស់ក្រុមហ៊ុនផាត់ថាណា ប៉ុន្តែសកម្មភាពនោះកើតមានឡើងមិនមែនក្នុងអំឡុងពេលដែលដើមបណ្តឹងធ្វើការនៅ រោងចក្រនោះទេ។ ក្រុមមេធាវីបានបន្ថែមថា៖ «មិនមានភស្តុតាងដែលថាមានដើមបណ្តឹងណាម្នាក់ដែលបានប៉ះផលិតផលដែលក្រុមហ៊ុន Wales ត្រួតពិនិត្យទេ។ ដូច្នេះហើយការពាក់ព័ន្ធណាមួយដូចការចោទប្រកាន់របស់ដើមបណ្តឹងស្តីពីពលកម្មដោយបង្ខំគឺមិនមានស្ថានទំងន់គ្រប់គ្រាន់ទេ»។ មេធាវីក៏បានការពារថាក្រុមហ៊ុនថៃផាត់ថាណាមិនមានពាក់ព័ន្ធនៅក្នុងការជួញដូរមនុស្សទេ ដោយសារតែក្រុមហ៊ុននេះមិនបានជ្រើសរើសពលករទាំងនោះដោយផ្ទាល់ទេហើយគ្រាន់តែមានភារកិច្ចអនុវត្តតាមច្បាប់ថៃដោយជួយរៀបចំបំពេញឯកសារសុំលិខិតអនុញ្ញាតធ្វើការងារ។ ការណ៍ដែលជនរងគ្រោះសម្រេចចិត្តចូលមកប្រទេសថៃដោយខុសច្បាប់មិនមានលិខិតឆ្លងដែននោះទេដែលមិនអាចឱ្យពួកគេធ្វើដំណើរដោយសេរីក្នុងប្រទេសថៃ ហើយមិនអាចប្តូរការងារបានដោយសារខ្លាចអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួន។ មេធាវីបានបន្ថែមថា៖ «ផលវិបាកទាំងនេះមិនអាចស្តីបន្ទោសមកលើក្រុមហ៊ុនផាត់ថាណាបានទេ»។ មេធាវីចុងចម្លើយបានការពារបន្ថែមថា រយៈពេលដែលដើមបណ្តឹងកែវ រដ្ឋាដែលជាជនរងគ្រោះតែម្នាក់គត់ធ្លាប់ធ្វើការនៅរោងចក្របង្កក S.S. Frozen Food ពីខែវិច្ឆិកាឆ្នាំ២០១១ដល់ខែមករាឆ្នាំ២០១២គឺក្រុមហ៊ុនមិនទទួលបានការបញ្ជាទិញណាមួយពីសហរដ្ឋអាមេរិកទេ។ ហើយក្រុមហ៊ុននេះក៏មិនដែលធ្វើការដោះដូរទំនិញជាមួយនឹងក្រុមហ៊ុនអាមេរិកាំងទាំងពីរផងដែរ។

ការចាញ់ក្តីនៅតុលាការជាន់ទាបនេះនាំឱ្យលោក កែវ រដ្ឋា នៅមានក្តីសង្ឃឹមតិចតួចប៉ុណ្ណោះលើសាលាឧទ្ធរណ៍របស់សហរដ្ឋអាមេរិក។ លោកកែវ រដ្ឋាបានបញ្ជាក់បន្ថែមថា៖ «បាទដូចជាពិបាកសង្ឃឹមដែរពីព្រោះអីមិនដឹងថា រាល់ពាក្យបណ្តឹងយើងហ្នឹងសាលាឧទ្ធរណ៍យកទៅពិនិត្យពិច័យច្បាស់លាស់យ៉ាងម៉េចឬក៏ថា ខាងហ្នុងបដិសេធទៀតឬក៏ឱ្យពួកខ្ញុំចាញ់ក្តីទៀតគឺអស់សង្ឃឹមមែនទែនហើយពីព្រោះថាមិនដឹងរកវិធីអី ដើម្បីតតាំងជាមួយគេទេពីព្រោះអីពួកខ្ញុំជាជនរងគ្រោះ គឺកាន់តែរងគ្រោះមួយសារទៀតហើយព្រោះខំចំណាយពេលវេលា និងធ្វើការជាមួយមេធាវីហើយទៅជាអាសារបង់ក៏ពិបាកដែរ»។ ដើមបណ្តឹងត្រូវប្រគល់ឯកសារទៅតុលាការ និងចុងចម្លើយនៅថ្ងៃទី១២ ខែមិនា។ បន្ទាប់ពីនោះចុងចម្លើយដែលជាក្រុមហ៊ុនមានពេលចំនួនមួយខែដើម្បីផ្តល់ចម្លើយការពារខ្លួន។ នេះបើតាមដីកាជូនដំណឹងរបស់សាលាឧទ្ធរណ៍ដែល VOA ទទួលបាន៕

## ចៅកែម៉ាស្សាផ្លូវភេទ បានបញ្ជូនដល់តុលាការ

http://www.rasmeinews.com/ រស្មីកម្ពុជា January 19, 2018, 12:15 PM

(ភ្នំពេញ)៖ស្ត្រីម្នាក់ជាចៅកែហាងម៉ាស្សាបង្កប់សេវាកម្មផ្លូវភេទ នៅថ្ងៃទី១៩ ខែមករា ត្រូវបាននគរបាលការិយាល័យ ប្រឆាំង ការ ជួញ ដូរ មនុស្ស និង ការពារ អនីតិជន នៃ ស្នង ការ ដ្ឋាន នគរបាល រាជធានី ភ្នំពេញ បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។ បច្ចុប្បន្នស្ត្រីរូបនេះ កំពុងស្ថិតក្រោមការសាកសួររបស់លោក គុជ គឹមឡុង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ស្ត្រីរូបនេះ ឈ្មោះ ប៉ែន រ៉ានី អាយុ ៣៩ ឆ្នាំ ស្នាក់ នៅ ផ្ទះ លេខ6F ផ្លូវ លឹម ឈាង ហាក់ ទី៣ ភូមិកន្ទោក ខាង ជើង សង្កាត់ កន្ទោក ខណ្ឌពោធិ៍សែន ជ័យ ៕ផាយានាថ/sn

## សូន្យ(OSS,One Stop Service) ជាដំណោះស្រាយចុងក្រោយរបស់ពលករខ្មែរ

http://www.prakpheaktra.com/ January 19, 2018

គ្រប់ចម្ងល់របស់បងប្អូនពលករខ្មែរនៅក្នុងប្រទេសថៃ និងមានដំណោះស្រាយនៅពេលឆាប់ៗខាងមុខនេះ.! ឯកសារប្រកាស (សូន្យវ៉ាន់ស្តប់) នៅក្នុងពេលឆាប់ៗខាងមុខនេះ ក្រសួងមហាផ្ទៃប្រទេសថៃ និងចុះបើកសូន្យ(OSS,OneStopService) ដើម្បីកែសម្រួលបញ្ហាមួយចំនួនជូនដល់បងប្អូនពលករខ្មែរ, ភូមា, ឡាវ, ដែលកំពុងជួបប្រទះបញ្ហាមួយចំនួនដូចជា៖

១-មានលិខិតឆ្លងដែនត្រួតសញ្ជាតិ(TD) តែស្នើសុំVisa អត់បាន,

២-Visa ហួស១៥ថ្ងៃ សុំប្តូរស្ថានភាពអត់បាន(workpermit)

៣-ពលករលុងបៀនថ្មីទាំងត្រួតសញ្ជាតិហើយនិងមិនទាន់ត្រួតសញ្ជាតិ ត្រូវទៅធ្វើប្រវត្តិរូបឬហៅថា(ថ.រ៣៨)

៤-ពលករដែលកាន់ប័ត្រស៊ីជម្ពូទាំងត្រួតសញ្ជាតិហើយ និងមិនទាន់ត្រួតសញ្ជាតិត្រូវទៅធ្វើប្រវត្តិរូបថ្មី។

៥-ពលករដែលបានត្រួតសញ្ជាតិហើយ មានវីសារធ្វើការផុតកំណត់នៅថ្ងៃទី៣១ មីនា ឆ្នាំ២០១៨ ត្រូវទៅធ្វើរឿងស្នើសុំវីសារការងាររយៈពេល០២ឆ្នាំនៅក្នុងសូន្យខាងលើផងដែរ។

*ចំពោះពលករដែលស្នាក់នៅខុសច្បាប់ក្នុងប្រទេសថៃ រាជរដ្ឋាភិបាលថៃមិនបានបើកអោយចុះឈ្មោះថ្មីទៀតឡើយដូច្នេះបងប្អូនគួរវិលត្រឡប់ទៅធ្វើប៉ាស្ព័រ MOU នៅឯប្រទេសខ្លួនរួចចូលមកធ្វើការម្តងទៀតអោយបានត្រឹមត្រូវ។

ទាំងអស់នេះគឺជាខ្លឹមសារនៃសេចក្តីប្រកាសរបស់គណៈរដ្ឋមន្ត្រីថៃកាលពីថ្ងៃអង្គារទី១៧ ខែមករា ឆ្នាំ២០១៨ កាលពីពេលថ្មីកន្លងទៅនេះ។

ដូច្នេះចំពោះបងប្អូនពលករខ្មែរដែលមានបញ្ហាដូចខាងលើ សូមរង់ចាំសេចក្តីប្រកាសបើកសូន្យ (OSS,One Stop Service) នៅក្នុងខេត្តក្រុងទាំងអស់ក្នុងប្រទេសថៃនាពេលឆាប់ៗខាងមុខនេះ។

## រាជរដ្ឋាភិបាលថៃ ប្រកាសដំឡើងប្រាក់ឈ្នួលជូនកម្មករទូទាំងប្រទេស

http://www.prakpheaktra.com/ January 18, 2018

រាជរដ្ឋាភិបាលថៃប្រកាសដំឡើងប្រាក់ឈ្នួលជូនកម្មករទូទាំងប្រទេសថៃ ចាប់តាំងពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ នេះតទៅ។ ខេត្ត-ក្រុង ដែលក្រសួងការងារថៃប្រកាសដំឡើងប្រាក់ឈ្នួលមានដូចជាខាងក្រោម៖

១-ភូកេត, ឈុនបុរី, រ៉ាក់យ៉ង =៣៣០បាត

២-ក្រុងថេប, ណាខនប៉ាធុម, នុនថាកបុរី, បាធុមថានី, សាមុតប្រាកាន,សាមុតសាខន, ឆាកឈើងសៅ = ៣២៥បាត-៣២៥បាត។

៣-ឌជនថានី, សុផាន់បុរី,សារ៉ាក់បុរី, អយុធ្យា, ណងខាយ, ឡប់បុរី,ត្រាត, ខនកែន, សង់ក្លា,សុរាថានី,ក្រាក់ប៊ី, ឈាងម៉ៃ, ណាខនរាចស៊ីម៉ា, ផាងងា=៣២៥បាត

៤-ចាន់បុរី, សាមុសង់ក្រោម, សាគន់ណាខន, មុខជាហាន, ណាខនយក, កាឡាសិន, ប្រាជីនបុរី=៣១៨បាត

៥-រយអិត,ប្រាជួបខិរីខាន់,ណាខនសុវណ្ណ,ស្រះកែវ,ផាត់ថាលុង,អុតតាឌិត,ឧដុនថានី,បុរីរ៉ាម,សុរិន្ទ,ផេតបុរី, ភិកសុតណាលោក,ភេតចាបូណ៌,ឆៃណាត, លេយ,យាក់សូថេន,ផាក់យៅ, បឹងកាន,ណាន,កាន់ចាក់ណាក់បុរី,អាងថង=៣១៥បាត

៦-សិងបុរី,ណាខនស៊ីថាមរាជ,ត្រាំង,ម៉ែហងសុសន,ឡាំប៉ាង,ឡាំភូន,ឈាងរ៉ាយ,សូកគោថៃ,កាំផែងភេត,ភិចិត, ឧថៃថានី, ស៊ីសារកេត, តាក់, ឆៃយ៉ាភូមិ, អំណាចឆាករើន, ភែរ, រាជបុរី, រ៉ាក់ណង, មហាសាខាម, ជុមផន, ណងបួឡាំភូ, សាក់ទូន=៣១០បាត

## ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៨

## អាជីវកម្មផ្លូវភេទ លើអនីតិជន មានការប្រែប្រួលពីលក្ខណៈចំហ មកជ្រកក្រោមរូបភាព ហាងម៉ាស្សា

http://www.cen.com.kh/ January 20, 2018

ភ្នំពេញ ៖ ប្រធាននាយដ្ឋានប្រឆាំងប្រឆាំងការជួញដូរ និងការពារអនីតិជន បញ្ជាក់ថា ឆ្លងតាមកិច្ចសហប្រតិបត្តិការ រវាងនគរបាលជាតិកម្ពុជា ជាមួយអង្គការមេត្រីអន្តរជាតិ (AIMSWAT) កន្លងមក ពិនិត្យឃើញថា បទល្មើសជួញដូរមនុស្ស ពិសេសអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជន មានការប្រែប្រួលពីលក្ខណៈចំហ មកជ្រកក្រោមរូបភាព ហាងម៉ាស្សា កោសជប់ ហាងកាត់សក់ និងខារ៉ាអូខេជាដើម ចំពោះជនរងគ្រោះជាអនីតិជន ដែលជ្រកក្រោមរូបភាពទាំងនេះ ត្រូវបាននាយកដ្ឋានសហការ ជាមួយអង្គការមេត្រីអន្តរជាតិ ធ្វើការស្រាវជ្រាវស៊ើបអង្កេត និងបង្ក្រាបបានជាបន្តបន្ទាប់ ។

លោកឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយដ្ឋានប្រឆាំងប្រឆាំងការជួញដូរ និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលជាតិ បានថ្លែងក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ នេះ នៅនាយកដ្ឋានប្រឆាំងប្រឆាំងការជួញដូរ និងការពារអនីតិជន មានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះពិតជាបានផ្តល់នូវចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗតាមរយៈនៃការហ្វឹកហាត់ផ្ទាល់សំដៅរកភាពរីកចម្រើន និងកិច្ចសហប្រតិបត្តិការល្អក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ពិសេសការបង្ក្រាបបទល្មើសចាប់ជនសង្ស័យបញ្ជូនទៅតុលាការ និងជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។

លោកឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បន្តថា បច្ចុប្បន្នប្រទេសកម្ពុជាទទួលបានសុខសន្តិភាពពេញលេញ ហើយការប្រើប្រាស់អាវុធត្រូវបានកាត់បន្ថយយ៉ាងច្រើន ប៉ុន្តែចំពោះមន្ត្រីនគរបាលជំនាញដែលបាននឹងកំពុងបំពេញភារកិច្ចរក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋចាំបាច់ត្រូវតែមានការស្វែងយល់បន្ថែមនូវវិធីសាស្ត្រការពារខ្លួនពេលប្រតិបត្តិការបង្ក្រាបបទល្មើស និងការប្រើប្រាស់អាវុធជាក់ស្តែងពេលចាប់ជនសង្ស័យ និងសង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលាប្រកបដោយសុវត្ថិភាព ។ លោកឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ បានគ្រូឧទ្ទេសនាម ដែលមានបទពិសោធន៍ខ្ពស់ ក្នុងការបំពេញភារកិច្ចកន្លងមក នៅសហរដ្ឋអាមេរិក ហើយក៏ជាលើកទី៨ ដែលអង្គការមេត្រីអន្តរជាតិ បានរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលនេះឡើង ជាពិសេសគឺជាលើកទី១ ដែលនគរបាលទទួលបានការហ្វឹកហាត់បាញ់កាំភ្លើងកាំរស្មី៕ ដោយះបញ្ញាស័ក្តិ

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អះអាងថាពលករខ្មែរជាង១លាននាក់ នៅថៃក្នុងនោះមានជាង៤០ភាគរយ ពុំទាន់មានលិខិតស្នាមត្រឹមត្រូវ**

http://cambodiapolice.com/ 12:12 pm 22 មករា 2018

ភ្នំពេញ ៖ ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអះអាងថា នាពេលបច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាងមួយលាននាក់នៅប្រទេសថៃ ហើយក្នុងនោះមានជាង៤០ភាគរយ ពុំទាន់មានលិខិតស្នាមនៅប្រទេសខ្លួនឯងត្រឹមត្រូវនៅឡើយ ខណៈពលករខ្មែរទៅធ្វើការនៅបរទេសមានលិខិតធ្វើដំណើរត្រឹមតែ ៣៩៧.៨៣៨ក្បាលប៉ុណ្ណោះ ។ ថ្លែងនៅក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអត្តសញ្ញាណកម្មឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ និងលើកទិសដៅបន្ត របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នាព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨នេះ នៅទីស្តីការក្រសួងមហាផ្ទៃ ឯកឧត្តម ព្រុំ សុខា បានលើកឡើងថា រាជរដ្ឋាភិបាលបានកំពុងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះពលករខ្មែរនៅក្រៅប្រទេស ជាពិសេសបានខិតខំធ្វើលិខិតស្នាមដោយស្របច្បាប់ដល់ពួកគេនោះ ។ ឯកឧត្តមរដ្ឋលេខាធិការ បញ្ជាក់ថា « នាពេលបច្ចុប្បន្ននេះពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ ហើយពុំទាន់មានលិខិតស្នាមត្រឹមត្រូវជាង៤០ភាគរយ ក្នុងចំណោមពលករប្រមាណជាងមួយលាននាក់នោះ ។ តែយ៉ាងណាក្តីរាជរដ្ឋាភិបាលនៅពីក្រោយខ្នងពួកគេជានិច្ច រាជរដ្ឋាភិបាលការពារសិទ្ធិរបស់ពួកគេជានិច្ច ហើយរាជរដ្ឋាភិបាលនឹងខិតខំធ្វើយ៉ាងណាឲ្យពួកគេធ្វើការដោយស្របច្បាប់ និងមានលិខិតស្នាមត្រឹមត្រូវផងដែរ » ។

បើយោងតាម ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃបានលើកឡើងថា ចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧នេះ ក្រសួងមហាផ្ទៃបានផ្តល់លិខិតឆ្លងដែនដល់ពលរដ្ឋខ្មែរប្រមាណ១.០៨២.៩១៦នាក់ និងលិខិតធ្វើដំណើរជូនពលករកម្ពុជាទៅធ្វើការនៅបរទេសចំនួន៣៩៧.៨៣៨នាក់ ។ យ៉ាងណាក៏ដោយដើម្បីផ្តល់ភាពងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋខ្មែរបន្ថែមទៀតនោះ ក្រសួងមហាផ្ទៃ បាននឹងកំពុងរៀបចំបើកបន្ថែមកន្លែងផ្តល់លិខិតឆ្លងដែនចំនួនបួនកន្លែងទៀតនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងផ្សារអ៊ីអនទី២ ។ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា បានបន្តទៀតថាការងារផ្តល់លិខិតធ្វើដំណើរពលករកម្ពុជានៅបរទេស ដែលមានសម្តេចក្រឡាហោម ស ខេង ដឹកនាំផ្ទាល់នោះបានកែសម្រួលលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដើម្បីកាត់បន្ថយបែបបទនីតិវិធីសាំញ៉ាំ និងបានរៀបចំបើកច្រកចេញចូលតែមួយចំនួន៣កន្លែង គឺនៅផ្សារទំនើបស្ទឹងមានជ័យថ្មី ខេត្តបាត់ដំបង និងក្រុងប៉ោយប៉ែត ។ រីឯការងារផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាកំពុងធ្វើការនៅប្រទេសថៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានបញ្ជូនក្រុមការងារចំនួន១៧៩នាក់ ទៅប្រចាំការនៅប្រទេសថៃ ដើម្បីផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ។

បើយោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានឲ្យដឹងផងដែរថា ចាប់ពីឆ្នាំ២០១៤ ដល់២០១៧ ការងារអត្រានុកូលដ្ឋាន បានសម្រេចចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបាន ដូចជាចុះបញ្ជីកំណើតបានចំនួន ៦១១.៣៧៩នាក់ បូកយោង ១.៨៩៤.៩២៤នាក់ ។ ចុះបញ្ជីបញ្ជាក់កំណើតបានចំនួន ១.២៣៦.៥៨២នាក់ បូកយោង១៣.៤៨៦.៧៤៥នាក់។ ចុះបញ្ជីអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរជាមួយជនបរទេសបានចំនួន ៥.២៦៩គូ ៕

**អតីតពលករចំណាកស្រុកអ្នកស្រី ឆាត់ ស បង្ហាញបទពិសោធន៍ធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី**

http://wmc.org.kh/ ថ្ងៃសុក្រ ទី១៩ ខែមករា ឆ្នាំ២០១៨ ជុំ ដោគជាតា

ជីវះព័ត៌មាន៖ អតីតពលករចំណាកស្រុក អ្នកស្រី ឆាត់ ស ដែលធ្លាប់ទៅបម្រើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ីបានឱ្យដឹងថា ការងារនៅប្រទេសមួយដែលមិនចេះភាសា និងស្គាល់ភូមិសាស្ត្រច្បាស់លាស់ ការចាញ់បោកមេ

ខ្យល់ ឬក្រុមហ៊ុន គឺជារឿងដែលសំណាងអាក្រក់ និងវេទនាបំផុតសម្រាប់អ្នកដែលជួបប្រទះនិងបញ្ហានេះ ។ តើរឿងរបស់អ្នកស្រី ឆាត់ ស ជួបប្រទះនឹងអ្វីខ្លះ?

អ្នកស្រី ឆាត់ ស ៖«*កាលណឹងមកពីខ្ញុំនឹកកូនខ្ញុំពេក ហើយខ្ញុំទារគេតេទៅកូន គេខ្លាចខ្ញុំរត់ទៅផ្ទះ ឈប់លែងធ្វើការអោយគេ ។ថៅកែប្រុសណឹងយកកែវមកបោកនៅមុខខ្ញុំ ខ្ញុំខ្លាចឡើងរាកនោម ហើយខ្ញុំខ្លាចក៏លួចរត់*»។ នេះជាការរៀបរាប់របស់អ្នកស្រី ឆាត់ ស ពលករដែលធ្លាប់ចេញទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

*ជីវៈប្រវត្តិនិងស្ថានភាពគ្រួសារ៖* អ្នកស្រី ឆាត់ ស ជាកូនកំព្រាឪពុកម្តាយស្លាប់ចោលតាំងពីក្មេងនៅក្នុងសម័យសង្គ្រាម។ មានបងប្អូន ៥នាក់ បាត់បង់ជីវិតអស់ ២នាក់។ មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែង។ អ្នកស្រីបានរៀបការនៅឆ្នាំ១៩៩៥ ។ ក្រោយរៀបការរួចអ្នកស្រីបានមករស់នៅទីក្រុងភ្នំពេញជាមួយនឹងស្វាមីនៅទីក្រុងភ្នំពេញ។ នៅពេលឡើងមករស់នៅទីក្រុងភ្នំពេញ អ្នកស្រីក៏ចូលធ្វើការងារជាកម្មការិនីរោងចក្រ។ ក្នុងជីវិតអាពាហ៍ពិពាហ៍របស់អ្នកស្រី ឆាត់ ស គឺមិនសូវមានការចុះសម្រុងនឹងគ្នា។ នៅឆ្នាំ ២០០៣ អ្នកស្រី ក៏បានសម្រេចចិត្តលែងលះស្វាមី ដោយសារតែមានបញ្ហាមួយចំនួន។ អ្នកស្រី ឆាត់ ស៖ «*ប្តីខ្ញុំកាលពីនេះណឹង ចាស់ទុំនាំទៅស្តីដណ្តឹង ហើយនៅពេលទៅទិញដីនៅមណ្ឌលគិរីនឹង ខ្ញុំប្រាប់គាត់ថា ប៉ាឯងស៊ីឈ្នួលអោយគេទៅ ពេលបានលុយហើយទៅដាំដំឡូងយើងទៅ ហើយដាំដំឡូងនឹងហើយ ខ្ញុំនៅធ្វើការរោចក្រ អោយ លុយកូនរៀន។ ខ្ញុំបង់លុយវេ្គដល់ហើយគាត់ញ៉ាំច្រើនរាល់តែថ្ងៃ ដល់ពេលរួចខ្ញុំពិបាកពេក ហើយក្រុមហ៊ុនឈូសយកដីនៅមណ្ឌលគិរីបាត់ទៀត ក៏លែងគ្នាតែម្តងទៅ*»។

*មូលហេតុទៅធ្វើការនៅប្រទេសម៉ាឡេស៊ី៖* ស្ថានភាពគ្រួសារក្រីក្រ និងជំពាក់បំណុលគេធ្វើអោយអ្នកស្រី ឆាត់ ស សម្រេចចិត្តរកការងារធ្វើនៅក្រៅប្រទេស ។ អ្នកស្រី អោយដឹងថា ការទៅធ្វើការនៅប្រទេសម៉ាឡេស៊ី គឺតាមរយៈក្រុមហ៊ុនមួយដែលមានភ្នាក់ងារបញ្ជូនពលករពីកម្ពុជាទៅប្រទេសម៉ាឡេស៊ី។ ក្នុងការដាក់ពាក្យទៅធ្វើការនៅប្រទេសម៉ាឡេស៊ីជាអ្នកបម្រើការងារតាមផ្ទះ អ្នកស្រី ឆាត់ ស ទទួលបានប្រាក់ចំនួន ៨០០ដុល្លារពីក្រុមហ៊ុនបញ្ជូនពលករនោះ។ អ្នកស្រី ឆាត់ ស៖«*ខ្ញុំទៅប្រទេសម៉ាឡេស៊ី ដើមឡើយខ្ញុំពិបាកចិត្ត ខ្ញុំអត់មានអីសម្រាប់ចិញ្ចឹមគ្រួសារ កាលនោះខ្ញុំលែងគ្នា(ស្វាមី) ហើយខ្ញុំមានកូនពីរ កូនខ្ញុំប្រុសនៅតូចទេ ហើយកូនស្រីរៀនថ្នាក់ទី៨ ។ ពេលក្រោយមកខ្ញុំគិតថា ខ្ញុំឡើងយន្តហោះទៅក្រុមហ៊ុននឹង គេអោយខ្ញុំ ៨០០ដុល្លារ ៨០០០នឹងខ្ញុំយកទៅសងគេដែលយើងសល់ពីជំពាក់គេកាលយើងទៅទិញដីនៅមណ្ឌលគិរី ហើយខ្ញុំអោយទៅមើលការទទួលខុសត្រូវកូនខ្ញុំគេអោយ ២០០ដុល្លារ ហើយខ្ញុំយកទៅទិញខោអាវស្លៀកពាក់យកទៅប្រទេសគេខ្លះ*»។

*ស្ថានភាពធ្វើការនៅប្រទេសម៉ាឡេស៊ី៖* អ្នកស្រី ឆាត់ ស ទៅធ្វើការងារនៅម៉ាឡេស៊ី មានរយៈពេល ២ឆ្នាំ ហើយប្រាក់ខែដែលត្រូវទទួលបាន គឺ ១៨០ដុល្លារ ក្នុងមួយខែ។ការងារដែលអ្នកស្រី ធ្វើនៅទីនោះ គឺត្រូវក្រោកពីក្បាលព្រលប់ជារៀងរាល់ថ្ងៃ។ អ្នកស្រី ឆាត់ ស ៖«*ក្រោយពីយប់ម៉ោង ៤ណឹង ខ្ញុំត្រូវដើបហើយ ខ្ញុំបោកខោអាវ លាងចាន លាងឆ្នាំង ហើយខ្ញុំមិនដឹងញ៉ាំអីទេ ខ្ញុំលើកមនុស្សចាស់ម្នាក់ណឹង១០០គីឡូ យកគាត់ លើកគាត់ទៅហាត់ប្រាណរួចហើយ ពេលព្រលឹមឡើងធ្វើការងារផ្ទះហើយ ខ្ញុំកាត់ស្មៅ លាងឡាន២ ហើយជូតផ្ទះ ជញ្ជាំងផ្ទះ ដំបូលផ្ទះគឺត្រូវតែជូតរាល់ថ្ងៃ តែពេលថ្ងៃចឹងគេអោយយើងគេងបានកន្លះម៉ោងដែរ ហើយដល់ពេលរួច ពេលបងប្អូនគេមកចឹងយើងធ្វើចេះតែធ្វើទៅ តែការញ៉ាំរបស់គេ គេអោយយើងញ៉ាំគ្រប់គ្រាន់*»។ ត្បិតថា ការផ្តល់អាហារហូបចុកគ្រប់គ្រាន់តែការងារដែលត្រូវទទួលខុសត្រូវរបស់អ្នកស្រី ឆាត់ ស ក៏មានច្រើន និងហួសពីកម្លាំង ពលកម្ម បូករួមទាំងការសម្លុតពីថៅកែដែលជាម្ចាស់ផ្ទះមិនអោយជួបសាច់ញាតិ ធ្វើអោយអ្នកស្រី សម្រេចចិត្តលួចរត់នៅពេលដែលធ្វើការបានរយៈពេលបីខែ។ អំឡុងពេលលួចរត់មិនមែនជារឿងងាយស្រួលសម្រាប់អ្នកស្រី នោះទេ គឺមានបញ្ហាជាច្រើនដែលបានកើតឡើង។

អ្នកស្រី ឆាត ស ៖ «*ពេលរត់ទៅជនជាតិណឹងគេសួរ ទៅណា ហើយខ្ញុំធ្វើការវិកាយហាត់ប្រាណ ហើយគេសួរផ្ទះនៅណា? ហើយខ្ញុំក៏ចង្អុលផ្ទះ ហើយគេអោយខ្ញុំចូលទៅផ្ទះវិញ ហើយខ្ញុំក៏ចាក់សោរចូលព្រៃតាមមាត់ទន្លេក៏រត់*

*ទៀត គេឲ្យខ្ញុំទៅផ្ទះវិញ ?កូនខ្ញុំពេក្រទេស ហបុរីចំនួន ៤៧៨នាក់ ពលករកម្ពុជាដែលកំពុងធ្វើការនៅបរទេសចំនួន ប ផ្ទះវិញ ហើយគេក៏ទៅផុត កន្លះម៉ោងក្រោយមកខ្ញុំក៏រត់ម្តងទៀត ដោយរត់ចូលក្នុងព្រៃតាមមាត់ទន្លេ ហើយនៅពេលនោះ អ្នកហាត់ប្រាណនៅទីនោះឃើញខ្ញុំហើយគេក៏បានស្រែកហៅប៉ូលិស ខ្ញុំថា កុំហៅប៉ូលិសខ្ញុំសុំអង្វរានស្រែកហៅប៉ូលីសយកខ្ញុំទៅ ខ្ញុំក៏វើអោយដៃអោយខ្ញុំស្រែកហៅប៉ូលីស ប៉ុន្តែខ្ញុំក៏បានលើកដៃសំពះសុំអង្វរគេ ប៉ុន្តែប្តីជាជនជាតិម៉ាឡេស៊ីនោះខ្ទប់មាត់ប្រពន្ធកុំអោយស្រែក ហើយធ្វើអោយដៃអោយខ្ញុំទៅ ខ្ញុំក៏ចេះរត់ទៅហួត*»។ តែទីបំផុត អ្នកស្រីបានជួបរឿងសំណាងមួយ ដោយបានជួបក្រុមពលករចំណាកស្រុកដូចគ្នា។ ពួកគេក៏ជួយ អ្នកស្រី បានផ្តល់ព័ត៌មានមកកម្ពុជា។ អ្នកស្រី ឆាត់ ស បានប្រាប់បន្តថា ៖«*ខ្ញុំដើរទៅដល់ណឹង ខ្ញុំឃើញផ្ទះមួយល្វែងណឹងស្ងាត់ ខ្ញុំក៏ចូលទៅណឹង ហើយខ្ញុំឃើញប្តីប្រពន្ធគេដេកនៅណឹង ខ្ញុំក៏ធ្វើកាយវិការដាក់គេ គេមិនដឹងធ្វើម៉េច គេក៏ហៅមេការគេមក ហៅមេការមកគេកយកខ្ញុំទៅប៉ូលិស។ ខ្ញុំនិយាយអង្វរគេ ហើយគេអាណិត គេក៏អោយលេខ(ទូរស័ព្ទ)ចុចមកបងប្អូនខ្មែរបងស្រីខ្ញុំទាក់ទងទៅតាមមេខ្យល់គេនៅខាងស្ពួង ហើយគេយកខ្ញុំមកស្រុកខ្មែរវិញជាង ៣យប់ ៣ថ្ងៃ ហើយអស់ ១ពាន់ដុល្លារ ហើយខ្ញុំធ្វើការអោយគេ ៣ខែ អត់បានលុយទេ*»។ រយៈពេលធ្វើការ ៣ខែនៅទីនោះ អ្នកស្រីមិនទទួលបានប្រាក់ខែអ្វីនោះទេ។ មួយវិញទៀតអំឡុងពេលដែលអ្នកស្រី ឆាត់ ស លួចរត់ និងស្វែងរកជំនួយពីសាច់ញាតិនៅកម្ពុជាធ្វើយ៉ាងម៉េចអោយបានត្រឡប់មកកម្ពុជាវិញ អ្នកស្រីក៏ត្រូវចំណាយប្រាក់ចំនួន ១០០០ ដុល្លារ។

អ្នកស្រី ឆាត សៈ «*ការមកណឹងគេញត់ឡើង ជិះតាមថៃ បីយប់បីថ្ងៃ មកដល់ថៃណឹង អត់មានអីទេ ហើយអ្នកដែលមកជាមួយខ្ញុំសុទ្ធតែអ្នកលួចរត់ដូចជាខ្ញុំ ហើយពួកយើងនាំគ្នាចែកបាយគ្នាញ៉ាំ អ្នកណាមានលុយទិញអីអោយញ៉ាំចឹងទៅ។នៅពេលមកដល់ប៉ោតប៉ែតបានជិះឡានមកផ្ទះវិញ។មកដល់ផ្ទះពីរខែ បីខែ ទើបយើងដឹងថាខ្លួនខ្ញុំឈឺញ៉ាំអីកើត ហើយដើរអត់កើត។ តែឥលូវខ្ញុំមានសុខភាពល្អវិញ ធ្វើការធម្មតាវិញ តែកាលយើងមកពីណឹងវិញ បីខែ គឺពិបាក* »។ ទាំងនេះគឺជាសាច់រឿងពិតរបស់អ្នកស្រី ឆាត់ ស ។ នៅមានរឿងមួយទៀតដែរ ដែល អ្នកស្រី ឆាត់ ស បានចែករំលែកដែរនោះ គឺ ទាក់ទងទៅនិងភ្នាក់ងារបញ្ជូនពលករ។ អ្នកស្រី ឆាត់ ស ៖«*នៅកន្លែងស្តុបមនុស្សនៅកន្លែង Agencyណឹង គឺធ្វើបានគ្នាណាស់ មានអាវ៉ៃគ្នា មានអាគុកងងឹត មានកន្លែងភ្លឺ មានអ្នកទៅពីស្រុកខ្មែរទៅគេអោយនៅកន្លែងផ្សេងដាច់ដោយឡែក ហើយមានអ្នកខ្លះទៀតលួចរត់ដូចខ្ញុំដែរ* »។

ក្នុងរបាយការណ៍រួមគ្នាមួយរបស់អង្គការពលកម្មអន្តរជាតិ(ILO)និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) រកឃើញថា ពលករចំណាកស្រុកខ្មែរ ៨នាក់ ក្នុងចំណោម ១០នាក់ត្រូវបានរំលោភបំពានសិទ្ធិការងារ ឬស្មើនឹង៨០ ភាគរយ និង ៧នាក់ ក្នុងចំណោម ១០នាក់ មានបញ្ហាជំងឺផ្លូវចិត្ត ឬស្មើនឹង ៦៦ភាគរយ។ ក្នុងនោះមន្ត្រីអង្គការសង្គមស៊ីវិលដែលធ្វើការលើការការពារសិទ្ធិស្ត្រី និងកុមារ រកឃើញថា មូលហេតុនាំឲ្យមានបញ្ហាផ្លូវចិត្តដោយសារតែពលករត្រូវបានថៅកែបង្ខំឲ្យធ្វើការហួសកម្លាំង របបអាហារមិនគ្រប់គ្រាន់ និងការមិនផ្តល់ប្រាក់កម្រៃ ឬបិទសិទ្ធិមិនឲ្យទាក់ទងមកសាច់ញាតិ។ តាមសំណូមពររបស់អ្នកស្រី ឆាត់ ស គឺចង់អោយរដ្ឋាភិបាល និងអ្នកមានទាំងអស់ នៅក្នុងស្រុកខ្មែរជួយបង្កើតការងារអោយបានច្រើន ជាជាងអោយពួកគាត់ទៅធ្វើជាកម្មករគេនៅក្រៅប្រទេស។ អ្នកស្រី ឆាត់ ស ៖«*ខ្ញុំគិតថា ធ្វើការនៅក្នុងស្រុកស្រួលជាងចំណាកស្រុក ចំណាកស្រុកបើគេមាននិស្ស័យ សំណាងគេល្អទៅគេមានបានទៅ ប៉ុន្តែបើយើងអត់សំណាងវិញគឺពិបាកណាស់ គឺមិនដូចស្រុកយើងបើយើងឈឺយើងចេះតែប្រាប់គេថាឈឺ យើងនិយាយស្តាប់គ្នាបាន។ ចំពោះខ្មែរយើងអ្នកដែលទៅគេគ្មានសូម្បែអ្នកដែលចេះភាសាគេទេ*»។

## អាជ្ញាធរថៃចាប់ឆ្នើមចុះចាប់ពលករដែលធ្វើការខារលក់ដូរក្នុងផ្សារ

http://www.prakpheaktra.com/ January 19, 2018

ថៅកែហាងលក់មាស និងលក់ឥវ៉ាន់ចាបហួយព្រមទាំងពលករសញ្ជាតិភូមាចំនួន០៨នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួន បន្ទាប់ពីជួលពលករអោយធ្វើការខុសលក្ខខ័ណ្ឌច្បាប់ការងារ។ កាលពីថ្ងៃសុក្រទី១៩ ខែមករា ឆ្នាំ២០១៨ កម្លាំងសមត្ថកិច្ចក្រសួងការងារសហការជាមួយកម្លាំងអាជ្ញាធរមូលដ្ឋានមានទាហាន និងតម្រួតអន្តោប្រវេសន៍ចុះ

បង្ក្រាបទីតាំងលក់មាស និងឥវ៉ាន់ចាបហួយមួយកន្លែង ស្ថិតនៅផ្ទះលេខ 293-35-36 ជាប់ផ្សារគេតកាសេម១ ក្នុងស្រុកសុរាច ខេត្តសុរ៉ាតថានី ប្រទេសថៃ ។ យោងតាមប្រភពព័ត៌មានថៃ ចុះផ្សាយអោយដឹងថា ទីតាំងលក់ដូរខាងលើបានជួលពលករភូមាចំនួន ០៨នាក់ អោយធ្វើការលក់ឥវ៉ាន់ និងទទួលប្រាក់ពីអ្នកទិញ ដោយការងារបែបនេះគឺខុសនិងច្បាប់ការងារប្រទេសថៃ ដែលហាមឃាត់មិនឲ្យពលករបរទេសលក់ដូរ និងមុខតូបជាដាច់ខាត ហើយអត្រាទោសទណ្ឌត្រូវផាកពិន័យជាប្រាក់ចាប់ពី២០០០฿ ដល់ ១០០,០០០฿ ឬទាំងចាប់ទាំងផាក់ពិន័យ។

## ចាប់ពលករខ្មែរ០៩នាក់ កាន់លិខិតឆ្លងដែនដើរលេង មកធ្វើការនៅថៃ

http://www.prakpheaktra.com/ January 19, 2018

ពលករខ្មែររស់នៅក្នុងខេត្តបន្ទាយមានជ័យ, សៀមរាប និងកំពុងធំ ចំនួន០៩នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួន បន្ទាប់ពីធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ។ កាលពីថ្ងៃអង្គារទី១៧ ខែមករា ឆ្នាំ២០១៨ កន្លងទៅ កម្លាំងអាជ្ញាធរថៃបានធ្វើការចុះបង្ក្រាបពលករចំណាកស្រុកខុសច្បាប់ដែលកំពុងធ្វើការនៅក្នុងតំបន់ទេសចរណ៍ក្រុងប៉ាតាយា ស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ប្រទេសថៃ បានបើកយុទ្ធនាការបង្ក្រាបពលករចំណាក់ស្រុកខុសខច្បាប់នៅក្នុងតំបន់ក្រុងប៉ាតាយាយ៉ាងសកម្មដើម្បីទប់ស្កាត់បញ្ហាអំពើជួញដូរមនុស្ស។

យោងតាមប្រភពពីពលករខ្មែរយើងម្នាក់ បានរាយការណ៍ប្រាប់តាមរយៈទូរស័ព្ទអោយបានដឹងថា មានបងប្អូនមិត្តភក្តិរបស់គាត់ចំនួន០៩នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួន ខណៈពេលកំពុងធ្វើការនៅក្នុងហាងម៉ាស្សាបាតជើងមួយកន្លែង ស្ថិតនៅក្នុងផ្លូវ (សាយសង) ក្បែរឆ្នេរសមុទ្រក្រុងប៉ាតាយ៉ា តាមការរៀបរាប់របស់ពលករខ្មែររូបនោះបន្តទៀតថា បងប្អូនគាត់ និងមិត្តភក្តិខ្លះទៀតមានលិខិតឆ្លងដែន ដើរលេង និងខ្លះទៀតគ្មានឯកសារអ្វីទាំងអស់ ។ ក្រោយពេលចាប់ខ្លួនបងប្អូនមិត្តភក្តិទាំង០៩នាក់ ត្រូវកម្លាំងអាជ្ញាធរថៃបញ្ជូនទៅដាក់គុកនៅក្នុងអធិការដ្ឋានតម្រួតក្រុងប៉ាតាយ៉ាបានចំនួនពីរយប់ រួចត្រូវសមត្ថកិច្ចបញ្ជូនបន្តទៅដាក់គុកនៅទីក្រុងបាងកក ប្រទេសថៃ។ ពលករខ្មែររូបនោះបានសូមអំពាវនាវដល់បងប្អូនពលករខ្មែរខុសច្បាប់ទាំងអស់ អោយមានការប្រុងប្រយ័ត្ន និងកុំធ្វើការខុសច្បាប់អោយសោះទោះបីជាមានលិខិតឆ្លងដែនលេងក៏មិនអាចជួយបងប្អូនបានដែរ។

## អាជ្ញាធរថៃ ចុះអនុវត្តច្បាប់ការងារ ហាមពលករបរទេសធ្វើការលក់ដូរ

http://www.prakpheaktra.com/ January 21, 2018

ថៅកែថៃដេកព្រួយបន្ទាប់ពីអាជ្ញាធរថៃចុះអនុវត្តច្បាប់ការងារម៉ឺងម៉ាត់ចាប់ពលករធ្វើការលក់ដូរខុសលក្ខខ័ណ្ឌបន្ទាប់ពីកម្លាំងអាជ្ញាធរថៃចុះអនុវត្តច្បាប់ការងារ និងបង្ក្រាបពលករចំណាកស្រុកធ្វើការខុសច្បាប់អស់រយៈពេលជាងមួយសប្តាហ៍កន្លងមក គេសង្កេតឃើញថា បណ្តាថៅកែថៃមួយចំនួនធំដែលប្រកបរមុខរបររកស៊ីលក់ដូរនៅតាមផ្សារឬក្នុងហាងទំនើបនានាក្នុងប្រទេសថៃ ហើយកំពុងជួលពលករបរទេសអោយធ្វើការនោះ ចាប់ផ្តើមមានការព្រួយបារម្ភចំពោះកម្មកររបស់របស់ខ្លួនព្រោះកម្មករភាគច្រើនជាពលករបរទេស ហើយការងារដែលពលករទាំងនោះកំពុងធ្វើជាការងារ ដែលខុសពីលក្ខខ័ណ្ឌនៃច្បាប់ការងារបានកំណត់។ ដូច្នេះបញ្ហានេះបានអោយថៅកែថៃខ្លះទៀតរងគ្រោះដោយសារច្បាប់នេះ ហើយអាចនឹងត្រូវបានបិទទ្វារមុខរបររបស់ខ្លួន ដោយសារតែរត់មិនរួចនិងការជួលជនជាតិថៃដូចគ្នាអោយមកធ្វើការជនួសពលករបរទេស។

រីឯរាជគិបាលថៃក៏មិនមានដំណោះស្រាយ ជួយការកែសម្រួលលើបញ្ហាច្បាប់ការងារនេះនៅឡើយ ដូច្នេះបណ្តាថៅកែថៃ កំពុងតែព្រួយបារម្ភយ៉ាងខ្លាំង ព្រោះត្រង់ចំណុចវាធ្វើអោយសម្ថកិច្ចខិលខូចមួយចំនួន ឆ្លៀតឱកាសរកផលប្រយោជន៍ពីច្បាប់ការងារនេះ។ យ៉ាងណាមិញថៅកែថៃមួយចំនួនបានទាមទារឲ្យរាជរដ្ឋាភិបាលថៃ យកបញ្ហានេះទៅពិចារណា ហើយកែសម្រួលលើច្បាប់ការងារមួយចំនួនដែលពលរដ្ឋថៃមិនធ្វើ អាចសម្រួលអោយពលករបរទេសធ្វើការបាន ដើម្បីជួយសម្រួលដល់អាជីវករថៃកំពុងជួលពលករបរទេសអោយធ្វើការ។ គួរបញ្ជាក់ផងដែរថាកាលពីឆ្នាំ២០១៧កន្លងទៅក្រុមអាជីវករលក់ខោអាវក្នុងតំបន់ប៉ាទូណាម ទីក្រុងបាងកក ធ្លាប់នាំគ្នាទាមទារឲ្យសភាពាណិជ្ជកម្ម

ថៃលើកយករឿងនេះមកដោះស្រាយផងដែរ តែបានស្ងាត់ទៅវិញបន្ទាប់ពីរាជ រដ្ឋាភិបាលថៃប្រកាសច្បាប់មាត្រា៤៤ ពន្យារការអនុវត្តច្បាប់គ្រប់គ្រងពលករបរទេសថ្មីកាលពីពាក់កណ្ដាលឆ្នាំ២០១៧។

## ជួយស្វែងរកសាច់ញាតិផងពលករខ្មែរ២នាក់ ត្រូវរថយន្តបុកស្លាប់នៅខេត្តឈុនបុរី

http://www.prakpheaktra.com/ January 21, 2018

ពលករខ្មែរធ្វើការនៅក្នុងខេត្តឈុនបុរីពីរនាក់ជិះម៉ូតូទៅផ្សារត្រូវរថយន្តសណ្ដោងបុកស្លាប់ម្នាក់ និងរងរបួសម្នាក់យ៉ាងអាណោចអាធ័ម។ កាលពីវេលាម៉ោង០៤:០០ល្ងាចថ្ងៃអាទិត្យទី២១ ខែមករា ឆ្នាំ២០១៨ មានករណីគ្រោះថ្នាក់ចរាចរមួយបានកើតឡើងនៅត្រង់ចំណុចផ្លូវជាតិលេខ៣៤៤ បានបឹង-ក្លែងម៉ុំបង្គោលគីឡូម៉ែត្រ២៦-២៧ ស្ថិតក្បែរណងព្រី ស្រុកបានបឹងខេត្តឈុនបុរី ក្នុងករណីគ្រោះថ្នាក់ចរាចរនេះបានបណ្ដាលឲ្យបុរសពលករខ្មែរម្នាក់ត្រូវស្លាប់ភ្លាមៗនៅនិងកន្លែងកើតហេតុ និងម្នាក់ទៀតរងរបួសធ្ងន់ ត្រូវបានភ្នាក់ងារសង្គ្រោះ(ស្វាងស្រុកបានបឹង)បញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យបានបឹង ខេត្តឈុនបុរី បច្ចុប្បន្នជនរងគ្រោះដែលស្លាប់គេនៅមិនទាន់បញ្ជាក់ឈ្មោះប្រាប់នៅឡើយទេ ។ ក្រោយពេលកើតហេតុកម្លាំងសមត្ថកិច្ចតម្រួតស្រុកបានបឹងបានចុះធ្វើអន្តរាគមន៍ និងបញ្ជូនសាកសពជនរងគ្រោះយកទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីរង់ចាំសាច់ញាតិយកទៅធ្វើបុណ្យតាមប្រពៃណី។

## ហ្វីលីពីន ឈប់បញ្ជូនពលករទៅប្រទេសគុយវ៉ែត ដោយសារមូលហេតុមួយ

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 10:18

**រដ្ឋាភិបាលហ្វីលីពីន បានប្រកាសផ្អាកការបញ្ជូនពលកររបស់ខ្លួនទៅកាន់ប្រទេសគុយវ៉ែត ជាបណ្ដោះអាសន្ន ក្រោយមានករណីអត្តឃាតជាច្រើនរបស់ពលករហ្វីលីពីន នៅទីនោះ។ លោក Rodrigo Duterte ប្រធានាធិបតីហ្វីលីពីន អះអាងថា និយោជកគុយវ៉ែត ដែលរស់នៅក្នុងរដ្ឋ Gulf បានប្រើប្រាស់អំពើហិង្សាទៅលើពលករហ្វីលីពីនចំនួន ៤នាក់ ដែលជាហេតុបណ្ដាលឲ្យពួកគេត្រូវបង្ខំចិត្តធ្វើអត្តឃាត។ លោកបញ្ជាក់ទៀតថា នៅមានពលករនារីហ្វីលីពីនជាច្រើននាក់ទៀតក៏ធ្លាប់ត្រូវគេរំលោភបំពានផ្លូវភេទផងដែរនៅក្នុងប្រទេសគុយវ៉ែត។ ទាក់ទងនឹងបញ្ហានេះ គុយវ៉ែត បានធ្វើការពិភាក្សាជាមួយនឹងសមត្ថកិច្ចហ្វីលីពីនរួចមកហើយ ដើម្បីស៊ើបអង្កេត៕ ប្រភព៖ BBC ប្រែសម្រួល៖ ឈាង**

# ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាលនឹងធ្វើកន្លែងស្នាក់នៅបណ្ដោះអាសន្នដល់ពលករខ្មែរដែលថៃចាប់បញ្ជូនមកវិញ

http://bayontv.com.kh/ 22/01/2018

ភ្នំពេញ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងឲ្យដឹងថា រាជរដ្ឋាភិបាលនឹងធ្វើកន្លែងស្នាក់នៅបណ្ដោះអាសន្នជូនដល់ពលករខ្មែរ ដែលត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកកម្ពុជាវិញក្នុងមួយថ្ងៃៗប្រមាណ១០០នាក់ តាមច្រកអន្តរជាតិប៉ោយប៉ែតនោះ។

ថ្លែងនៅក្នុងកម្មវិធីបិទស្ដីពីការបូកសរុបលទ្ធផលការងារអត្តសញ្ញាណកម្ម ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ និងលើកទិសដៅបន្ត នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨នេះ នៅទីស្ដីការក្រសួងមហាផ្ទៃសម្ដេចក្រឡាហោម ស ខេង បានលើកឡើងថា នាពេលនេះសម្ដេចបានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរកទីកន្លែងដ៏សមគួរមួយនៅច្រកប៉ោយប៉ែតដើម្បីធ្វើកន្លែង ស្នាក់នៅបណ្ដោះអាសន្នជូនដល់បងប្អូនពលករខ្មែរយើងដែលត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនមកវិញ ដោយសារតែពួកគាត់បានធ្វើការនៅប្រទេសគេដោយខុសច្បាប់នោះ។

សម្ដេចក្រឡាហោម បានបន្តទៀតថា ដើម្បីផ្ដល់ភាពងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋខ្មែរបន្ថែមទៀតនោះ ក្រសួងមហាផ្ទៃបាននឹងកំពុងរៀបចំបើកបន្ថែមកន្លែងផ្ដល់លិខិតឆ្លងដែនចំនួនបួនកន្លែងទៀត នៅខេត្តបាត់ដំបង

ខេត្តបន្ទាយមានជ័យ ខេត្តកោះកុងនិងផ្សារអ៊ីអនទី២ ហើយលិខិតឆ្លងដែនដែលធ្វើរួចហើយនឹងផ្តល់ដល់ពួកគាត់តាមរយៈច្រកចេញចូលតែមួយផងដែរ។

បើយោងតាមឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ បានលើកឡើងថា ចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧នេះ ក្រសួងមហាផ្ទៃ បានផ្តល់លិខិតឆ្លងដែនដល់ពលរដ្ឋខ្មែរប្រមាណ១.០៨២.៩១៦នាក់ និងលិខិតធ្វើ ដំណើរជូនពលករកម្ពុជាទៅធ្វើការនៅបរទេសចំនួន៣៩៧.៨៣៨ននាក់។ យ៉ាងណាក៏ដោយពលករខ្មែរ ដែលធ្វើការនៅប្រទេសដែលមិនទាន់ស្របច្បាប់នោះ រាជរដ្ឋាភិបាលនឹងខិតខំធ្វើយ៉ាងណាសហការជា មួយនិងអាជ្ញាធរថៃដើម្បីផ្តល់ដល់ពួកគេជាបន្តបន្ទាប់។ ឯកឧត្តម ម៉ៅ ច័ន្ទតារា បានបន្តទៀតថាការងារផ្តល់លិខិតធ្វើដំណើរពលករកម្ពុជានៅបរទេស ដែលមានសម្តេចក្រឡាហោម ស ខេងដឹកនាំផ្ទាល់នោះបានកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីកាត់បន្ថយបែបបទនីតិវិធីសាំញ៉ាំ និងបានរៀបចំបើកច្រកចេញចូលតែមួយចំនួន៣កន្លែង គឺនៅផ្សារទំនើបស្ទឹងមានជ័យថ្មី ខេត្តបាត់ដំបង និងក្រុងប៉ោយប៉ែត។

រីឯការងារផ្តល់ភាពស្របច្បាប់ដល់ពលករ កម្ពុជាកំពុងធ្វើការនៅប្រទេសថៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានបញ្ជូនក្រុមការងារចំនួន១៧៩នាក់ទៅប្រចាំការនៅប្រទេសថៃ ដើម្បីផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបររទេស៕

**ក្រុមសិទ្ធិមនុស្សជំរុញអោយរដ្ឋាភិបាលកម្ពុជាបង្កើនការបង្ក្រាបលើការជួញដូរកម្លាំងពលកម្មនៅថៃ**

http://www.rfa.org/khmer/ ដោយ តាំង សារ៉ាដា 2018-01-22

អង្គការសិទ្ធិមនុស្សអន្តរជាតិ នៅថ្ងៃចន្ទ ទី២២ ខែមករា ជំរុញអោយរដ្ឋាភិបាលកម្ពុជា ផ្តន្ទាទោសបុគ្គល និងក្រុមនាំពលករទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធនឹងការជួញដូរកម្លាំងពលកម្មខុសច្បាប់ទៅធ្វើការជាកម្មករលើទូកនេសាទរបស់ថៃ។ មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជា អះអាងថា កន្លងមកកម្ពុជា បានចាត់ការលើបញ្ហានេះ ហើយបានកែសម្រួលលក្ខខណ្ឌការងារជាច្រើន។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) ជំរុញអោយរដ្ឋាភិបាលកម្ពុជា សហការជាមួយរដ្ឋាភិបាលថៃ ដើម្បីបញ្ចប់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើទាសភាពនៅតាមទូកនេសាទរបស់ថៃ។ ការអំពាវនាវរបស់ក្រុមសិទ្ធិមនុស្សអន្តរជាតិមួយនេះធ្វើឡើងតាមរយៈការបញ្ចេញរបាយការណ៍របស់ខ្លួនមួយឈ្មោះ "ការកេងប្រវ័ញ្ចកម្លាំង ពលកម្មដោយអាថ៌កំបាំង" ដែលមានកម្រាស់ ១៣៤ទំព័រ បានស៊ើបអង្កេតករណីជួញដូរមនុស្សខុសច្បាប់ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើទូកនេសាទរបស់ថៃ។

របាយការណ៍ស៊ើបអង្កេតនោះបានរកឃើញថា ពលករមកពីតាមបណ្តាប្រទេសមួយចំនួនដែលនៅជិតខាងប្រទេសថៃដូចជាមកប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ត្រូវបានថៅកែទូកនេសាទរបស់ថៃរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ការរំលោភទាំងនោះរួមមាន ការទទួលប្រាក់ខែមិនបានទៀងទាត់ ការទទួលបានប្រាក់ខែទាបជាងអប្បបរមា ការមិនអាចបង្កើតសហជីព និងភាពខ្វះកិច្ចការពារដោយប្រព័ន្ធច្បាប់របស់ថៃ។ មន្ត្រីជាន់ខ្ពស់នៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ បានជំរុញឲ្យសហគមន៍អឺរ៉ុបបន្ថែមការដាក់សម្ពាធដល់ប្រទេសថៃដើម្បីអោយមានការគាំពារដល់សិទ្ធិ សុខភាព និងសុវត្ថិភាពរបស់ក្រុមអ្នកនេសាទ។

ប្រទេសថៃ បានទទួលកាតលឿង ជាការព្រមានមួយដែលអាចនាំឲ្យប្រទេសមួយនេះអាចប្រឈមនឹងការបិទមិនឲ្យនាំចេញផលិតផលអាហារសមុទ្រទៅលក់នៅសហគមន៍អឺរ៉ុប ដោយសារការនេសាទខុសច្បាប់ គ្មានបទបញ្ជា និងគ្មានការរាយការណ៍។ ជាងនេះទៅទៀត សហរដ្ឋអាមេរិក ធ្លាប់បានដាក់ប្រទេសថៃ ចូលទៅក្នុងចំណាត់ថ្នាក់ទី២នៃបញ្ជីឃ្លាំមើលការជួញដូរមនុស្ស។

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Rights Watch បានរកឃើញភាពខ្វះចន្លោះប្រហោងនៃការអនុវត្តច្បាប់ជាច្រើនរបស់រដ្ឋាភិបាលថៃ ថ្មីសព្វថ្ងៃនេះ ដែលតម្រូវឲ្យមានការកែទម្រង់ ខាងផ្នែកឧស្សាហកម្មនេសាទរបស់ខ្លួន។ នាយកប្រតិបត្តិទទួលបន្ទុកកិច្ចការតំបន់អាស៊ីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Rights Watch លោក ប្រ៊ែដ អាដាម (Brad Adams) បានជំរុញអោយសហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក និងជប៉ុន ត្រូវមានការជឿជាក់ចំពោះអាហារសមុទ្រដែលពួកគេទិញពីប្រទេសថៃ មិនត្រូវជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ឬការបង្ខំកម្លាំងពលកម្មនោះឡើយ។ លោកបន្តថា រដ្ឋាភិបាលថៃថ្មីគ្មានឆន្ទៈក្នុងការបោសសំអាតរឿងអាស្រូវដែលបណ្តាលអោយមានអំពើទាសភាពនៅតាមទូកនេសាទក្នុងប្រទេសរបស់ខ្លួននោះឡើយ ហើយថាបញ្ហានេះនៅតែបន្តកើតមាន។ អង្គការអន្តរជាតិមួយនេះ ក៏បានជំរុញឱ្យភាគីរដ្ឋាភិបាលកម្ពុជា បើកការស៊ើបអង្កេត និងផ្តន្ទាទោសបុគ្គល ឬក្រុមនាំពលករទាំងឡាយណាដែលបានចូលរួមជាមួយបណ្តាញជួញដូរកម្លាំងពលកម្មខុសច្បាប់ក្នុងប្រទេសកម្ពុជា ដែលបានសហការរកស៊ីជាមួយមេខ្យល់ក្នុងប្រទេសថៃ ក្នុងការជួញដូរកម្លាំងក្មេងមិនទាន់គ្រប់អាយុ និងកម្លាំងមនុស្សប្រុសពេញវ័យទៅធ្វើការជាកម្មករលើទូកនេសាទរបស់ថៃ។

មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជាអះអាងថា កម្ពុជាមិនដែលបណ្តែតបណ្តោយអោយក្រុមហ៊ុននាំពលករទៅធ្វើការនៅក្រៅប្រទេសណាមួយអាចធ្វើអ្វីតាមអំពើចិត្តនោះឡើយ។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន បានប្រាប់អាស៊ីសេរី តាមទូរស័ព្ទកាលពីថ្ងៃច័ន្ទ អំពាវនាវអោយពលករខ្មែរទាំងអស់កុំចាញ់បោកមេខ្យល់ដែលនាំទៅធ្វើការខុសច្បាប់នៅក្រៅប្រទេស ដើម្បីជៀសឲ្យផុតពីអំពើទាសភាពទាំងឡាយ៖ «រដ្ឋាភិបាលមិនដែលបណ្តែតបណ្តោយអោយក្រុមហ៊ុនធ្វើផ្តេសផ្តាសនោះទេ។ ដំបូងឡើយមកយើងមិនទាន់មានបទពិសោធន៍តាំងពីអាណត្តិមុនៗមកដែលក្រុមហ៊ុនហ្នឹងឆ្លៀតឱកាសដើម្បីបោកបញ្ឆោតបងប្អូនដែរ។ ប៉ុន្តែតាមពិតទៅ អាហ្នឹងវាមិនមែនក្រុមហ៊ុនទៅទៀត វាគ្រាន់តែជាអាអ្នកមេខ្យល់ទេដែលវាមានបញ្ហាអ៊ីចឹង។ ប្រសិនបើក្រុមហ៊ុនមានការទទួលស្គាល់ដោយរដ្ឋាភិបាល មានកិច្ចសន្យាច្បាស់លាស់ទៅ ខ្ញុំយល់ថា អត់មានជួបហានិភ័យដល់បងប្អូនទេ»។

អង្គការមូលនិធិយុត្តិធម៌បរិស្ថាន (Environment Justice Foundation) ធ្លាប់បានសម្តែងការព្រួយបារម្ភចំពោះការប្រើប្រាស់កម្លាំងពលកម្មរបស់អ្នកនេសាទដែលត្រូវបានគេជួញដូរ និងត្រូវបានបង្ខំឲ្យធ្វើការលើទូកនេសាទថៃ ដែលកំពុងប្រតិបត្តិការនៅក្រៅដែនទឹកប្រទេសថៃ កំពុងកើតមានយ៉ាងច្រើន។ កន្លងមកសហរដ្ឋអាមេរិក បានទម្លាក់កម្រិតប្រទេសថៃ ទៅជាប្រទេសដែលជាប់លំដាប់ទី៣ ជាលេខរៀងទាបបំផុតដោយសារតែប្រទេសនេះមិនបានការពារសិទ្ធិរបស់ពលករបរទេសដែលមកធ្វើការក្នុងប្រទេសថៃ៕

**ពលករខ្មែរ ០២នាក់ប្តីប្រពន្ធត្រូវឃាតករបាញ់ប្រហារបណ្តាលឲ្យរងរបួសធ្ងន់នៅក្នុងចំការអំពៅថៃ**

http://www.prakpheaktra.com/ January 23, 2018

មានករណីពលករខ្មែរធ្វើការជាជំរកៅស៊ូ ២នាក់ប្តីប្រពន្ធ ត្រូវពលករខ្មែរដូចគ្នាលបបាញ់ប្រហារបណ្តាលឱ្យរងរបួសធ្ងន់ទាំងពីរនាក់។ កាលពីវេលាម៉ោង០៨:២០នាទីយប់ថ្ងៃច័ន្ទទី២១ ខែមករា ឆ្នាំ២០១៨ មានករណីអំពើឃាតកម្មពលករខ្មែរពីរនាក់ប្តីប្រពន្ធធ្វើការជាជ័រកៅស៊ូនៅក្នុងស្រុកកាបីនបុរី ខេត្តប្រាជីនបុរី ប្រទេសថៃ ត្រូវពលករខ្មែរដូចគ្នា ប្រើកាំភ្លើងវែងបាញ់ប្រហារបណ្តាលឱ្យបុរសជាប្តីរងរបួសធ្ងន់ និងស្ត្រីជាប្រពន្ធត្រូវឃាតកវាយនិងគ្រាកាំភ្លើងបណ្តាលឲ្យសន្លប់បាត់ស្មារតីនៅក្នុងចំការអំពៅ។

ករណីខាងលើនេះបានកើតឡើងកាលពីវេលាម៉ោង០៨:២០នាទី យប់ស្ថិតនៅក្នុងចំការអំពៅមួយកន្លែងស្ថិតនៅក្នុងភូមិបានណងម៉ូតាយ ក្រុមទី១ សង្កាត់បានណា ស្រុកកាបីនបុរី ខេត្តប្រាជីនបុរី ប្រទេសថៃ យោងតាមប្រភពព័ត៌មានកន្លែងកើតហេតុបានឲ្យដឹងថាស្ត្រីរងគ្រោះមានឈ្មោះភឹម សុខ អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ ត្រូវជាប្រពន្ធជនរងគ្រោះបានប្រាប់អោយដឹងថារូបគាត់និងប្តីធ្វើការជាជ័រកៅស៊ូនៅក្នុងចំការរបស់(ថៅអយ) លុះដល់ម៉ោងលើកការគាត់

និងប្ដីបានជិះម៉ូតូវិលត្រឡប់ទៅកន្លែងស្នាក់នៅវិញ ស្រាប់តែមានបុរសពលករខ្មែរធ្វើការជាមួយគ្នាម្នាក់ បានឈរស្ទាក់កណ្ដាលផ្លូវព្រមទាំងតម្រង់កាំភ្លើងមកចំប្ដី គាត់រួចបាញ់មួយគ្រាប់ចំកណ្ដាលមុខប្ដីគាត់បណ្ដាលឲ្យម៉ូតូដួលភ្លាមនោះ ឃាតករបានយកគ្រាកាំភ្លើងវាយលើរូបគាត់បណ្ដាលសន្លប់បាត់ស្មារតី ទើបឃាតកររត់គេចខ្លួនបាត់ស្រមោល។

បច្ចុប្បន្នជនរងគ្រោះទាំងពីរនាក់ត្រូវបានភ្នាក់ងារសង្គ្រោះស្រុកកាបីនបុរី បញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យថៅផាយ៉ាភ័យភូបេត ចំណែកឯជនរងគ្រោះត្រូវជាប្ដីបានរងរបួសធ្ងន់ស្លាប់រស់ស្មើគ្នាព្រោះត្រូវឃាតកបាញ់ចំកណ្ដាលថ្ងាស។ ចំណែកឯមូលហេតុកម្លាំងសមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវតាមចាប់ខ្លួនជនសង្ស័យយកមកផ្ដន្ទាទោសតាមច្បាប់។

## អាជ្ញាធរក្រសួងការងារថៃ ចុះបង្ក្រាបពលករភូមា ធ្វើការលក់ដូរ

http://www.prakpheaktra.com/ January 22, 2018

កម្លាំងអាជ្ញាធរក្រសួងការងារថៃ ព័ទ្ធចាប់ពលករបរទេសធ្វើការលក់ដូរខុសលក្ខខ័ណ្ឌក្នុងផ្សារក្នុងផ្សារ (ថេសបាន) ខេត្តរ៉ាក់ណង់ឃាត់ខ្លួនបានពលករភូមាមួយចំនួន។ កាលពីថ្ងៃច័ន្ទទី២១ ខែមករា ឆ្នាំ២០១៨ នេះកម្លាំងអាជ្ញាធរក្រសួងការងារថៃ សហការជាមួយកម្លាំងតម្រួត,ទាហានអាជ្ញាធរមូលដ្ឋាន ចុះបង្ក្រាបពលករបរទេសដែលកំពុងធ្វើការលក់ដូរ នៅក្នុងផ្សារ(ថេសបាន)ស្រុករ៉ាក់ណង ខេត្តរ៉ាក់ណង ប្រទេសថៃ។ ក្នុងកិច្ចព្រឹត្តិបត្រការណ៍ចុះបង្ក្រាបពលករធ្វើការខុសលក្ខខ័ណ្ឌលើកនេះ កម្លាំងអាជ្ញាធរថៃធ្វើការឃាត់ខ្លួនបានពលករសញ្ជាតិភូមាមួយចំនួន និងមួយចំនួនរត់គេចខ្លួនបាត់អស់។

## ពលករខ្មែរ ១នាក់ រិះគន់មន្ត្រីនគរបាលកម្ពុជា ប្រចាំច្រកព្រំដែន អន្តរជាតិបានទ្បែមរឿងយកប្រាក់ ថ្លៃជាងខាងថៃ

http://www.prakpheaktra.com/ January 22, 2018

ពលករខ្មែរម្នាក់បង្ហោះសាររិះគន់ចំពោះមន្ត្រីនគរបាលកម្ពុជាប្រចាំច្រកទ្វារព្រំដែនអន្តរជាតិបានទ្បែម បន្ទាប់ពីមន្ត្រីរូបនោះយកប្រាក់ពីគាត់ចំនួន១០០បាត ដោយខាងភាគីថៃយកត្រឹមតែ ២០បាតប៉ុណ្ណោះ។ ម្ចាស់អាខោនហ្វេសប៊ុកឈ្មោះ Sea Yoeun បានសរសេរសារបង្ហោះនៅលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនរបស់គាត់ថា៖ "អ្នកដែលចូលតាមច្រកទ្បែម ទៅថៃ មានប៉ាស្ព័រវីសារ២ឆ្នាំ ទិញសំបុតចូល១០បាតក្នុងមួយនាក់ នគបាលច្រកមិនឲ្យចូលទេត្រូវចំណាយ ១០០បាត ក្នុង១នាក់ទៀតសុពលភាព រយៈពេល១ថ្ងៃ បានវាឲ្យចូល ហើយចំណែកខាងថៃ ចូលយកតែ20បាតទេក្នុង ១នាក់ បានសុពលភាពរយៈពេល១ខែទៀត គឺតំលៃថោកជាងខាងខ្មែរច្រើនដង តើនគរបាលច្រកទ្បែមវាបឺតឈាមតែខ្មែរដែរទេ?សូមជួយជាយបល់ផង"

ចំពោះបញ្ហាខាងលើនេះ មានបងប្អូនពលករខ្មែរខ្លះទៀតគាត់បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំងចំពោះរឿងមន្ត្រីនគរបាលព្រំដែនកម្ពុជាដែលតែងតែយកប្រាក់ពីពួកគាត់ថ្លៃជាងភាគថៃគេយក។ យ៉ាងណាមិញចំពោះបងប្អូនពលករខ្មែរដែលមានលិខិតឆ្លងដែនធ្វើការហើយមានវីសារធ្វើការត្រឹមត្រូវ នៅពេលដែលវិលត្រឡប់ទៅលេងស្រុកកំណើតពលករត្រូវធ្វើវីសារដើរផ្លូវហៅថា(វីសារជីអ៊ិនទ្រីរ)ដើម្បីជៀសវាងបញ្ហារឿងសម្ថកិច្ចតាមព្រំដែនទាប្រាក់ ព្រោះបើពលករគ្មានវីសារនេះទេ បងប្អូនអាចនឹងត្រូវសមត្ថកិច្ចតាមព្រំដែនទាប្រាក់លើសពីរយបាតនេះទៀត។

## កម្ពុជាបញ្ជូនពលករទៅធ្វើការ នៅម៉ាឡេស៊ី មានការកើនឡើង ជាបន្តបន្ទាប់

https://www.dap-news.com/kh/ អង្គារ, ២៣ មករា ២០១៨ 12:27 ដោយ: ជី លីថូ ID:049

ភ្នំពេញ៖រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោកអ៊ិតសំហេងបានបញ្ជាក់ថា ចាប់តាំងពីឆ្នាំ ១៩៩៨ រហូតដល់បច្ចុប្បន្ននេះចំនួនពលករខ្មែរដែលទៅធ្វើការនៅប្រទេស ម៉ាឡេស៊ីមានការកើនឡើង ជាបន្តបន្ទាប់។ លោក អ៊ិត សំហេងបានលើកឡើងបន្ថែម ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៣ ជាមួយនឹងលោក Dato' Srchard Riot AnakJem រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ីស្ដីពី ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាពីការជ្រើសរើស បញ្ជូន និងគ្រប់គ្រងពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នាសណ្ឋាគារសូហ្វីតែលថ្ងៃទី២៣ ខែមករា

ឆ្នាំ២០១៨ថា "ការបញ្ជូនពលករកម្ពុជាទៅធ្វើការ នៅម៉ាឡេស៊ី បានចាប់ដំណើរការ តាំងពីឆ្នាំ១៩៩៨ នៅក្រោយពេលដែលរាជរដ្ឋាភិបាល កម្ពុជាទទួលបានការអនុញ្ញាតពីរដ្ឋាភិបាល ម៉ាឡេស៊ី ក្នុងខែតុលា ឆ្នាំ១៩៩៦។ ចាប់ពីពេលនោះមក ចំនួនពលករដែលបានបញ្ជូនទៅធ្វើការ នៅម៉ាឡេស៊ី បានកើនឡើង ជាបន្តបន្ទាប់"។ លោកបានបន្តថាចំនួនពលករ ដែលបានបញ្ជូនទៅធ្វើការ នៅប្រទេស ម៉ាឡេស៊ី មានចំនួនសរុប ៤៦,៥៤១នាក់ (ស្រី ៤០,០៨៤នាក់) ក្នុងនោះ ពលករការងារផ្ទះមានចំនួន ៣៣,៧០៧នាក់ ស្រីទាំងអស់។

ក្នុងឱកាសនោះដែរលោកបាន បន្តទៀតថាការខិតខំ របស់ប្រទេសបញ្ជូនពលករតែម្ខាង មិនអាចធានាបាននូវការការពារ និងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ បានឡើយ បើមិនមានកិច្ចសហការល្អ និងការគាំទ្ររបស់ប្រទេស ទទួលទេនោះ។ លោកបានបន្ថែមថារាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់អំពីកិច្ចខិតខំប្រឹងប្រែងដ៏ល្អប្រសើរ របស់រដ្ឋាភិបាលម៉ាឡេស៊ីក្នុងការដោះស្រាយ រាល់បញ្ហាដែលបានជួបប្រទះ នាពេលកន្លងមក។ លោកបានសង្កត់ធ្ងន់ថា ពិតពលោកក៏ដូចជា បណ្ដាប្រទេសក្នុងអាស៊ាន មានការគាំទ្រ និងទទួលស្គាល់ថា ការធ្វើទេសន្តរប្រវេសន៍ការងារ ពិតជាបានចូលរួមយ៉ាងសំខាន់ក្នុង កិច្ចអភិវឌ្ឍន៍គ្រួសារ សហគមន៍ និងសេដ្ឋកិច្ចសង្គមក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។ ក្នុងទស្សនៈ បែបនេះ រាជរដ្ឋាភិបាលកម្ពុជាគាំទ្រ ក្នុងការធ្វើទេសន្តរប្រវេសន៍ ការងារដោយស្របច្បាប់។ សម្រាប់ការងារនេះ កម្ពុជាមានការប្ដេជ្ញាចិត្តថា សិទ្ធិរបស់ពលករនឹងត្រូវបាន ការពារយ៉ាងល្អ ដោយក្របខណ្ឌច្បាប់ ដ៏រឹងមាំ ក្នុងវដ្តនៃទេសន្តរប្រវេសន៍៕

## ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨
## កម្ពុជា នឹងបញ្ជូនពលករ ទៅធ្វើការ នៅម៉ាឡេស៊ីជាថ្មី នាដើមខែមិថុនា ឆ្នាំ២០១៨នេះ

https://www.dap-news.com/kh/ អង្គារ, ២៣ មករា ២០១៨ 13:48 ដោយ: ស សំណាង ID:013

ភ្នំពេញ៖ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈ បានឲ្យដឹងថា រដ្ឋាភិបាលគ្រោងនឹងបញ្ជូនពលករកម្ពុជាទៅម៉ាឡេស៊ីនៅដើមខែមិថុនា ឆ្នាំ២០១៨ នេះ បន្ទាប់ពីមានការអាក់ខាន មួយរយៈពេលកន្លងមក ។

ក្នុងកិច្ចសម្ភាសន៍ជាមួយ អ្នកសារព័ត៌មាននាព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨នេះ ស ណ្ឋាគាសូហ្វីទែលភូកេត្រា លោករដ្ឋមន្ត្រី អ៊ិត សំហេង បានលើកឡើងថា តាំងពីឆ្នាំ២០១៥ មក រដ្ឋាភិបាលកម្ពុជា និងម៉ាឡេស៊ី បានចុះកិច្ច ព្រមព្រៀងក្នុងការបញ្ជូន និងទទួលពលករកម្ពុជា ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។ រហូតមកដល់ពេល ក្រសួងការងារទាំងពីរ បានជួបពិភាក្សាគ្នាជាច្រើនលើកមក ដើម្បីជជែកគ្នាពីនីតិវិធីក្នុងការជ្រើសរើស និងបញ្ជូនពលករដោយសុវត្ថិភាព ។ លោកបញ្ជាក់ថា «ថ្ងៃនេះផងដែរ យើងបានជជែកពិភាក្សាគ្នាអំពី ស្ដីពីនីតិវិធីជ្រើសរើស បណ្ដុះបណ្ដាលពលករមុននឹងបញ្ជូន និងបានកំណត់ពេលវេលា សម្រាប់ការបញ្ជូនពលករ កម្ពុជា ទៅធ្វើការជាលើកដំបូងនៅម៉ាឡេស៊ី។ ភាគីទាំងពីរបានឯកភាពគ្នា នឹងបញ្ជូនពលករ ដែ លជាក្រុមទី១ នឹងត្រូវបញ្ជូននៅក្នុងថ្ងៃទី១ ខែមិថុនាខាងមុខនេះ» ។ លោករដ្ឋមន្ត្រីបានឲ្យដឹងដែរថា ចំនួនពលករកម្ពុជា ដែលទៅបំរើការងារ នៅប្រទេសម៉េឡេស៊ី ស្របច្បាប់មានប្រហែលជាង ៨៣ាន់នាក់ ទាំងធ្វើការតាមផ្ទះ និងធ្វើការទូទៅ ។ ដែលចំនួន នេះមានតិច ទើបរដ្ឋាភិបាលនៃប្រទេសទាំងពីរ ឯកភាពក្នុងការបញ្ជូន និងទទួលពលករ បន្ទាប់ពី អាក់ខានមួយរយៈពេលមក ។

ទាក់ទិននឹងការបញ្ជូនពលរកខ្មែរ ទៅបំរើការនៅម៉ាឡេស៊ី ជាថ្មីម្ដងទៀតនេះ បើតាមលោករដ្ឋមន្ត្រីក៏បានឲ្យដឹងដែរថា ភាគីកម្ពុជា និងម៉ាឡេស៊ី នឹងជួបជជែកគ្នាម្ដងទៀត នៅដើមខែកុម្ភៈ ឆ្នាំ២០១៨ នៅទីក្រុងកូឡាំពួរ ប្រទេសម៉ាឡេស៊ី ដែលលោករដ្ឋមន្ត្រី នឹងចូលរួមប្រជុំ ។ យ៉ាងណាក្ដី លោករដ្ឋមន្ត្រី មិនទាន់ឲ្យដឹងថា ចំនួនពលករប៉ុន្មាន នៅ

ឡើយទេ គឺអាស្រ័យលើការជ្រើសរើស និងបណ្តុះបណ្តា លនិងការពេញចិត្តរបស់ពលករក្នុង ការទៅធ្វើការនៅម៉ាឡេស៊ី។ លោកបន្តថា ការជ្រើសរើសនោះនឹង ត្រូវធ្វើដោយតម្លាភាព ដោយមានការបញ្ជាក់ច្បាស់ អំពីលក្ខខណ្ឌការងារ និង សុវត្ថិភាព ដែលពលករអាចនឹងទទួលបាន ។ លោករដ្ឋមន្ត្រីបានលើកឡើងទៀតថា ពលករដែលត្រូវបញ្ជូន ទៅម៉ាឡេស៊ីលើកនេះ ត្រូវឆ្លងកាត់ និតិវិធីជាច្រើន ដូចជា ការបណ្តុះបណ្តាលជំនាញ ណាមួយច្បាស់លាស់ ដែលជាបឋមមាន ចំនួនពី ១ខែទៅ ២ខែ។ កិច្ចសន្យាការងារ ដែលមានទាំងប្រាក់ខែ ជំនាញ ការងារ ដែលពលករធ្វើ ហើយ ករណីមានការរំលោភបំពាន ពលករត្រូវមាននីតិវិធីធ្វើការតវ៉ាជាដើម ។ លោករដ្ឋមន្ត្រីបន្ថែមថា ការជ្រើសរើសពលករទៅធ្វើការ នៅម៉ាឡេស៊ី នៅតែធ្វើតាមទីភ្នាក់ងារនៅកម្ពុជា ក្នុងការធ្វើទំនាក់ទំនងជាមួយ ភ្នាក់ងាររបស់ម៉ាឡេស៊ី ។ សម្រាប់ពលករទៅធ្វើការ ម៉ាឡេស៊ីមិនទាន់ត្រូវបានដឹងថា មានចំនួនប៉ុន្មាននៅឡើយទេ ដែលត្រូវក្នុងការបញ្ជូនទៅបំរើការងារនៅទៅនោះ ប៉ុន្តែ បើតាមលោករដ្ឋមន្ត្រី ក្រសួងការងារ បានអះអាងថា ភាគីម៉ាឡេស៊ី ចង់បានពលករកម្ពុជាទៅធ្វើ ការកាន់តែច្រើនកាន់តែល្អ។

ជាមួយគ្នានោះដែរលោក Dato' Sri Richard Riot AnakJaem រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ី ក៏បានលើកឡើងថា ការបញ្ជូន និងទទួលពលករកម្ពុជា ទៅម៉ាឡេស៊ីធ្វើឡើង គោរពតាមអនុសាសន៍យោគយល់គ្នា រវាងកម្ពុជា និងម៉ាឡេស៊ី ទាំងអស់។ អនុស្សារណៈនេះ ធ្វើឡើង មិនតែជាមួយកម្ពុជានោះទេ គឺធ្វើឡើងដូចបណ្តាប្រទេសទាំងអស់ ដែលបានបញ្ជូនទៅ ធ្វើការនៅម៉ាឡេស៊ី ។ លោកបញ្ជាក់ថា «រហូតមកដល់ពេលនេះ មានពលករ ដែលជាជនបរទេស ធ្វើការនៅប្រទេសម៉ាឡេស៊ី មានចំនួន ១លាន ៧សែននាក់។ ហើយក្រោយពីរដ្ឋាភិបាលដាក់ឲ្យអនុវត្តជួលធ្វើការសារឡើងវិញ មកមានពលករកម្ពុជា បានទៅចុះបញ្ជីមានជាង ៨ពាន់នាក់ ។ ខ្ញុំសង្ឃឹមថា ពលករកម្ពុជាដែលទៅចុះបញ្ជី ធ្វើការនោះជាពលករល្អមិន ដែលបង្កឲ្យមានបញ្ហា អ្វីនោះទេ» ។ លោករដ្ឋមន្ត្រីម៉ាឡេស៊ី ក៏បានលើកឡើងទៀតថា តាមរយៈអនុស្សារណៈរវាងកម្ពុជា និងម៉ាឡេស៊ី នោះពលករ ដែលទៅបំរើការងារ នៅម៉ាឡេស៊ីនោះ នឹងទទួលបានការការពារ បន្ថែមពីលើច្បាប់ការងារម៉ាឡេស៊ី ឬអនុសញ្ញាការងាររបស់ អង្គការខាងការងារថែមទៀត ។ លោកថា ក្នុងចំនោមវិស័យចំនួន ៥ ពលករកម្ពុជា ទៅធ្វើមានការងារ ផ្នែកឧស្សាហកម្ម និងការងារតាមផ្ទះ ៕

## កម្ពុជា-ម៉ាឡេស៊ី ពង្រឹងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើការ ជ្រើសរើស បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី

http://www.akp.gov.kh/kh/ AKP ភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨

ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញចូលរួម ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៣ជាមួយនឹង ឯកឧត្តម Dato' Sri Richard Riot AnakJaem រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ីស្តីពីការ អនុវត្ត អនុស្សរណៈនៃការយោគយល់គ្នាពីការជ្រើសរើសបញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅ ធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ កាលពីព្រឹកថ្ងៃអង្គារ៍ ៩កើត ខែមាឃ នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨។

ឯកឧត្តម អ៊ិត សំហេង បានបញ្ជាក់ថា ការបញ្ជូនពលករកម្ពុជាទៅធ្វើការ នៅម៉ាឡេស៊ី បានចាប់ដំណើរ ការតាំងពីឆ្នាំ១៩៩៨ នៅក្រោយពេលដែលរាជរដ្ឋាភិបាល កម្ពុជាទទួលបានការអនុញ្ញាតពីរដ្ឋាភិបាល ម៉ាឡេស៊ី ក្នុងខែតុលា ឆ្នាំ១៩៩៦។ ចាប់ពីពេលនោះមក ចំនួនពលករដែលបានបញ្ជូន ទៅធ្វើការនៅ ម៉ាឡេស៊ី បានកើនឡើងជាបន្តបន្ទាប់។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា ការខិតខំរបស់ប្រទេសបញ្ជូនតែម្ខាង មិនអាចធា នាបាននូវការការពារ និងការ

លើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍បានឡើយ បើមិនមានកិច្ច សហការល្អ និងការគាំទ្ររបស់ប្រទេសទទួលទេនោះ។ ចំពោះបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់អំពី កិច្ចខិតខំប្រឹងប្រែងដ៏ល្អប្រសើររបស់ រដ្ឋាភិបាលម៉ាឡេស៊ី ក្នុងការដោះស្រាយ រាល់បញ្ហាដែលបានជួប ប្រទះនាពេលកន្លងមក។

ឯកឧត្តមលើកឡើងទៀតថា ពិតពលោក ក៏ដូចជាបណ្តាប្រទេសក្នុងអាស៊ានមាន ការគាំទ្រ និងទទួល ស្គាល់ថា ការធ្វើទេសន្តរប្រវេសន៍ការងារ ពិតជាបានចូលរួមយ៉ាង សំខាន់ក្នុងកិច្ច អភិវឌ្ឍន៍គ្រួសារ សហគមន៍ និង សេដ្ឋកិច្ចសង្គមក្នុងការកាត់បន្ថយ ភាពក្រីក្រផងដែរ។ ឯកឧត្តមបានបន្ថែមថា ក្នុងទស្សនៈបែបនេះ រាជរដ្ឋាភិបាលកម្ពុជាគាំទ្រក្នុងការធ្វើទេសន្តរប្រវេសន៍ ការងារ ដោយស្របច្បាប់ ហើយសម្រាប់ការងារនេះ កម្ពុជាមានការ ប្តេជ្ញាចិត្តថា សិទ្ធិរបស់ពលករ នឹងត្រូវបានការពារយ៉ាងល្អ ដោយក្របខ័ណ្ឌច្បាប់ដ៏រឹងមាំ សម្រាប់ទេសន្តរប្រវេសន៍។ ឯកឧត្តមសង្ឃឹមថា អនុស្សរណៈនៃការយោគយល់គ្នា ដែលរដ្ឋាភិបាលនៃប្រទេស ទាំងពីរបានចុះហត្ថ លេខារួចមក ពិតជាឧបករណ៍ដ៏ប្រសើរសម្រាប់ដោះស្រាយបញ្ហាទាំងឡាយ។ ជាមួយគ្នានេះដែរ ទេសន្តរប្រវេសន៍ការងារនឹងជួយលើកកម្ពស់កិច្ចអភិវឌ្ឍន៍តាមរយៈការបង្កើត សហគ្រាសថ្មីៗ និងការពង្រឹងចំណងទាក់ទងរវាងប្រទេសទាំងពីរ តាមរយៈការផ្ទេរ បច្ចេកវិទ្យា ជំនាញ និងធនធានផ្សេងៗទៀត។ សូមបញ្ជាក់ថា រហូតមកដល់ពេលនេះ ពលករ ដែលបានបញ្ជូនទៅធ្វើការ នៅប្រទេស ម៉ាឡេស៊ី មានចំនួនសរុប ៤៦.៥៤១នាក់ ស្រី ៤០.០៨៤នាក់ ក្នុងនោះពលករធ្វើការងារផ្ទះ មានចំនួន ៣៣.៧០៧នាក់ ដែលជាស្ត្រីទាំងអស់៕ ដោយ អ៊ុន រិទ្ធី

## ក្រសួងការងារ៖ កម្ពុជា-ម៉ាឡេស៊ី ឯកភាពគ្នាបង្កើតមណ្ឌលអប់រំណែនាំតម្រង់ទិសពលករ មុនចេញទៅធ្វើការនៅម៉ាឡេស៊ី

http://www.freshnewsasia.com/ 2018-01-23

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា បានឯកភាពជាមួយក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ី បង្កើតឲ្យមានមណ្ឌលសម្រាប់អប់រំណែនាំតម្រង់ទិសពលករកម្ពុជា មុនចេញទៅធ្វើការនៅម៉ាឡេស៊ី និងចេញវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់ពលករខ្មែរដែលបានបញ្ចប់វគ្គអប់រំណែនាំតម្រង់ទិសនេះដោយជោគជ័យ។ ការឯកភាពគ្នានេះ ត្រូវបានធ្វើឡើងក្នុងកិច្ចពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា ជាមួយលោក ដាតូ ស្រ៊ីរីចាត រដ្ឋមន្ត្រីក្រសួងធនធានមនុស្សម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ-ភូកេត្រា នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨។

ក្រោយពីបញ្ចប់កិច្ចពិភាក្សានេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីប្រកាសមួយ ដោយបញ្ជាក់ពីលទ្ធផលការងារ ដែលកើតចេញពីកិច្ចពិភាក្សាខាងលើ ដោយក្នុងនោះភាគីទាំងពីរបានឯកភាពគ្នាបង្កើតឲ្យមានមណ្ឌលសម្រាប់អប់រំណែនាំតម្រង់ទិសពលករកម្ពុជា មុនចេញទៅធ្វើការនៅម៉ាឡេស៊ី និងចេញវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់ពលករខ្មែរ ដែលបានបញ្ចប់វគ្គអប់រំណែនាំតម្រង់ទិសនេះដោយជោគជ័យ។ សេចក្តីប្រកាសបានបន្តថា ភាគីទាំងពីរក៏បានឯកភាពគ្នាបន្តកិច្ចប្រជុំថ្នាក់មន្ត្រីបច្ចេកទេសជាន់ខ្ពស់លើកទី៥ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី២ នាសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០១៨ ខាងមុខ នៅប្រទេសម៉ាឡេស៊ី ដើម្បីបន្តធ្វើការពិភាក្សាលើបញ្ហាដែលសេសសល់ ឲ្យបានចប់សព្វគ្រប់ ដែលអាចឲ្យដំណើរការចាប់ផ្តើមបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ីលើកដំបូង នាដើមសប្តាហ៍ខែមិថុនា ឆ្នាំ២០១៨ តទៅ៕

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ នៅសណ្ឋាគារសូហ្វីតែល ភូគីត្រា រាជធានីភ្នំពេញ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារ ជាមួយ **ឯកឧត្តម Dato' Sri Richard Riot Anak Jaem** រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស នៃប្រទេសម៉ាឡេស៊ី ដើម្បីពិភាក្សាកិច្ចសហប្រតិបត្តិការក្នុងការជំរុញ និងបង្កើនល្បឿននៃការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ស្តីពីការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ឱ្យបានឆាប់ ដើម្បីធានាដល់ការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ពលករកម្ពុជាទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

ក្នុងជំនួបនៃកិច្ចប្រជុំនេះ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំងនូវលទ្ធផលដ៏ល្អនៃកិច្ចសហប្រតិបត្តិការនាពេលកន្លងមក។ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការពារពលករកម្ពុជាដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ភាគីទាំងពីរ បានឯកភាពរៀបចំឱ្យមានមជ្ឈមណ្ឌលសម្រាប់អប់រំណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងការចេញវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់ពលករខ្មែរ ដែលបានបញ្ចប់វគ្គអប់រំណែនាំតម្រង់ទិសមុនចេញដំណើរដោយជោគជ័យ។ ទន្ទឹមនឹងនេះ ភាគីទាំងពីរក៏បានឯកភាពគ្នាបន្តកិច្ចប្រជុំថ្នាក់មន្ត្រីបច្ចេកទេសជាន់ខ្ពស់លើកទី៥ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៤ នាសប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០១៨ ខាងមុខនេះ នៅប្រទេសម៉ាឡេស៊ី ដើម្បីបន្តធ្វើការពិភាក្សាលើបញ្ហាដែលសេសសល់ឱ្យចប់សព្វគ្រប់ ដែលអាចឱ្យដំណើរការចាប់ផ្តើមបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីលើកដំបូង នាដើមខែមិថុនា ឆ្នាំ២០១៨ តទៅ។

*រាជធានីភ្នំពេញ ថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*
*ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

# សម្តេចក្រឡាហោម ៖ ឆ្នាំ២០១៨ ត្រូវរួមគ្នាបិទច្រករបៀងឱ្យបាន

http://www.rasmeinews.com/ January 24, 2018, 8:03 AM

(បាត់ដំបង)៖នៅក្នុងពិធីបិទសន្និបាត បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តបាត់ដំបង នារសៀលថ្ងៃទី២៣ខែមករាឆ្នាំ២០១៨ នៅសាលមហោស្រពស្ទឹងសង្កែ សម្តេចក្រឡាហោម ស ខេងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា «ឆ្នាំ២០១៨ ត្រូវបិទច្រករបៀងឱ្យបាន» បើមិនអីចឹងទេ ទំនិញវាមកតាមច្រករបៀង ហ្នឹងធ្វើឱ្យរដ្ឋខាតបង់ថវិការាប់លានដុល្លារ។

សម្តេចក្រឡាហោម បានបញ្ជាក់ថា មិនមែនតែទំនិញគេចពន្ធទេ វាមានការរត់ពន្ធមនុស្ស ការជួញដូរគ្រឿងញៀន វាមកតាមច្រករបៀងហ្នឹងនេះ ជាបញ្ហាដ៏គ្រោះថ្នាក់ បើសិនជាយើងធ្វើមិនបានត្រឹមត្រូវ។ យើងលើកទឹកចិត្ដដើម្បីឱ្យអាជ្ញាធរខេត្ត អាជ្ញាធរពាក់ព័ន្ធ សមត្ថកិច្ចពាក់ព័ន្ធ បន្តធ្វើការងារនេះ ឱ្យបានល្អ។ ការពិតយើងមានយន្តការច្រើនណាស់ តែកិច្ចប្រតិបត្តិការព្រំដែននោះ រួមទាំងយន្តការប្រជុំរវាងខេត្តនិងខេត្តជាប់ព្រំដែនកម្ពុជាថៃ ដែលយើងបានអនុវត្តជាបន្តបន្ទាប់។ ប៉ុន្តែមានការខកខានខ្លះ ដោយព្រះមហាក្សត្រថៃ ចូលទិវង្គត គឺខកខានមួយឆ្នាំហើយ នៅឆ្នាំ២០១៧ យើងប្រជុំនៅភ្នំពេញ ហើយឆ្នាំក្រោយ ២០១៨ យើងនឹងទៅប្រជុំនៅប្រទេសថៃម្តង។ មានបញ្ហាតិចតួចកើតឡើងតាមព្រំដែនមិនបាច់ទៅថ្នាក់លើទេ គឺខេត្តនិងខេត្ត ដោះស្រាយជាមួយគ្នាដូចជាបទល្មើសគ្រឿងញៀន បទល្មើសជួញដូរមនុស្ស បទល្មើសទំនិញរត់ពន្ធ លាងលុយកខ្វក់ ឬក៏បទល្មើសតូចតាចផ្សេងៗទៀត។

សម្តេចក្រឡាហោម បានបន្តថា ក្រោយប្រជុំជាមួយរដ្ឋមន្ត្រី អានុពង្ស ផៅចិន្តា ទាក់ទងនឹងការបាញ់សម្លាប់មនុស្ស ពេលដែលពលរដ្ឋខ្មែរ ចូលទៅកាប់ឈើគ្រញូង នៅក្នុងទឹកដីថៃ។ តើមូលហេតុ ពិតមកពីអ្វី មកពីគ្មានអ្នកទិញឈើគ្រញូងទៀត ដល់អីចឹងទៅ ក៏អត់មានអ្នកចូលទៅកាប់ដែរ។ ទ្រឹស្តីវាឡូស៊ីកអីចឹង «បើគ្មានអ្នកទិញ ក៏គ្មានអ្នកលក់ដែរ»។ មកពីមូលហេតុហ្នឹង ឬមួយក៏មូលហេតុយើងអប់រំប្រជាជន មិនឱ្យចូលដីថៃកាប់ឈើ។ ចំណែកខាងថៃ គេអប់រំកម្លាំងឈរជើងតាមព្រំដែន មិនឱ្យបាញ់សម្លាប់។ ពីព្រោះរឿងកាប់ឈើគ្រញូងនេះ មានអ្នកកាប់ខ្លះមិនទាំងស្គាល់ឈើគ្រញូងផង ពួកគាត់មិនមែនជាអ្នកនៅជាប់ព្រំដែនទេ មានអ្នកខ្លះ មកពីខេត្តព្រៃវែង ស្វាយរៀង មិនដឹងថាឈើគ្រញូង វាមានពណ៌ខ្មៅ ពណ៌ស ខៀវ ឬក្រហមទេ ម៉េចបានជាដឹងថា ដើមគ្រញូង ដើមពីកន្លែងដើមគ្រញូងដុះទៀត វាមានអ្នកនាំទៅកាប់ ទៅចង្អុលឱ្យកាប់។

ចំពោះអ្នកកាប់ខ្លះបានត្រឹមតែកាប់ ហើយលីមកឱ្យគេ ក្រៅពីហ្នឹងអត់បានអីទេ ក្រៅពីហ្នឹងមានតែបាត់ទៅវិញបាត់គឺត្រូវគេបាញ់ចោល។ អ្នកដែលបានផលប្រយោជន៍ គឺឈ្មួញខ្មែរនិងឈ្មួញថៃ។ តែឥឡូវវាអត់ានបញ្ហានេះទៀតទេ តាំងពីមុនប្រជុំខែ៧ឆ្នាំ២០១៧ មានម្តងនៅខេត្តព្រះវិហារ ក្រោយមកអត់មានការបាញ់សម្លាប់ប្រជាពលរដ្ឋខ្មែរចូលទៅកាប់ឈើទៀតនេះ នេះគឺជាជោគជ័យមួយធំណាស់។ ដូចនៅប្រទេសឡាវ ក៏ដូច្នេះដែរ ដោយយើងស្នើសុំឱ្យទុកជីវិតអ្នកចូលដីគេ គឺខុសហើយសុំចាប់ដាក់គុក ឬផ្តន្ទាទោសតាមច្បាប់ទៅ សុំកុំសម្លាប់ចោល។ មកដល់ឥឡូវ អត់មានទៀតទេ គឺជាជោគជ័យធំមួយទៀត។ ដូច្នេះខេត្តជាប់ព្រំដែន ត្រូវខិតខំហៅរកគ្នាទៅវិញទៅមក ប៉ុន្តែមិនមែនក្នុងន័យ លក់អធិបតេយ្យភាព លក់ឯករាជ្យភាពរបស់យើងទេ ក្នុងន័យការពារផលប្រយោជន៍របស់ប្រជាជន។

ប្រជាជនទាំងសងខាង ខុសឆ្គងតិចតួច ត្រូវចេះអធ្យាស្រ័យឱ្យគ្នា។ កុំគិតថា ខ្មែរយកផលប្រយោជន៍ពីថៃ តាមរយៈពលករ។ ចំណែកថៃ យកផលប្រយោជន៍ពីខ្មែរ ក៏មិនស្មើរដែរ ដូចជាការនាំទំនិញរបស់គាត់ រាប់ពាន់មុខចូលមកលក់នៅកម្ពុជា បើកម្ពុជាមិនទិញ១ឆ្នាំៗ រាប់ពាន់លាន ចូលមកស្រុកខ្មែរ។ ដូច្នេះទេ វាមានផលប្រយោជន៍ទៅវិញទៅមក។ ចុងក្រោយ សម្តេចក្រឡាហោម បានដាក់ផែនការ ក្នុងឆ្នាំ២០១៨ ត្រូវលុបបំបាត់ឱ្យអស់បទល្មើសគ្រឿងញៀន ធ្វើឱ្យបានជោគជ័យ ដូចគ្នានឹងបញ្ហាចរាចរណ៍ ជួញដូរមនុស្ស ត្រូវតែខិតខំធ្វើឱ្យបានសម្រេច នៅឆ្នាំនេះ។ ក្នុងឱកាសនោះ ក៏មានបំពាក់គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការមួយចំនួនផងដែរ៕ដោយ៖*គ្រញូង/sn*

## លោកជំទាវ ម៉ែន សំអនៈ រាជរដ្ឋាភិបាលនៅតែបន្តយកចិត្តទុកដាក់ជាមួយពលករ ពលការិនីខ្មែរនៅប្រទេសថៃ

http://www.akp.gov.kh/ AKP ភ្នំពេញថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨

លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានដឹកនាំគណៈប្រតិភូទៅជួបសំណេះសំណាល ផ្តល់ការលើកទឹកចិត្តជាមួយពលករ ពលការិនីខ្មែរប្រមាណជាង ៧០០នាក់ ដែលកំពុងធ្វើការនៅរោងចក្រផលិតអាហារសមុទ្រនៅខេត្តសមុទ្រសាខនប្រទេសថៃ នាព្រឹកថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។

តាមការឱ្យដឹងពីឯកឧត្តម ចាប សុថារិទ្ធ នាយកខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន បានបញ្ជាក់ថាថ្លែងក្នុងឱកាសនោះ លោកជំទាវ ក៏បានពាំនាំនូវការផ្តាំផ្ញើ និងសាកសួរសុខទុក្ខពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងបានផ្តល់កម្លាំងចិត្តឱ្យពលករ ពលការិនីខ្មែរទាំងអស់ប្រឹងប្រែងធ្វើការងារឱ្យកាន់តែសកម្មថែមទៀត ដើម្បីទទួលបានប្រាក់ខែខ្ពស់ និងទទួលការពេញចិត្តពីថៅកែរោងចក្រ។ រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចតេជោ ហ៊ុន សែន ជាប្រមុខ ជានិច្ចកាលតែងតែមានមនោសញ្ចេតនាជិតស្និទ្ធជាមួយប្រជាជន និងពលករ ពលករ ពលការិនី ដែលកំពុងធ្វើការនៅក្នុងស្រុក និងនៅក្រៅប្រទេស។

លោកជំទាវបានបន្តថា ជាក់ស្តែងដូចជាពេលនេះ ទោះជាបងប្អូនមកធ្វើការនៅប្រទេសថៃ ឆ្ងាយពីស្រុកកំណើតក្តីក៏សម្តេចនៅតែគិតគូរ និងបានចាត់តាំងថ្នាក់ដឹកនាំមួយចំនួនទៀតរួមមានៈ រូបខ្ញុំម៉ែន សំអន,លោកជំទាវបាន ស្រីមុំ, ឯកឧត្តម អ៊ិត សំហេង ឯកឧត្តម ហ៊ុន ម៉ាណែត ឯកឧត្តម ហ៊ុន ម៉ានី និង ឯកឧត្តម ព្រុំ សុខា ជាតំណាងមកជួបសំណេះ សំណាលជាមួយបងប្អូនដើម្បីសាកសួរសុខទុក្ខ និងចែករំលែកព័ត៌មាន និងជួយដោះស្រាយបញ្ហាប្រឈមផ្សេងៗ ដែលបងប្អូន ពលករ ពលការិនីជួបប្រទះ។ លោកជំទាវបានលើកឡើងថា បច្ចុប្បន្នរាជរដ្ឋាភិបាលបានផ្តល់លិខិតឆ្លងដែនជូនពលករ ពលការិនីយើងដោយឥតគិតថ្លៃ និងបានរៀបចំគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដើម្បីដោះស្រាយការលំបាកនានា ជាពិសេសជួយសម្រួលឱ្យបងប្អូនពលករ ពលការិនីយើងរស់នៅ និងធ្វើការដោយស្របច្បាប់ និងដោយមានកិត្តិយស រួចផុតពីការរំលោភ ជិះជាន់ កេងប្រវ័ញ្ច និងហានិភ័យផ្សេងៗ។

ដោយឡែក ភាគីកម្ពុជាបានបើកយុទ្ធនាការ ១០០ថ្ងៃ ដោយផ្តល់ឯកសារជាលិខិតធ្វើដំណើរ(TD) និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស(OCWC) ជូនពលករពលការិនីយើងបានចំនួន១៦ ទៅ១៧ម៉ឺននាក់រួចហើយ។ ការធ្វើ TD និង OCWC ថ្មី ដោយប្រើរយៈពេលតែមួយថ្ងៃ តម្លៃ២.៣៥០បាត និងបញ្ជូនបុគ្គលិក ៣៦០នាក់ មកបំពេញបេសកកម្មនេះ។ សូមបញ្ជាក់ថា រហូតមកពេលនេះពលករ ពលការិនីកម្ពុជា មកធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបប្រមាណជាង ១លានាក់។ រហូតមកដល់ពេលនេះរាជរដ្ឋាភិបាលកម្ពុជាបានខិតខំធ្វើទំនាក់ទំនងការងារឱ្យស្របច្បាប់ និងផ្តល់សិទ្ធិឱ្យពលករ ពលការិនីកម្ពុជារស់នៅ ធ្វើដំណើរ និងធ្វើការងារដោយស្របច្បាប់នៅប្រទេសថៃ អាចសុំទិដ្ឋាការស្នាក់នៅ (Stay Permit) និងសៀវភៅការងារ (Work Permit) ពីអាជ្ញាធរថៃប្រមាណ៨០ភាគរយហើយ។ នៅសល់តែ២០ភាគរយទៀត រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំជំរុញឱ្យមន្ត្រីពាក់ព័ន្ធសហការជាមួយអាជ្ញាធរភាគីថៃ ផ្តល់លិខិតស្នាក់នៅនិងធ្វើការដោយស្របច្បាប់ ឱ្យបានរួចរាល់នៅឆ្នាំ២០១៨នេះ ។

លើសពីនេះទៀតបងប្អូនក៏អាចទទួលបាននូវការការពារសិទ្ធិតាមច្បាប់ ទទួលបានប្រាក់ឈ្នួលសមស្រប មានសិទ្ធិបើកគណនីធនាគារ និងអាចធ្វើប័ណ្ណបើកបរបាន ។ជាមួយគ្នានោះដែរ លោកជំទាវមានប្រសាសន៍ផ្តាំផ្ញើរថា បងប្អូនពលករខ្មែររស់នៅនិងធ្វើការងារត្រូវគោរពច្បាប់ប្រទេសថៃ ដាច់ខាតមិនត្រូវប្រព្រឹត្តិបទល្មើសដូចជា អំពើហឹង្សា

គ្រឿងញៀនជាដើម ។ កុំជឿតាមការញុះញង់របស់គណបក្សប្រឆាំងដែលមានបំណងបំផ្លាញសន្តិភាព និងរារាំងដល់ការអភិវឌ្ឍប្រទេស ។

ចំណែកឯថៅកែក្រុមហ៊ុនសូមបន្តទទួលយកពលករខ្មែរបន្ថែមទៀត និងត្រូវអាណិត ស្រឡាញ់ពលករខ្មែរ ដូចពលករថៃផងដែរ ។ ដោយឡែកស្ថានទូត ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅប្រទេសថៃ សូមបន្តការយកចិត្តទុកដាក់តាមដាន និងជួយដោះស្រាយរាល់បញ្ហានានារបស់ពលករខ្មែរ ស្របតាមច្បាប់អន្តរជាតិ ច្បាប់ប្រទេសថៃ និងស្មារតីនៃអនុស្សរណៈយោគយល់គ្នា( MOU) ដែលរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរបានចុះហត្ថលេខាជាមួយគ្នាកន្លងម៕

ដោយសួស សំរិត

## មនុស្សរាប់សិបនាក់ ត្រូវគេឆបោកដោយសន្យានាំទៅធ្វើការនៅ ជប៉ុន

http://www.postkhmer.com/ Tue, 23 January 2018 យន់ ស៊ីនាត

**កណ្ដាល:**មានមនុស្សរាប់សិបនាក់ នៅក្នុងខេត្តកណ្ដាល បានធ្វើការចោទប្រកាន់ ឈ្មួញកណ្ដាល ក្នុងមូលដ្ឋានម្នាក់ថា បានឆបោកប្រាក់ពួកគាត់ អស់ប្រាក់រាប់ពាន់ដុល្លារ ដោយបានសន្យាថា នឹងផ្ដល់ការងារឱ្យពួកគេនៅប្រទេសជប៉ុន ប៉ុន្តែរហូតមកដល់ពេលនេះ ពួកគេមិនដែលបានទទួលការងារនោះទេ។

អ្នកស្រី វ័ន្ត សុភឿន អាយុ ៣៨ ឆ្នាំដែលតំណាងឱ្យជនរងគ្រោះ មកពីឃុំបន្ទាយដែក ស្រុកគៀនស្វាយបានឱ្យដឹងថា អ្នកស្រីបានចំណាយប្រាក់អស់ ៣ ពាន់ដុល្លារ ទៅឱ្យឈ្មួញកណ្ដាលម្នាក់នោះ ដែលមកពីឃុំជិតខាង ដើម្បីរកការងារឲ្យរូបគាត់ និងប្ដីរបស់គាត់ កាលពីឆ្នាំ ២០១៦។ អ្នកស្រី សុភឿន ថ្លែងថា អ្នកស្រីចាប់ផ្ដើមមានការសង្ស័យបន្ទាប់ពីឈ្មួញកណ្ដាលរូបនោះ បានពន្យារពេលពីដំបូងរហូតដល់ខែមីនាឆ្នាំ ២០១៧ និងបន្ទាប់មកទៀត ពន្យារហូតដល់ខែតុលាឆ្នាំ ២០១៧។ អ្នកស្រីសុភឿនបញ្ជាក់ថា អ្នកស្រីក៏មានការសង្ស័យផងដែរ ពីព្រោះអ្នកស្រីត្រូវបានគេបញ្ជូនឲ្យទៅរៀននៅសាលាភាសាជប៉ុនមួយ ដែលមើលទៅហាក់ដូចជាផ្ទះរបស់នរណាម្នាក់។ បើតាមអ្នកស្រី សុភឿន អ្នកភូមិប្រមាណ ៣០ នាក់ នៅក្នុងឃុំរបស់អ្នកស្រី បានសំរេចចិត្តដាក់ពាក្យបណ្ដឹងបន្ទាប់ពីពួកគេ បានរកឃើញថា ស្ត្រីម្នាក់ឈ្មោះ អៀត សារឹម អាយុ ៥៣ ឆ្នាំ ត្រូវបានចាប់ខ្លួននិងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ រយៈពេលមួយឆ្នាំ ពីបទលួចបន្លំមួយផ្សេងទៀត ដែលមិនទាក់ទិននឹងករណីនេះកាលពីខែវិច្ឆិកា។

អ្នកនាំពាក្យតុលាការខេត្តកណ្ដាល លោក ទិន សុចិត្រា បានឲ្យដឹងថា តុលាការបានទទួលពាក្យបណ្ដឹងរបស់អ្នកស្រីសុភឿនរួចហើយ ដែលបានចុះហត្ថលេខា ដោយជនរងគ្រោះ ៥ នាក់ ប៉ុន្តែលោកបញ្ជាក់ថា តុលាការនៅតែស៊ើបអង្កេតនៅឡើយ។

អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ក៏បានរំលឹកដល់អ្នកស្វែងរកការងារធ្វើទាំងនោះ ឲ្យមានការប្រុងប្រយ័ត្ន និងពិនិត្យឲ្យបានហ្មត់ចត់ មុនពេលសម្រេចចុះឈ្មោះជាមួយ ឈ្មួញកណ្ដាលឯករាជ្យណាមួយនោះ។ លោកថ្លែងថា៖«នោះហើយជាមូលហេតុដែលយើងតែងតែស្នើឱ្យអ្នកដែលកំពុងស្វែងរកឱកាសបណ្ដុះបណ្ដាល ទៅធ្វើការនៅប្រទេសជប៉ុន ត្រូវតែត្រួតពិនិត្យឈ្មោះភ្នាក់ងារទាំងនោះ ឲ្យបានហ្មត់ចត់មុនពេលពួកគេ សម្រេចចិត្តចុះឈ្មោះជាមួយភ្នាក់ងារណាមួយ ឬមនុស្សណាម្នាក់»៕ NS

## អនិកជនខ្មែរម្នាក់ ត្រូវជំនុំជម្រះរឿងឆបោកប្រាក់រាប់ម៉ឺនដុល្លារ

http://www.postkhmer.com/ Tue, 23 January 2018 នៀម ឆេង

**ភ្នំពេញ:** បុរសអនិកជនម្នាក់ ត្រូវបានតុលាការបើកសវនាការជំនុំជម្រះកាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៨ ពីបទឆបោកប្រាក់រាប់ម៉ឺនដុល្លារ ពីជនរងគ្រោះ ៩ នាក់ដោយសន្យាថា នឹងបញ្ជូនពួកគេទៅធ្វើការនៅប្រទេសអូស្ត្រាលី ប៉ុន្តែ មិនបានបញ្ជូនពួកគេទៅតាមការសន្យានោះទេ។

ជនជាប់ចោទមាន ឈ្មោះ វ័ន្ត យ៉េនវីលៀម អាយុ ៤៧ ឆ្នាំ ត្រូវបានកងរាជអាវុធហត្ថចាប់ខ្លួនកាលពីចុងខែមិថុនា ឆ្នាំ ២០១៧ តាមបណ្ដឹងរបស់ជនរងគ្រោះ។ សវនាការនេះ មានលោក សេង លាង ចៅក្រមជំនុំជម្រះនិងលោកស្រី ស៊ី វណ្ណនី ជាព្រះរាជអាជ្ញា។

លោកស្រី ស៊ី វណ្ណនី បានថ្លែងក្នុងសវនាការថា ជនជាប់ចោទ វ័ន្ត យ៉េនវីលៀម ពិតជាបានប្រព្រឹត្តបទល្មើសឆបោកពិតប្រាដកមែន កាលពីអំឡុងឆ្នាំ ២០១៥ ហើយលោកស្រីស្នើឲ្យចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ លោកស្រីថ្លែងថា៖ «កាលពីអំឡុងឆ្នាំ ២០១៥ ឈ្មោះ វ័ន្ត យ៉េនវីលៀម បាន សន្យាថា នឹងបញ្ជូនជនរងគ្រោះ ៩ នាក់ទៅធ្វើការនៅប្រទេសអូស្ត្រាលី ដោយយកប្រាក់ម្នាក់ៗចាប់ពី ៦ ពាន់ដុល្លារដល់ ២ ម៉ឺនដុល្លារ។ បទល្មើសដែលមានចែងក្នុងមាត្រា ៣៧៧ និង ៣៧៨ នៃក្រមព្រហ្មទណ្ឌ»។

ជនជាប់ចោទ វ័ន្ត យ៉េនវីលៀម បានបដិសេធថា ខ្លួនមិនបានឆបោកទេ ហើយការដែលមិនបានបញ្ជូនជនទាំង ៩ នាក់ទៅអូស្ត្រាលី ដោយសារតែភាគីខាងអូស្ត្រាលី បានពន្យារពេលទទួលយកពួកគេ។ ជនជាប់ចោទនិយាយថា ខ្លួនធ្លាប់បញ្ជូនមនុស្សទៅធ្វើការជាច្រើនមកហើយ។ ជនជាប់ចោទនិយាយថា «ខ្ញុំនឹងលក់ដីមួយកន្លែងនៅកំពង់សោម ដើម្បីសងបំណុលគេ។ ដីខ្ញុំបើលក់បានប្រហែល ៧ម៉ឺនដុល្លារ»។

យោងតាមរបាយការណ៍របស់កងរាជអាវុធហត្ថក្រុងភ្នំពេញ ជនជាប់ចោទ ទទួលបានសញ្ជាតិអាមេរិក ហើយបានមកបើកអង្គការមិត្តភាពកម្ពុជា ជប៉ុន ដោយខ្លួនមានឋានៈជាប្រធានអង្គការ។ ជនរូបនេះ បានជ្រើសរើសមនុស្សទៅធ្វើការនៅអូស្ត្រាលី ដោយប្រមូលប្រាក់កម្រៃជើងសារ ពី១ម៉ឺនទៅ២ម៉ឺនដុល្លារ។ ក្រោយពេលប្រមូលប្រាក់បានហើយ ជនជាប់ចោទ បាមគេចខ្លួន។ របាយការណ៍បន្ថែមថា ជនជាប់ចោទ ធ្លាប់បានទទួលប្រាក់ពីមនុស្សជាង ៣០ នាក់រួចមកហើយ។ ចៅក្រមជំនុំជម្រះ លោក សេង លាង បានលើកពេលប្រកាសសាលក្រមទៅថ្ងៃទី ៧ ខែកុម្ភៈ៕

## រដ្ឋាភិបាលជប៉ុនអនុញ្ញាតឱ្យនិស្សិតកម្ពុជាអាចទៅធ្វើការ និងរស់នៅប្រទេសជប៉ុនបានអស់មួយជីវិត

http://www.akp.gov.kh/kh/ AKP សៀមរាប ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨

ប្រធានសហជីពទទួលពលករពីកម្ពុជាឱ្យទៅធ្វើការនៅប្រទេសជប៉ុន បានអះអាងថា បច្ចុប្បន្ននេះប្រជាពលរដ្ឋជប៉ុនភាគច្រើនមានវ័យចំណាស់ ដែលមិនអាចធ្វើការបាន ហើយដើម្បីឱ្យសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសជប៉ុន ចេះតែទៅបានល្អ រដ្ឋាភិបាលជប៉ុនបានអនុញ្ញាតឱ្យពលករនៃបណ្តាប្រទេសផ្សេងៗ ក្នុងនោះ ក៏មានកម្ពុជាដែរ ចូលទៅនៅប្រទេសជប៉ុនបាន។

នៅក្នុងឱកាសជួបជាមួយនិស្សិតសកលវិទ្យាល័យអង្គរខេត្តសៀមរាប កាលពីចុងសប្តាហ៍កន្លងទៅនេះ លោក Harima Hiroki ប្រធានសហជីពទទួលពលករពីកម្ពុជាឱ្យទៅធ្វើការនៅប្រទេសជប៉ុន បានបញ្ជាក់ថា ពលករទាំងនោះអាចទៅធ្វើការនៅប្រទេសជប៉ុន បានត្រឹមតែ៣ទៅ៥ឆ្នាំប៉ុណ្ណោះ គឺត្រូវត្រឡប់មកកម្ពុជាវិញ។ តែឥឡូវនេះ រដ្ឋាភិបាលជប៉ុនបានសម្រេចអនុញ្ញាតឱ្យនិស្សិតកម្ពុជា ដែលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកវិស្វកម្ម និងស្ថាបត្យកម្ម នៅសកលវិទ្យាល័យអង្គរអាចទៅធ្វើការ និងរស់នៅប្រទេសជប៉ុនអស់មួយជីវិតបាន។ លោកបានបន្តថា ដោយសារមានកិច្ចសហប្រតិបត្តិការរវាងប្រទេសជប៉ុន និងសកលវិទ្យាល័យអង្គរ ខេត្តសៀមរាប នៅក្នុងជំនួបជាមួយនិស្សិតលើកនេះ ខាងសហជីពទទួលពលករ នៃប្រទេសជប៉ុន បាននាំប្រធានក្រុមហ៊ុនសំណង់ធំៗ នៅជប៉ុនប្រមាណជា៤ ក្រុមហ៊ុន ឱ្យមកជួបជាមួយនិស្សិតនៅសកលវិទ្យាល័យអង្គរនេះដោយផ្ទាល់ ដើម្បីធ្វើការទំនាក់ទំនងជាមួយនិស្សិតទាំងអស់នេះដោយផ្ទាល់។

លោកប្រធានសហជីពបានលើកឡើងទៀតថា នៅពេលដែលនិស្សិតណាម្នាក់យល់ព្រមទៅធ្វើការជាមួយក្រុមហ៊ុនណាមួយហើយនោះក្រុមហ៊ុននោះ នឹងចេញថវិកាថ្លៃការសិក្សាទាំងអស់រហូតទល់បញ្ចប់ការសិក្សារួចមកខាងក្រុមហ៊ុន និងរៀបចំឯកសារយកនិស្សិតនោះទៅធ្វើការនៅប្រទេសជប៉ុនតែម្តង ហើយទៅធ្វើការនេះនិស្សិតអាចទៅរស់នៅមួយជីវិតបាន ឬអាចធានាយកម្តាយឪពុកទៅរស់នៅជាមួយគ្នាក៏បាន។ ទន្ទឹមនេះបច្ចុប្បន្ននៅមានក្រុមហ៊ុនចំនួន ៣.០០០ក្រុមហ៊ុនលើគ្រប់វិស័យចាំទទួលពលករ និងអ្នកជំនាញពីកម្ពុជាទៅធ្វើការនៅទីនោះ ហើយមានពលករខ្មែរប្រមាណជា១៥០នាក់ហើយ ដែលបានទៅធ្វើការនៅតាមបណ្តាក្រុមហ៊ុនទាំងនេះ។

លោក សុខ តុញ អនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាភិបាលនៃសកលវិទ្យាល័យអង្គរ បានមានប្រសាសន៍ថា នេះជាឱកាសល្អសម្រាប់និស្សិតទាំងក្នុងការចាប់យកអាជីព ឬជំនាញណាមួយឱ្យច្បាស់លាស់សម្រាប់អនាគត ព្រោះឱកាសទទួលបានទាំងអាហារូបករណ៍សម្រាប់ការសិក្សា និងមានការងារធ្វើល្អមានកម្រៃខ្ពស់ទៀត បែបនេះមិនងាយមាននោះទេ។ លោកបានបន្ថែមថា ដោយមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសជប៉ុន និស្សិតទាំងអស់ដែលរៀននៅក្នុងសកលវិទ្យាល័យអង្គរមានឱកាសទៅបន្តការសិក្សាឬទៅធ្វើការនៅប្រទេសជប៉ុនគ្រប់មុខជំនាញ។ ជាមួយគ្នានេះ ក្រៅពីប្រទេសជប៉ុន សាលកវិទ្យាល័យអង្គរ ក៏មានប្រទេសដៃគូធ្វើកិច្ចសហប្រតិបត្តិការ ចំនួន២៣ផ្សេងទៀត ក្នុងនោះមានដូចជា កូរ៉េ ចិន អូស្ត្រាលី និងថៃជាដើម ៕ ដោយ យុត សៅ

**អង្គការសម្ព័ន្ធចាប់ដៃ ៖ មកដល់ឆ្នាំ២០១៧ ករណីជួញដូរស្ត្រីខ្មែរ ទៅក្រៅប្រទេស នៅតែកើតមាន**

http://wmc.org.kh ថ្ងៃអង្គារ ទី២៣ ខែមករា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ អង្គការ សម្ព័ន្ធចាប់ដៃ ដែលធ្វើការងារលើកិច្ចការពារ ស្ត្រី ពីការជួញ និងការរំលោភបំពានលើកុមារីទៅក្រៅប្រទេស បានបង្ហាញរបាយការណ៍របស់ខ្លួនថា ក្នុងឆ្នាំ២០១៧ អំពើជួញដូរស្ត្រី ទៅក្រៅប្រទេសនៅតែកើតមាន។ ប៉ុន្តែសកម្មភាពនៃការជួយស្ត្រីរងគ្រោះត្រូវបានរកឃើញច្រើនជាមុន ព្រោះមានការសហការបានល្អជាមួយរដ្ឋាភិបាលកម្ពុជា។ អង្គការសម្ព័ន្ធចាប់ដៃ មានទស្សនវិស័យ ព្យាយាមលុបបំបាត់រាល់អំពើជួញដូរស្ត្រី និងការរំលោភបំពានទៅលើកុមារ។ អង្គការសង្គមស៊ីវិល ក្រៅរដ្ឋាភិបាលមួយនេះ បានធ្វើការងារជួយដល់ស្ត្រីខ្មែរ ដែលត្រូវបានជនខិលខូចបោកយកទៅលក់នៅក្រៅប្រទេសចាប់តាំងពីឆ្នាំ២០០៥។

លោក ស្រ៊ន់ ឡង់ដា ប្រធានគម្រោង ក្នុងគម្រោងគាំទ្រករណី នៃការជួញដូរ របស់អង្គការសម្ព័ន្ធចាប់ដៃ បានផ្តល់បទសម្ភាសន៍ឲ្យវិទ្យុស្ត្រីអេហ្វអឹម១០២ កាលពីដើមខែមករា កន្លងទៅនេះថា បញ្ហាពីការជួញដូរស្ត្រីនៅទៅក្រៅប្រទេសនៅតែកើតមាន។ ក៏ប៉ុន្តែមិនមានចំនួនច្រើនដូចកាលពីប៉ុន្មានឆ្នាំមុនឡើយ។ លោកបានបន្តទៀតថា ក្នុងឆ្នាំ២០១៧ អង្គការសម្ព័ន្ធចាប់ដៃ បានទទួលការសហការកាន់តែល្អពីរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិនានា ដែលបានធ្វើឲ្យអង្គការសង្គមស៊ីវិលមួយនេះ ជួយស្ត្រីរងគ្រោះពីការជួញដូរ បានហួតដល់ជាង ១០០ករណីពីប្រទេសមួយចំនួន ដែលមានដូចជាប្រទេសចិន ថៃ និងប្រទេសម៉ាឡេស៊ី។ យោងតាមតួលេខ ដែលអង្គការសម្ព័ន្ធចាប់ដៃ សហការជាមួយស្ថានទូតខ្មែរ ប្រចាំប្រទេសទាំងប៉ុន្មាននេះ បានធ្វើអន្តរាគមន៍ជួយស្ត្រីខ្មែរ ដែលត្រូវបានជនខិលខូចបោកយកទៅលក់នៅក្រៅប្រទេស ឲ្យវិលត្រឡប់មកកាន់ទឹកដីកំណើតវិញ បានបង្ហាញថា ចំនួននេះ មានការកើនឡើងប្រមាណ ១០ករណី បើធៀបនឹងឆ្នាំ២០១៦។

លោក ស្រ៊ន់ ឡង់ដា ៖«នៅពេលដែលយើងបានជួយច្រើន មិនមែនមានន័យថា ករណីជួញដូរហ្នឹងកើនឡើងច្រើនលើសលប់ បើធៀបនឹងឆ្នាំចាស់ទេ តែមានន័យថា យើងធ្វើការបានច្រើន យើងមានការសហការបានល្អជាមួយនិងអាជ្ញាធរជាមួយនិងស្ថានទូតនិងអង្គការដៃគូ ដើម្បីព្យាយាមលុបបំបាត់ ជួយជនរងគ្រោះទាក់ទងនិងការជួញដូរ»។ ស្ត្រីខ្មែរ មិនថា អ្នករស់នៅទីក្រុង ឬទីជនបទនោះទេ ពួកគេតែងតែងាយត្រូវបានជនខិលខូចលួងលោម ឲ្យស្ម័គ្រចិត្តទៅធ្វើការងារនៅក្រៅប្រទេស តាមរយៈពួកគេ។ ស្ត្រី ងាយចាញ់បោកជនខិលខូច ឬហៅថា មេខ្យល់ ដែលលោក ស្រ៊ន់ ឡង់ដា មើលឃើញហេតុផលមួយចំនួនដូចជាស្ត្រីភាគច្រើនរស់នៅតំបន់ដាច់ស្រយាល ឪពុក ម្តាយ មានជីវភាពក្រីក្រ ស្ត្រីខ្វះចំណេះដឹង កត្តាអត់ការងារធ្វើក្នុងស្រុក និងមួយចំណុចទៀត គឺការខ្វះព័ត៌មានជុំវិញការធ្វើចំណាកស្រុក។

លោក ស្រ៊ន់ ឡង់ដា ៖«ហេតុផលមួយទៀត អាចថា គាត់ខ្វះចំណេះដឹង គាត់ខ្វះប្រព័ន្ធព័ត៌មាន។ អញ្ចឹងប្រព័ន្ធព័ត៌មានគឺជាកត្តាសំខាន់ណាស់ ដើម្បីឲ្យគាត់សម្រេចចិត្តបានត្រឹមត្រូវ។ នៅពេលដែលគាត់ខ្វះខាតព័ត៌មាន ថាអ្វីទៅគឺជាការចំណាកស្រុក អ្វីទៅគឺជាការជួញដូរមនុស្ស អញ្ចឹងនៅពេលដែលគាត់ខ្វះខាតព័ត៌មានទាំងអស់ហ្នឹង គឺគាត់ជឿស្លុងទៅលើមេខ្យល់ ឬក៏ក្រុមហ៊ុន បោកបញ្ឆោតឲ្យទៅធ្វើការនៅប្រទេសក្រៅដើម្បីទទួលបានប្រាក់ខែខ្ពស់»។ ចាប់តាំងពីឆ្នាំ២០០៥មក អង្គការសម្ព័ន្ធចាប់ដៃ បានជួយស្ត្រីជាច្រើនពីការជួញដូរទៅក្រៅប្រទេស។ លោក ស្រ៊ន់ ឡង់ដា បានឲ្យដឹងថា ស្ត្រីចាប់ពីវ័យ ១៨ឆ្នាំឡើងទៅភាគច្រើនត្រូវបានជួញដូរទៅកាន់ បី ប្រទេសសំខាន់ៗ គឺប្រទេសម៉ាឡេស៊ី ថៃ និងប្រទេសចិន។

តែយ៉ាងណាក្រៅតែពីប្រទេសមុខសញ្ញាទាំងបីនេះ អង្គការសម្ព័ន្ធចាប់ដៃ ក៏បានសហការជាមួយអាជ្ញាធរខ្មែរ ជួយស្ត្រីពីការជួញដូរ ទៅកាន់ទីក្រុងហុងកុង ប្រទេសអារ៉ាប់ប៊ីសារអូឌីត និងប្រទេសជប៉ុន ផងដែរ តែក្នុងករណីតិចតួចប៉ុណ្ណោះ។ ស្ត្រីខ្មែរ ដែលត្រូវបានជួញដូរទៅប្រទេសចិន គឺភាគច្រើនបំផុតត្រូវបានមេខ្យល់ លក់ពួកគាត់ឲ្យធ្វើទាសករផ្លូវភេទរបស់បុរសចិន។ ស្ត្រី ដែលត្រូវលក់ឲ្យបុរសជនជាតិចិនទាំងអស់ ពួកគាត់តែងតែត្រូវបុរសជនជាតិចិន បង្ខំរំលោភ ធ្វើទារុណកម្ម និងជាពិសេសពួកគាត់ត្រូវបង្ខំឲ្យធ្វើការងារផ្ទះច្រើនស្ទើរតែគ្មានពេលឈប់។ លោក លោក ស្រ៊ន់ ឡង់ដា ពន្យល់ បន្ថែមថា ៖«រូបភាពដែលយើងទទួលបាននៅក្នុងប្រទេសចិន ទាំងអស់គឺជាករណីស្រី ហើយករណីស្ត្រីទាំងអស់ហ្នឹង គឺជាការបង្ខំឲ្យរៀបការជាមួយប្ដីចិន ។ បានន័យថា យកគាត់ទៅរំលោភបំពានហ្នឹង មុនដំបូងភូតគាត់ថា ទៅធ្វើការរោងចក្រ ប្រាក់ខែល្អធ្វើការក្រុមហ៊ុន។

ក៏ប៉ុន្តែនៅពេលដែលទៅដល់ប្រទេសគោលដៅ គាត់ហ្នឹងត្រូវបានគេលក់ទៅឲ្យប្ដីចិន បុរសជនជាតិចិន ធ្វើទាសករផ្លូវភេទ នេះជាករណីដែលយើងទទួលបាន»។ អ្នកជំនាញប្រឆាំងការជួញដូរ ស្ត្រី បាន បន្ថែមទៀតថា ចំណែកឯស្ត្រីខ្មែរ ដែលត្រូវបានមេខ្យល់បោកយកទៅលក់នៅប្រទេសម៉ាឡេស៊ី គឺត្រូវបានយកទៅ ធ្វើជាអ្នកបម្រើតាមផ្ទះ ដោយមិនបានទទួលប្រាក់កម្រៃ ហើយលើសពីនេះ ស្ត្រីភាគច្រើនត្រូវបានចាប់រំលោភ ឬធ្វើទារុណកម្ម រហូតដល់មានរបួសគ្រាំគ្រា ហើយមានស្ត្រីខ្លះទៀត បានសម្រេចចិត្តសម្លាប់ខ្លួន។ ដោយឡែក ប្រទេសថៃវិញ ស្ត្រីត្រូវបានជួញដូរកម្លាំងពលកម្ម ធ្វើការងារលំបាកៗជាច្រើន ដោយទទួលបានកម្រៃតិចតួច។

លោក ស្រ៊ន់ ឡង់ដា ៖«ដោយឡែកនៅប្រទេសម៉ាឡេ ករណីដែលយើងទទួលបានគឺករណីធ្វើការតាមផ្ទះ។ ធ្វើការតាមផ្ទះពេលខ្លះថៅកែហ្នឹង អត់គោរពតាមពាក្យសន្យាដែលមេខ្យល់បានប្រាប់គាត់ពីខ្មែរទៅទេ បានន័យថា ឲ្យតែមានការងារ គឺប្រគាត់គ្រប់ម៉ោងទាំងអស់។ ពេលខ្លះត្រូវធ្វើការពីម៉ោង ៥ភ្លឺ ៤ភ្លឺ រហូតដល់ម៉ោង ១២យប់ក៏មាន ហើយបាយនៅពេលគាត់ទទួលបាន គាត់ឲ្យហូបតែមីទៀត ហើយធ្វើការមិនល្អគេវ៉ៃទៀត ហើយពេលខ្លះគេវ៉ៃហើយគេរំលោភបំពានទៅលើផ្លូវភេទទៀត អញ្ចឹង រូបភាពច្រើន ដែលយើងឃើញ ហើយប្រសិនណាគាត់មិនធ្វើតាមថៅកែហ្នឹងទេ គេវ៉ៃគាត់ គេចងគាត់ រហូតដល់ករណីខ្លះគាត់សម្រេចចិត្តសម្លាប់ខ្លួនក៏មាន»។ ស្ត្រីខ្មែរ ដែលត្រូវបានជនខិលខូច បោកបញ្ឆោតយកទៅលក់នៅក្រៅប្រទេស ក្រោយពីត្រូវបានជួយសង្គ្រោះត្រឡប់មកកាន់ដែនដីកំណើតវិញ ពួកគេជិត ៧០ភាគរយ បានក្លាយខ្លួនជាមនុស្សមានជំងឺផ្លូវចិត្ត និងស្ទើរតែទាំងអស់មានរងរបួសគ្រាំគ្រា។

ពាក់ព័ន្ធនឹងការជួញដូរស្ត្រីខ្មែរ ទៅក្រៅប្រទេសនេះដែរ កាលពីថ្ងៃចន្ទ ទី១៥ មករា អាជ្ញាធរខេត្តបាត់ដំបង បានចាប់ខ្លួនស្ត្រីម្នាក់ដែលបានបោកបញ្ឆោតស្ត្រីខ្មែរ ចំនួន០៥នាក់ យកទៅឲ្យមេខ្យល់នាំយកទៅធ្វើការនៅប្រទេសម៉ាឡេស៊ី រយៈជាង ១ឆ្នាំ។ កញ្ញា ចម្ប៉ា ឈ្មោះអ្នកនិពន្ធដាក់ឲ្យ នាងគឺជាស្ត្រីម្នាក់ ក្នុងចំណោមស្ត្រីទាំងប្រាំនាក់នោះ នាងត្រូវបានថៅកែ ម៉ាឡេស៊ី ប្រើឲ្យធ្វើការលើសែង កេះផ្លែឈើ និងរបស់របរផ្សេងៗ ដែលមានទម្ងន់ពី ៧០ ទៅ ៨០ គីឡូក្រាម ហើយមិនតែប៉ុណ្ណោះ ថៅកែម៉ាឡេស៊ី បានវាយដំកញ្ញា ចម្ប៉ា ដោយប្រើដំទឹកកក និងបានយកនាងទៅបង្ខាំងទុកក្នុងទូរទឹកកក ដាក់ផ្លែឈើ នៅពេលដែលស្ត្រីម្នាក់នោះ មានកំហុសម្ដងៗ។ រយៈពេលជាង ១ឆ្នាំ ដែលកញ្ញា ចម្ប៉ា ត្រូវបាននាំយកទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នាងបានជួបផលលំបាក និងការវាយដំជាទម្ងន់ រហូតដល់នាងមានបញ្ហាសុខភាពធ្ងន់ធ្ងរ របួសគ្រាំក្នុង និងបត់ជើងតូចមានលាយឈាម។

ជុំវិញបញ្ហានេះ លោក ស្រ៊ន់ ឡង់ជាប្រធានគម្រោង ក្នុងគម្រោងគាំទ្រករណី នៃការជួញដូរ របស់អង្គការសម្ព័ន្ធចាប់ដៃ អំពាវនាវដល់អាជ្ញាធរមូលដ្ឋានទាំងអស់ បង្កើនការយកចិត្តទុកដាក់ឲ្យខ្ពស់បន្ថែមទៀត ដោយត្រូវប្រុងប្រយ័ត្ន និងពិនិត្យឲ្យបានច្បាស់រាល់ឯកសារមុនពេលចុះហត្ថលេខា នៅពេលដែលមានអ្នកទៅស្នើសុំនាំស្ត្រីទៅក្រៅប្រទេស។ លោកបន្តថា បញ្ហាជួញដូរស្ត្រីគឺជាបញ្ហាសកល ដែលមិនមែនជាបញ្ហា ឬក៏ជាទំនួលខុសត្រូវរបស់នណាម្នាក់នោះទេ តែវាគឺបញ្ហាដែលត្រូវរួមគ្នាដើម្បីដោះស្រាយ។ បន្ថែមពីលើនេះ លោក ស្នើសុំអាជ្ញាធរមូលដ្ឋាន បង្កើនសកម្មភាពចុះផ្សព្វផ្សាយឲ្យបានច្រើនជាងសព្វថ្ងៃ ដោយត្រូវពន្យល់ពលរដ្ឋឲ្យបានយល់កាន់តែច្បាស់ ពីគ្រោះថ្នាក់នៃការចំណាកស្រុកទាំងប្រថុយប្រថាន៕

## ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨

## សមត្ថកិច្ច ចុះឆែកឆេរកន្លែងម៉ាស្សាមួយកន្លែង ក្នុងសង្កាត់បឹងកេងកង២ រកឃើញមានបង្កប់សេវាកម្មផ្លូវភេទ

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៤ មករា ២០១៨ 23:53 ដោយ: ដើមអម្ពិល ID:019

**ភ្នំពេញ៖** នៅយប់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ដោយមាន លោក កុល បុន ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក យិន ភារិន ក្រឡាបញ្ជី និងមន្ត្រីពាក់ពន្ធក្នុងមូលដ្ឋាន បានធ្វើការចុះបង្ក្រាបជាក់ស្តែង ហាងម៉ាស្សា កោសជប់ មួយកន្លែង ហៅ (៧៦៦) ស្ថិតនៅផ្ទះលេខ ៤៦៨ ផ្លូវ២៧៨ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ រកឃើញមានបង្កប់សេវាផ្លូវភេទ និងឈានទៅដល់ការឃាត់ខ្លួន ជនសង្ស័យជាម្ចាស់ទីតាំងម្នាក់ និងជនរងគ្រោះ៣នាក់ ។

ប្រត្តិបត្តការចុះបង្ក្រាបជាក់ស្តែងនេះ បានរកឃើញថា ទីតាំងម៉ាស្សា កោសជប់៧៦៦ ដែលមានទីតាំងខាងលើនេះ មានបង្កប់សេវាផ្លូវភេទ ដោយក្នុងនោះ បានរកឃើញជនរងគ្រោះ៣នាក់ ទី១ឈ្មោះ រៀង ធីទីង ភេទស្រី ជនជាតិវៀតណាម, ទី២ឈ្មោះ ប៉ែន បូលក្ខិណា ភេទស្រី ជនជាតិខ្មែរ និងទី៣ ឈ្មោះ វៀន ធីហ្វុង ភេទស្រី ជាជនជាតិវៀតណាម ។ ក្នុងនោះបានឃាត់ខ្លួន ជនសង្ស័យជាម្ចាស់ទីតាំង ឈ្មោះ ហេង ចន្ទូ ភេទស្រី អាយុ៤០ឆ្នាំ ជាជនជាតិខ្មែរ ជាមួយវត្ថុតាង ជាស្រោមអនាម័យមួយចំនួនផងដែរ៕

## រាជរដ្ឋាភិបាល កម្ពុជាកំពុងពិភាក្សា ជាមួយភាគីថៃ ដើម្បីការពារសុវត្ថិភាព និងសិទ្ធិការងារឲ្យពលករខ្មែរ

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៤ មករា ២០១៨ 19:24 ដោយ: ដើមអម្ពិល ID:030

ភ្នំពេញ៖ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា ក្រៅពីកិច្ចខិតខំប្រឹងប្រែង ក្នុងការរៀបចំផ្តល់ ភាពស្របច្បាប់ជូនដល់ ពលករកម្ពុជាដែលកំពុង ធ្វើការនៅក្នុងប្រទេសថៃ រាជរដ្ឋាភិបាលកម្ពុជា កំពុងពិភាក្សាជាមួយភាគីថៃដើម្បីការពារ សុវត្ថិភាព សិទ្ធិការងារ ដែលក្នុងនោះរួមមាន របបគ្រោះថ្នាក់ការងារ របបថៃទាំសុខភាព និងប្រាក់សោធននិវត្តន៍ ជូនដល់ពលករកម្ពុជា ដូចពលករថៃដែរ។ នេះបើតាមការលើកឡើងរបស់លោក អ៊ិត សំហេងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី២៤ ខែមករាឆ្នាំ២០១៨ ក្នុងឱកាសដឹកនាំគណប្រតិភូចុះជួបសួរសុខទុក្ខបងប្អូនពលករខ្មែរ ចំនួន៥២៦ នាក់ក្នុងចំណោមពលករខ្មែរចំនួន ១៧៣០ នាក់ដែលធ្វើការនៅរោងចក្រផលិតសាច់មាន់របស់ក្រុមហ៊ុនសាន់ហ្វូត អិនធើណាសិនណាល់ ក្នុងខេត្តសារ៉ាក់បុរី នៃព្រះរាជាណាចក្រថៃឡង់ដ៍។

លោករដ្ឋមន្ត្រីបានឲ្យដឹងបន្ថែមថា កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ភាគីថៃបានពន្យាពេល៦ខែទៀតរហូតដល់ខែមិថុនា ២០១៨ដើម្បីក្រុមការងាររៀបចំឯកសាផ្តល់ភាពស្របច្បាប់ជូនដល់បងប្អូនពលករដែលកំពុងធ្វើការ និងស្នាក់នៅក្នុងប្រទេសថៃ ហេតុដូចនេះសូមបងប្អូនធ្វើការដោយស្ងប់ចិត្តហើយបើបងប្អូនមិនទាន់មានឯកសារស្រេបច្បាប់សូមនាំគ្នាទៅធ្វើអោយបានទាន់ពេលវេលា។ លោកបញ្ជាក់ថាទាំងនេះក៏ដោយសារតែមានកិច្ចសហប្រតិបត្តិការល្អរវាងរាជរដ្ឋាភិបាលកម្ពុជា-ថៃដែលបានផ្តល់ឱកាសជូនពលករកម្ពុជាមកធ្វើការងារនៅប្រទេសថៃ ព្រមទាំងបន្តគោលនយោបាយធានា សុវត្ថិភាព និងភាពស្របច្បាប់ចំពោះបងប្អូនខ្មែរនៅទីនេះផងដែរ ។ លោកក៏បានលើកឡើងបន្តថា ក្រុមការងារផ្តល់ភាពស្របច្បាប់ យើងកំពុងបន្តការងារដោយៈ

១-ផ្តល់លិខិតធ្វើដំណើរនិងបណ្ណពលករ ៣ មណ្ឌល ដែលមានទីតាំងនៅទីក្រុងបាងកក ខេត្ត រ៉ាកយ៉ង និង ខេត្ត សុងខ្លា ធ្វើមួយថ្ងៃហើយ តម្លៃ ២៣៥០បាត។

២-ចែកឯកសាធ្វើដំណើរ(TD) និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេស (OCWC) ដែលធ្វើរួចហើយចំនួន ១២ម៉ឺន នៅសល់១១ម៉ឺន តម្លៃ៩៥០បាត។

៣-រៀបចំ បន្ថែមក្រុមចលត័២ទៀត ចុះតាមកន្លែងដែលមានពលករខ្មែរច្រើនតាមសំណូមពរភាគីថៃ។

៤-អនុញ្ញាតិឲ្យសុំលិខិតពីមន្ទីរកាងារថៃដោយអាចទៅធ្វើឯកសារពីក្នុងប្រទេសបាន

៥-បើកមណ្ឌលផ្តល់ឯកសាធ្វើដំណើរ(TD) និងបណ្ណពលករកម្ពុជាធ្វើការនៅបរទេស (OCWC)ចំនួនបីកន្លែង រយៈពេលបីថ្ងៃ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។

លោករដ្ឋមន្ត្រីបានអំពាវនាវដល់បងប្អូនពលករកំពុងធ្វើការ និងរស់នៅប្រទេសថៃគឺត្រូវអនុវត្តច្បាប់របស់ប្រទេសគេអោយបានល្អចៀសវាងកុំធ្វើពលករខុសច្បាប់ ដែលនាំឲ្យគេកេងប្រវ័ញ្ចយកផលប្រយោជន៍ពីបងប្អូន ត្រូវពិន័យ និង ត្រូវជាប់ទោសទៀតផង។ ទន្ទឹមនឹងនេះដែរលោកបានស្នើសុំថៅកែក្រុមហ៊ុនបន្តទទួលពលករខ្មែរនិងផ្តល់ក្តីស្រឡាញ់ព្រមទាំងអត្ថប្រយោជន៍ដូចពលករថៃ និង សុំស្ថានទូតបន្តយកចិត្តទុកដាក់តាមដានដោះស្រាយរាល់បញ្ហានានាស្របតាមច្បាប់នៃប្រទេសថៃផងដែរ៕

## HRW៖ កម្មករខ្មែរនៅតែរងគ្រោះដោយការជួញដូរកម្លាំងពលកម្មលើទូកនេសាទថៃ

https://www.rfa.org/khmer/news/ ដោយ តាំង សារ៉ាដា 2018-01-24

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ (Human Rights Watch) រកឃើញថា ពលករចំណាកស្រុកខ្មែរជាច្រើននាក់ នៅតែបន្តរងគ្រោះដោយសារការជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្មនៅលើទូកនេសាទថៃដដែល។ ខណៈរដ្ឋាភិបាលយោធាថៃព្រងើយកន្តើយមិនចាត់វិធានការចាំបាច់នានា ដើម្បីបញ្ឈប់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានធ្ងន់ធ្ងរនៅលើទូកនេសាទនោះ។ យូមែន រ៉ៃត៍ វ៉ច្ឆ អំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យដាក់ចេញនូវចំណាត់ការដាក់លាក់ ដើម្បីជួយដល់ពលរដ្ឋរបស់ខ្លួនដែលបានរងគ្រោះ និងដែលកំពុងរងគ្រោះដោយការរំលោភបំពានកម្លាំងពលកម្មនៅលើទូកនេសាទរបស់ថៃទាំងនោះ។

ពលករចំណាកស្រុកខ្មែរជាច្រើននាក់ដែលបានធ្វើការនៅលើទូកនេសាទថៃ អះអាងថា ពួកគាត់រងការជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ព្រមទាំងការរំលោភសិទ្ធិធ្ងន់ធ្ងរដទៃទៀតជាច្រើនពីសំណាក់មេការទូកនេសាទ ថៅកែទូក និងអាជ្ញាធរថៃ។ ភាពរងគ្រោះទាំងនោះ មានដូចជា ការប្រើអំពើហិង្សា ការហាមឃាត់មិនឱ្យប្តូរកន្លែងធ្វើការ ការបើកប្រាក់ខែមិនទៀងទាត់ ប្រាក់ខែទាបជាងប្រាក់ឈ្នួលអប្បបរមា ការមិនទទួលបានការការពារពីច្បាប់របស់ប្រទេសថៃ និងគ្មានសិទ្ធិបង្កើតសហជីពការងារជាដើម។ ការរៀបរាប់ពីទុក្ខលំបាករបស់ពលករខ្មែរទាំងនេះ ធ្វើឡើងតាមរយៈរបាយការណ៍កម្រាស់ជាង ១ រយទំព័រ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ មានចំណងជើងថា "ការកេងប្រវ័ញ្ចកម្លាំងពលកម្មដោយអាថ៌កំបាំង" ដែលនិយាយអំពីការរំលោភសិទ្ធិ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មនេសាទរបស់ប្រទេសថៃ។

របាយការណ៍នេះ ធ្វើឡើងផ្អែកលើបទសម្ភាសន៍ និងការស្រាវជ្រាវដែលបង្កើតឡើងតាំងពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ដោយមានការប្រឹក្សាយោបល់ត្រឹមត្រូវពីក្រុមអ្នកជំនាញ។ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) បានជួបសម្ភាសដោយផ្ទាល់ជាមួយកម្មករ និងអតីតកម្មករទូកនេសាទចំនួន ២៤៨នាក់ ដែលភាគច្រើនគឺជាពលរដ្ឋខ្មែរ និងភូមា។ យូមែន រ៉ៃត៍ វ៉ច្ឆ រកឃើញថា ការធ្វើការនៅលើទូកនេសាទថៃ គឺជាការងារដ៏គ្រោះថ្នាក់ ព្រោះមិនមានប្រព័ន្ធការពារសុខភាព និងសុវត្ថិភាព ហើយអ្នកនេសាទត្រូវធ្វើការជាមួយគ្រឿងម៉ាស៊ីន បណ្តាញអគ្គិសនី និងបំពង់ផ្សែងក្តៅខ្លាំង ដែលងាយប្រឈមនឹងគ្រោះថ្នាក់។ ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជំនួយកម្លាំង និងអំហេ្វតាមីនច្រើនលើសកម្រិតបានក្លាយជារឿងធម្មតាទៅហើយនៅលើទូកនេសាទថៃ។ យូមែន រ៉ៃត៍ វ៉ច្ឆ រកឃើញទៀតថា កង្វះខាតការបណ្តុះបណ្តា

ល ទូកនេសាទដែលមិនបានថែទាំត្រឹមត្រូវ ឧបសគ្គខាងភាសា និងកង្វះខាតបរិក្ខារដែលមានសុវត្ថិភាព ធ្វើឱ្យអ្នកនេសាទទាំងអស់ត្រូវប្រឈមនឹងហានិភ័យនៃគ្រោះថ្នាក់ ការរងរបួស និងការស្លាប់។

ម្យ៉ាងវិញទៀត ទូកនេសាទភាគច្រើនខ្វះបន្ទប់ទឹក ហើយប្រឈមនឹងអាកាសធាតុមិនល្អនៅលើសមុទ្រផង ធ្វើឱ្យអ្នកនេសាទភាគច្រើនកើតជំងឺផ្សេងៗ ដូចជា រាគរូស គ្រុនក្តៅ ពុលរលក ខ្សោយបេះដូង និងជំងឺប្លែកៗជាច្រើនមុខទៀត ហើយក្នុងករណីកម្មករទូកណាដែលឈឺញឹកញាប់ ថៅកែនឹងកាត់ប្រាក់ខែរបស់គេទៀតផង។ ការផ្លាស់ប្តូរគ្នានៅលើសមុទ្ររវាងទូកនេសាទនឹងទូកនេសាទ ក៏ជាបញ្ហាប្រឈមសំខាន់មួយដែរ។ វាធ្វើឱ្យទូកនេសាទនោះស្ថិតនៅលើសមុទ្ររយៈពេលជាច្រើនខែ ឬដល់ឆ្នាំផងក៏មាន និងបណ្តាលឱ្យមានការជួញដូរកម្លាំងពលកម្មបន្តទៀត។

អ្នកនេសាទខ្មែរម្នាក់មកពីខេត្តស្វាយរៀង គឺលោក អ៊ំ ចាន់ ថ្លែងថា គាត់ត្រូវបានគេជួញដូរក្នុងរយៈចម្ងាយជាង ៧ពាន់គីឡូម៉ែត្រ តាមកប៉ាល់ដឹកគ្រឿងសមុទ្រមួយ ពីខេត្តសាមុទ្រសាខន ប្រទេសថៃ ទៅដល់តំបន់ដាច់ស្រយាលមួយនៃឆ្នេរអាហ្វ្រិកខាងលិច ជាកន្លែងដែលគាត់បានចំណាយពេល ១៣ខែ ធ្វើការនៅទីនោះ មុនពេលជួយសង្គ្រោះដោយក្រុមអាជ្ញាធរល្បាតសមុទ្ររបស់ថៃ។ ចំណែកនៅឯដីគោកវិញ អ្នកនេសាទទាំងនោះក៏មិនមានសេរីភាពដើរហើរផងដែរ។ ពួកគាត់ត្រូវរងនូវការគំរាមកំហែងទាំងខាងរូបកាយ និងផ្លូវចិត្តពីសំណាក់មេខ្យល់ មេការទូក ថៅកែ និងអាជ្ញាធរថៃ។ ហើយពេលខ្លះត្រូវបានឃុំឃាំងនៅទីតាំងរបស់ក្រុមហ៊ុនមិនឱ្យចេញទៅណាទៀតផង។

ឧទាហរណ៍អ្នកនេសាទខ្មែរម្នាក់មកពីខេត្តកំពង់ស្ពឺ ឈ្មោះ ផុន សុភ័ក្រ្ត ត្រូវបានគេជួញដូរយកទៅធ្វើការលើទូកនេសាទក្នុងតំបន់ដាច់ស្រយាលមួយនៃមហាសមុទ្រឥណ្ឌា។ សុភ័ក្រ្ត និងជនរងគ្រោះដោយការជួញដូរចំនួន ២៨ នាក់ផ្សេងទៀត ត្រូវបានថៅកែឃុំឃាំងនៅក្នុងទីតាំងរបស់ក្រុមហ៊ុន ដើម្បីកុំឱ្យពួកគាត់លួចរត់។ ពួកគាត់ត្រូវបានលក់ក្នុងតម្លៃ ៣ម៉ឺនបាត ឬប្រហែល ៩រយដុល្លារអាមេរិក ដើម្បីនាំយកទៅធ្វើការលើទូកនេសាទ។

អ្នកនេសាទខ្មែរ និងភូមា ដែលធ្វើការលើទូកនេសាទថៃ បានអះអាងប្រាប់ យូមែន រ៉ៃត៍ វ៉ច្ឆ ថា ពួកគាត់ទទួលរងនូវការប្រើអំពើហិង្សា ការវាយដំ និងគំរាមកំហែងគ្រប់បែបយ៉ាងពីសំណាក់មេការទូកនេសាទ និងកម្មករទូកដូចគ្នាដែលធ្វើការយូរឆ្នាំជាង ប្រសិនបើពួកគាត់ធ្វើការមិនលឿនដូចការចង់បានរបស់ពួកគេទេនោះ។ ពេលខ្លះទៀតពួកគាត់ត្រូវគេវាយដំដោយសារតែមិនយល់ពីបញ្ជារបស់មេការព្រោះតែនិយាយភាសាខុសគ្នា។ ពួកគាត់បន្តថា ក្រៅពីដាល់និងទាត់ធាក់ មេការ និងកម្មករទូកជើងចាស់ បានប្រើប្រាស់ថ្មសំលៀងកាំបិត ដែកតាន់ ខ្សែតី ខ្សែព្រួរ និងគល់ឈើវាយទៅលើពួកគាត់ផងដែរ ហើយលើសពីនេះ គឺការចាប់ច្រមុជទឹក និងយកជើងជាន់ក្បាលរបស់ពួកគាត់ថែមទៀត។ កាន់តែសាហាវជាងនេះ គឺពួកមេការ ឬថៅកែនឹងសម្លាប់អ្នកណាដែលហ៊ានរត់គេចហើយត្រូវពួកគេចាប់ខ្លួនបានមកវិញ ឬក៏អ្នកដែលធ្វើឱ្យខូចខាតឧបករណ៍នេសាទ។ ការប្រើអំពើហិង្សា ការគំរាមកំហែង និងការធ្វើបាបនេះ ត្រូវបានប្រើប្រាស់ដើម្បីបង្ខំកម្មករឱ្យស្តាប់តាមបញ្ជា និងដើម្បីកុំឱ្យពួកគាត់រត់គេចខ្លួន។

អតីតអ្នកនេសាទខ្មែរម្នាក់ គឺលោក ហាក់ ណាំ បានអះអាងប្រាប់យូមែន រ៉ៃត៍ វ៉ច្ឆ ថា លោកត្រូវបានមេខ្យល់បោកប្រាស់ថា នាំយកទៅឱ្យធ្វើការនៅរោងចក្រត្រីខកំប៉ុង ក៏ប៉ុន្តែពេលទៅដល់ គេក៏នាំពួកលោកចុះទូកនេសាទទៅវិញ។ លោកថ្លែងបន្តជាភាសាថៃថា គ្រប់គ្នាមានការភ្ញាក់ផ្អើល និងភ័យខ្លាច ដោយសារដឹងថា ចាញ់បោកមេខ្យល់ ហើយម្យ៉ាងមិនធ្លាប់ធ្វើការលើទូកពីមុនមកផង។ បន្ទាប់ពីបានក្លាយជាកម្មករទូកនេសាទ លោក ហាក់ ណាំ បានបាត់ដំណឹងសូន្យឈឹងរហូតដល់គ្រួសាររបស់លោកគិតថា លោកបានស្លាប់ទៅហើយ៖ «មេខ្យល់បានប្រាប់ពួកយើងថាពួកយើងនឹងត្រូវទៅធ្វើការនៅរោងចក្រត្រីខកំប៉ុង ប៉ុន្តែពេលពួកយើងមកដល់ផ្ទះរបស់ម្ចាស់ទូក ពួកគេក៏នាំយកទៅចុះទូកតែម្តង។ មានគ្នាយើងខ្លះមិនធ្លាប់បានឡើងទូកផងពីមុនមក។ ពួកយើងមានអារម្មណ៍ភ័យខ្លាច។ ម្ចាស់ទូកបានទាត់ពួកយើង និងបង្ខំឱ្យចុះទូក។ ពេលដែលខ្ញុំមកដល់ផ្ទះ គ្រប់គ្នាក៏យំ ទាំងឪពុកម្តាយ និងយាយតារបស់ខ្ញុំសុទ្ធតែយំទាំងអស់គ្នា។ សាច់ញាតិរបស់ខ្ញុំសុទ្ធតែយល់ថា ខ្ញុំបានស្លាប់បាត់ទៅហើយ ព្រោះខ្ញុំបានបាត់ខ្លួនជាយូរឆ្នាំណាស់មកហើយ»។

ការស្ទង់មតិបង្ហាញថា ២០ភាគរយនៃកម្មករ និងប្រហែល ៥០ភាគរយនៃជនរងគ្រោះដោយការជួញដូរក្នុងវិស័យនេសាទរបស់ថៃ ទទួលរងគ្រោះថ្នាក់ការងារ ក៏ប៉ុន្តែពួកគេមិនទទួលបានសំណងអ្វីឡើយ។ កម្មករទូកនេសាទអះអាងថា កត្តាសំខាន់ដែលនាំឱ្យពួកគាត់ធ្លាក់ចូលក្នុងឧស្សាហកម្មនេសាទរបស់ថៃនេះ គឺតាមរយៈការឱ្យយោបល់ពីមិត្តភ័ក្តិ សាច់ញាតិ ឬមួយក៏អ្នកស្គាល់គ្នានៅក្នុងសហគមន៍របស់ពួកគាត់ នៅតំបន់ក្បែរព្រំដែន ឬក៏អំឡុងពេលពួកគាត់ធ្វើការក្នុងវិស័យដទៃទៅប្រទេសថៃ ដូចជា សំណង់ កសិកម្ម និងការផលិតជាដើម។ មូលហេតុនៃការសម្រេចចិត្តធ្វើចំណាកស្រុកទៅធ្វើការលើទូកនេសាទថៃនេះ គឺដោយសារតែភាពក្រីក្រ និងស្ថានភាពសេដ្ឋកិច្ចដ៏លំបាកលំបិននៅក្នុងសហគមន៍ ការទៅរស់នៅជុំសមាជិកគ្រួសារដែលកំពុងធ្វើការនៅប្រទេសថៃ និងជម្លោះជាមួយសមាជិកគ្រួសារក្នុងប្រទេសកំណើត។

បញ្ហាប្រឈមសំខាន់មួយទៀតរបស់ក្រុមកម្មករទូកនេសាទ គឺការរឹតត្បិតសិទ្ធិស្របច្បាប់ធ្វើការនៅក្នុងប្រទេសថៃ ព្រោះលិខិតឆ្លងដែនហាក់មិនសូវមានប្រយោជន៍ដូចប័ណ្ណពណ៌ផ្កាឈូកដែលចេញដោយអាជ្ញាធរថៃនោះឡើយ។ ពលករចំណាកស្រុកខ្មែរម្នាក់ឈ្មោះ កុសល ដែលធ្វើការលើទូកនេសាទថៃក្នុងខេត្តប៉ាត់តានី អះអាងថា ទោះបីជាមានលិខិតឆ្លងដែនក្តី ក៏ពួកគាត់បោះវាចោលដែរ ព្រោះវាមិនបានជួយអ្វីច្រើននោះទេ ដោយសារថៅកែទូកនឹងឱ្យប័ណ្ណពណ៌ផ្កាឈូកទៅពួកគាត់ជំនួសវិញ។ ប័ណ្ណពណ៌ផ្កាឈូកនោះទៀតសោត ក៏មិនផ្តល់សិទ្ធិការពារដល់កម្មករទូកនេសាទដូចកម្មករចំណាកស្រុកទូទៅនោះទេ ព្រោះវាបង្ហាញពីឈ្មោះថៅកែ និងខេត្តដែលពួកគេត្រូវចុះឈ្មោះធ្វើការ។ ប្រសិនបើចង់ធ្វើដំណើរទៅខេត្តដទៃ កម្មករទូកទាំងនោះត្រូវសុំការអនុញ្ញាតពីអាជ្ញាធរខេត្ត ឬពីថៅកែរបស់ពួកគាត់ ហើយការធ្វើដំណើរនោះ គឺកំណត់ត្រឹម រយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ។ កម្មករទូកដែលមានប័ណ្ណពណ៌ផ្កាឈូកនោះ អាចទទួលបាននូវយន្តការការពារសង្គមខ្លះៗ ក៏ប៉ុន្តែពួកគាត់មិនអាចទាមទារសំណងអ្វីបានឡើយចំពោះគ្រោះថ្នាក់ការងារ។

ការដាក់ពាក្យស្នើសុំប័ណ្ណពណ៌ផ្កាឈូកនោះ គឺចំណាយអស់ជិត ១រយដុល្លារអាមេរិក ហើយវាជាបន្ទុករបស់កម្មករខ្លួនឯង តាមរយៈការកាត់ប្រាក់ខែពីថៅកែទូករបស់ពួកគាត់។ កម្មករទាំងនោះអះអាងថា ពួកគាត់ត្រូវបង់ឱ្យថៅកែលើសពីការកំណត់របស់អាជ្ញាធរថៃចន្លោះពី ១៥ ទៅ ៣០ ដុល្លារអាមេរិក ដោយសារពួកគាត់មិនបានដឹងពីតម្លៃដែលមានកំណត់នៅក្នុងច្បាប់នោះទេ ព្រោះថៅកែមិនប្រាប់ពួកគាត់ឡើយ។ ថ្លៃប័ណ្ណពណ៌ផ្កាឈូកនេះ គឺជាផ្នែកមួយនៃការចំណាយសព្វគ្រប់របស់កម្មករទូកទៅមេខ្យល់ និងថៅកែទូក ដែលជាហេតុធ្វើឱ្យក្រុមកម្មករត្រូវជំពាក់បំណុលគេរណ្តែក។ ការចំណាយទាំងនោះរួមមាន ការធ្វើដំណើរ ម្ហូបអាហារ ការរត់ការឯកសារ ថ្លៃរដ្ឋបាល និងថ្លៃរើសបុគ្គលិក ហើយការចំណាយលើមុខការដាក់លាក់នីមួយៗនោះ ថៅកែទូកមិនប្រាប់ទៅក្រុមកម្មករនោះទេ។ ហើយបើពួកគាត់ហ៊ានប្តូរកន្លែងធ្វើការ ថៅកែនឹងមិនបើកលុយឱ្យឡើយ។

ម្យ៉ាងវិញទៀត ក្រុមកម្មករខ្មែរអះអាងថា មេការទូក ឬថៅកែ គឺជាអ្នកទុកដាក់ប័ណ្ណពណ៌ផ្កាឈូកនោះ ហើយដរាបណាពួកគាត់មានហេតុផលសមរម្យ ទើបមេការ ឬថៅកែទូក ឱ្យប័ណ្ណនោះមកពួកគាត់វិញ។ តែក៏មានមេការ ឬថៅកែទូកខ្លះមិនឱ្យប័ណ្ណផ្កាឈូកនោះមកពួកគាត់ដែរ ដោយលើកហេតុផលថា ទុកនៅនឹងពួកគេទើបមានសុវត្ថិភាពជាង ឬក៏ចាំដល់ពេលដែលកម្មករសងបំណុលពួកគេចប់សព្វគ្រប់។ នេះគឺជាល្បិចកលដែលពួកថៅកែទូកប្រើប្រាស់ដើម្បីចងកម្មករមិនឱ្យចេញទៅណារួចពីទូកនេសាទរបស់ពួកគេ។

មន្ត្រីថៃម្នាក់បានប្រាប់ យូមែន រ៉ៃត៍ វ៉ច្ឆ ថា មានហេតុផល ៥យ៉ាងដែលកម្មករអាចប្តូរថៅកែបាន គឺទីមួយ ថៅកែនោះស្លាប់ ទីពីរ ក្រុមហ៊ុននោះបិទទ្វារ ទីបី ថៅកែលែងចង់ជួលកម្មករ ទីបួនថៅកែគ្មានលុយបើកឱ្យកម្មករ ឬទីប្រាំ កម្មករខ្លួនឯងរងការរំលោភបំពានខ្លាំងពេក។ ចំណែកឯរឿងកិច្ចសន្យាការងារវិញ ក្រុមកម្មករទូកនេសាទទាំងនោះក៏មិនដែលបានដឹងលឺអ្វីដែរ គឺថៅកែជាអ្នកទុកដាក់ទាំងអស់។

ក្រុមកម្មករខ្មែរអះអាងថា ពួកគាត់មិនបានឃើញកិច្ចសន្យាការងារដាក់លាក់រវាងពួកគាត់ និងថៅកែឡើយ ព្រោះថៅកែមិនឱ្យមើល ដូច្នេះពួកគាត់មិនបានដឹងទេថា ថៅកែបើកលុយឱ្យគ្រប់ចំនួនតាមកិច្ចសន្យាដែរឬអត់។ ហើយដោយសារតែមិនអាចតតាំងជាមួយថៅកែបាន ពួកគាត់ខ្លះសុខចិត្តទទួលយកប្រាក់ឈ្នួល ៦ ពាន់បាត ឬ ប្រហែល ១៨០ ដុល្លារអាមេរិក ក្នុងមួយខែ ដោយពួកគាត់ត្រូវធ្វើការដល់ទៅ ២៥ថ្ងៃ ហើយថ្ងៃខ្លះធ្វើការរហូតដល់ ១៩ ម៉ោងទើបបានឈប់សម្រាក។ មានអ្នកខ្លះទៀតទទួលបានត្រឹមតែ ៤ ពាន់ ៦ រយបាត ឬប្រហែល ១៤០ ដុល្លារអាមេរិកប៉ុណ្ណោះ ក្នុងមួយខែ ហើយប្រាក់ឈ្នួលនេះទៀតសោត ក៏មិនត្រូវបានថៅកែបើកឱ្យទៀងទាត់នោះដែរ គឺជាច្រើនខែទើបថៅកែបើកឱ្យម្តង និងអ្នកខ្លះមានដល់មួយឆ្នាំទើបបើកអោយ។ ដោយសារបញ្ហានេះ ធ្វើឱ្យពួកគាត់ត្រូវបង្ខំចិត្តខ្ចីលុយពីថៅកែដើម្បីយកមកទប់ទល់នឹងការចំណាយ និងផ្ញើទៅស្រុកខ្លះ ក្នុងអត្រាការប្រាក់ដ៏ខ្ពស់ គឺ ២០ ភាគរយក្នុងមួយខែ ដូច្នេះលុយដែលពួកគាត់ទទួលបានគឺមិនច្រើនប៉ុន្មាននោះទេ បន្ទាប់ពីកាត់កងការចំណាយ និងបំណុលរបស់ថៅកែរួច។

ឆ្លើយតបទៅនឹងរបាយការណ៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ នេះ ប្រធានសមាគមនេសាទជាតិរបស់ប្រទេសថៃ លោក មង្គល ស៊ុកចារើនខាណា (Mongkol Sukcharoenkana) បានបដិសេធថា មិនមានការកេងប្រវ័ញ្ចកម្លាំងពលកម្មដូចពីមុនទៀតឡើយ ត្បិតរដ្ឋាភិបាលបានធ្វើកំណែទម្រង់រឿងនេះរួចរាល់ហើយ៖ «កាលពីមុន យើងប្រើកម្លាំងពលកម្មខុសច្បាប់។ ដោយសារកម្លាំងពលកម្មច្រើន ដូច្នេះឱកាសនៃការជួញដូរកម្មករក៏មានច្រើនដែរ ប៉ុន្តែបច្ចុប្បន្ន រឿងនេះត្រូវបានផ្លាស់ប្តូរអស់ហើយ។ គ្មានការជួញដូរកម្លាំងពលកម្មដូចកាលពីមុនទៀតទេ។ អតិថិជននៅអាមេរិក និងអឺរ៉ុបអាចទទួលទានគ្រឿងសមុទ្ររបស់យើងបានហើយ ត្បិតអ្វីគ្រប់យ៉ាងសុទ្ធតែល្អអស់ហើយ។ រដ្ឋាភិបាលសព្វថ្ងៃបានដោះស្រាយបញ្ហាទាំងអស់នេះរួចរាល់ហើយ។ ទាំងទូកនេសាទ និងកម្មករទាំងអស់សុទ្ធតែត្រឹមត្រូវទៅតាមច្បាប់អស់ហើយ មិនមានការកេងប្រវ័ញ្ចកម្លាំងពលកម្មទៀតនោះទេ»។

ទោះបីជាយ៉ាងណា បន្ទាប់ពីចុះទៅស៊ើបអង្កេតគ្រប់កំពង់ផែក្នុងប្រទេសថៃ និងជួបសម្ភាសផ្ទាល់ជាមួយអ្នកនេសាទរាប់រយនាក់រួចមក អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ រកឃើញថា កំណែទម្រង់របស់រដ្ឋាភិបាលយោធាថៃទាក់ទងនឹងរឿងជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្មលើទូកនេសាទនេះ គឺមិនបានផលអ្វីនោះទេ។ អ្នកស្រាវជ្រាវជាន់ខ្ពស់នៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ ទទួលបន្ទុកកិច្ចការតំបន់អាស៊ី លោក ស៊ូណៃ ផាស៊ុក (Sunai Phasuk) ថ្លែងថា រដ្ឋាភិបាលថៃ កាលពីឆ្នាំ២០១៤ បានឆ្លើយតបនឹងសម្ពាធអន្តរជាតិតាមរយៈការប្រកាសអំពីកំណែទម្រង់ដ៏ធំក្នុងវិស័យនេសាទ ដែលមានដូចជា ដាក់ចេញនូវច្បាប់ បទបញ្ញត្តិ និងគោលការណ៍ជាច្រើន ដើម្បីរកឱ្យឃើញពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានផ្សេងទៀត ក៏ប៉ុន្តែចំណាត់ការទាំងអស់នោះ គ្មានប្រសិទ្ធភាពអ្វីឡើយ៖ «ឥលូវនេះថៅកែទូកនេសាទ និងសមាគមគ្រឿងសមុទ្រកំពុងតែស្រែកក្តែងៗថា ការរំលោភបំពានសិទ្ធិនានាត្រូវបានលុបបំបាត់អស់ហើយ។ ពួកគេក៏កំពុងព្យាយាមបញ្ចុះបញ្ចូលរដ្ឋាភិបាលបរទេស និងហាងលក់គ្រឿងសមុទ្រអន្តរជាតិថា កំណែទម្រង់នេះ គឺមានប្រសិទ្ធភាព។ ក៏ប៉ុន្តែ ពេលនិយាយដល់រឿងធ្វើឱ្យជីវិតរបស់អ្នកនេសាទប្រសើរឡើងនោះ បទបញ្ញត្តិថ្មីរបស់រដ្ឋាភិបាលគឺគ្មានប្រសិទ្ធភាពអ្វីជាដុំកំភួនឡើយ ហើយបញ្ហាចាស់ៗជាច្រើននៅតែកើតមានដដែល។ បញ្ហាដែលមិនទាន់ត្រូវបានដោះស្រាយនោះ គឺអ្នកនេសាទជាច្រើននៅតែធ្វើការច្រើនម៉ោងដោយទទួលបានកម្រៃតិច ប្រឈមនឹងការរំលោភបំពានគ្រប់បែបយ៉ាងពីម្ចាស់ទូក និងគ្មានផ្លូវគេចចេញពីស្ថានភាពដ៏លំបាករបស់ពួកគាត់ឡើយ»។

ធនាគារពិភពលោករាយការណ៍ថា ប្រទេសថៃមានចំនួនកម្មករចំណាកស្រុកខ្ពស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជិត ៤ លាននាក់ (៣.៧៦) នៅក្នុងឆ្នាំ២០១៥ ក្នុងនោះ ៥៣ ភាគរយមកពីប្រទេសភូមា ២៦ ភាគរយមកពីប្រទេសឡាវ និង ២១ ភាគរយមកពីកម្ពុជា។ ចំណែកទិន្នន័យរបស់រដ្ឋាភិបាលថៃវិញ បង្ហាញថា កម្មករចំណាកស្រុក

កម្ពុជា ឡាវ និងភូមា ដែលបានចុះឈ្មោះរួចរាល់គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០១៧ មានចំនួនជិត ២លាននាក់ (១,៧២៦,៤១៥) ក្នុងនោះជិត ៥ម៉ឺននាក់ ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ។

ដោយសារមានពលរដ្ឋកម្ពុជាជាច្រើននាក់បានធ្លាក់ខ្លួនចូលក្នុងអំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្មនៅលើទូកនេសាទថៃបែបនេះ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែន រ៉ៃត៍ វ៉ច្ឆ អំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យគិតគូរ និងចាត់វិធានការដាក់លាក់នានា ដើម្បីការពារ និងជួយសង្គ្រោះពលរដ្ឋរបស់ខ្លួន។ អនុសាសន៍របស់ឃ្យូមែនរ៉ៃត៍ វ៉ច្ឆ សម្រាប់រដ្ឋាភិបាលកម្ពុជា មាន ៦ចំណុច។

ទីមួយ គឺស៊ើបអង្កេត និងដាក់ទោសតាមផ្លូវច្បាប់ចំពោះជនណាដែលទទួលខុសត្រូវ និងចូលរួមក្នុងបណ្ដាញជួញដូរមនុស្សនៅក្នុងប្រទេសដែលសហការជាមួយឈ្មួញកណ្ដាលនៅក្នុងប្រទេសថៃប្រើប្រាស់មធ្យោបាយទុច្ចរិតដើម្បីផ្គត់ផ្គង់បុរស និងក្មេងប្រុសទៅកាន់ទូកនេសាទថៃ។

ទីពីរ គឺជួយអាជ្ញាធរថៃក្នុងការកាត់ទោសអ្នកជួញដូរមនុស្ស ជួយបង្កបរិយាកាសធ្វើចំណាកស្រុកដោយសុវត្ថិភាព និងរិះរកយុទ្ធសាស្ត្រផ្សេងទៀតដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះពលករចំណាកស្រុកគ្រប់ប្រភេទ។

ទីបី គឺដាក់ចេញនូវបទបញ្ញត្តិនានា ដើម្បីកាត់បន្ថយថ្លៃឈ្នួលរើសបុគ្គលិកខ្ពស់កប់ពពក ដែលក្រុមហ៊ុននាំពលករចេញទៅប្រទេសថៃទាមទារពីក្រុមពលករ តាមរយៈមធ្យោបាយនៃការចុះអនុស្សរណៈយោគយល់គ្នា។ រដ្ឋាភិបាលក៏ត្រូវចាត់វិធានការឱ្យបានតឹងរ៉ឹងប្រឆាំងនឹងក្រុមហ៊ុននាំពលករចេញ តាមរយៈការលុបឈ្មោះក្រុមហ៊ុន និងការដាក់ទោសទណ្ឌចំពោះប្រធានក្រុមហ៊ុន ពេលពួកគេហ៊ានយកថ្លៃឈ្នួលបន្ថែម ដែលធ្វើឱ្យក្រុមពលករជំពាក់បំណុលគេវ័ណ្ឌកនៅក្នុងប្រទេសថៃ។

ទីបួន គឺណែនាំឱ្យស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក ឱ្យបង្កើតប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ឬ Hotlines ដើម្បីផ្ដល់ជំនួយ និងគាំទ្រផ្សេងៗដល់ពលករខ្មែរដែលទទួលរងការជួញដូរ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានសិទ្ធិពលកម្មដទៃទៀត។

អនុសាសន៍ចុងក្រោយរបស់ ឃ្យូមែន រ៉ៃត៍ វ៉ច្ឆ គឺរដ្ឋាភិបាលកម្ពុជាត្រូវជំរុញឱ្យរដ្ឋាភិបាលថៃចាត់វិធានការចំពោះការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើទូកនេសាទថៃ ព្រមទាំងដាក់ទោសទណ្ឌដល់ម្ចាស់ទូក និងមន្ត្រីពុករលួយណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋទៅលើកម្មករទូកនេសាទ៕

## ថៃច្រានចោលការរិះគន់ថាប្រទេសថៃបរាជ័យក្នុងការលុបបំបាត់អំពើជួញដូរមនុស្សនិងកម្លាំងពលកម្ម

https://www.rfa.org/khmer/news/ ដោយ មាន ឫទ្ធិ 2018-01-24

អាជ្ញាធរថៃ កាលពីថ្ងៃពុធ ទី២៤ ខែមករា បានច្រានចោលការរិះគន់ពីសំណាក់ក្រុមឃ្លាំមើលសិទ្ធិមនុស្សដែលចោទថា ប្រទេសថៃបរាជ័យក្នុងការលុបបំបាត់ចោលអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចកម្លាំងពលកម្មនៅលើទូកនេសាទថៃ។ ការច្រានចោលនេះ ធ្វើឡើងក្រោយពេលដែលក្រុមអង្គការឃ្លាំមើលសិទ្ធិមនុស្សរកឃើញថា ឧស្សាហកម្មនេសាទរបស់ប្រទេសថៃ គឺជាសំបុកនៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចកម្លាំងពលកម្មខុសច្បាប់។ អាជ្ញាធរថៃបានអះអាងមូលហេតុដែលអាជ្ញាធរមិនអាចទទួលយករបាយការណ៍អង្គការសិទ្ធិមនុស្សបាន ដោយសារតែអាជ្ញាធរនេះអះអាងថា ជោគជ័យនៃការបង្ក្រាបលើអំពើជួញដូរមនុស្ស បានបណ្ដាលឲ្យមានការកាត់ទោសជនសង្ស័យជាង ១០០នាក់ និងជួយសង្គ្រោះជនរងគ្រោះ ១៦០នាក់ ចាប់តាំងពីខែឧសភា ឆ្នាំ២០១៥ ក្រោយពេលដែលសហភាពអឺរ៉ុប បានចេញ «កាតលឿង» ដែលជាការព្រមានដល់ប្រទេសថៃ។

អាជ្ញាធរថៃ អះអាងបន្តថា បានដកហូតអាជ្ញាប័ណ្ណពីទូកនេសាទចំនួនជាង ៤.២០០អាជ្ញាប័ណ្ណ ដោយសារតែម្ចាស់ទូកទាំងនេះបានប្រព្រឹត្តិល្មើសច្បាប់ រួមមានដូចជា នេសាទក្នុងដែនទឹកខុសច្បាប់ និងខកខានមិនបានដំឡើង

ឧបករណ៍ប្រព័ន្ធតាមដាន GPS ជាដើម។ មេបញ្ជាការថៃ ទទួលបន្ទុកនាយកដ្ឋានពង្រឹងការអនុវត្តច្បាប់ លោក ចារុវ៉ាត វៃស្សាយ៉ា (Jaruvat Vaisaya) ត្រូវបានទីភ្នាក់ងារសារព័ត៌មានបារាំង អា.អេហ្វ.ប៉េ (AFP) ស្រង់ប្រសាសន៍ថា ក្រោយពេលដែលប្រទេសថៃ ទទួលបានកាតលឿងពីសហភាពអឺរ៉ុប ដែលជាការព្រមានថា ប្រទេសនេះអាចប្រឈមនឹងការបិទមិនឲ្យនាំចេញផលិតផលអាហារសមុទ្រទៅដាក់លក់នៅសហភាពអឺរ៉ុប អាជ្ញាធរថៃ បានចុះអនុវត្តយ៉ាងតឹងតែង និងធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីឧស្សាហកម្មនេសាទរបស់ខ្លួន។

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) នៅដើមសប្តាហ៍នេះ បានបញ្ចេញរបាយការណ៍បង្ហាញលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនអស់រយៈពេលពីរឆ្នាំ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ កម្រាស់ជាង ១០០ទំព័រស្តីពី «ការកេងប្រវ័ញ្ចកម្លាំងពលកម្មដោយអាថ៌កំបាំង» ដែលលាតត្រដាងអំពីការរំលោភបំពានសិទ្ធិមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មនេសាទរបស់ប្រទេសថៃ។ របាយការណ៍លើកឡើងថា ឧស្សាហកម្មនេសាទដែលផ្តល់ផលកម្រៃយ៉ាងច្រើនក្រាស់ក្រែលនេះ គឺជាសំបុកនៃអំពើរំលោភបំពាន រួមមានការប្រព្រឹត្តអំពើនេសាទខុសច្បាប់យ៉ាងរីករាលដាល និងការពឹងផ្អែកលើកម្មករដែលត្រូវបានជួញដូរកម្លាំងពលកម្មមកពីប្រទេសជិតខាងរួមមាន ប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងប្រទេសឡាវ ជាដើម។

របាយការណ៍ដដែលនេះ រកឃើញថា ពលករចំណាកស្រុកមកពីតាមបណ្តាប្រទេសទាំងនេះ ត្រូវបានថៅកែទូកនេសាទរបស់ថៃ រំលោភបំពានសិទ្ធិយ៉ាងធ្ងន់ធ្ងរ ដោយមិនបើកប្រាក់ខែឲ្យបានទៀងទាត់ ផ្តល់ប្រាក់ខែទាបជាងប្រាក់ឈ្នួលអប្បបរមា ការមិនអាចបង្កើតសហជីព និងភាពខ្វះកិច្ចការពារដោយប្រព័ន្ធច្បាប់របស់ថៃ ជាដើម។ របាយការណ៍ដដែលនេះ គូសបញ្ជាក់ថា ការធ្វើការនៅលើទូកនេសាទថៃ គឺជាការងារដ៏គ្រោះថ្នាក់ ព្រោះមិនមានប្រព័ន្ធការពារសុខភាព និងសុវត្ថិភាព ហើយអ្នកនេសាទត្រូវធ្វើការជាមួយគ្រឿងម៉ាស៊ីន បណ្តាញអគ្គិសនី និងបំពង់ផ្សែងក្តៅខ្លាំង ដែលងាយប្រឈមនឹងគ្រោះថ្នាក់។ ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជំនួយកម្លាំង និងអំហ្វេតាមីន ច្រើនលើសកម្រិត បានក្លាយជារឿងធម្មតាទៅហើយនៅលើទូកនេសាទថៃ។

ប្រទេសថៃ គឺជាប្រទេសនាំចេញទី៤ ធំបំផុតនៃផលិតផលអាហារសមុទ្រតាមរយៈការផ្គត់ផ្គង់ទីផ្សារទៅកាន់សហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងប្រទេសជប៉ុន។ សហភាពអឺរ៉ុប នឹងធ្វើបច្ចុប្បន្នភាពការវាយតម្លៃរបស់ខ្លួនអំពីស្ថានភាពឧស្សាហកម្មនេសាទនៅប្រទេសថៃ នាខែមេសា ខាងមុខនេះ។ នាយកប្រតិបត្តិទទួលបន្ទុកកិច្ចការតំបន់អាស៊ីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ លោក ប្រ៊ែដ អាដាម (Brad Adams) ជំរុញសហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងក្រុមអ្នកបញ្ជាទិញអន្តរជាតិ ឲ្យដាក់សម្ពាធជាបន្ទាន់មកលើប្រទេសថៃ ដើម្បីការពារសិទ្ធិសុខភាព និងសុវត្ថិភាពរបស់កម្មករនេសាទទាំងនេះ៕

## លោក អ៊ិត សំហេង កោតសរសើរចំពោះថៅកែក្រុមហ៊ុនថៃ ដែលបានយកចិត្តទុកដាក់ចំពោះពលករកម្ពុជា

http://www.freshnewsasia.com/ 2018-01-24

**(ថៃ)៖** ក្នុងជំនួបជាមួយតំណាងក្រុមហ៊ុនថៃឈ្មោះ Sun Food International Co.,Ltd នៅខេត្តសារ៉ាក់បុរី ប្រទេសថៃ នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨នេះ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកោតសរសើរចំពោះថៅកែក្រុមហ៊ុនថៃ ដែលបានយកចិត្តទុកដាក់ចំពោះពលករកម្ពុជា ដោយភាពល្អប្រសើរនេះ មានការប្រែប្រួលគួរឲ្យកត់សម្គាល់ ក្រោយពីរាជរដ្ឋាភិបាលកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយភាគីថៃ កាលពីឆ្នាំ២០១៣ និងឆ្នាំ២០១៥។

ភាគីក្រុមហ៊ុនថៃបានលើកឡើងថា ៥ឆ្នាំមុន ក្រុមហ៊ុនទទួលពលករបរទេសឲ្យធ្វើការចំនួន ២០០នាក់ សម្រាប់បច្ចុប្បន្នក្រុមហ៊ុនមានពលករបរទេសជាង ១,៩០០នាក់ ក្នុងនោះមានពលករថៃ ឡាវ និងកម្ពុជា ក្នុងចំណោម

នោះពលករកម្ពុជាមានចំនួនច្រើនជាងគេ ១,៧៣០នាក់។ លក្ខខណ្ឌដែលក្រុមហ៊ុនទទួលពលករកម្ពុជាឲ្យចូលធ្វើការច្រើនជាងគេ ដោយសារពលករកម្ពុជាមានលក្ខណសម្បត្តិល្អ រួសរាយរាក់ទាក់ ស្មោះត្រង់ ហើយពួកគេបានបង្រៀនភាសាខ្មែរដល់ខាងក្រុមហ៊ុនផងដែរ។ ជាការវាយតម្លៃ ក្រុមហ៊ុនពិតជាមានការពេញចិត្តចំពោះឥរិយាបថរបស់ពលករកម្ពុជា ដែលបានចូលរួមយ៉ាងសស្រាក់សស្រាំ ក្នុងការជំរុញចង្វាក់ផលិតកម្មរបស់ក្រុមហ៊ុនឲ្យមានភាពរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

លោករដ្ឋមន្ត្រីបានថ្លែងថា ជំនួបជាមួយក្រុមហ៊ុនថៃនេះ បានទាក់ទងទាំងអ្នកវិនិយោគជាច្រើនឲ្យមកបណ្តាក់ទុនវិនិយោគយ៉ាងច្រើន នៅក្នុងខេត្តមួយនេះ ក្នុងនោះលោកបានថ្លែងអំណរគុណចំពោះក្រុមហ៊ុនដែលបានរៀបចំ និងអនុញ្ញាតឲ្យពលករកម្ពុជាចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងលោកផងដែរ។ បន្ទាប់ពីការបានឃើញពីការធ្វើបទបង្ហាញរបស់ក្រុមហ៊ុន លោកបានកោតសរសើរចំពោះក្រុមហ៊ុនដែលបានរៀបចំលក្ខខណ្ឌការងារល្អប្រសើរ មានបទដ្ឋានខ្ពស់ មានកន្លែងអនាម័យប្រកបដោយស្តង់ដារ ដែលនេះជាការយកចិត្តទុកដាក់ ចំពោះពលកម្មបរទេសដែលកំពុងបម្រើការងារនៅក្នុងក្រុមហ៊ុន។ ជាងនេះទៀត ការយកចិត្តទុកដាក់ ពីសំណាក់ក្រុមហ៊ុនថៃចំពោះពលករកម្ពុជានេះ គឺក្រោយពីរាជរដ្ឋាភិបាលប្រទេសទាំងពីរកម្ពុជា-ថៃ បានចុះអនុស្សរណៈនៃការយោគយល់គ្នា ក្នុងឆ្នាំ២០១៣ និងចុះអនុស្សរណៈជាថ្មីម្តងទៀត ក្នុងឆ្នាំ២០១៥។

សូមបញ្ជាក់ថា កម្ពុជាជាប្រទេសទី២ ដែលមានពលករកំពុងធ្វើការនៅប្រទេសថៃចំនួន ១លាន៥ម៉ឺននាក់ បន្ទាប់ពីភូមា បន្ថែមពីនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងសហការជាមួយប្រទេសថៃ ដើម្បីផ្តល់ឯកសារស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃផងដែរ៕

## ឆ្នាំ២០១៧ មានពលរដ្ឋខ្មែរ និងបរទេស ឆ្លងកាត់ព្រំដែនកម្ពុជាទៅថៃ តាមខេត្តបាត់ដំបង ជិត៦លាននាក់

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២៥ មករា ២០១៨ 09:35 ដោយ: រិទ្ធិ ជ័យ ID:039

បាត់ដំបង៖ ក្នុងឆ្នាំ២០១៧កន្លងទៅនេះ ប្រជាពលរដ្ឋខ្មែរ និងជនជាតិបរទេសបានធ្វើដំណើរឆ្លងកាត់ព្រំដែនប្រទេសកម្ពុជាចូលទៅកាន់ប្រទេសថៃ ក្នុងគោលបំណងរកការងារធ្វើ និងដំណើរកម្សាន្តតាមខេត្តបាត់ដំបង ដោយទៅតាមច្រកអន្តរជាតិដូង (ឡែម) ច្រកតំបន់ភ្នំព្រឹក សំពៅលូន និងសំឡូតជាដើម មានចំនួន ៥៨៩៣ ៨៨៩ដង/នាក់ ។ យោងតាមរបាយការណ៍ សាលាខេត្តបាត់ដំបង បានឲ្យដឹងថា ក្នុងចំណោមនេះមានពលរដ្ឋខ្មែរឆ្លងកាត់ចំនួន ៥៣៤៦ ៤៨២នាក់ និងបរទេសចំនួន ៥៤៧ ៤០៧នាក់ ។ ពលរដ្ឋដែលឆ្លងដែនចូលទឹកដីថៃតាមច្រករបៀងត្រូវសមត្ថកិច្ចបញ្ជូនមកវិញចំនួន ៤៨៥លើក ស្មើនឹង ៥១ ០៩៣នាក់, បានទទួលសពប្រជាពលរដ្ឋខ្មែរចំនួន ៤២លើក ស្មើនឹង ១៤៤នាក់ ដែលស្លាប់ដោយឧប្បទវហេតុផ្សេងៗ និងបានបញ្ជូនទៅដល់ ក្រុមគ្រួសារតាម ស្រុកកំណើតរៀងៗខ្លួន ។

យ៉ាងណាក៏ដោយ បើតាមការបញ្ជាក់ក្នុង របាយការណ៍ខាងលើ បានឲ្យដឹងថា ជារួមសន្តិសុខ សណ្តាប់ធ្នាប់ទូទាំងខេត្ត និងតាមតំបន់ព្រំដែន មានសភាពស្ងប់ស្ងាត់ល្អ ជាពិសេសបានធ្វើការសហការ អប់រំ ផ្សព្វផ្សាយ និងចាត់វិធានការណ៍បង្រ្កាប ទប់ស្កាត់ចលនាបដិវត្តន៍ពណ៌ ផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ បានទាន់ពេលវេលា ។ មួយវិញទៀត បទល្មើសឧក្រិដ្ឋ និងមជ្ឈិមមានការថយចុះ ដែលធានាបាននូវភាពរឹងមាំ និងស្ថិរភាពនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម ៕

## ពលករឡាវនិងភូមាចំនួន ០៤នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួនបន្ទាប់ពីធ្វើការដណ្តើមមុខរបររបស់ពលរដ្ឋថៃ

http://www.prakpheaktra.com January 24, 2018

កាលពីរាត្រីថ្ងៃអង្គារទី២៣ ខែមករា ឆ្នាំ២០១៨ កម្លាំងសមត្ថកិច្ចក្រសួងការងារថៃ សហការជាមួយកម្លាំងតម្រួតទីក្រុងបាងកក ប្រទេសថៃ ធ្វើយុទ្ធនាការចុះត្រួតពិនិត្យពលករចំណាកស្រុកខុសច្បាប់ ដែលកំពុងធ្វើការនៅក្នុង

តំបន់ទេសចរណ៍ ផ្លូវខាវសាន ស្ថិតនៅកណ្តាលទីក្រុងបាងកក ប្រទេសថៃ។ ក្នុងយុទ្ធនាការដ៏ក្តៅគគុកនេះកម្លាំងសមត្ថកិច្ចថៃបានធ្វើការឃាត់ខ្លួនបានពលករភូមា និងឡាវចំនួន០៨នាក់ ដែលកំពុងធ្វើការលក់ដូរខុសច្បាប់ និងធ្វើការខុសលក្ខខ័ណ្ឌនៃច្បាប់អនុញ្ញាតការងាររបស់ប្រទេសថៃ។ គួរបញ្ជាក់ផងដែរថានៅពេលថ្មីៗនេះអាជ្ញាធរថៃបានចាប់ផ្តើមរិតបន្តឹងច្បាប់ការងារលើពលករបរទេស ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ បន្ទាប់ពីមានពលករបរទេសមួយចំនួនបានមកប្រកបមុខរបរលក់ដូរ និងដណ្តើមអាជីពការងាររបស់ប្រជាពលរដ្ឋថៃ។ ចំពោះករណីពលករធ្វើការខុសលក្ខខ័ណ្ឌនៃច្បាប់អនុញ្ញាតការងារត្រូវមានទោសពិន័យជាប្រាក់ចាប់ពី២០០០បាត-ដល់១០០,០០០បាត។

## ពលរដ្ឋថៃជៀលខ្មែរដូចព្យុះរឿងពលករខ្មែរ ប៉ៃឆ្កែថៃស៊ី

http://www.prakpheaktra.com January 24, 2018

ពលរដ្ឋថៃអំពាវនាវអោយអាជ្ញាធរខេត្តសាក៉ាកុរី ប្រទេសថៃ តាមចាប់ខ្លួនពលករខ្មែរពីរនាក់ ក្នុងករណីបទល្មើសសម្លាប់សត្វឆ្កែយកទៅធ្វើម្ហូបអាហារ។ ករណីនេះបានកើតឡើងកាលពីថ្ងៃអង្គារទី២៣ ខែមករា ឆ្នាំ២០១៨ បន្ទាប់ពីមានប្រជាពលរដ្ឋថៃបានថតរូបភាពហេតុការណ៍ករណីពលករខ្មែរធ្វើការសំណង់ ចំនួន០២នាក់ កំពុងនាំគ្នាសម្លាប់សត្វឆ្កែមួយក្បាលយកទៅធ្វើម្ហូបអាហារ ដើម្បីបរិភោគ។ យោងតាមការបញ្ជាក់របស់ហ្វេសប៊ុក WatchGogThaiLand បានអោយដឹងថា ហេតុការណ៍ពលករខ្មែររួមគ្នាសម្លាប់សត្វឆ្កែយកទៅធ្វើម្ហូបអាហារបរិភោគនេះបានកើតឡើងនៅការដ្ឋានសំណង់មួយកន្លែងស្ថិតនៅក្នុងស្រុកក្លែងខយ ខេត្តសាក៉ាកុរី ប្រទេសថៃ ហើយបច្ចុប្បន្ននេះខាងមូលនិធិគាំពារសត្វ Gog បានអំពាវនាវអោយកម្លាំងអាជ្ញាធរតម្រួតខេត្តសាក៉ាក់ធ្វើការតាមស្រាវជ្រាវរកពលករខ្មែរនៅក្នុងរូបភាពទាំងពីរនាក់ដើម្បីយកទៅផ្តន្ទាទោសតាមច្បាប់។ បញ្ជាក់:សត្វឆ្កែត្រូវបានការពារដោយច្បាប់ការពារសត្វរបស់ប្រទេសថៃ ចំពោះបុគ្គលណាដែលសម្លាប់ឬធ្វើទារុណកម្មលើសត្វឆ្កែត្រូវមានទោសពិន័យជាប្រាក់និងដាក់ពន្ធនាគារតាមច្បាប់កំណត់។

## ពលករភូមាចំនួន ១៣នាក់ ទៀតហើយត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួន បន្ទាប់ពីរកស៊ីដឹកភ្ញៀវទេសចរណ៍នៅក្នុងប្រទេសថៃ

http://www.prakpheaktra.com January 24, 2018

កម្លាំងអាជ្ញាធរតម្រួតអន្តោប្រវេសន៍ថៃ ធ្វើការបង្ក្រាបពលករសញ្ជាតិភូមាចំនួន ១៣នាក់ បន្ទាប់ពីពលករទាំង១៣នាក់មកដណ្តើមមុខរបររកស៊ីដឹកភ្ញៀវទេសចរណ៍នៅក្នុងប្រទេសថៃ។ កាលពីថ្ងៃអង្គារទី២៣ ខែមករា ឆ្នាំ២០១៨ កម្លាំងអាជ្ញាធរតម្រួតអន្តោប្រវេសន៍ថៃសហការជាមួយកម្លាំងតម្រួតប្រចាំព្រំដែន ខេត្តតាក ប្រទេសថៃ បានបើកយុទ្ធនាការបង្ក្រាបពលករភូមាចំនួន១៣នាក់ បន្ទាប់ពីជនជាតិខាងលើបានមកប្រកបមុខរបរបើកបរម៉ូតូកង់បីដឹកភ្ញៀវទេសចរណ៍នៅត្រង់ចំណុចផ្សារឆាក់រើន ស្ថិតក្នុងសង្កាត់ម៉ែសត ស្រុកម៉ែសត ខេត្តតាក ប្រទេសថៃ ដោយខុសច្បាប់ពីច្បាប់អនុញ្ញាតធ្វើការរបស់ពលករបរទេស ដែលហាមឃាត់មិនឲ្យពលករបរទេសប្រកបមុខរបរឬធ្វើជំនួញនៅក្នុងប្រទេសថៃ ។ ក្រោយពេលឃាត់ខ្លួនពលករភូមាទាំងអស់ត្រូវបានកម្លាំងអាជ្ញាធរថៃបញ្ជូនខ្លួនទៅកាន់អធិការដ្ឋានតម្រួតខេត្តតាកដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## យ៉ាន មួន ខិចត្ត ខ្លួនពីពលករត្រូវគេបំពានទៅជាអ្នកជួយពលករ

http://www.postkhmer.com/ យន់ ស៊ីនាត and Andrew Nachemson Publication date 25 January 2018 10:55 ICT

**ភ្នំពេញ:** ដូចប្រជាពលរដ្ឋកម្ពុជាជាច្រើនដែរលោក យ៉ាន មួន បានធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ី ដើម្បីស្វែងរកការងារធ្វើរកប្រាក់ផ្គត់ផ្គង់គ្រួសារ ប៉ុន្តែផ្ទុយទៅវិញបានជួបការរំលោភបំពាន និងខ្វះកិច្ចអន្តរាគមន៍ជួយដោះស្រាយសម្រាប់ពលករចំណាកស្រុកប្រឆាំងនឹងនិយោជក «ព្រៃផ្សៃ» ដែលរំលោភបំពាន។

អង្គុយនៅលើឥដ្ឋពណ៌សក្នុងផ្ទះរបស់លោកនៅជាយរាជធានីភ្នំពេញលោក មួន បាននិយាយភាសាខ្មែរផង អង់គ្លេសទៅមុខថយក្រោយតាមដែលលោកបានចាំកាលពី ៤ ឆ្នាំមុនដែលបានធ្វើការនៅរោងចក្រអេឡិចត្រូនិកមួយក្នុងប្រទេសម៉ាឡេស៊ី។ លោក មួន ថ្លែងថា ប្រាក់ខែគោលរបស់លោកត្រូវបានរំពឹងថានឹងមានប្រហែល ២២៧ ដុល្លារ ប៉ុន្តែនិយោជករបស់លោកបានបើកប្រាក់ខែដល់លោកតែប្រហែល ១៥១ ដុល្លារប៉ុណ្ណោះ។ «ខ្ញុំឈឺចាប់ណាស់»។ ផ្ទះរបស់លោក មួន គឺជាបន្ទប់រាងការ៉េដែលមានទំហំប្រហែល ៨ ម៉ែត្រការ៉េ ដំបូលប្រក់ស័ង្កសី ហើយស្ទើរតែគ្មានអ្វីបិទបាំងដោយឃើញផ្ទាំងបាយត្រូវបានព្យួរនៅលើជញ្ជាំងពណ៌សដែលមានស្នាមប្រេះនៅពីលើចង្ក្រាន ខណៈអង្រឹង ២ ត្រូវបានចងផ្ទប់នឹងជញ្ជាំង។ លោកនិយាយថានៅប្រទេសម៉ាឡេស៊ី និយោជកព្រៃផ្សៃ និងមហិច្ឆតាបានកេងប្រវ័ញ្ចលើកម្មករ និងបានកាត់ទុកប្រាក់ខែជាច្រើនខែ ដើម្បីតម្រូវឲ្យកម្មករធ្វើការងារថែមម៉ោងដោយមិនមានប្រាក់ថែមម៉ោង និងថែមទាំងប្រើហិង្សាទៅលើពួកគេទៀតផង។

លោក មួន រំឭកថា៖ «ពួកគេមិនទទួលបានប្រាក់ខែរហូតដល់ជាង ៦ ខែ។ និយោជកតែងតែរក្សាទុកប្រាក់ខែរបស់យើងដោយនិយោជកមិនចង់ឲ្យយើងទៅណា»។ លើសពីនេះនិយោជកមួយចំនួនក៏ដកហូតលិខិតឆ្លងដែនរបស់ពលករផងដែរ។ នៅពេលទៅដល់ម៉ាឡេស៊ីដំបូងក្នុងឆ្នាំ ២០១៣ លោក មួន មិនមានបណ្តាញ និងទំនាក់ទំនងជាមួយពលករចំណាកស្រុកកម្ពុជាទេ ហើយពួកគេជាច្រើនមិនបានដឹងអំពីសិទ្ធិរបស់ខ្លួននោះទេ។ ដោយមិនចង់ទទួលរងការរំលោភបំពានតទៅទៀត និងដើម្បីជួយសម្រួលការឈឺចាប់របស់ពលករផ្សេងទៀតលោក មួន បានទៅអង្គការក្រៅរដ្ឋាភិបាលមួយដើម្បីស្នើសុំឲ្យមានការជួយ។ «ពួកគេបានផ្តល់ដំបូន្មានអំពីច្បាប់ និងអ្វីដែលយើងគួរធ្វើ»។

លោក Adrian Pereira នាយកប្រតិបត្តិនៃអង្គការគំនិតផ្តួចផ្តើមជើង-ត្បូង ដែលជាអង្គការសិទ្ធិមនុស្សម៉ាឡេស៊ីបានថ្លែងថាការរំលោភបំពានដូចជាការរក្សាទុកលិខិតឆ្លងដែន និងប្រាក់ខែ គឺកើតមានច្រើនណាស់ដែលបានធ្វើឲ្យរដ្ឋាភិបាលកម្ពុជាបានព្យួរការបញ្ជូនពលករទៅប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ ២០១១ ហើយមិនទាន់បន្តជាផ្លូវការនៅឡើយទេ។ លោក Pereira ថ្លែងថា របាយការណ៍នៃការរំលោភផ្លូវភេទគឺកម្រជាងករណីរំលោភបំពានផ្សេងៗទៀតដោយសារមិនបានកើតឡើង ប៉ុន្តែដោយសារ «វាកម្រមានកម្មករប្តឹង»។ លោក Pereira ថ្លែងថាការរក្សាទុកប្រាក់ខែ និងឯកសារ «គឺកើតមានស្ទើរតែទូទៅដើម្បីគ្រប់គ្រងកម្មករឲ្យពួកគេបន្តនៅធ្វើការ»។ លោកបន្តថាមិនមានប្រព័ន្ធសម្រាប់កម្មករប្តូរនិយោជក នៅពេលធ្វើការនៅម៉ាឡេស៊ី។ លោកថ្លែងថាការដោះស្រាយរបស់រដ្ឋាភិបាលម៉ាឡេស៊ីចំពោះស្ថានភាពនេះជាទូទៅគឺ «មិនជោគជ័យ»។ «រដ្ឋាភិបាលមិនបានបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចឲ្យបានគ្រប់គ្រាន់... នៅពេលមានការរំលោភបំពានកើតឡើងគ្មាននរណាម្នាក់ដឹងរហូតទាល់តែកម្មកររត់ចេញ»។ លោក Pereira បានថ្លែងផងដែរថាអាជ្ញាធរកម្ពុជាមិនបានធ្វើការណែនាំចង្អុលបង្ហាញដល់ពលករពីមុនពេលចាកចេញទៅធ្វើការនៅប្រទេសម៉ាឡេស៊ីអំពីសិទ្ធិរបស់ពួកគេឬថាតើត្រូវទាក់ទងនរណានៅពេលពួកគេទទួលរងការរំលោភបំពាន។

លោក មួន បានសម្រេចចិត្តប្រតិកម្មតបតវិញដោយធ្វើការប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានកម្មករហើយបង្កើតមូលនិធិផ្ទាល់របស់លោកដើម្បីប្រមូលកម្លាំងកម្មករ ហើយក្នុងករណីធ្ងន់បំផុតជួយពួកគេឲ្យរត់គេចចេញពីប្រទេសម៉ាឡេស៊ី។ មូលនិធិសប្បុរសធម៌ពលករចំណាកស្រុកត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដោយក្រុមមួយដែលមានសមាជិក ២០ នាក់។ មេដឹកនាំនីមួយៗក្នុងចំណោមមេដឹកនាំទាំង ២០ នាក់បានចំណាយប្រាក់ផ្ទាល់ខ្លួនរបស់ពួកគេចំនួន ១០ រីងហ្គីតនៃប្រាក់ផ្ទាល់ខ្លួនរបស់ពួកគេក្នុងមួយខែហើយធ្វើការអង្គាសថវិកាពីប្រភពផ្សេងៗផងដែរ។ សមាជិកស្ថាបនិកម្នាក់ៗអាចដកប្រាក់រហូតដល់ ២០% នៃមូលនិធិសរុបនៅពេលណាមួយដើម្បីសម្រួលដល់ការរត់គេចខ្លួនរបស់ពលករ។ ១០% អាចដកដើម្បីជួយគ្រួសារបន្ទាប់ពីការស្លាប់។ លោក មួន បន្តថា៖ «ប្រសិនបើពួកគេមិនរួបរួមគ្នានៅពេលមានបញ្ហាបុគ្គល ពួកគេមិនអាចជួយគ្នាបាន។ និយោជកអាចធ្វើអ្វីមួយ។ ការរួមកម្លាំងគ្នាយើងមានអំណាចជាងមុន»។ សរុបទៅលោក មួន បានជួយដល់ការវិលត្រឡប់មកវិញរបស់ពលករចំណាកស្រុកចំនួន ៧ នាក់មកប្រទេសកម្ពុជាវិញដែល ៤ នាក់បានជាប់ពន្ធនាគារបន្ទាប់ពី «បំពាន» កិច្ចសន្យារបស់ពួកគេ។

លោក មួន ថ្លែងបន្តថា៖ «ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីបម្រើការងារតាមផ្ទះបានទទួលរងការរំលោភបំពានលើរាងកាយ»។ លោកបានពន្យល់ថាអ្នកនាង កែវ ស្រីជា បានទទួលរងការវាយដំ និងរំលោភសេពសន្ថវៈរហូតដល់មានផ្ទៃពោះនៅអាយុប្រហែល ១៩ ឆ្នាំ។ «ខ្ញុំបានទាក់ទងមេខ្យល់ឲ្យបញ្ជូននាងត្រឡប់មកវិញតាមរយៈប្រទេសថៃ»។ នាងត្រូវបានជួញដូរចេញពីប្រទេសដោយថៅកែបានដកហូតលិខិតឆ្លងដែនរបស់នាង។

អ្នកនាង ស្រីជា បានថ្លែងថានាង «សំណាង» ដែលបានជួបលោក មួន ។ នាងនិយាយដោយយំតាមទូរស័ព្ទថា៖ «ខ្ញុំមិនចង់រំឭកអំពីការឈឺចាប់នោះទេ... ខ្ញុំបានព្យាយាមគេចចេញពីផ្ទះនោះ ប៉ុន្តែជាអកុសលបុរសនោះបានចាប់ខ្ញុំ និងវាយខ្ញុំពេញរាងកាយ ហើយចាប់រំលោភខ្ញុំ»។ អ្នកនាងបានពន្យល់ថាអ្នកនាងបានជួយក្មេងស្រីបួននាក់ដទៃៗទៀតគេចចេញពីផ្ទះតែមួយនោះនៅមុនពេលនាងរត់ចេញពីផ្ទះនោះ ហើយម្នាក់ក្នុងចំណោមពួកគេ បានបាក់ជើងនៅពេលលោតចុះពីជញ្ជាំង។ អ្នកនាងបន្តថា៖ «[លោក មួន] ល្អណាស់ លោកបានផ្តល់អាហារ និងកន្លែងស្នាក់នៅដល់ខ្ញុំ ។ នៅពេលខ្ញុំរត់ចេញពីថៅកែ ខ្ញុំមិនមានលិខិតឆ្លងដែននៅនឹងខ្លួនដូច្នេះគាត់បានឲ្យលុយខ្ញុំ និងទាក់ទងស្ថានទូតដើម្បីស្វែងរកជំនួយ»។ «គាត់មើលថែខ្ញុំដូចបងប្រុសមើលថែប្អូនស្រី»។ ស្រីជា បានថ្លែងថា នាងបានស្វះស្វែងរកជំនួយពីស្ថានទូតកម្ពុជាដែលអ្នកនាងយល់ឃើញថាស្ថានទូតមិនស្វះស្វែងជួយអ្នកនាង។ «ដំណើរការទាំងមូលនៃការបញ្ជូនខ្ញុំត្រឡប់មកប្រទេសកម្ពុជាវិញគឺតាមរយៈការជួយរបស់លោក មួន។ តាមរយៈលោក មួន ខ្ញុំទទួលបានកន្លែងមួយដើម្បីស្នាក់នៅ។ លោកបានប្រមូលប្រាក់ពីបណ្តាញពលករចំណាកស្រុកដទៃៗទៀតនៅម៉ាឡេស៊ី ហើយបានឲ្យប្រាក់នោះមកខ្ញុំ»។

លោក មួន បានរំឭកអំពីពលករម្នាក់ទៀតដែលលោកបានជួយឲ្យរត់គេចខ្លួន ក្នុងអំឡុងជើងហោះហើរពេលយប់។ «នាងធ្វើការនៅប្រទេសម៉ាឡេស៊ីអស់រយៈពេល ៦ ឆ្នាំ ជាពលករបម្រើការងារតាមផ្ទះ។ បន្ទាប់ពីរយៈពេល ៣ ឆ្នាំ នាងបានទៅធ្វើការនៅក្រុមហ៊ុនផ្សេង ប៉ុន្តែនាងមិនដែលទទួលបានប្រាក់ខែទេ។ នាងមិនត្រូវបានអនុញ្ញាតឲ្យទាក់ទងគ្រួសារ និងមិនអនុញ្ញាតសូម្បីតែនិយាយជាមួយពលករដទៃទៀត»។ លោកបន្ថែមថា កាលពេលលោក ជួបនាង ដំបូងនាង «ស្គមណាស់»។ លោក មួន បានថ្លែងថានារីម្នាក់នោះត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងរោងចក្រមួយ ហើយបន្ទាប់មកបង្ខំឲ្យធ្វើការងារផ្ទះបន្ថែមពីលើការងាររោងចក្រ ដោយមិនទទួលបានប្រាក់ឈ្នួលបន្ថែមនោះទេ។ ជាមធ្យម នាងធ្វើការពីម៉ោង ៧:៣០ ព្រឹកដល់ម៉ោង ១២ យប់។ «នៅពេលយើងឃើញពីស្ថានភាពអាក្រក់របស់នាង យើងបានព្យាយាមជួយនាង និងបានសួរនាងថា តើនាងចង់ចាកចេញឬអត់? នាងភ័យខ្លាចណាស់»។

ពលករចំណាកស្រុកម្នាក់ឈ្មោះ សាន កុសល បានថ្លែងថាលោក មួន មិនត្រឹមតែជួយពលករទេ ប៉ុន្តែថែមទាំងចំណាយពេលវេលាធ្វើការអប់រំនៅតាមសហគមន៍។ «ខ្ញុំពិតជាបានឃើញថាគាត់ជាមនុស្សល្អណាស់ ហើយចង់ជួយអ្នកដែលទន់ខ្សោយ។ គាត់យកចិត្តទុកដាក់ចំពោះពលករចំណាកស្រុកនៅប្រទេសម៉ាឡេស៊ី ហើយជួយពលករផ្សេងៗដែលទទួលរងការរំលោភបំពាន...»។ ខណៈលោក មួន មានអារម្មណ៍ក្រៀមក្រំចំពោះការចាកចេញពីប្រទេសម៉ាឡេស៊ីលោកបានថ្លែងថាលោកត្រឡប់មកស្រុកកំណើតវិញគឺដោយសារម្តាយរបស់លោកមានជំងឺជាទម្ងន់ ដែលលោកត្រូវមើលថែគាត់។ ក្តីសុបិនរបស់លោកគឺចង់ចូលនយោបាយ ប៉ុន្តែដំបូងលោកត្រូវរៀនច្បាប់ និងធ្វើការងារជាមួយអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការងារកម្មករក្នុងប្រទេសកម្ពុជា។

លោក កៅ ពឿន អនុប្រធាន សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហៅកាត់ អាយឌៀ ថ្លែងថាអង្គការរបស់លោកជាញឹកញាប់ពឹងផ្អែកលើលោក មួន កាលពេលលោកនៅប្រទេសម៉ាឡេស៊ី។ «អង្គការរបស់យើង និងអង្គការដៃគូរបស់យើងក្នុងប្រទេសម៉ាឡេស៊ីទទួលបានការគាំទ្រច្រើនពីលោក មួន យើងកំពុងខិតខំតស៊ូដោយសារឥឡូវនេះលោកត្រឡប់មកកម្ពុជា»។ «ឥឡូវនេះអង្គការរបស់យើងកំពុងស្វែងរកថវិកាដើម្បីជួលគាត់ឲ្យធ្វើការជាមួយយើង ដូច្នេះគាត់អាចធ្វើការងារក្រៅម៉ោងបាននៅប្រទេសម៉ាឡេស៊ី និងក្រៅម៉ោងនៅកម្ពុជា»។

ទន្ទឹមនេះលោក សាម អ៊ីន អគ្គលេខាធិការ និងជាអ្នកនាំពាក្យនៃគណបក្សប្រជាធិបតេយ្យមូលដ្ឋានមានទំនាក់ទំនងជាមួយលោក មួន អស់រយៈពេលជាច្រើនឆ្នាំ និងគិតថាលោក មួន នឹងមានអនាគតល្អប្រសិនបើនៅជាមួយគណបក្ស។ «កាលពេលគាត់ជាពលករនៅប្រទេសម៉ាឡេស៊ី គាត់ចាប់អារម្មណ៍គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ដូច្នេះគាត់នៅបន្តទាក់ទងជាមួយខ្ញុំតាមរយៈហ្វេសប៊ុក»។ «គាត់ទើបតែត្រឡប់មកកម្ពុជា... គាត់បានចាប់ផ្តើមមកប្រជុំ និងចាប់អារម្មណ៍ចង់ក្លាយជាសមាជិកផ្លូវការ»។ លោក អ៊ីន បានថ្លែងបន្តថា៖ «យើងស្វាគមន៍គាត់ដោយកក់ក្តៅ យើងអញ្ជើញគាត់ និងលើកទឹកចិត្តគាត់ឲ្យក្លាយជាផ្នែកនៃក្រុមការងាររបស់គណបក្សប្រជាធិបតេយ្យមូលដ្ឋានក្នុងរាជធានីភ្នំពេញ និងក្រុមយុវជនថ្នាក់ជាតិ»៕ PS

## ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៨

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបញ្ជាឲ្យបិទច្រករបៀងតាមព្រំដែនឲ្យបាននៅឆ្នាំ២០១៨ ករណីទប់ស្កាត់ការជួញដូរមនុស្ស

https://wmc.org.kh/ ថ្ងៃព្រហស្បតិ៍ ទី២៥ ខែមករា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានចេញបញ្ជា ដល់មន្ត្រីក្រោមឱវាទទាំងអស់ឲ្យបង្កើនសកម្មភាពការងារឈានទៅដល់ការបិទច្រករបៀងតាមព្រំដែនកម្ពុជាឲ្យបាន បំណងធ្វើយ៉ាងណារក្សាសន្តិសុខតាមព្រំដែន ទប់ស្កាត់បទល្មើសឆ្លងដែន ដែលមានទាំងការជួញដូរមនុស្សនិងការរត់ពន្ធគ្រឿងញៀនជាដើម។

សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចេញបទបញ្ជាផ្ទាល់មាត់ដូចនេះ នៅក្នុងពិធីបិទសន្និបាត បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៧ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៨ កាលពីរសៀលថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ នៅក្រុងបាត់ដំបង។ ក្នុងពិធីនេះសម្តេច ស ខេង បានថ្លែងលើកសរសើរដល់ការខិតខំប្រឹងប្រែងអនុវត្តតួនាទីរបស់មន្ត្រីអាជ្ញាធរ ក្រោមឱវាទ ដែលបានទប់ស្កាត់បទល្មើសផ្សេងៗតាមព្រំដែន។ ក៏ប៉ុន្តែសម្តេចរដ្ឋមន្ត្រី បានបង្ហាញពីក្តីបារម្ភ ជុំវិញបទល្មើសតាមព្រំដែនដែលមិនទាន់អាចទប់ស្កាត់បានទាំងស្រុង។ សម្តេច ស ខេង មើលឃើញថា មានតែការបិទច្រករបៀងតាមព្រំដែនទេ ទើបអាចធ្វើឲ្យបទល្មើសតាមព្រំដែន មានដូចជា ការហូរចូលទំនិញគេចពន្ធ ការរត់ពន្ធមនុស្ស ការលាងលុយ ការជួញដូរគ្រឿងញៀន ការលួចចេញទៅកាប់ឈើដោយខុសច្បាប់ និងបទល្មើសផ្សេងៗទៀត។ លោករដ្ឋមន្ត្រីបន្តថា បញ្ហានេះគឺជារឿងគ្រោះថ្នាក់ ប្រសិនបើមិនមានយន្តការទប់ស្កាត់ និងដោះស្រាយឲ្យបានត្រឹមត្រូវ។

សម្តេច ស ខេង ៖«អញ្ចឹងការគ្រប់គ្រងច្រកនេះ ជាផ្នែកមួយសំខាន់ដែរ ។ ការគ្រប់គ្រងខ្សែបន្ទាត់ទាំងមូលរឿងមួយទៀត ហើយបិទច្រករបៀងឲ្យបានព្រោះថា បើមិនអញ្ចឹងទេទំនិញវាមកតាមច្រករបៀងនោះការរត់ពន្ធមនុស្ស ការជួញដូរគ្រឿងញៀន វាមកតាមច្រករបៀងដែលជាបញ្ហាដ៏គ្រោះបើយើងធ្វើមិនបានត្រឹមត្រូវ»។ បន្ថែមលើសនេះ សម្តេច ស ខេង មានប្រសាសន៍ថា គោលដៅរបស់លោកគឺការលុបបំបាត់ឲ្យបានការជួញដូរខុសច្បាប់ឆ្លងកាត់ព្រំដែនទាំងអស់របស់កម្ពុជា។ ជាងនេះលោកក៏បានលើកទឹកចិត្តដល់មន្ត្រីក្រោមឱវាទទាំងអស់រួមគ្នាអនុវត្តការងារនេះឲ្យបាន។ ក្នុងពិធីបិទសន្និបាត បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៧នេះ សម្តេច ស ខេង ក៏បានលើកឡើងពីជោគជ័យ នៃការស្នើសុំទៅកាន់អាជ្ញាធរថៃ និងឡាវ ដែលបានបញ្ឈប់ការបាញ់សម្លាប់ពលរដ្ឋខ្មែរ ដែលបានលួចចូលទៅកាប់ឈើដោយខុសច្បាប់នៅប្រទេសទាំងនោះទេ។

សម្តេច ស ខេង ៖«សុំធ្វើម៉េចគឺទុកជីវិត បើថា ខុស គឺខុសហើយ ប៉ុន្តែសុំថា ចាប់ទៅផ្តន្ទាទោសទៅ កុំសម្លាប់ចោល ដល់ឥឡូវធ្វើបាន គឺអត់មានទេ មកដល់ឥឡូវគឺអត់មាន អញ្ចឹងគឺជាជោគជ័យមួយដែរដោយកិច្ចសហប្រតិបត្តិការ អញ្ចឹងខេត្តជាប់ព្រំដែនយើងខិតខំហៅរកគ្នាទៅ ប៉ុន្តែមិនមែនហៅរកក្នុងន័យលក់អធិបតេយ្យភាព លក់ឯករាជ្យយើងទេ គឺក្នុងន័យការពារផលប្រយោជន៍របស់ប្រជាជន»។

ទាំងប្រទេសវៀតណាម ឡាវ ថៃ និងកម្ពុជា សុទ្ធតែមានគណៈកម្មាធិការព្រំដែនរួមគ្នា។ គណៈកម្មាធិការនេះ មានភារកិច្ច ជួយទប់ស្កាត់ការប៉ះទង្គិចគ្នា តាមព្រំដែន និង ការទប់ស្កាត់សកម្មភាព ជួញដូរដែលមិនស្របច្បាប់ នៅតាមព្រំដែននៃប្រទេសទាំង ៣នេះ។ ប្រសាសន៍របស់ សម្តេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើឡើង ស្របពេលដែលករណីបាតុភាពផ្សេងៗ តាមព្រំដែន នៅតែបន្តកើតមាន មានជាអាទិ៍ ការជួញដូរគ្រឿងញៀន ការនាំទំនិញគេចពន្ធ និងលួចរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់ជាដើម៕

## ឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន ជួបសួរសុខទុក្ខផ្ទាល់ និងស្វែងយល់ពីបញ្ហានានា ពីពលករ-ពលការិនីខ្មែរជាង៧០០នាក់ នៅខេត្តសាមុតសាខន ប្រទេសថៃ

http://www.freshnewsasia.com/ 2018-01-25

(ថៃ)៖ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨នេះ លោកស្រីឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានជួបសំណេះសំណាលដោយផ្ទាល់ ជាមួយពលករ-ពលការិនីខ្មែរជាង៧០០នាក់ ដែលកំពុងធ្វើការនៅរោងចក្រផលិតត្រីខកំប៉ុង និងគ្រឿងកំប៉ុង របស់រោងចក្រ Thai Union Manufacturing Co.,Ltd នៅខេត្តសាមុទ្រសាខន ប្រទេសថៃ។

ថ្លែងក្នុងឱកាសនោះ លោកស្រីក៏បានពាំនាំនូវការផ្តាំផ្ញើ និងសាកសួរសុខទុក្ខពីសំណាក់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងបានផ្តល់កម្លាំងចិត្តឲ្យកម្មករពលករខ្មែរទាំងអស់ ប្រឹងប្រែងធ្វើការងារ កាន់តែសកម្មថែមទៀត ដើម្បីទទួលបានប្រាក់ខែខ្ពស់ និងទទួលការពេញចិត្តពីថៅកែរោងចក្រ។ លោកស្រីបន្តថា នេះជាការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ ហ៊ុន សែន ជាប្រមុខ ដែលជានិច្ចកាលតែងតែ មានមនោសញ្ចេតនាជិតស្និទ្ធជាមួយប្រជាជន កម្មករ និងជាមួយពលករ មិនថាក្នុងប្រទេស ឬក្រៅប្រទេសនោះទេ។ ជាក់ស្តែង ដូចជាពេលនេះ ទោះជាបងប្អូនមកធ្វើការនៅប្រទេសថៃ ឆ្ងាយពីស្រុកកំណើតក្តី ក៏សម្តេចនៅតែគិតគូរ និងបានចាត់តាំងក្រុមការងារ៥ក្រុម ដែលក្នុងនោះ មានមួយក្រុមដឹកនាំដោយលោកស្រី និងមានក្រុមផ្សេងទៀត ដូចជា៖ ក្រុមដឹកនាំដោយលោក អ៊ិត សំហេង, លោក ហ៊ុន ម៉ានី, លោក ហ៊ុន ម៉ាណែត និងលោក ព្រុំ សុខា ជាតំណាងមកជួបសំណេះសំណាលជាមួយប្អូនៗ ដើម្បីសាកសួរសុខទុក្ខ និងចែករំលែកព័ត៌មាន និងជួយដោះស្រាយបញ្ហាផ្សេងៗដែលប្អូនៗជួបប្រទះ។

បច្ចុប្បន្នរាជរដ្ឋាភិបាល បានផ្តល់លិខិតឆ្លងដែនជូនពលក និងបានរៀបចំគណៈកម្មាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដើម្បីដោះស្រាយការលំបាកនានា ជាពិសេសជួយសម្រួលឱ្យប្អូនៗពលករយើងរស់នៅ និងធ្វើការដោយស្របច្បាប់ និងដោយមានកិត្តិយស រួចផុតពីការរំលោភ ជិះជាន់កេងប្រវ័ញ្ច និងហានិភ័យផ្សេងៗ។ ជាទីបញ្ចប់ លោកស្រីបានផ្តាំផ្ញើដល់ប្អូនៗ ដែលជាលករខ្មែរ រស់នៅ ធ្វើការងារ ត្រូវគោរពច្បាប់ប្រទេសថៃ ដាច់ខាតមិនត្រូវ ប្រព្រឹត្តបទល្មើស នោះឡើយ។ ចំណែកឯថៅកែក្រុមហ៊ុន សូមបន្តទទួលពលករខ្មែរបន្ថែមទៀត និងសូមអាណិតស្រឡាញ់ពលករខ្មែរដូចពលករថៃ និងស្ថានទូត ស្ថានអគ្គកុងស៊ុលកម្ពុជា សូមបន្តការយកចិត្តទុកដាក់តាមដាន និងជួយដោះស្រាយរាល់ បញ្ហានានារបស់ពលករខ្មែរ ស្របតាមច្បាប់អន្តរជាតិ ច្បាប់ប្រទេសថៃ និងស្មារតីនៃ MOU ដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានចុះហត្ថលេខា។

សូមបញ្ជាក់ថា កាលពីម្សិលមិញ លោកស្រីឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន បានដឹកនាំគណៈប្រតិភូមួយក្រុម ទៅជួបសំណេះសំណាល ផ្តល់ការលើកទឹកចិត្ត ជាមួយពលករ ពលការិនីជាង៧០០នាក់ ដែលកំពុងធ្វើការនៅរោងចក្រផលិតគ្រឿងសមុទ្រនៅខេត្តសាមុតសាខន ប្រទេសថៃ៕

# រដ្ឋមន្ត្រីក្រសួងការងារ ជួបសំណេះសំណាលជាមួយពលករកម្ពុជា នៅរោងចក្រ Sun Food International ក្នុងខេត្ត សាវ៉ាក់ប៊ុរី ប្រទេសថៃ

http://www.akp.gov.kh/kh/ AKP ភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨

ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈ ប្រតិភូចុះជួបសួរសុខទុក្ខបងប្អូនពលករខ្មែរ ចំនួន៥២៦នាក់ ក្នុងចំណោមពលករខ្មែរចំនួន ១.៧៣០នាក់ ដែលធ្វើការនៅរោងចក្រផលិតសាច់មាន់របស់ ក្រុមហ៊ុនសាន់ហ្វូត អ៊ីនធឺណេសិនណល់ ក្នុងខេត្តសាវ៉ាក់ប៊ុរី នៃព្រះរាជាណាចក្រថៃឡង់ដ៍ កាលពីថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨។

នេះបើតាមគេហទំព័រហ្វេសប៊ុករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ឯកឧត្តម អ៊ិត សំហេង បាននាំមកនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ សម្តេចអគ្គមហាសេនា បតីតេជោហ៊ុនសែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនដល់បងប្អូន ខ្មែរដែលរស់ នៅក្នុងប្រទេសថៃទាំងអស់ ទោះបីជាបងប្អូនចាកចេញមកធ្វើការនៅ ក្រៅស្រុកក៏ដោយ ក៏សម្តេចនៅតែចាត់គណៈប្រតិភូចុះមកតាមដានពីសុខទុក្ខ និងតាមមើលការខុសត្រូវបងប្អូនជាប់ជានិច្ច ដើម្បីធ្វើយ៉ាងណាឱ្យបងប្អូនពលករ យើង ទទួលបាននូវភាពស្របច្បាប់។

ឯកឧត្តមរដ្ឋមន្ត្រីបានរម្លឹកថា កាលពីចុងខែធ្នូ ឆ្នាំ២០១៧ កន្លងទៅនេះ ឯកឧត្តមបានមកជួបចរចាម្តង ទៀតជាមួយភាគីថៃជាលទ្ធផល ភាគីថៃបានព្រមពន្យារ ពេលរយៈពេល៦ខែទៀតរហូតដល់ខែមិថុនា ២០១៨ ដើម្បីក្រុមការងារ រៀបចំឯកសារផ្តល់ភាពស្របច្បាប់ជូនដល់ បងប្អូនពលករដែលកំពុងធ្វើការ និងស្នាក់នៅក្នុងប្រទេសថៃ។ឯកឧត្តមបានបន្តថា "សូមបង ប្អូនធ្វើការដោយស្ងប់ចិត្ត ហើយបើបងប្អូនមិនទាន់មានឯកសារស្របច្បាប់ សូមនាំគ្នាទៅធ្វើឱ្យ បានទាន់ពេលវេលា"។ឯកឧត្តមរដ្ឋមន្ត្រីបានបន្ថែមថា ការសំពន្យារពេលនេះ ដោយសារតែមានកិច្ចសហប្រតិបត្តិការល្អរវាង រាជរដ្ឋាភិបាលកម្ពុជា និងថៃ ដែលបានផ្តល់ឱកាសជូនពលករកម្ពុជាមកធ្វើការ ងារនៅប្រទេសថៃ ព្រមទាំងបន្តគោលនយោបាយធានាសុវត្ថិភាព និងភាពស្របច្បាប់ចំពោះ បងប្អូនខ្មែរនៅទីនេះផងដែរ ។

ជាមួយគ្នានេះដែរ ក្រុមការងារផ្តល់ភាពស្របច្បាប់ កំពុងបន្តការងារដោយផ្តោតទៅលើ ទី១-ផ្តល់លិខិត ធ្វើដំណើរនិងប័ណ្ណពលករ៣មណ្ឌល ដែលមានទីតាំងនៅទីក្រុងបាងកក ខេត្ត រ៉ាកយ៉ង និងខេត្តសុងខ្លា ធ្វើមួយថ្ងៃហើយ តម្លៃ២៣៥០បាត។ ទី២-ចែកឯកសារធ្វើដំណើរ(TD) និងប័ណ្ណពលករកម្ពុជាធ្វើ ការនៅបរទេស(OCWC) ដែលធ្វើរួចហើយចំនួន១២ម៉ឺន នៅសល់ ១១ម៉ឺន តម្លៃ៩៥០បាត។ ទី៣-រៀបចំ បន្ថែមក្រុមចល័ត២ទៀត ចុះតាមកន្លែងដែលមាន ពលករខ្មែរច្រើនតាមសំណូមពរភាគីថៃ។ ទី៤-អនុញ្ញាតឱ្យសុំលិខិតពីមន្ទីរការងារថៃដោយអាច ទៅធ្វើឯកសារពីក្នុងប្រទេសបាន និងទី៥-បើក មណ្ឌលផ្តល់ឯកសារធ្វើដំណើរ(TD) និងប័ណ្ណ ពលករកម្ពុជាធ្វើការនៅបរទេស(OCWC)ចំនួនបីកន្លែង ក្នុងរយៈពេលបីថ្ងៃ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។

ឯកឧត្តមរដ្ឋមន្ត្រីបានលើកឡើងថា ក្រៅពីកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំផ្តល់ភាពស្របច្បាប់ជូនដល់ ពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ រាជរដ្ឋាភិបាលកម្ពុជា កំពុងតែពិភាក្សាជាមួយ នឹងភាគីថៃដើម្បីការពារសុវត្ថិភាព និងសិទ្ធិការងារ ដែលក្នុងនោះរួម មាន របបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ ជូនដល់ពលករកម្ពុជា ដូចពលករថៃដែរ។ ឯកឧត្តម អ៊ិត សំហេង ក៏បានអំពាវនាវដល់បងប្អូនពលករកំពុងធ្វើការ និងរស់នៅប្រទេសថៃ គឺត្រូវអនុវត្តន៍ច្បាប់របស់ប្រទេសគេឱ្យបានល្អ ជៀសវាងកុំធ្វើពលករខុសច្បាប់ ដែលនាំឱ្យគេកេងប្រវ័ញ្ចយកផលប្រយោជន៍ពីបងប្អូន ត្រូវពិន័យ និងត្រូវជាប់ទោសទៀត ផង។

ទន្ទឹមនេះ បងប្អូនត្រូវ ថែរក្សាសុខភាព ខំរៀនជំនាញដើម្បីអនាគត និងត្រូវចេះជួយគ្នាទៅវិញទៅ មកបីដូចជាក្រុមគ្រួសារតែមួយ។ឯកឧត្តមបានស្នើសុំថៅកែក្រុមហ៊ុន បន្តទទួលពលករខ្មែរ និងផ្តល់ក្តីស្រឡាញ់ព្រមទាំងអត្ថប្រយោជន៍ ដូចពលករថៃ និងសុំស្ថានទូតបន្តយកចិត្តទុកដាក់តាមដាន ដោះស្រាយរាល់បញ្ហានានា នៃប្រទេសថៃផងដែរ៕ ដោយ អ៊ុន រិទ្ធី

# អង្គការអន្តរជាតិថាពលករខ្មែរជាច្រើននៅលើទូកនេសាទថៃកំពុងរងការរំលោភសិទ្ធិ

http://km.rfi.fr/cambodia/ 25/01/2018

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ កាលពីថ្ងៃអង្គារ បានចេញផ្សាយរបាយការណ៍មួយ ដោយបានរិះគន់លើការអនុវត្តច្បាប់ និងប្រព័ន្ធការពារកម្មករនេសាទក្នុងប្រទេសថៃ និងស្នើឲ្យរដ្ឋាភិបាលប្រទេសនេះ ពង្រឹងការអនុវត្តច្បាប់របស់ខ្លួនឲ្យបានម៉ឺងម៉ាត់។ បើតាមរបាយការណ៍ ការរំលោភសិទ្ធិចំពោះពលករនេសាទក្នុងប្រទេសថៃ នៅតែកើតឡើងដដែល និងច្រើនថែមទៀត ហើយភាគច្រើនកើតចំពោះពលករខ្មែរ និងភូមា។ អត្ថបទដោយៈ អ៊ឹង ប៊ុនថន

ក្នុងរបាយការណ៍កម្រាស់១៣៤ទំព័រ ដែលមានចំណងជើងថា «**ការរំលោភសិទ្ធិ និងការបង្ខំឲ្យធ្វើការ ក្នុងឧស្សាហកម្មនេសាទនៅប្រទេសថៃ**» អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Rights Watch អះអាងថា ពលករដែលធ្វើការលើទូកនេសាទថៃក្នុងនោះមានខ្មែរនិងភូមាផងដែរ ភាគច្រើនប្រឈមនឹងបញ្ហាជួញដូរមនុស្ស ការបើកប្រាក់ខែមិនទៀងទាត់ និងទទួលបានប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បបរមា ហើយមិនអាចផ្លាស់ប្តូរនិយោជក និងមិនទទួលការគាំពារផ្នែកច្បាប់ ឬអាចចូលរួមជាមួយសហជីពដើម្បីជួយការពារសិទ្ធិពួកគេបានឡើយ។

ប្រធានផ្នែកតស៊ូមតិនិងការពារសិទ្ធិស្ត្រីនិងកុមារនៃសមាគមការពារសិទ្ធិមនុស្សអាដហុក លោកស្រី ធន សុគន្ធា កត់សំគាល់ប្រហាក់ប្រហែលគ្នានឹងរបាយការណ៍នេះដែរ។ លោកស្រី និយាយថា ពលករខ្មែរដែលទៅធ្វើការលើទូកនេសាទថៃគឺសុទ្ធតែទៅដោយខ្លួនឯងភាគច្រើនខុសច្បាប់ ដែលនេះជាបញ្ហាពិបាកក្នុងការជួយសង្គ្រោះនៅពេលមានបញ្ហាកើតឡើង។ បើតាម លោកស្រី ធន សុគន្ធា មិនដឹងថាមានក្រុមហ៊ុនណាដែលបញ្ជូនពលករខ្មែរឲ្យធ្វើការនៅលើទូកនេសាទថៃនោះទេ។ អ្នកធ្វើការលើទូកនេសាទគឺពួកគេត្រូវបណ្តែតជីវិតនៅលើទូកគ្មានកោះគ្មានត្រើយរាប់ខែទំរាំបានឡើងគោកម្តងៗ។ ហើយជួនកាលក៏ត្រូវបានថៅកែទូកនេសាទបញ្ជូនបន្តទៅឲ្យថៅកែផ្សេងទៀតរហូតដល់ម៉ាឡេស៊ីក៏មាន។ នេះជាការកត់សំគាល់របស់មន្ត្រីអាដហុកដដែល។

ទោះជាយ៉ាងណា ក្នុងពេលចុះជួបពលករខ្មែរដែលធ្វើការនៅរោងចក្រផលិតសាច់មាន់កាលពីពេលថ្មីៗនេះ ក្នុងខេត្តសារ៉ាក់បុរី ប្រទេសថៃ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា បានប្រាប់ពលករខ្មែរនៅទីនោះថា រដ្ឋាភិបាលកម្ពុជាកំពុងតែពិភាក្សាជាមួយភាគីថៃ ដើម្បីការពារសុវត្ថិភាព និងសិទ្ធិការងារ ក្នុងនោះមានរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ជូនដល់ពលករកម្ពុជា។ នេះបើតាមការផ្សាយរបស់បណ្តាញសារព័ត៌មានដែលស្និទនឹងរដ្ឋាភិបាល។

បើតាម Human Rights Watch កាលពី២០១៥ រដ្ឋាភិបាលថៃ បានទទួលរងការថ្កោលទោសយ៉ាងខ្លាំងពីមជ្ឈដ្ឋានអន្តរជាតិ និងបណ្តាប្រទេសនាំចូលផលិតផលគ្រឿងសមុទ្រពីប្រទេសថៃ។ ក្នុងនោះ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ក៏បានព្រមានហាមឃាត់ការនាំចេញទៅទីផ្សារអន្តរជាតិ និងបានដាក់បញ្ចូលប្រទេសនេះ ទៅក្នុងបញ្ជីស្ថិតក្រោមការឃ្លាំមើលផងដែរ។ បន្ទាប់ពីមានការព្រមាន និងជំរុញឲ្យគោរពសិទ្ធិមនុស្ស រដ្ឋាភិបាលថៃ បានកែប្រែលក្ខខណ្ឌក្នុងច្បាប់ការងារ កែលម្អប្រព័ន្ធតាមដានការរំលោភសិទ្ធិ និងចាត់វិធានការជាបន្តបន្ទាប់។ អង្គការ Human Rights Watch រិះគន់ថា ចំណាត់ការទាំងអស់នោះ គឺគ្រាន់ដើម្បីលាក់បាំងភ្នែកអន្តរជាតិ និងមានតែនៅតែលើក្រដាសប៉ុណ្ណោះ ប៉ុន្តែមិនបានអនុវត្តឲ្យបានពេញលេញនោះទេ។ Human Rights Watch អះអាងថា នៅឆ្នាំ២០១៥ រដ្ឋាភិបាលថៃ មិនអាចរកឃើញសូម្បីតែមួយករណី ក្នុងចំណោមពលករជាង៤៧ម៉ឺននាក់ ដែលទទួលរងការបង្ខំឲ្យធ្វើការ។ ជាក់ស្តែងថ្មីៗនេះ អង្គការ Human Rights Watch និយាយថា កម្មករធ្វើការលើទូកនេសាទក្នុងប្រទេសថៃប្រមាណ៥ម៉ឺននាក់ ក៏បានទទួលរងការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរថែមទៀត៕

## ក្រសួងការងារថៃ បញ្ជាក់ពលករបរទេសអាចប្តូរថៅកែថ្មីបាន ក្នុងរយៈពេល ៧ថ្ងៃ

http://www.prakpheaktra.com January 25, 2018

អគ្គនាយកដ្ឋានក្រសួងការងារថៃ បញ្ជាក់ពលករបរទេសអាចប្តូរថៅកែបានក្នុងរយៈពេល៧ថ្ងៃ កាលពីថ្ងៃពុធទី ២៥ ខែមករា ឆ្នាំ២០១៨ លោកអនុរ៉ាក់ សត្យាវ៉ាក់ អគ្គនាយកដ្ឋាននៃក្រសួងការងារថៃ បានមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានក្នុងស្រុកថៃអោយបានដឹងថា ករណីពលករបរទេសធ្វើការប្តូរថៅកែថ្មីបាន ក្នុងលក្ខខ័ណ្ឌមាន ១.ថៅកែបាត់បង់ជីវិត ២.ក្រុមហ៊ុនក្ស័យធន ៣.ថៅកែធ្វើទារុណកម្មលើពលករ ៤.ថៅកែមិនគោរពកិច្ចសន្យា ៥.ការងារផ្សេងនិងគ្រោះថ្នាក់គ្រប់ប្រភេទ។ ចំពោះករណីពលករឈប់ធ្វើការ ហើយថៅកែមិនព្រមចែងឈប់ជូលទៅមន្ទីការងារក្នុងរយៈពេល៧ថ្ងៃ ថៅកែត្រូវមានទោសតាមច្បាប់ការងាររបស់ប្រទេសថៃ។

## អាជ្ញាធរថៃ, បង្ហាញលិទ្ធផលបង្ក្រាបពលករបរទេស ដណ្តើមមុខរបររកស៊ីរបស់ពលរដ្ឋថៃ ប្រមាណជិត១០០០នាក់

http://www.prakpheaktra.com January 25, 2018

អាជ្ញាធរថៃ បង្ហាញលិទ្ធផលបង្ក្រាបទល្មើសពលករបរទេសដណ្តើមមុខរបររកស៊ីរបស់ពលរដ្ឋថៃ ឃាត់ខ្លួនបានពលករខុសច្បាប់ចំនួនជិត១០០០នាក់។

យោងតាមរបាយការណ៍ក្រសួងការងារថៃបញ្ជាក់លិទ្ធផលសរុបក្នុងការបង្ក្រាបពលករបរទេសខុសច្បាប់ក្នុងរយៈពេលឆ្នាំ២០១៧កន្លងមក កម្លាំងអាជ្ញាធរថៃធ្វើការបង្ក្រាបពលករបរទេសខុសច្បាប់និងស្របច្បាប់ប្រកបរបររកស៊ីលក់ដូរដណ្តើមអាជីពពលរដ្ឋថៃបានចំនួន៣៩២នាក់ ក្នុងមានពលករសញ្ជាតិភូមាចំនួន៣៦៥នាក់, ពលករសញ្ជាតិឡាវចំនួន12នាក់, ពលករសញ្ជាតិខ្មែរចំនួន០៦នាក់, ពលករសញ្ជាតិវៀតណាមចំនួន០៣នាក់, ជនជាតិឥណ្ឌាចំនួន ០៤នាក់ ផ្សេងទៀតចំនួន០២នាក់ និងថៅកែថៃ០១នាក់ ព្រមទាំងឆែកឆេរកន្លែងធ្វើការចំនួន១៩កន្លែង។

ហើយនៅដើមឆ្នាំ២០១៨នេះ កម្លាំងអាជ្ញាធរថៃធ្វើការបង្ក្រាបបានពលករបរទេសប្រកមុខរបរកស៊ីលក់ដូរខុសច្បាប់បានចំនួន២៩៧នាក់ ក្នុងនោះមានពលករសញ្ជាតិភូមាចំនួន២៨១នាក់ ,ពលករសញ្ជាតិខ្មែរចំនួន០២នាក់, ពលករសញ្ជាតិឡាវចំនួន០៨នាក់, ជនជាតិវៀតណាមចំនួន០៥នាក់, ជនជាតិឥណ្ឌា០១នាក់ ព្រមទាំងឆែកឆេរកន្លែងតំបន់ធ្វើការរស់នៅរបស់ពលករបរទេសចំនួន១៩កន្លែង។

## បណ្តេញជនជាតិអាមេរិកម្នាក់ ឲ្យចេញពីកម្ពុជា ពាក់ពន្ធ័នឹងករណីបំពានផ្លូវភេទលើកុមារ

http://www.arey-news.com/ (ថ្ងៃទី 26 January 2018 ម៉ោង 8:36 am)

ភ្នំពេញ៖ កម្លាំងនគរបាលនាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ បានធ្វើការ បណ្តេញជនជាតិអាមេរិចម្នាក់ ឲ្យចេញពីកម្ពុជា ឆ្ពោះទៅប្រទេសដើមរបស់ខ្លួនវិញ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ។

ជនបរទេសខាងលើនេះមានឈ្មោះ LOVEJOY SAMUEL DOUGLAS ភេទប្រុស កើតថ្ងៃទី១០ ខែមីនា ឆ្នាំ ១៩៨៦ លិខិតឆ្លងដែនលេខ 548552504 ពាក់ពន្ធ័នឹងបទល្មើស បំពានផ្លូវភេទលើកុមារ ត្រូវកម្លាំងនាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ បណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ តាមប្រកាសបណ្តេញចេញរបស់ក្រសួងមហាផ្ទៃលេខ ៣៣០ ប្រ.ក ចុះថ្ងៃច័ន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ពីភ្នំពេញនៃប្រទេសកម្ពុជា ឆ្ពោះទៅប្រទេសដើមវិញ ដោយមានតំណាង Regional Security Office (RSO) ប្រចាំស្ថានទូតអាមេរិកនៅរាជធានីភ្នំពេញមកទទួលយក។ បញ្ជាក់៖ ជនជាតិអាមេរិកខាងលើ ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨ នៅខេត្តកំពត៕

# ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៨

## កម្ពុជា-ឥណ្ឌា ចុះកិច្ចព្រមព្រៀងចំនួន៤ ក្នុងដំណើរទស្សនកិច្ចរបស់ សម្តេចតេជោ ហ៊ុន សែន ទៅប្រទេសឥណ្ឌា

http://www.freshnewsasia.com/ 2018-01-27

**(ភ្នំពេញ)៖** កម្ពុជា-ឥណ្ឌា បានកិច្ចព្រមព្រៀងចំនួន៤ នៅក្នុងដំណើរទស្សនកិច្ចរបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ទៅកាន់ប្រទេសឥណ្ឌារយៈពេល៥ថ្ងៃនេះ។ នេះបើតាមសេចក្តីប្រកាសរបស់ ក្រសួងការបរទេសកម្ពុជា អំពីលទ្ធផលនៃដំណើរទស្សនកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ទៅកាន់ប្រទេសឥណ្ឌា។

**កិច្ចព្រមព្រៀងចំនួន៤ ដែលត្រូវបានចុះហត្ថលេខានោះរួមមាន៖**

១៖ អនុស្សារណៈនៃការយោគយល់គ្នាស្តីពីការទប់ស្កាត់ ការជួញដូរមនុស្ស

២៖ សន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់លើបញ្ហាព្រហ្មទណ្ឌ

៣៖ កម្មវិធីផ្លាស់ប្តូរវប្បធម៌

៤៖ កិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ៣៦,៩២ លានដុល្លារអាមេរិកសម្រាប់គម្រោង អភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់។

សូមបញ្ជាក់ថា សម្តេចតេជោ ហ៊ុន សែន បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋឥណ្ឌា ពីថ្ងៃទី២៤ ដល់២៧ ខែមករា ឆ្នាំ២០១៨នេះ តបតាមការអញ្ជើញរបស់ លោក ណារិនដ្រា ម៉ូឌី (Narendra Modi) នាយករដ្ឋមន្ត្រីឥណ្ឌា៕

## រដ្ឋបាលខេត្តសៀមរាប បើកកិច្ចប្រជុំឆ្លុះបញ្ចាំងទទួលផលការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សឆ្នាំ២០១៧ និង លើកទិសដៅអនុវត្តបន្ត ឆ្នាំ២០១៨

http://ann.com.kh/ ថ្ងៃសុក្រ, 26 ខែមករា 2018 4:03 ល្ងាច

**ខេត្តសៀមរាប៖** នៅសាលប្រជុំនៃរដ្ឋបាលសាលាខេត្តសៀមរាប នាព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨នេះ បានបើកកិច្ចប្រជុំឆ្លុះបញ្ចាំងទផលការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឆ្នាំ២០១៧ និង លើកទិសដៅអនុវត្តបន្ត ឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត នូ ផល្លា ប្រធានក្រុមប្រឹក្សាខេត្ត ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត អស់លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព និងអាជ្ញាធរក្រុង ស្រុក និងមន្ត្រីរាជការ។

លោកជំទាវ យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្តសៀមរាប បានធ្វើសេចក្តីរាយការណ៍ អំពីលទ្ធផល ការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឆ្នាំ២០១៧ ព្រមទាំងបានលើកផងដែរ អំពីបញ្ហាប្រឈមដែលក្រុមការងារបានជួបក្នុងពេលកន្លងមក និងបានលើកនូវទិសដៅសម្រាប់អនុវត្តបន្តឆ្នាំ២០១៨ផងដែរ។

ជាមួយគ្នានោះ ឯកឧត្តមបណ្ឌិត នូ ផល្លា ក៏បានធ្វើការកោតសរសើរអំពីលទ្ធផល នៃកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្តអនុវត្តបាន ឆ្នាំ២០១៧ ដោយមានកិច្ចសហការបានល្អជាមួយគ្រប់បណ្តាជំនាញ ដើម្បីបង្ការបង្ក្រាប និងទប់ស្កាត់រាល់សកម្មភាពរបស់ជនល្មើស ដោយទទួលបានលទ្ធផលល្អ ក៏

អាស្រ័យដោយបងប្អូនសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ អង្គការដៃគូរជាតិ អន្តរជាតិរួមសហការគ្នាបានល្អ។ ទន្ទឹមនោះដែរ យើងក៏រកឃើញនូវភាពប្រឈម និងឧបសគ្គមួយចំនួន ក្នុងការរាំងស្ទះដល់ការអនុវត្តការងារ ក៏អាស្រ័យ ដោយកត្តា អន្តោម៉ត និងសត្យានុម័តមួយចំនួនផងដែរ។

ឯកឧត្តមបណ្ឌិត ក៏បានលើកឡើងថា ក្នុងការជំនះគ្រប់ឧបសគ្គ បង្កាទប់ស្កាត់នូវរាល់ល្បិចកលរបស់ជនល្មើស ជួញដូរមនុស្ស ដែលបង្កនូវភាពរងគ្រោះដល់ប្រជាពលរដ្ឋទាំងបុរស ស្ត្រី យុវវ័យគ្រប់រូប និងកុមារកម្ពុជា នៅគ្រប់ទីកន្លែង។ ការឆកល្វែងខ្លះ ដោយការយល់ឃើញ នូវបទពិសោធន៍ការងារ និងស្ថានភាពនៃក្រុមគោលដៅ និងបទល្មើសគ្រប់រូបភាព ដែលធ្វើឲ្យកិច្ចប្រតិបត្តិការ និងកិច្ចសហការគ្នា នៅខ្វះចន្លោះដែលធ្វើឲ្យបទល្មើសអាចកើតមានឡើង ហើយជនល្មើសមួយចំនួនអាចរួចខ្លួន ដែលធ្វើឲ្យជះឥទ្ធិពលដល់ជនរងគ្រោះ ក្នុងការជួយសង្គ្រោះជនរងគ្រោះមានការយឺតយ៉ាវមិនទាន់ពេលវេលា។

ឯកឧត្តមបណ្ឌិត សង្ឃឹមថា ក្នុងឆ្នាំ២០១៨នេះ គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្ត និងអនុវត្តបានដោយជោគជ័យ ដោយយើងរកឃើញ នូវចំណុចខ្វះខាត និងទទួលបានបទពិសោធន៍ល្អៗ ដើម្បីឲ្យទិសដៅសម្រាប់អនុវត្តបន្ត កាន់តែមានប្រសិទ្ធភាព៕

## បង្ក្រាបទីតាំងច្រៀងរាំអាសអាភាសរបស់ជនបរទេសមួយកន្លែង ក្នុងក្រុងសៀមរាប

http://ann.com.kh/ ថ្ងៃអាទិត្យ, 28 ខែមករា 2018 8:49 ព្រឹក

ខេត្តសៀមរាបៈ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ បានចុះបង្ក្រាបករណីរូបភាព និងសម្ភារៈអាសអាភាសមួយកន្លែង នៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ដឹកនាំសម្របសម្រួលដោយលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប និងលោកស្រីឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្ត ដោយឃាត់ខ្លួនមនុស្សចំនួន១០នាក់ផងដែរ។

សមត្ថជំនាញ បានអោយដឹងថា ជនសង្ស័យខាងលើ ទី១.ឈ្មោះ Hone Daniel Richard ភេទប្រុស ជនជាតិអង់គ្លេស កាន់លិខិតឆ្លងដែនលេខ៥២៦១៣២៦៣១, ទី២.ឈ្មោះ PaulFrancisHarris ភេទប្រុស ជនជាតិអង់គ្លេស កាន់លិខិតឆ្លងដែនលេខ៥១៨០៣៩៤៤១, ទី៣.Thomas alexanderJeffries ភេទប្រុស ជនជាតិអង់គ្លេសកាន់លិខិតឆ្លងដែនលេខGBR៥២៦៤៧៩០៩០, ទី៤.Job robertus ភេទប្រុស ជនជតិអង់គ្លេសកាន់លិខិតឆ្លងដែនNR ៥២១៩RP៧, ទី៥.VINcenthook ភេទប្រុស កាន់លិខិតឆ្លងដែនលេខGBR ៥២៨២៥០៧៨៦, ទី៦.Brasch paul Martin ភេទប្រុស ជនជាតិញូហ្សីឡែន កាន់លិខិតឆ្លងដែន lk៥៣៧០៩៦, ទី៧.Stevens billy ភេទប្រុស ជនជាតិអង់គ្លេស, ទី៨.ballvrre David Nikolais Alex ភេទប្រុសជនជាតិអង់គ្លេសកាន់លិខិតឆ្លងដែនលេខ៣២២២២៨២, ទី៩.drolet Jessicaភេទ ស្រី ជនជាតិកាណាដាកាន់លិខិតឆង្លដែនលេខAD២០៩៨១២ និងទី១០.Kazoleas Edensaran ភេទស្រី ជនជាតិ កាណាដា កាន់លិខិតឆ្លងដែនលេខGF៣២៨៦៥១។

ការណីនេះ លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ប្រមូលភ្ញៀវទេសចរបាន ៧៧នាក់ ស្រី៣៦នាក់ និងក្រុមអ្នករៀបចំចំនួន១០នាក់(ជនសង្ស័យ) ដែលកំពុងច្រៀងរាំជារបៀបអាសអាភាស។ ចំណែកភ្ញៀវចំនួន៧៧នាក់នាំទៅស្នងការដ្ឋានដើម្បីធ្វើការអប់រំរួចឲ្យត្រឡប់ទៅវិញហើយ។ ជនសង្ស័យ ត្រូវបានកសាងសុំណុំរឿង បញ្ជូនទៅតុលាការខេត្តហើយ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ម្សិលមិញ៕

## បុរសយកកូនដើរសុំទានម្នាក់រត់គេចខ្លួនបន្ទាប់ពីកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍ប៉ោយប៉ែតដេញចាប់

http://nokorwatnews.com/ 27-01-2018

ប៉ោយប៉ែត៖ បុរសម្នាក់តែងតែយកកូនប្រុសដើរសុំទានតាមទីសាធារណៈ ក្នុងក្រុងប៉ោយប៉ែតរត់គេចខ្លួនបន្ទាប់ពីកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជននៃស្នងការនគរបាលខេត្តបន្ទាយមានជ័យសហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍ប៉ោយប៉ែតដេញឃាត់កាលពីវេលាម៉ោង៨និង៣៥នាទីព្រឹកថ្ងៃសៅរ៍ ១១កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ នៅក្នុងភូមិអូរជ្រៅសង្កាត់ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

សមត្ថកិច្ចប្រាប់ថា បុរសដែលយកកូនទៅដើរសុំទាននោះឈ្មោះចាន់ ធី អាយុ៣៤ឆ្នាំ ប្រពន្ធឈ្មោះ តាប់ ហេង អាយុ២៨ឆ្នាំ មានកូនប្រុសក្នុងបន្ទុក៤នាក់ ទាំងក្នុងផ្ទៃ។ កូនប្រុសបងឈ្មោះធី តឿ អាយុ៧ឆ្នាំ, កូនប្រុសទី២ ឈ្មោះធី ចិន អាយុ៣ឆ្នាំ, កូនប្រុសទី៣ អាយុ២ឆ្នាំ ស្នាក់នៅផ្ទះជួលក្នុងភូមិកើតហេតុខាងលើ។

លោកអោក សំណុក នាយរងការិយាល័យប្រឆាំការជួញដូរមនុស្ស និងការពារអនិតិជននៃស្នងការនគរបាលខេត្តបន្ទាយមានជ័យមានប្រសាសន៍ថា ដោយអនុវត្តទៅតាមគោលការណ៍ និងបទបញ្ជាពីលោកឧត្តសេនីយ៍អាត់ ខែម ស្នងការខេត្តបន្ទាយមានជ័យ គឺឲ្យនាំខ្លួនប្រពន្ធគាត់ទៅសាកសួរ បន្ទាប់ពីប្តីរបស់គាត់រត់គេចខ្លួន អំពីព័ត៌មានតាមបណ្តាញព័ត៌មានចុះផ្សាយអំពីបុរសខាងលើនាំកូនគាត់ដើរធ្វើអាជីវកម្មសុំទាន ស្រែកច្រៀង ស្រែកជេរគេតាមផ្លូវសាធារណៈធ្វើឲ្យបាត់បង់សណ្តាប់ធ្នាប់ក្រុង ក៏ដូចជាបាត់បង់នៅសោភ័ណភាពមុខមាត់ច្រកទ្វារដែលមានភ្ញៀវជាតិ និងអន្តជាតិធ្វើដំណើរឆ្លងកាត់ ហើយគោលបំណងរបស់លោកស្វែងរកការស៊ើបអង្កេត តើបុរសខាងលើនោះ ជាកូនរបស់គាត់បង្កើត ឬជាកូនអ្នកដទៃដែលនាំយកមកសុំទាន។

ម្យ៉ាងពិនិត្យមើលផ្នែកច្បាប់តើច្បាប់អាចដាក់បន្ទុកបាន នងកសាងសំណុំរឿងបញ្ជូនទៅតុលាកា បើទោះជាកូនបង្កើតក៏ដោយ។ ចំណែកកូនបុរសខាងលើលោកសហការជាមួយសង្គមកិច្ចខេត្តដើម្បីវាយតម្លៃទៅតាមស្ថានភាពតើត្រូវយកឬក៏ត្រូវធ្វើកិច្ចសន្យាប្រគល់ឲ្យអាណាព្យាបាលវិញ។ លោកបញ្ជាក់ថា បុរសខាងលើនេះខាងនគរបាលក្រុងលោកបានណែនាំជាច្រើនដងមកហើយ តែមិនអនុវត្តតាមនោះទេ ទើបថ្ងៃនេះ លោកបានសហការចុះអនុវត្តផ្ទាល់តែម្តង តែចៃដន្យបុរសរូបនោះបានរត់គេចខ្លួនបន្សល់ទុកតែកូន និងប្រពន្ធ ដូច្នេះហើយនាំប្រពន្ធយកទៅអប់រំជំនួសប្តីដើម្បីឲ្យប្រពន្ធយកការណែនាំរបស់កម្លាំងសមត្ថកិច្ចមកប្រាប់ប្តីឲ្យបញ្ឈប់ធ្វើសកម្មភាពតទៅទៀត ៕ វណ្ណា

## អភិបាលខេត្តប៉ៃលិន ស្នើភាគីថៃ បន្តសហប្រតិបត្តិការលើបញ្ហា ការប្រើប្រាស់ប័ណ្ណឆ្លងព្រំដែនថ្មី និងបញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2018-01-26

**(ប៉ៃលិន)៖** លោក កើត សុជា អភិបាលខេត្តប៉ៃលិន បានអនុញ្ញាតឲ្យប្រតិភូនៃប្រទេសថៃ ដែលដឹកនាំដោយលោកឧត្តមនាវីត្រី ណុប ផាដុនប៉ាន់យ៉ាឈូម មេបញ្ជាការរងការពារព្រំដែន ខេត្តច័ន្ទបូរី-ត្រាត នៃប្រទេសថៃ និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារមួយចំនួន ដើម្បីពង្រឹកចំណងមិត្តភាពរវាងខេត្ត នៅជាប់ព្រំដែននៃប្រទេសទាំង២ ឲ្យកាន់តែ ជិតស្និទ្ធថែមទៀត។

ក្នុងជំនួបពិភាក្សានេះដែរ ក៏មានការអញ្ជើញចូលរួមពីលោកអភិបាលរងខេត្ត លោកមេបញ្ជាការ-មេបញ្ជាការរងកងកម្លាំងប្រដាប់អាវុធ ទាំងបីប្រភេទ និងជំនាញពាក់ព័ន្ធផងដែរ ដែលរៀបចំធ្វើឡើងនៅសាលប្រជុំក្រុមប្រឹក្សាខេត្តប៉ៃលិន នាល្ងាចថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨។ លោក កើត សុជា បានសម្តែងនូវការស្វាគមន៍ និងថ្លែងអំណរគុណ

ចំពោះលោកឧត្តមនាវីត្រី មេបញ្ជាការរងការពារព្រំដែនខេត្តច័ន្ទបូរី-ត្រាត នៃប្រទេសថៃ និងប្រតិភូអមដំណើរ ដែលបានអញ្ជើញមកជួបសម្តែងការគួរសម និងពិភាក្សាការងារទំនាក់ទំនងការងារសន្តិសុខ នៅតាមព្រំដែនរវាងប្រទេសទាំង២។ អភិបាលខេត្តប៉ៃលិន បានបន្តថា ជំនួបពិភាក្សានេះ បង្ហាញឲ្យឃើញពីចំណងសាមគ្គីភាព មិត្តភាពដ៏ល្អជាមួយគ្នា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ លើគ្រប់វិស័យ ជាពិសេសវិស័យ ការពារជាតិ នៅតាមបណ្តោយព្រំដែនរវាងកម្ពុជា-ថៃ ឲ្យកាន់តែល្អប្រសើរបន្ថែមទៀត។ នៅក្នុងឱកាសនោះផងដែរ លោក កើត សុធា ក៏បានសំណូមពរ ដល់ភាគីថៃ បន្តសហប្រតិបត្តិការនូវបញ្ហាមួយចំនួនដូចជា៖ ការប្រើប្រាស់ប័ណ្ណឆ្លងព្រំដែនថ្មី, ពលករខ្មែរឆ្លងដែន ខុសច្បាប់, បទល្មើសឆ្លងដែននានា និងការដឹកកសិកផល ឆ្លងដែនរវាងខេត្តទាំង២ ចាន់បុរី និងប៉ៃលិន។

ជាការឆ្លើយតប លោកឧត្តមនាវីត្រី ណុប ផាដុនប៉ាន់យ៉ាឈូម មេបញ្ជាការរង ការពារព្រំដែនខេត្តច័ន្ទបូរី-ត្រាត នៃប្រទេសថៃ បានសន្យានាំយកនូវរាល់សំណូមពរ របស់រដ្ឋបាល ខេត្តប៉ៃលិន ទៅពិភាក្សាជាមួយអភិបាលខេត្តចាន់បុរី និងជំនាញពាក់ព័ន្ធ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងខេត្តទាំង២ ឲ្យបានកាន់តែល្អប្រសើរឡើង។ លោកបានបន្តថា នៅពេលខាងមុខ លោកចង់ឲ្យរដ្ឋបាលខេត្តចាន់បុរី និងខេត្តប៉ៃលិន ជួបប្រជុំគ្នាឲ្យបានញឹកញ៉ាប់ ដើម្បីរក្សានូវសន្តិសុខតាមបណ្តោយព្រំដែន និងផលប្រយោជន៍នៃប្រជាជនប្រទេសខេត្តទាំង២៕

## មន្ត្រីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់បទល្មើសធំៗលើផ្ទៃសមុទ្រចំនួន០៣

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ ម៉ោង ០៩:២៣ ឈុន គឹមហៃ

ខេត្តព្រះសីហនុ ៖ នៅក្នុងពិធីប្រកាសតែងតាំង និងបំពាក់ឋានន្តរសក្តិដល់មន្ត្រីនគរបាលបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រនាចុងសប្តាហ៍កន្លងទៅនេះលោក យន្ត មិន អភិបាលនៃគណៈអភិបាលខេត្ត បានអំពាវនាវ និងស្នើយ៉ាងទទូចដល់មន្ត្រីនគរបាលដែលទើបចូលកាន់តំណែងថ្មីទាំងអស់ត្រូវរួមគ្នា បង្ការ និងបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រអំពើរត់ពន្ធឆ្លងដែនខុសច្បាប់ និងការជួញដូរមនុស្ស ។

ថ្លែងក្នុងឱកាសនោះដែរលោកអភិបាលខេត្តបានថ្លែងអំណរគុណ និងកោតសសើរដល់មន្ត្រីពាក់ព័ន្ធដែលកន្លងមកបានបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រជាច្រើនក្រោមកិច្ចសហការណ៍គ្នាយ៉ាងល្អពីកម្លាំងជំនាញគ្រប់ស្ថាប័នពាក់ព័ន្ធ ប៉ុន្តែទទ្ទឹមនឹងភាពជោគជ័យនេះ មន្ត្រីពាក់ព័ន្ធក្នុងនោះមន្ត្រីនគរបាលបង្ក្រាបបទល្មើសផ្ទៃសមុទ្រត្រូវបន្តការខិតខំនេះបន្តទៀតបង្ការនិងបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រដើម្បីបង្ក្រាបបទល្មើសផ្សេងៗក៏ដូចជារួមចំណែកក្នុងការពង្រឹងការអនុវត្តន៍ការពារសន្តិសុខលើផ្ទៃសមុទ្រ ជាពិសេសបទល្មើសឆក់ បំពុល និងបោកគ្រាប់ថ្មៃ ដែលបទល្មើសទាំងនេះ វាបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវៈចម្រុះ និងបច្ចាជាតិនៅក្នុងសមុទ្រ ។

មានប្រសាសន៍ក្នុងឱកាសនោះដែរឧត្តមសេនីយឯក តេង សួន អគ្គលេខាធិការរងគណៈកម្មាធិការជាតិសន្តិសុខសមុទ្រ និងជាប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹកបានថ្លែងបញ្ជាក់ថា ដើម្បីអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាលក៏ដូចជាក្រសួងមហាផ្ទៃ និងអគ្គស្នងការនគរបាលជាតិដែលសមត្ថកិច្ចមានតួនាទីការពារជាតិមាតុភូមិ និងប្រជាពលរដ្ឋបានសុខសន្តិភាព ។ ដូននេះមន្ត្រីនគរបាលជាតិនៃនាយកដ្ឋាននគរបាលព្រំដែនទឹកដែលទើបតែងតាំងមុខតំណែងថ្មីនាពេលនេះ ត្រូវអនុវត្តភារៈកិច្ចរបស់ថ្នាក់លើជឿជាក់ផ្តល់ជូនដល់អង្គភាពនគរបាលបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រដែលតែងតាំងលោក ឌឹម សំបូរ ជាប្រធានត្រូវខិតខំពង្រឹងអង្គភាព និងបង្កាបង្ក្រាបបទល្មើសផ្សេងៗលើផ្ទៃសមុទ្រឱមានប្រសិទ្ធិភាពដូចជាករណីអំពើរត់ពន្ធឆ្លងដែនខុសច្បាប់ ការជួញដូរមនុស្ស បទល្មើសនេសាទសុខច្បាប់ និងសុវត្ថិភាពភ្ញៀវទេសចរណ៍ទៅលេងតាមបណ្តាកោះក៏ដូចជាប្រជាពលរដ្ឋ និងប្រជានេសាទនៅតាមបណ្តាកោះផងដែរ ។

ដើម្បីឆ្លើយតបទៅនឹងទំនុកចិត្តរបស់ថ្នាក់លើលោកវរសេនីយ៍ឯក ឌឹម សំបូរ ដែលទើបតម្លើងឋានន្តរសក្តិ និងទទួលតំណែងថ្មីជាប្រធានអង្គភាពបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រ បានប្តេជ្ញាចិត្តនឹងខិតខំកសាងអង្គភាព និងបង្ក្រាបបង្ក្រាបនូវរាល់បទល្មើសដែលកើតឡើងនៅលើដែនសមុទ្រឱ្យមានប្រសិទ្ធិភាពតាមគោលការរបស់ក្រសួងបានដាក់ឱ្យ ៕

**កម្ពុជាគាំទ្រ ការសម្រេចរបស់ ចៅក្រមអាមេរិក ដែលរារាំងការនិរទេស ពលរដ្ឋកម្ពុជា ៩២នាក់**

https://www.dap-news.com/kh/ សៅរ៍, ២៧ មករា ២០១៨ 13:54 ដោយៈ ដើមអម្ពិល ID:014

ភ្នំពេញ៖ លោក ជុំ សុន្ទរី អ្នកនាំពាក្យ ក្រសួងការបរទេសកម្ពុជា នៅថ្ងៃទី២៧ ខែមករានេះ បានសម្តែងការគាំទ្រ ចំពោះការសម្រេច របស់ចៅក្រមអាមេរិក ដែលរារាំងមិនឲ្យ រដ្ឋបាលលោក ដូណាល់ ត្រាំ បណ្តេញជនជាតិខ្មែរ៩២ នាក់ ចេញពីទឹកដីអាមេរិក។ លោក ជុំ សុន្ទរី បានលើកឡើង នៅចំណុចសំខាន់៤ ទាក់ទងនឹងការសម្រេចរបស់ចៅក្រមអាមេរិកនេះថា៖

១-យើងសូមស្វាគមន៍ ចំពោះការសម្រេចរបស់ ចៅក្រមសហរដ្ឋអាមេរិក ដើម្បីរារាំងការនិរទេសពលរដ្ឋកម្ពុជា ៩២ នាក់ ពីសហរដ្ឋអាមេរិក ដោយពុំអនុញ្ញាតឱ្យពួកគេ មានឱកាសធ្វើការតវ៉ា រឿងក្តីនៅក្នុងតុលាការ។

២- ការសម្រេចចិត្តរបស់ចៅក្រមអាមេរិក បានផ្តល់ឱ្យកម្ពុជានូវតម្លាភាព និងយុត្តិធម៌ ឈរលើមូលដ្ឋាននៃច្បាប់ របស់សហរដ្ឋអាមេរិក និងគោលការណ៍ជាសកល ស្តីពីសិទ្ធិមនុស្ស ក៏ដូចជាតម្លៃមនុស្សធម៌ផងដែរ។

៣- ការសម្រេចចិត្ត របស់ចៅក្រមសហរដ្ឋអាមេរិក បង្ហាញយ៉ាងច្បាស់ថា "ការដាក់កំហិតទិដ្ឋាការ" ដែលបានចេញកាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ កន្លងទៅ ដោយសហរដ្ឋអាមេរិក ស្តីពី មន្ត្រីនៃក្រសួងការបរទេសកម្ពុជា និងសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសកម្ពុជា សម្រាប់ "ពន្យារពេលដំណើរការដាក់ពាក្យសុំ" គឺមិនសមហេតុផល ទាល់ អយុត្តិធម៌ និងសូម្បីតែច្បាប់ របស់អាម៉េរិក។

៤-យើងសូមឆ្លៀតឱកាសនេះ ដើម្បីបន្តការអំពាវនាវរបស់យើង ឱ្យអាមេរិកលើកកម្ពស់ ការដាក់កំហិតទិដ្ឋាការរបស់ខ្លួន ដើម្បីត្រួសត្រាយផ្លូវ សម្រាប់ការបន្ត កិច្ចសហប្រតិបត្តិការទ្វេភាគី ល្អឥតខ្ចោះនៅលើ MIA ៕

**សេវាកម្មរបស់សូន្យOSS,(OneStopService)ដែលត្រៀមនិងបើកនៅថ្ងៃទី០៥ខាងមុខនេះ.!**

http://www.prakpheaktra.com January 26, 2018

សូន្យOSS (OneStopService) ជាកន្លែងប្រមូលផ្តុំនៅសេវាកម្មផ្សេងៗមករួមគ្នានៅមួយកន្លែង បើនិយាយអោយចំទៅគឺជាកន្លែងផ្តល់សេវាកម្មស្របច្បាប់ជូនពលករខ្មែរ,ភូមា,ឡាវ ដែលដែលរាជរដ្ឋាភិបាលថៃ ចាត់តាំងឡើងដើម្បីជួយសម្រួលលើបញ្ហាផ្សេងៗដូចជា, តប័ត្រស៊ីជម្ពូ, ធ្វើប័ត្រស៊ីជម្ពូថ្មី,សេវាកម្មវិរីសារ, សេវាកម្មពិនិត្យសុខភាព, និងផ្តល់ច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេស។ ហើយសេវាកម្មទាំងអស់នេះហើយដែលរាជរដ្ឋាភិបាលថៃ តែងតែបើកសូន្យOSS, (OneStopService) ព្រោះវាងាយស្រួលក្នុងការផ្តល់សេវាកម្មដល់ពលករបរទេស ដូចជានៅពេលឆាប់ៗខាងមុខនេះក្រសួងមហាផ្ទៃថៃបានសហការជាមួយតម្រួត(តម៉)និងក្រសួងសុខាភិបាល,មន្ទីរការងារថៃ និងចាប់ផ្តើមបើកដំណើរការសូន្យ OSS (OneStopService) ដើម្បីផ្តល់សេវាកម្មដូចខាងក្រោម។

1.ពលករកាន់ប័ត្រស៊ីជម្ពូធ្វើការធ្វើការនេសាទត្រីនិងផ្នែកសមុទ្រផុតកំណត់កាលពីថ្ងៃទី០១ខែ១១ឆ្នាំ២០១៧ត្រូវមកបង្ហាញខ្លួននៅសូន្យOSS, (OneStopService) ដែលពលកររស់នៅជាមួយថៅកែ។

2.ពលករលុងបៀនថ្មីមានលិខិតបញ្ជាក់ទំនាក់ទំនងរវាងពលកនិងថៅកែ ត្រូវមកបង្ហាញខ្លួននៅសូន្យ OSS, (OneStopService)ក្នុងខេត្តដែលពលកររស់នៅជាមួយថៅកែ។

3.ពលករមានប័ត្រស៊ីជម្ពូផុតកំណត់នៅថ្ងៃទី៣១ ខែ០៣ ឆ្នាំ២០១៨ តែមិនទាន់បានត្រួតសញ្ជាតិ ត្រូវមកបង្ហាញខ្លួននៅសូន្យOSS,(OneStopService)នៅក្នុងខេត្តដែលពលកររស់នៅជាមួយថៅកែ។

4.ពលករដែលត្រូតសញ្ជាតិហើយតែមិនទាន់បានសុំវីសាឬសុំវីសារអត់បាន និងប័ត្រស៊ីជម្ពូដាច់នេសាទវីសារអត់បានឬក៏វីសារហួស១៥ថ្ងៃ ត្រូវមកបង្ហាញខ្លួននៅសូន្យOSS, (OneStopService) នៅក្នុងខេត្តដែលពលករធ្វើការរស់នៅជាមួយថៅកែ។

5.ពលករដែលបានសុំដែលបានត្រូតសញ្ជាតិរួចរាល់ ហើយបានសុំវីសារ និង workpermit វីសារផុតកំណត់នៅថ្ងៃទី៣១ ខែ០៣ ឆ្នាំ២០១៨ ត្រូវមកបង្ហាញខ្លួននៅសូន្យOSS, (OneStopService) នៅខេត្តដែលពលកររស់នៅជាមួយនឹងថៅកែ។

*បញ្ជាក់:សូន្យOSS,(OneStopService)និងចាប់បើកដំណើរការនៅថ្ងៃច័ន្ទទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ខាងមុខនេះទូទាំងខេត្តក្រុងនៃប្រទេសថៃ សម្រាប់ព័ត៌មានលម្អិតពីទីតាំងសូមទំនាក់ទំនងសាកសួរតាមរយៈលេខទូរស័ព្ទរបស់ក្រសួងការងារថៃ:1694។

## ពលរដ្ឋខ្មែររស់នៅស្រុកថ្មពួក ១នាក់ ត្រូវបានកម្លាំងអាជ្ញាធរថៃចាប់ខ្លួនបន្ទាប់ពីពួកគាត់ឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងនៅឧទ្យានជាតិថៃ

http://www.prakpheaktra.com January 28, 2018

អ្នកស្រុកបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យម្នាក់ត្រូវបានកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួនបន្ទាប់ពីពីរពួកគាត់ឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងនៅក្នុងតំបន់ឧទ្យានជាតិថៃ។ កាលពីថ្ងៃសុក្រទី២៦ ខែមករា ឆ្នាំ២០១៨ កម្លាំងអាជ្ញាធរអភិរក្សព្រៃឈើឧទ្យានជាតិតាបផាយ៉ា ខេត្តបុរីរ៉ាម ប្រទេសថៃ បានធ្វើការឃាត់ខ្លួនបុរសជនជាតិខ្មែរ១នាក់ ឈ្មោះ អៀម រ៉ៃ ភេទប្រុស អាយុ២២ ឆ្នាំ ស្រុកកំណើតរស់នៅក្នុងភូមិឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ បន្ទាប់ពីបុរសជនជាតិខ្មែរខាងលើបាននាំគ្នាប្រមាណជាង១០នាក់ឆ្លងដែនខុសច្បាប់ចូលទៅប្រព្រឹត្តបទល្មើសកាប់ឈើគ្រញូងខុសច្បាប់នៅក្នុងឧទ្យានជាតិតាបផាយ៉ា ស្ថិតក្នុងភូមិបុកហុក ឃុំឡាំនាងរ៉ង ស្រុកណូនដេង ខេត្តបុរីរ៉ាម កាលពីថ្ងៃសុក្រកន្លងទៅ។

បុរសជនជាតិខាងលើ ត្រូវបានកម្លាំងអាជ្ញាធរថៃធ្វើការចាប់ឃាត់ខ្លួនបានជាមួយនឹងវត្ថុតាងមានម៉ាស៊ីនកាត់ឈើ និងឧបករណ៍ប្រើប្រាស់ចំនួនទៀត នៅតំបន់ឧទ្យានជាតិថៃ ចំណែកឯបក្សពួកផ្សេងទៀតបានរត់គេចខ្លួនបាត់អស់ បច្ចុប្បន្នពលរដ្ឋខ្មែរខាងលើត្រូវអាជ្ញាធរថៃកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## កម្ពុជាមានបំណង ពង្រីកទីផ្សារការងារ ទៅកាន់ប្រទេសលីបង់

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ២៩ មករា ២០១៨ 11:10 ដោយ: នឿត មង្គល ID:014

ភ្នំពេញ៖ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៩ ខែមករានេះ បានបង្ហាញពីបំណង ពង្រីកទីផ្សារការងារ ទៅកាន់ប្រទេសលីបង់ ដើម្បីបង្កើតការងារ ជូនប្រជាពលរដ្ឋកម្ពុជា ដោយសារលីបង់ មានការងារគ្រប់ផ្នែក ដូចប្រទេសដទៃដែរ ដូចជា ផ្នែកឧស្សាហកម្ម ផ្នែកសេវាកម្ម និងផ្នែកជំនួយការមេផ្ទះជាដើម។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងក្នុងឱកាស អនុញ្ញាតឲ្យក្រុមការងារ ទំនាក់ទំនងរបស់សាធារណរដ្ឋលីបង់ ចូលជួបពិភាក្សាការងារ ដើម្បីសុំយោបល់ពាក់ព័ន្ធ នឹងកិច្ចសហប្រតិបត្តិការ លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួង" នេះជាឱកាសមួយដ៏ល្អ បើសិនជាយើង មានកិច្ចសហ ប្រតិបត្តិការនេះ ជាមួយសាធារណរដ្ឋលីបង់ ព្រោះថាលីបង់ជាប្រទេសមួយ មានការអភិវឌ្ឍន៍ ហើយទន្ទឹមនឹងនេះ យើង អាចពង្រីកទៅប្រទេសជិតខាងនៅក្បែរនោះ ដែលស្ថិតនៅជាប់អឺរ៉ុបថែមទៀត។ នេះជាការជំរុញការបង្កើត នូវឱកាសក៏ ដូចជា បើកទូលាយទីផ្សារការងារ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ពិសេសយុវជន ដែលមានចំណាប់អារម្មណ៍"។ លោករដ្ឋមន្ត្រីលើកឡើងបន្តថា ប្រទេសទាំងពីរ ត្រូវពិភាក្សាដើម្បីបន្ត ជំរុញឲ្យមានកិច្ចព្រមព្រៀង

ជាមុនសិន ព្រោះថា ដើម្បី បង្កើតបានឱកាសការងារ និងសុវត្ថិភាពនៃការងារ រួចហើយយើងត្រូវតែមាន ចុះកិច្ចព្រមព្រៀងជាមុនសិន។ លោកលើក ឡើងបន្ថែមថា កន្លងមកយើង មានកិច្ចព្រមព្រៀង ជាមួយកាតាអារ៉ាប់សាអូឌីត។ ប្រសិនបើកម្ពុជា បង្កើតទីផ្សារការងារ ជាមួយលីបង់បន្តទៀត ក៏ជាឱកាសដ៏ល្អ សម្រាប់ប្រជាពលរដ្ឋ ទៅធ្វើការនៅទីនោះដែរ។

លោក អ៊ិត សំហេង បញ្ជាក់ថា នេះជាការបើកឱកាស ការងារថ្មីមួយទៀត ដល់បងប្អូនពលករ ដែលអាចនឹងទទួលបាន ប្រាក់ ឈ្នួលខ្ពស់ និងមាន ឱកាសដើម្បី ចាប់យកមុខជំនាញថ្មីៗ ដែលប្រទេសទាំងនោះ ក៏មានការអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗ ដែលយើង នឹងអាចឲ្យកម្លាំងពលកម្មរបស់យើង អាចទៅសិក្សា និងចេះនូវជំនាញទាំងនោះ ហើយពេលត្រឡប់មកវិញ ពួកគេអាចក្លាយជាធនធានមនុស្ស សម្រាប់បម្រើឲ្យសំណូមពរ នៃទីផ្សារការងារ ឬមួយបង្កើតមុខរបរការងារថ្មី នៅក្នុង ប្រទេសជំរុញការអភិវឌ្ឍន៍ ដើម្បីឈានទៅគោលដៅកម្ពុជា ជាប្រទេសដែលមានចំណូល មធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ នេះ ជាយុទ្ធសាស្ត្រមួយ ក្នុងការដោះស្រាយ ទៅលើបញ្ហាមុខរបរនិងការងារ ជូនដល់ប្រជាពលរដ្ឋផងដែរ៕

## ប្តី ប្រពន្ធម៉ាឡេស៊ីធ្វើឲ្យពលករខ្មែរស្លាប់ត្រូវបានសម្រាលទោស

http://www.postkhmer.com/ Leonie Kijewski | Publication date 29 January 2018 | 10:34 ICT

ភ្នំពេញៈ ប្តីប្រពន្ធជនជាតិម៉ាឡេស៊ីដែលត្រូវបានកាត់ទោសប្រហារជីវិត ពាក់ព័ន្ធនឹងករណីសម្លាប់ស្ត្រីបម្រើការងារតាមផ្ទះជនជាតិកម្ពុជា តាមរយៈការបង្អត់បាយត្រូវបានកាត់បន្ថយទោសមកនៅត្រឹម ១០ ឆ្នាំវិញកាលពីសប្តាហ៍មុន។ នេះបើតាមអង្គការក្នុងស្រុក។

អ្នកស្រី Chin Chui Ling និងប្តីរបស់គាត់ Soh Chew Tong កាលពីឆ្នាំ ២០១៣ ត្រូវបានកាត់ទោសពីបទមនុស្សឃាត ប៉ុន្តែត្រូវបានកាត់ទោសប្រហារជីវិតពីបទឃាតកម្មគិតទុកជាមុនក្នុងឆ្នាំ ២០១៥។ កាលពីថ្ងៃ ២៥ ខែមករាតុលាការសហព័ន្ធម៉ាឡេស៊ីបានកាត់ទោសពួកគេពីបទមនុស្សឃាតវិញ។

នារីខ្មែរឈ្មោះ មី ស៊ីចាន់ បានទៅម៉ាឡេស៊ីក្នុងឆ្នាំ ២០១១ ក្នុងវ័យប្រមាណជាង ២០ ឆ្នាំហើយបានស្លាប់នៅក្នុងទម្ងន់ខ្លួន ២៦,១ គីឡូក្រាម និងមានស្លាកស្នាមរំលោភបំពានលើរាងកាយក្នុងឆ្នាំ ២០១២។

លោកស្រី Glorene Das នាយិកាប្រតិបត្តិនៃអង្គការ Tenaganita ដែលជាអង្គការសិទ្ធិមនុស្សម៉ាឡេស៊ីបានប្រាប់អ្នកយកព័ត៌មានថា ខណៈអង្គការរបស់លោកស្រីមិនគាំទ្រការកាត់ទោសប្រហារជីវិត ការកាត់ទោសនេះមិនអាចទទួលយកបានទេ។ «វាត្រូវការឲ្យមានការកាត់ទោសធ្ងន់ធ្ងរជាងនេះចំពោះការសម្លាប់ជីវិតគេ»។ លោកស្រីបន្តថាអនុស្សរណៈនៃការយោគយល់គ្នា មិនមែនជាការការពារគ្រប់គ្រាន់នោះទេដោយសារអនុស្សរណៈនេះមិនបានធ្វើឲ្យជនល្មើសមានការទទួលខុសត្រូវ។ ក្រៅពីកិច្ចព្រមព្រៀងទូលំទូលាយផ្សេងៗជាមួយប្រទេសដៃគូ លោកស្រីអំពាវនាវឲ្យមានច្បាប់ដោយឡែកសម្រាប់ស្ត្រីបម្រើការតាមផ្ទះ។

លោកស្រី Sally Alexander ដែលមកពីអង្គការ Tenaganita ដូចគ្នានោះថ្លែងថា លោកស្រីបានទៅស្ថានទូតកម្ពុជាកាល ២-៣ សប្តាហ៍មុនដែលមានតែបន្ទប់តូចមួយសម្រាប់ជាជម្រកបណ្តោះអាសន្នដល់ជនរងគ្រោះ ហើយបានស្នើសុំឲ្យមានការពង្រីកបន្ទប់នេះ៕ PS

## រដ្ឋមន្ត្រីក្រសួងការងារ អះអាងថា ការស្នើសុំពលករពីកម្ពុជា ទៅធ្វើការនៅបរទេសគឺជារឿងល្អ

http://bayontv.com.kh/ 29/01/2018

ភ្នំពេញ ៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានប្រសាសន៍ថា ការស្នើសុំ ក៏ដូចជាមានកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃផ្សេងទៀតពីការនាំយកពលករពីក្នុងស្រុកទៅធ្វើការនៅបរទេសគឺជារឿងល្អ ដែលជាជាឱកាសការងារថ្មីជាមួយ នឹងប្រាក់ឈ្នួលខ្ពស់ និងមានឱកាសដើម្បីឆាប់ចាប់យកមុខជំនាញថ្មីៗនៅពេលត្រឡប់មកប្រទេសវិញ។

មានប្រសាសន៍ប្រាប់ក្រុមអ្នកសារព័ត៌មានក្រោយជំនួបពិភាក្សាការងារជាមួយ ក្រុមការងារទំនាក់ទំនងរបស់សាធារណរដ្ឋលីបង់ នៅព្រឹកថ្ងៃ២៩ មករា ឆ្នាំ២០១៨នេះ នៅទីស្តីការក្រសួង ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានលើកឡើងថា នេះជាយុទ្ធសាស្ត្រមួយក្នុងការដោះស្រាយការងារ ទន្ទឹមនឹងការបង្កើតការងារនៅក្នុងប្រទេស។ ឯកឧត្តមបន្តថា ជាមួយគ្នានេះ ការបើកឱកាសការងារថ្មីជូនដល់បងប្អូនពលករខ្មែរ ក្រោយត្រឡប់មកវិញបងប្អូនពលករ អាចក្លាយជាធនធានមនុស្សសម្រាប់បម្រើឲ្យសំណូមពរនៃទីផ្សារ ការងារ ឬមួយបង្កើតមុខរបរការងារថ្មី នៅក្នុងប្រទេសជំរុញការអភិវឌ្ឍន៍ ដើម្បីឈានទៅគោលដៅកម្ពុជា ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ដែលនេះជាយុទ្ធសាស្ត្រមួយក្នុងការដោះ ស្រាយទៅលើបញ្ហាមុខរបរ និងការងារជូនដល់ប្រជាពលរដ្ឋ។

ទាក់ទងនឹងជំនួបរវាងកម្ពុជា និងលីបង់នាពេលនេះ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី មានប្រសាសន៍ថា នេះជាឱកាសមួយដ៏ល្អ បើសិនជាយើងមានកិច្ចសហប្រតិបត្តិការជាមួយលីបង់ ព្រោះថា លីបង់ជាប្រទេសមួយមានការអភិវឌ្ឍន៍ ហើយទន្ទឹមនឹងនេះ យើងអាចពង្រីកទៅប្រទេសជិតខាងនៅក្បែរនោះ ដែលស្ថិតនៅជាប់អឺរ៉ុបថែមទៀត។ នេះជាជំរុញការបង្កើតនូវឱកាស ក៏ដូចជាបើកទូលាយទីផ្សារការងារសម្រាប់ប្រជាពលរដ្ឋកម្ពុជា ពិសេសយុវជនដែលមានចំណាប់អារម្មណ៍។ ឯកឧត្តម អ៊ិត សំហេ ង បានបន្តថា កន្លងមកយើងមានកិច្ចព្រមព្រៀងជាមួយកាតា និងអារ៉ាប់សាអូឌីត ហើយប្រសិនបើកម្ពុជាបង្កើតបានឱកាសជាមួយលីបង់ថែមទៀត នោះក៏ជាឱកាសដ៏ល្អសម្រាប់ប្រជាពលរដ្ឋទៅធ្វើការនៅទីនោះផងដែរ។

សាធារណរដ្ឋលីបង់មកទល់បច្ចុប្បន្ន កំពុងទទួលពលករមកពីប្រទេសចំនួន៩ រួមមាន ៖ ម៉ាដាហ្គាសកា អេត្យូពី បង់ក្លាដេស នេប៉ាល់ហ្វីលីពីន សេរីលង្កា វៀតណាម ឥណ្ឌូណេស៊ី និងប្រទេសឥណ្ឌា ដែលមានប្រភេទការងារដូចជា ការងារក្នុងសណ្ឋាគារ ការងារផ្ទះ អ្នកលក់ក្នុងហាងទំនិញ ភោជនីយដ្ឋានហាងសាឡនសំអាង និងហាងកាត់សក់ជាដើម៕

## ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៨

## កម្ពុជា រៀបចំធ្វើកិច្ចព្រមព្រៀង ដើម្បីបញ្ជូនពលករទៅធ្វើការនៅ ប្រទេសលីបង់

http://www.postkhmer.com/ យន់ ស៊ីនាត | Publication date 29 January 2018 | 18:15 ICT

ភ្នំពេញៈ រដ្ឋមន្ត្រីក្រសួងការងារលោក អ៊ិត សំហេង បានទទួលជួបជាមួយប្រតិភូនៃសាធារណរដ្ឋលីបង់ ដឹកនាំដោយលោក Rafic Yazbeck នៅព្រឹកថ្ងៃទី ២៩ ខែមករានេះ ដើម្បីពិភាក្សាពីកិច្ចសហប្រតិបត្តិការលើវិស័យការងាររបស់ប្រទេសទាំងពីរ។

ក្រោយកិច្ចប្រជុំលោក អ៊ិត សំហេង មានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានថា ការជួបគ្នានេះគឺបន្តពិភាក្សាចំពោះការពិភាក្សាកន្លងទៅដែលនៅសេសសល់អំពីការផ្តួចផ្តើមឲ្យមានកិច្ចសហប្រតិបត្តិការរវាងគ្នានឹងគ្នារវាងប្រទេសលីបង់និងកម្ពុជា លើវិស័យការងារនិងបណ្តុះបណ្តាលនិងវិជ្ជាជីវៈជាពិសេសលើវិស័យពលកម្ម។ លោកថ្លែងថា ៖ « យើងគិតថាជាការល្អ ដែលគួរជំរុញឲ្យមានកិច្ចព្រមព្រៀង MoU និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យការងារនិងពលកម្មជាបឋមមុននឹងយើងធ្វើអ្វីបានតទៅមុខទៀត»។ លោកបន្តថា កន្លងមកក៏មានក្រុមការងារប្រតិភូបច្ចេកទេសធ្លាប់បានទៅបំពេញទស្សនកិច្ចនៅប្រទេសលីបង់ដែរ ដែលលោករដ្ឋមន្ត្រី យល់ថា ជា«ឱកាស» សម្រាប់ពលរដ្ឋកម្ពុជា ដែលចង់ធ្វើការនៅទីនោះ ដោយអះអាងថា លីបង់ ជា«ប្រទេសមួយដែលមានការអភិវឌ្ឍច្រើន»។ លោកបញ្ជាក់ថា ការងារនៅទីនោះមានគ្រប់ផ្នែក គឺមានផ្នែក ឧស្សាហកម្ម សេវាកម្មនិងការងារតាមផ្ទះ។ កន្លងមករដ្ឋាភិបាល ធ្លាប់បានចុះហត្ថលេខា(MoU) ជាមួយប្រទេសកាតា និងប្រទេសអារ៉ាប៊ី សាអ៊ូឌីត ដែលជាប្រទេសមានបញ្ហារំលោភបំពានលើលក្ខខណ្ឌការងារពលករ ។

ទោះយ៉ាងណាលោករដ្ឋមន្ត្រី ក៏បានពន្យល់ពីគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយរកការងារឲ្យពលរដ្ឋធ្វើនៅក្នុងប្រទេសនេះផងដែរ ដោយបញ្ជាក់អត្រាអ្នកមានការងារធ្វើ នៅដើមឆ្នាំ២០១៨នេះ មានរហូតដល់ ២០ភាគរយ៕

## បញ្ជូនបរទេស ១០នាក់ ទៅពន្ធនាគារករណីផលិតរូបអាសអាភាស នៅសៀមរាប

http://www.postkhmer.com/ នៀម ឆេង | Publication date 29 January 2018 | 17:00 ICT

សៀមរាបៈ ភ្ញៀវទេសចរបរទេសចំនួន ១០ នាក់ ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តសៀមរាប ដើម្បីឃុំខ្លួនបណ្ដោះអាសន្ន ដោយត្រូវចោទប្រកាន់ពីបទ «ផលិតរូបភាពអាសអាភាស» ក្រោយមានការបង្ក្រាប ទីតាំងរាំបែបអាសអាភាស នៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប កាលពីចុងសប្តាហ៍កន្លងទៅនេះ។ ពួកគេអាចប្រឈមនឹងការជាប់ទោសពី ១ខែ ដល់ ១ឆ្នាំ បើសិនគេរកឃើញកំហុស។

បរទេសទាំង ១០ នាក់នេះ ត្រូវបាន ឃាត់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍ទី ២៥ ខែមករា និងត្រូវបានតុលាការខេត្តសៀមរាប ធ្វើការចោទប្រកាន់ នៅថ្ងៃអាទិត្យ ទី២៨ ខែមករានេះ ពីបទចោទខាងលើនេះ រួចក៏បញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្ត។ នេះបើតាមលោក ឃិន ស្រាង អ្នកនាំពាក្យតុលាការខេត្តសៀមរាប ប្រាប់ភ្នំពេញប៉ុស្តិ៍ នៅថ្ងៃនេះ។

តាមរបាយការណ៍នគរបាល ឲ្យដឹងថា ពួកគេ ត្រូវបានឃាត់ខ្លួន ទាក់ទិននឹងការរៀបចំកម្មវិធីរាំច្រៀងបែបអាសអាភាសក្នុងខេត្តសៀមរាប ខណៈភ្ញៀវទេសចរ ៧៧ នាក់ផ្សេងទៀតត្រូវបានហៅមកអប់រំរួចដោះលែងវិញ។ គេហទំព័រអគ្គស្នងការនគរបាលជាតិ ក៏បានចុះផ្សាយថាកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានចុះបង្ក្រាបករណីរូបភាព និងសម្ភារអាសអាភាសមួយកន្លែងនៅភូមិក្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ដោយមានការសម្របសម្រួលពីលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត និងលោកស្រី ដួង ថាវរី ស្នងការរងនគរបាលខេត្ត។ ជនដែលត្រូវឃាត់ខ្លួនទាំងនោះមកពីប្រទេសអង់គ្លេស កាណាដា និងនូវែលសេឡង់។

របាយការណ៍សមត្ថកិច្ច ក៏បានបង្ហាញថា ទីតាំងខាងលើស្ថិតក្នុងផ្ទះវីឡាឈ្មោះថា Let's Get Wet។ អ្នកដែលចូលរួមសប្បាយនៅទីនេះត្រូវបង់ថ្លៃពី ១០ ទៅ ១៥ ដុល្លារ។ នៅក្នុងរូបភាពដែលគេថតបាន គេឃើញជនបរទេសដេកពពាក់ពពូន ពោបលើគ្នាជាដើម ប៉ុន្តែសមត្ថកិច្ច ក៏មិនបញ្ជាក់ថារូបនោះត្រូវបានថតពីពេលណានោះទេ៕